# សាសនវិទ្យា និងសេចក្តីជំនឿ នៃការស្តាបនាឡើងវិញ នូវរូបឆ្លុះរបស់ព្រះ

## (The Theology and its Faith of Restoration of the Image of God)

[Book III]



2018

លោកគ្រូបណ្ឌិត វ៉ាយ យ៉ុងជុន

White Young Jeon

CRFI

# សាសនវិទ្យា និងសេចក្តីជំនឿ របស់ការស្តាបនាឡើងវិញ នៃរូបឆ្លុះរបស់ព្រះ

**(The Theology and its Faith of Restoration of the Image of God)**

លោកគ្រូបណ្ឌិត វ៉ាយ យ៉ុងជុន

Author: White Young Jeon

Translator: Sokhen Cheaand Sreleak Kohn

Editor: Charany Yoeun

## អារម្មណ៍កថា

តាំងពីខ្ញុំបានទទួលជឿព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់របស់ខ្ញុំមក ខ្ញុំក៏បានបំរើទ្រង់នៅក្នុងព្រះវិហារ និងស្តាប់បង្គាប់បញ្ញត្តិរបស់ទ្រង់អស់រយៈពេល៥០ឆ្នាំមកហើយ(ដោយធ្វើព័ន្ធកិច្ចជាគ្រូគង្វាល៣០ឆ្នាំ ព័ន្ធកិច្ចនៃការអប់រំ និងព័ន្ធកិច្ចបេសកជនចំនួន២០ឆ្នាំ)។ ខ្ញុំចង់បង្ហាញពីការអះអាងរបស់ខ្ញុំ "សាសនវិទ្យា នៃការស្តារឡើងវិញ នូវរូបឆ្លុះរបស់ព្រះ និងសេចក្តីជំនឿ ព្រោះវាជាការធានារបស់ខ្ញុំ ដែលខ្ញុំបានដើរក្នុងសេចក្តីងងឹតនៃការរងទុក្ខវេទនាយ៉ាងយូរ ប៉ុន្តែព្រះបានដាំសេចក្តីពិតនៅក្នុងចិត្តរបស់ខ្ញុំ។

ខ្ញុំបានចាប់ផ្តើមជីវិតនៃសេចក្តីជំនឿរបស់ខ្ញុំ ក្នុងនាមជាអ្នកដែលមានចំណង់ចំណូលចិត្តខាងមេតូឌីសដែលស្ថិតនៅក្រោមការផ្សាយដំណឹងល្អ។ តាមរយៈការដឹកនាំរបស់ព្រះ ខ្ញុំបានធ្វើការសិក្សាលើទ្រឹស្តីសាសនវិទ្យាកំណែទំរង់ពួកបរិសុទ្ធនិយម  និងសេចក្តីជំនឿនៅក្នុងប្រទេសកូរ៉េខាងត្បូង នៅសហរដ្ឋអាមេរិក  ហើយខ្ញុំក៏បានបម្រើព្រះនៅក្នុងព្រះវិហារនៅកូរ៉េខាងត្បូង សហរដ្ឋអាមេរិក និងកម្ពុជា។ រហូតមកដល់ពេលនេះ ខ្ញុំបានជួបសាសនវិទូដ៏ស្មោះត្រង់ជាច្រើន និងគ្រូគង្វាលជាច្រើន អ្នកទាំងនោះមាន លោកគ្រូ យុន សាន់ ផាក (Yun Sun Park), ហាក់ កុន កាំង (Hak Kun Kang)  នៅកូរ៉េខាងត្បូង,អឹម ជី ក្លាញ( MG Kline),  ក្លោនណេ( Clowney) ចេ អាដាម( Jay Adams) ហ្កតប្រេ្យ ( Godfrey),ប្រេ្យម( Frame) ។ ល។ និងគ្រូបង្រៀនរបស់ខ្ញុំ ដែលជាបណ្ឌិតផ្នែកព័ន្ធកិច្ចគឺលោក យ៉ូសែបភីប៉ា (Joseph Pipa) បានធ្វើឱ្យខ្ញុំពង្រឹងសាសនវិទ្យា និងសេចក្តីជំនឿរបស់ខ្ញុំ និងគោលដៅរបស់ខ្ញុំឱ្យកាន់តែស៊ីជម្រៅថែមទៀត។ បន្ទាប់ពីនោះខ្ញុំបានរៀបចំគោលដៅនោះ ដោយបានចែកចាយជាមួយសាស្ត្រាចារ្យនៅសាលា ITCS និងសិស្សនិស្សិត តាមរយៈការបង្រៀនមុខវិជ្ជាមួយចំនួនដូចជា ការអធិប្បាយ ភាពបរិសុទ្ធ និងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសាសនវិទ្យា M. G. Kline ហើយខ្ញុំត្រូវបានលើកទឹកចិត្តដោយ ការអប់រំពីព័ន្ធកិច្ចនៅប្រទេសកម្ពុជាហើយបេកកម្ម ព័ន្ធកិច្ច សំរាប់ជាប្រយោជន៍ បង្កើតអាណាចក្ររបស់ព្រះនៅកម្ពុជា។សៀវភៅនេះត្រូវបានធ្វើឡើងដើម្បីប្រកាសដំណឹងល្អ ទៅកាន់ខេត្តចំនួន 26 នៃប្រទេសកម្ពុជានិងបង្កើតព្រះវិហារសាខានៃព្រះវិហារ ពេនីអែលព្រីប៊ីធើរៀន(Peniel Presbyterian) តាមរយៈការស្តារឡើងវិញនូវការលូតលាស់នៃក្រុមជំនុំអេភេសូរនិងការជួយខ្លួនឯងនៃពន្ធ័កិច្ចរបស់គ្រូ

គង្វាល។ គោលដៅនេះចេញមកពីនិមិត្តរបស់ខ្ញុំ ដែលព្រះបានផ្តល់ឱ្យក្នុងដំណើរការនៃការអប់រំព័ន្ធកិច្ចតូចរបស់ខ្ញុំ ដើម្បីចែកចាយនូវបទគម្ពីរ ព្រះបន្ទូលរបស់ព្រះ ទៅកាន់ប្រទេសកម្ពុជាដែលជាប្រទេសដែលមានអាកាសធាតុក្តៅ សើម និងមានសម្រស់ពណ៌បៃតងខ្ចី ប៉ុន្តែប្រទេសនេះ ជាប្រទេសដែលមានប្រវត្តិឈឺចាប់ គឺការសំលាប់រង្គាល់រហូតដល់អាណាចក្ររបស់ព្រះបានតាំងឡើង។

ខ្ញុំក៏បានយល់ពីអត្ថន័យនៃការឈឺចាប់របស់ខ្ញុំអស់រយៈពេល 13 ឆ្នាំក្នុងជីវិតដ៏តិចតួចរបស់ខ្ញុំ ហើយខ្ញុំក៏សរសើរតម្កើងសិរីរុងរឿងរបស់ព្រះ។ ទ្រង់បានរក្សាសេចក្តីសន្យារបស់ទ្រង់«ទ្រង់បានធ្វើឱ្យជើងទូលបង្គំដូចជាសត្វក្តាន់ហើយទ្រង់បានធ្វើឱ្យទូលបង្គំបានជាន់នៅឯទីខ្ពស់»។ (3:18) តាមរយៈសៀវភៅនេះខ្ញុំនឹងព្យាយាមបង្ហាញពីព្រះដែលស្មោះត្រង់ ទៅកាន់លោកីយ។

អត្ថបទនេះផ្តោតទៅលើប្រវត្តិសាស្ត្រនៃការប្រោសលោះនៃទស្សនវិជ្ជា ការបង្រៀនពីទស្សនវិជ្ជារបស់ខ្ញុំ គឺមាន លោក William Perkin′s ដែលខ្ញុំស្រឡាញ់ពេញមួយជីវិតរបស់ខ្ញុំយ៉ាងជ្រាលជ្រៅហើយថែមផ្តល់ជាសម្ភារៈសិក្សាព្រះគម្ពីរជាច្រើន នឹងការកែតម្រូវគោលលទ្ធិគ្រីស្ទបរិស័ទនឹង បទព្រះគម្ពីផ្ទាល់ខ្លួនរបស់ខ្ញុំ។ កិច្ចការទាំងនេះពឹងផ្អែក ទៅលើការបង្រៀនពីព័ន្ធកិច្ចរបស់ខ្ញុំនៅក្នុងសិក្ខាសាលាកំនែទម្រង់នៃសាសនវិទ្យានៅប្រទេស សហរដ្ឋអាមេរិច CBPCP នឹង KAPC នឹងការថ្វាយបង្គំជាលលក្ខណៈគ្រួសារ សរសេរទៅកាន់ គ្រីស្ទាននៅសហរដ្ឋអាមេរិច។ ហើយឥឡូវបេកជននៅប្រទេសគម្ពុជាបានបង្កើតសាសនវិទ្យាកំនែទម្រង់នៃពួកបរិសុទ្ធនឹង សេចក្តីជំនឿលើចិត្តរបស់គេទាំង២៥ខេត្តក្រុងនៃប្រទេសគម្ពុជា។

វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់សម្រាប់ជំហ៊ានដំបូងរបស់ខ្ញុំ ក្នុងគំរោងនៃសាសនវិទ្យាកំនែទម្រង់នៃពួកបរិសុទ្ធ នឹងសេចក្តីជំនឿ នៅចំនុចកណ្តាលនៃអាស៊ីអាគ្នេយ៍ដែលខ្ញុំបានអធិស្ឋានអស់រយៈពេលជាយូរមកហើយនៅក្នុងជីវិតរបស់ខ្ញុំ។

ខ្ញុំសូមកោតសរសើរចំពោះមិត្តរួមការងារទាំងអស់របស់ខ្ញុំ មិត្តភ័ក្រ្ត សាស្ត្រាចារ្យ សិស្សនៅ ITCS និងបុគ្គលិក CPPC របស់ខ្ញុំនិងក្រុមជំនុំព្រះវិហារ Peniel Presbyterian និងសាខាព្រះវិហារ Peniel សម្រាប់ការអធិស្ឋានដ៏កក់ក្តៅនិងការបម្រើដ៏ស្មោះត្រង់របស់ពួកគេទៅកាន់ព្រះយេស៊ូវគ្រីស្ទនិងការលើកទឹកចិត្តដ៏ស្មោះត្រង់ចំពោះព័ន្ធកិច្ចរបស់ខ្ញុំ លើសពីនេះទៅទៀត

ប្រពន្ធរបស់ខ្ញុំ(គីមប៊ីលី), កូនស្រីបីនាក់របស់ខ្ញុំអេសធើរសារ៉ុននិងម៉ារា បានលះបង់ ជាច្រើនសំរាប់ខ្ញុំនៅក្នុងព្រះគ្រីស្ទ។ ខ្ញុំជឿថាព្រះនឹងប្រទានព្រះពរនឹងព្រះគុណដ៏អស្ចារ្យដល់ពួកគេជាបន្តបន្ទាប់។

ខ្ញុំបានចំណាយពេលជាច្រើនម៉ោងនៅមុខកុំព្យូទ័ររបស់ខ្ញុំដើម្បីសរសេរនិងកែសម្រួល បញ្ចប់នូវការងាររបស់ខ្ញុំ បីភាសាគឺ ភាសាកូរ៉េ អង់គ្លេសនឹងខ្មែរ ដើម្បីចែករំលែកការងារទាំងនេះទៅកាន់ពិភពលោក តាមរយៈគោលដៅរបស់ខ្ញុំ។ ហើយខ្ញុំចាំថាពួកបរិសុទ្ធជាច្រើនអធិស្ឋានសម្រាប់ខ្ញុំ ហើយគាំទ្រនូវបេសកកម្មព័ន្ធកិច្ចជាមួយនឹងអំណោយទានដ៏មានតម្លៃរបស់ពួកគេ ហើយខ្ញុំថ្វាយសិរីល្អដល់ព្រះដែលមានព្រះជន្មរស់។

នៅខែធ្នូឆ្នាំ 1961 ខ្ញុំបានអធិស្ឋានថា «ព្រះអម្ចាស់អើយសូមប្រោសខ្ញុំឱ្យស្គាល់សេចក្ដីពិតហើយឱ្យខ្ញុំអាចនឹងប្រកាស សេចក្ដីពិត ទៅកាន់ពិភពលោក»។ ខ្ញុំបានលុតជង្គង់នៅលើភ្នំទឹកកកនៃរដូវរងា នឹងត្រជាក់ ហើយព្រះទ្រង់បានឆ្លើយតប់នូវការអធិស្ឋានរបស់ខ្ញុំ ដោយព្រះហស្តាំដ៏ស្មោះត្រង់របស់ទ្រង់ មកកាន់ជីវិតរបស់ខ្ញុំ។ ដូច្នេះខ្ញុំគួរតែស្មោះត្រង់នឹងបញ្ញាត្តិរបស់ទ្រង់នៅក្នុងព័ន្ធកិច្ច នៅកម្ពុជាក្នុងកំឡុងពេលសេសសល់ដែលខ្ញុំនៅរស់។ «ព្រះអម្ចាស់អើយសូមឱ្យទូលបង្គំសង់ព្រះវិហាររបស់ទ្រង់នៅលើទីវាលពិឃាត! (ម៉ាថាយ 16:18) "

មិថុនា ៣០ ២០១៧
នៅក្នុងបន្ទប់សិក្សារបស់ខ្ញុំនៅ ខាលី វរញ៉ា ប្រទេសសហរដ្ឋអាមេរិក
បេកជនអប់រំកម្ពុជា លោកបណ្ឌិត វ៉ាយ យ៉ុងជុន

**D. RGI នៅក្នុងសៀវភៅហោរាតូចទាំង១២**

និមិត្តទាំង៧របស់សាការី

១ អ្នកជិះនៅលើសេះក្រហម

២ ការជំនុំជំរះនៃប្រវត្តិសាស្ត្រ

៣ មនុស្សម្នាក់ដែលវាស់វែង

៤ បាវបំរើ នឹងអ្នកប្រមាញ់

៥ ទស្សនះរបស់ Goden Lampstand

៦ ប្រាជ្ញានៃការជំនុំជំរះរបស់ព្រះ

៧ ទស្សនះរបស់ Chariots

**E. RGI នៅក្នុងសៀវភៅកំនាព្យ**

១ ទំនុកតំកើង

២ សុភាសិត

**II. ការស្តារឡើងវិញនូវរូបឆ្លុះរបស់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី**

១ ការបង្រៀននៅលើភ្នំ

២ នៅក្នុងព្រះគម្ពីររ៉ូម

៣ នៅក្នុងព្រះគម្ពីកិច្ចការ

៤ ការបើកសំដែងនៅក្នុងព្រះគម្ពីយ៉ូហាន

**ជំពូកទី៥ ការអភិវឌ្ឍន៍នៃការសិក្សាប្រវត្តិសាស្ត្រ** (ការសិក្សាអំពីវប្បធម៌ សង្គមរបស់មនុស្ស នឹងរូបផ្តុំនៃគ្រោងឆ្អឹង)

**ជំពូកទី៦ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ក៏ដូចជាគោលបំណងនៃជីវិត**

១ សេចក្តីសង្គ្រោះចាប់ផ្តើមជាមួយនឹងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

២ ដំណើរការការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

៣ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះដែលបង្ហាញពីនិមិត្តរូបនៃព្រះគ្រីស្ទ

៤ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ត្រូវបានបើកសំដែងជាពន្លឺក្នុងជីវិត

**ជំពូកទី៧ ព័ន្ធកិច្ចក្នុងព្រះវិហារ ដែលសម្រេចក្នុងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ**

១ ការពឹងផ្អែកទៅលើការបើកសំដែង

២ ជីវិតដែលពឹងផ្អែកទៅលើព្រះវិញ្ញាណ

៣ ព្រះបន្ទូលដែលជាចំនុចកណ្តាលនៃជីវិត

៤ ការអធិស្ឋានជាចំនុចកណ្តាលនៃជីវិត

៥ ការថ្វាយបង្គំជាចំនុចកណ្តាលនៃជីវិត

៦ ព្រះគម្ពីជាចំនុចកណ្តាលនៃជីវិត

៧ ការផ្សាយដំណឹងល្អជាចំនុចកណ្តាលនៃជីវិត

៨ បេកកម្មជាចំនុចកណ្តាលនៃជីវិត

**ជំពូកទី៨  ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ក៏ដូចជាគោលបំណងនៃព័ន្ធកិច្ច**

១ ការលូតលាស់នៃក្រុមជំនុំអេភេសូរនឹងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

២ ការពិសោធន៏បទព្រះគម្ពី  សិក្សាពីបទព្រះគម្ពី  នឹងការបកស្រាយព្រះគម្ពី

៣ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ជាគោលបំណងនៃការអធិប្បាយក្នុងព័ន្ធកិច្ច

៤ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ជានិមិត្តរូបដំបូងនៃក្រុមជំនុំ (កិច្ចការ ២: ៤២-៥៤)

៥ ការស្នើសុំកំណែទំរង់នៃសេចក្តីជំនឿ នឹងកំណែទំរង់ជាក់លាក់ ឧទាហរណ៏ នៃ RGI

**ជំពូកទី៩ ជីវិត នឹងការចាត់ចែងនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ**

**ជំពូកទី១០ សេចក្តីសន្និដ្ឋាន**

**សេចក្តីបន្ថែម # 1** ទស្សនៈ ការសិក្សាព្រះគម្ពីសំរាប់ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

**សេចក្តីបន្ថែម # 2** ជីវិតជាគ្រីស្ទាន ក្នុងការសិក្សាព្រះគម្ពីសំរាប់ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

**ឯកសារយោង**

## D. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះបង្ហាញនៅក្នុងកណ្ឌគម្ពីរហោរាតូច

យើងរំលឹកពីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងសាការី។នៅពេលដែលយើងសង្កេតនូវនិមិ្មតទ៧របស់សាការី យើងរកឃើញ ពីរបៀបស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ត្រូវបានបង្ហាញនៅក្រោមពន្លឺនៃសេចក្តីប្រោសលោះដែលសំរេច និងរូបឆ្លុះនៅក្នុងសិរីល្អរបស់ព្រះ។

### និម្មិត៧បានបង្ហាញនៅក្នុងសាការី

1. អង្គដែលជិះនៅលើសេះក្រហម (សាការី 1:7-17)
2. ចៅក្រមនៃប្រវត្តិសាស្រ្ត (សាការី 1:18-21)
3. បុរសដែលកាន់បន្ទាត់វាស់វែង (សាការី 2:1-13)
4. អ្នកបំរើរបស់អញ ខ្នែងរបស់អញ (សាការី 3:1-10)
5. ជើងចង្កៀងមាស (សាការី 4:1-14)
6. ប្រាជ្ញានៃការវិនិច្ឆ័យទោសរបស់ព្រះ  (សាការី 5:1-11)
7. រទេះបួន (សាការី 6:1-15)

### 1. ការសង្កេតលើសាការី៖

(1) សាការីត្រូវបានដាក់ទាស់នឹងជីវៈប្រវត្តិនៃជំនាន់ទីមួយនៃមនុស្សដែលបានវិលត្រឡប់ពីការជំលៀសទៅបាប៊ីឡូន។ ការនិម្មិតនៅពេលយប់របស់គាត់ត្រូវបានកត់កាលបរិច្ឆេទនៅឆ្នាំទីពីរនៃស្តេចដារាស (520-519 B.C)។

(2) និម្មិតរបស់សាការីបង្ហាញពីរូបភាពនិងសិរីល្អនៃការប្រោសលោះរបស់ព្រះគ្រីស្ទ។

1) គ្រោងនៃកណ្ឌគម្ពីរសាការី




**សម្គាល់៖**

*1.* ការនិម្មិតទាំង៧បង្ហាញពីប្រវិត្តនៃសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទជាការបង់ថ្លៃជំនួស។

*2.* និម្មិតទាំង៧បង្ហាញពីដំណាក់កាលនៃសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទ ទាំងនោះមានដូចជា ការតាំងសញ្ញាចាស់ ការតាំងសញ្ញាថ្មី និងអេម៉ាញូអែល។

*3.* និម្មិតទាំង៧បង្ហាញពីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងក្រុមជំនុំ។ - សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ ភាពជាស្តេច ជាសង្ឃ និងជាហោរា។

*4.* និម្មិតទាំង៧បង្ហាញពីសេចក្តីប្រោសលោះដូចជាដំណាក់កាលបី មានដូចជា ការចាប់កំណើត ការរងទុក្ខ សេចក្តីស្លាប់ និងសេចក្តីរស់ឡើងវិញរបស់ព្រះគ្រីស្ទ និងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងការបញ្ចប់ចុងក្រោយរបស់ព្រះគ្រីស្ទ។

*5.* និម្មិតទាំង៧បង្ហាញពីការរាប់ជាសុចរិត ការបន្សុត និងការដំកើងឡើងនៃសេចក្តីប្រោសលោះ។

*3)* តារាងនៃនិម្មិតទាំង៧

| និម្មិត | អត្ថបទ | ចំណាងជើង | និមិត្តរូប | ការបកប្រែ | លក្ខណៈនៃការប្រោសលោះ |
|---|---|---|---|---|---|
| 1 | 1:7-17 | អង្គដែលជិះសេះក្រហម | អ្នកជិះ<br>ជម្រៅ<br>ដើមយីថោ | ព្រះគ្រីស្ទមុខពេលចាប់កំណើត | ចំណុចកណ្តាលនៃសេចក្តីប្រោសលោះ / អ្នកផ្សះផ្សា |
| 2 | 1:8-21 | ថៅក្រមនៃគ្រប់ជាតិសាសន៍ទាំងអស់ | ស្នែងទាំងបួន<br><br>កម្មករទាំងបួន | បាប៊ីឡូន<br>មីឌី<br>ភើសៀ<br>ស៊ីរៀ<br>ព្រះគ្រីស្ទ | សេចក្តីសុចរិតគោលការនៃការប្រោសលោះ |
| 3 | 2:1-13 | ម្នាក់ដែលមានបន្ទាត់វាស់វែង | ទេវតារបស់ព្រអម្ចាស់ | ព្រះគ្រីស្ទមុនពេលចាប់កំណើត | ការការពារទាំងស្រុងនិងសេចក្តីស្រឡាញ់នៃការប្រោសលោះ |
| 4 | 3:1-10 | អ្នកបំរើ និង ខ្នែង | ខ្នែង | ការបង់ថ្លៃលោះរបស់ព្រះគ្រីស្ត | ការបង់ថ្លៃលោះ |
| 5 | 4:1-14 | ជើងចង្កៀងមាស | | ព័ន្ធកិច្ចអនុវត្តនៃព្រះ | កិច្ចការរបស់ព្រះ |

| | | | | | |
|---|---|---|---|---|---|
| | | | | វិញ្ញាណ | វិញ្ញាណ |
| 6 | 5:1-11 | ប្រាជ្ញានៃការវិនិច្ឆ័យទោសរបស់ព្រះអម្ចាស់ | | សេចក្តីសុចរិតរបស់ព្រះ | សេចក្តីសុចរិតនៃសេចក្តីប្រោសលោះ |
| 7 | 6:1-15 | និម្មិតនៃរទេះទាំងបួន | | ការវិនិច្ឆ័យទោសចុងក្រោយរបស់ព្រះ | ចំណុចកណ្តាលនៃសេចក្តីប្រោសលោះ និងអ្នកសំរេចបំពេញ |

1. **អត្ថន័យ**

1) និម្មិតទាំង7បង្ហាញពីលំនាំនៃការអភិវឌ្ឍនៃសេចក្តីប្រោសលោះ (ប្រវត្តិសាស្ត្រ)

2) វិធីសាស្ត្រនៃការប្រោសលោះជាការបង់ថ្លៃលោះរបស់ព្រះគ្រីស្ទ។

3) អង្គប្រោសលោះជាព្រះគ្រីស្ទមុននឹងមកចាប់កំណើត។

4) លក្ខណៈនៃសេចក្តីប្រោសលោះមានផ្ទុកសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

2. **ការអនុវត្តៈ**

1) សេចក្តីសង្គ្រោះរបស់គ្រីស្ទានពឹងផ្អែកលើប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះរបស់ព្រះអម្ចាស់។

2) សេចក្តីសង្គ្រោះរបស់គ្រីស្ទានពឹងផ្អែកលើគុណរបស់ព្រះគ្រីស្ទ (ការសុគតនិងសេចក្តីរស់ឡើងវិញ)។

3) សេចក្តីសង្គ្រោះបរិបូរណ៍របស់គ្រីស្ទានពឹងលើព្រះគុណរបស់ព្រះគ្រីស្ទ។

4) ជ័យជំនះដ៏អស់កល្បរបស់គ្រីស្ទានពឹងផ្អែកលើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។

**1. អង្គដែលជិះលើសេះក្រហម (សាការី 1:7-11)**

1) នៅក្នុងជីវិតរបស់គ្រីស្ទានការយល់ពីព្រះគម្ពីរដោយត្រឹមត្រូវមានសារៈសំខាន់ណាស់ ដោយសារវាជាចរន្តនៃព្រះគុណយ៉ាងបរិបូររបស់ព្រះ។ ដូច្នេះយើងត្រូវតែរៀនពីប្រភពទន្លេនៃព្រះគម្ពីរ ដែលជាប្រវត្តិនៃសេចក្តីប្រោសលោះឲ្យបានល្អ។ នៅក្នុងការវិនិច្ឆ័យនៃថ្នាំពេទ្យរុក្ខជាតិ នៅពេលដែលយើងសង្កេតផ្នែកណាមួយនៃព្រះគម្ពីរ នោះយើងត្រូវតែដឹងពីលំហូរនៃចំណុចខ្លាំង ឬចំណុចខ្សោយ។ សេចក្តីពិតត្រូវការការបកប្រែពីកណ្ឌគម្ពីររបស់ហោរាដោយសកម្ម។

2) ក្នុងចំណោមនិម្មិតទាំង7 ក្នុងកណ្ឌគម្ពីរសាការី យើងសង្កេតឃើញនិម្មិតទីមួយពេលនេះដើម្បីនឹងស្គាល់ពីលំហូរ នៃប្រវត្តនៃការប្រោសលោះ។ ប្រសិនបើយើងយល់ការនិម្មិតមួយនេះបានល្អ យើងអាចស្គាល់ពីគន្លឹះយ៉ាងសំខាន់ទៅកាន់ការបកប្រែនូវរូបនិមិត្តនៅក្នុងព្រះគម្ពីរ។

ចូរអានខ 1:8 "នៅវេលាយប់ អញបានមើលទៅ ឃើញមានមនុស្សជិះសេះសម្បុរក្រហម ឈរនៅកណ្តាលដើមយីថោ ដែលដុះនៅទីទំនាប ឯខាងក្រោយអ្នកនោះ មានសេះជាច្រើន សម្បុរក្រហមពព្លាក់ ហើយស។" នៅទីនេះ យើងឃើញរូបភាពបីនៅក្នុងនិម្មិត ទាំងមាន អ្នកជិះសេះក្រហម ទំនាប និងដើមយីថោ។ តើអ្នកគិតថាពួកគេជាអ្វី?

**ទីមួយ តើអ្នកជិះលើសេះក្រហមជានរណា?**

1) សេះពណ៌ក្រហមជាសេះតំណាង ពីព្រោះគេបានចាប់ផ្តើមនិងគ្រប់គ្រប់នូវការចាប់ផ្តើមនៃសេះផ្សេងៗទៀត និងសេះក្រហម សេះត្នោត និងសេះសរផ្សេងទៀត។ "ឯខាងក្រោយអ្នកនោះ មានសេះជាច្រើន សម្បុរក្រហមពព្លាក់ ហើយស។"

ហើយនៅខ 10-11 មានបន្ទូលថា "រួចមនុស្សដែលឈរនៅកណ្តាលដើមយីថោ ក៏ឆ្លើយឡើងថា ទាំងអស់នេះជាពួកដែលព្រះយេហូវ៉ាបានចាត់ឲ្យដើរចុះឡើងនៅផែនដី។ ពួកនោះក៏តបដល់ទេវតានៃព្រះយេហូវ៉ា ដែលឈរកណ្តាលដើមយីថោថា យើងខ្ញុំរាល់គ្នាបានដើរចុះឡើងនៅផែនដី ពហើយក៏ឃើញថាផែនដីទាំងមូលនៅស្ងប់ស្ងាត់ ហើយស្រាកស្រាន្ត។"

2) តើពួកគេមានន័យយ៉ាងណា?

(1) សកម្មភាពរបស់អ្នកជិះមានន័យថា "ជ័យជំនះ" (វិវរណៈ 6:1-2) "កាលកូនចៀមបកត្រាទីមួយ នោះខ្ញុំក៏ឃើញ រួចខ្ញុំឮតួមានជីវិតមួយ បន្លឺសំលេងឡើងដូចផ្គរលាន់ថា ចូរមើលចុះ។ ខ្ញុំក៏ក្រឡេកទៅមើលសេះសមួយ ឯអ្នកដែលជិះក៏កាន់ធ្នូ ហើយមានគេឲ្យមកុដដល់អ្នកនោះ រួចអ្នកនោះចេញទៅទាំងមានជ័យជំនះ ហើយឲ្យបានឈ្នះតទៅ។"

(2) អ្នកជិះចង្អុលទៅកាន់បុគ្គលដែលមានមហិទ្ធិរិទ្ធ ដែលជាបុរសដែលនៅក្នុងខ 8 ដែលឈរនៅចន្លោះដើមយីថោនៅក្នុងវាលទំនាប។ ខ 10-11 និយាយថា បុរសនោះជាទេវតារបស់ព្រះយេហូវ៉ា។ គាត់ជាទេវតាពិសេសនៅក្នុងសញ្ញាចាស់ជាព្រះគ្រីស្ទមុនពេលចាប់កំណើតជាមនុស្ស។

(3) ហេតុអ្វីបានជាទ្រង់ឈរនៅក្នុងជ្រលងភ្នំសំរាប់សេចក្តីសង្គ្រោះរបស់រាស្ត្ររបស់ទ្រង់? ព្រះគ្រីស្ទបានសំរេចសេចក្តីប្រោសលោះនៅលើឈើឆ្កាង 2000 ឆ្នាំមុន។ ទ្រង់ជាទេវតារបស់ព្រះយេហូវ៉ា ដែលទ្រង់ជាព្រះគ្រីស្ទមុនពេលចាប់កំណើត។ និមិត្តសញ្ញាមានន័យថាជាអត្ថន័យពិតនៃនិម្មិតរបស់សាការី ដែលគាត់បានឃើញ ព្រះគ្រីស្ទនៅក្នុងសញ្ញាថ្មី បង្ហាញនៅលើផែនដីប្រហែល 600 ឆ្នាំបន្ទាប់មក។ ពេលនេះហោរាបានឃើញអង្គប្រោសលោះដែលបានសំរេចគ្រប់សេចក្តីសង្គ្រោះទាំងអស់ដោយអស្ចារ្យនៅក្នុងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ហេព្រើរ1:3 មានបន្ទូលថា "គឺទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់

ទាំងទ្រង់គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តានៃទ្រង់ ហើយក្រោយដែលបានសំអាតអំពើបាប របស់យើងរាល់គ្នាទាំងប៉ុន្មាន នោះក៏គង់នៅខាងស្តាំនៃឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់។"

1) ដូច្នេះការនិម្មិតរបស់គាត់បង្ហាញពីសេចក្តីពិតដែលពេញដោយសិរីល្អនៅក្នុងសេចក្តីសង្គ្រោះរបស់យើង។ នៅពេលដែលយើងប៉ះរូបភាពនោះ យើងនឹងអាចឃើញព្រះគុណប្រវត្តិសាស្ត្រនៃការប្រោសលោះដែលបានសន្យាមកកាន់យើង។ យើងបានយល់ពីសេចក្តីនោះរួចមកហើយ ហើយពេលនេះយើងនៅជាប់នឹងព្រះគុណដ៏បរិបូរនៅក្នុងព្រះគ្រីស្ទ។
ដូចដែលយើងបានដឹងហើយ យើងរកឃើញអត្ថន័យដូចនេះនៅក្នុងព្រឹត្តិការណ៍មួយចំនួន ការបង្កបង្កើត និក្ខមនំ និងការតាំងនៅស្រុកកាណានដែលជាកម្មសិទ្ធិរបស់ព្រះគុណ។

ចូរមើលទៅកាន់លោកុប្បត្តិ1:2 "ព្រះវិញ្ញាណរបស់ព្រះជាព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ ហើយបើកសំដែងនូវសេចក្តីពិតនៃសេចក្តីប្រោសលោះមកកាន់យើង ដែលត្រូវបានគ្រប់គ្រងនូវវត្តមានរបស់ព្រះ ជាអេម៉ាញូអែល។" ដូច្នេះប៉ូលបានចង្អុលថាព្រះអម្ចាស់ជាព្រះវិញ្ញាណនោះ។ (II កូរិនថូស 3:17 "រីឯព្រះអម្ចាស់ទ្រង់ជាព្រះវិញ្ញាណ ហើយកន្លែងណាដែលមានព្រះវិញ្ញាណនៃព្រះអម្ចាស់ នោះក៏មានសេរីភាពដែរ។" បន្ទាប់ពីយើងបានទទួលដំណឹងល្អ ភ្លាមនោះយើងចូលជិតទីវត្តមានជាព្រះគ្រីស្ទ។ (ម៉ាថាយ 28: 19-20) (I កូរិនថូស 5:17)

ហើយនិក្ខមនំក៏បានបង្ហាញនូវព្រឹត្តិការណ៍ដែលសំខាន់ជាងនេះទៅទៀត ដែលជាព្រះវត្តមានរបស់ព្រះនៅលើភ្នំស៊ីណាយ ជាទីបរិសុទ្ធ និងការអស្ចារ្យដ៏មានមហិទ្ធិរិទ្ធនៅក្នុងវាលរហោស្ថាន។ និមិត្តរូបទាំងនេះចង្អុលទៅកាន់វត្តមានរបស់ព្រះអម្ចាស់ ជាអាណាចក្ររបស់ព្រះ (សសរភ្លើង និងពពក) ដែលព្រះគ្រីស្ទមុនពេលចាប់កំណើតបានគ្រប់គ្រង។

ហើយការគ្រប់គ្រងស្រុកកាណានចង្អុលទៅកាន់សេចក្តីពិតផងដែរ។ ស្រុកកាណានពិតនោះមិនមែនទឹកដោះនិងទឹកឃ្មុំទេ ប៉ុន្តែជាព្រះវត្តមានរបស់ព្រះអម្ចាស់ ជាព្រះអេម៉ាញូអែលនៅក្នុងព្រះគ្រីស្ទ។ អ្នកដែលតាំងលំនៅបានទទួលការសំរាកចេញពីគ្រប់ទិស ដែលនោះជាព្រះអម្ចាស់ជាព្រះគ្រីស្ទ។ នៅពេលដែលយើងភ្ជាប់នូវព្រឹត្តិការណ៍នេះទៅនឹងនិម្មិតរបស់សាការី

ពេលនេះយើងអាចមើលឃើញព្រះវត្តមានរបស់ព្រះអម្ចាស់នៅក្នុងនិម្មិតនៃសេចក្តីប្រោសលោះ សេចក្តីសង្គ្រោះ និងការបង់ថ្លៃលោះ។ ព្រះអម្ចាស់ចង់លើកទឹកចិត្តអ្នកដែលបាក់ទឹកចិត្តដោយការបង្ហាញនូវសិរីល្អនៃការប្រោសលោះដ៏បរិបូរដល់ពួកគេ។ នៅពេលដែលយើងធ្លាក់ទឹកចិត្តនៅក្នុងអំពើបាបផ្ទាល់ខ្លួនរបស់យើង និងនៅក្នុងលក្ខខណ្ឌមិនល្អរបស់យើង នោះយើងត្រូវមើលទៅកាន់ព្រះគ្រីស្ទ (យ៉ូហាន 1:14)។ សិរីលញអរបស់បុត្រាតែមួយ ព្រះគុណនិងសេចក្តីពិត នៅពេលដែលហោរាបានឃើញ។ តើនរណាជាអ្នកកំសាន្តចិត្តដល់យើងពិតប្រាកដ? មានតែព្រះយេស៊ូវគ្រីស្ទ ដែលជាអង្គដែលជិះនៅលើសេះក្រហមប៉ុណ្ណោះ។

**ទីពីរ យើងអាចមើលឃើញពីរូបភាពយ៉ាងជ្រៅ**

1) អ្នកជិះក្រោកឈរនៅក្នុងជ្រលងដ៏ជ្រៅ ទំនាប ឬជ្រោះជ្រៅ។ តើវាមានន័យដូចម្តេច? ដើម្បីស្គាល់នូវអត្ថន័យ យើងត្រូវយល់អត្ថន័យនៃពាក្យសិន។ *mesula* មានន័យថាជម្រៅ។ ជ្រោះគឺជ្រៅ។ វាចង្អុលទៅកាន់ការវិនិច្ឆ័យទោសរបស់ព្រះអម្ចាស់ ការវិនាសអន្តរាយអំពើបាប និងសេចក្តីងងឹតខាងវិញ្ញាណ សាការីបានឃើញអំពើបាបនិងលក្ខខណ្ឌនៅក្នុងនិម្មិតតែមួយ។ ការពិតនោះទីជម្រៅបង្ហាញពីការមួយចំនួននៅក្នុងការបើកសំដែងម្តង់ទៀត។

2) នៅក្នុងលោកុប្បត្តិ 1:2 មុនពេលការបង្កបង្កើត តើអ្វីទៅជាសភាពដើម? វាជាទីជម្រៅ សេចក្តីរីករវ សេចក្តីងងឹតជាដើម។ មានន័យថាជាអំពើបាបនិងបណ្តាសារ។ ទីជម្រៅបង្ហាញពីស្ថាននរកដូចជារណ្តៅដែលមានបាតនៅក្នុងវិវរណៈ។ ហេតុអ្វីបានជាសាការីបានឃើញនិម្មិតលាយឡំរវាងជ័យជំនះនិងសេចក្តីអន្តរាយដូច្នេះ? វាសង្កត់ធ្ងន់ទៅលើសេចក្តីប្រោសលោះ។ នៅពេលដែលពណ៌សបានលេចមកកាន់តែច្បាស់នៅខាងលើងក្តាពណ៌ខ្មៅសេចក្តីប្រោសលោះបង្ហាញនៅលើជីវៈប្រវត្តិនៃសេចក្តីងងឹត អំពើបាប បណ្តាសារ នរក សេចក្តីស្លាប់ នៅពេលដែលការបង្កបង្កើតត្រូវបានចាប់ផ្តើមនៅក្នុងជីវៈប្រវត្តិនៃភាពរីករវ ជម្រៅនិងសេចក្តីងងឹត។

3) ទីជម្រៅនេះម្តងទៀតបង្ហាញនៅក្នុងព្រឹត្តិការណ៍នៃទឹកជំនន់ណូអេ។ ព្រឹត្តិការណ៍ចង្អុលទៅកាន់សេចក្តីសង្គ្រោះដ៏អស្ចារ្យចេញពីអំពើបាបនិងបណ្តាសារទាំងស្រុង។ ដូច្នេះលោកុប្បត្តិ 8:1-2 និយាយថា "ព្រះទ្រង់ក៏នឹងចាំពីណូអេ នឹងអស់ទាំងសត្វព្រៃ សត្វស្រុកទាំង

ប៉ុន្មាន ដែលនៅក្នុងទូកជាមួយនឹងគាត់ រួចទ្រង់ធ្វើឲ្យខ្យល់បក់មកលើផែនដី ហើយទឹកក៏ស្រកទៅ។ ឯរន្ធទឹកនៅទីជម្រៅនឹងទ្វារទំនប់ នៅលើមេឃបានបិទវិញ ហើយភ្លៀងដែលធ្លាក់ពីលើមេឃមកក៏រាំងទៅ។ ទឹកបានថយចេញពីផែនដីជាដរាប លុះដល់ផុតពី១៥០ថ្ងៃទៅទើបបានស្រកបន្តិច។" ទឹកជំនន់ត្រូវបានហៅថាទីជម្រៅ។

4) ហើយទីជម្រៅម្តងទៀតនៅក្នុងព្រឹត្តិការណ៍និក្ខមនំ។ មីរៀមបានច្រៀងចំរៀងមួយនៅពេលដែលពួកអ៊ីស្រាអែលត្រូវបានសង្គ្រោះពីជម្រៅសមុទ្រក្រហម។ ដូចដែលគំរូទាំងនេះបានកើតឡើង ទីជម្រៅនៅក្នុងនិម្មិតប្រកាសនូវសេចក្តីសង្គ្រោះដ៏អស្ចារ្យពិតប្រាកដមកកាន់យើង។ សាការីបានឃើញសេចក្តីសង្គ្រោះដ៏គួរកោតសរសើរនោះ។ (និក្ខមនំ 15:5 "រទេះរបស់ផារ៉ោននិងកងទ័ពរបស់ទ្រង់បរចូលទៅក្នុងសមុទ្រ។ ឯពួកមេទ័ពជ្រើសរើសទាំងប៉ុន្មាន ក៏បានលង់នៅក្នុងសមុទ្រក្រហម។ អស់ទាំងទីជម្រៅបានគ្របគេបាត់ គេបានចុះទៅដល់បាតសមុទ្រដូចជាថ្ម។"

5) ដោយសង្ខេប អង្គសង្គ្រោះជាទេវតារបស់ព្រះយេហូវ៉ា ដែលជាព្រះគ្រីស្ទ។ ហើយនៅក្នុងជីវៈប្រវត្តិនៃសេចក្តីសង្គ្រោះជាសេចក្តីវិនាសទាំងស្រុង។ ដូច្នេះយើងគួរតែទទួលស្គាល់សភាពពុករលួយទាំងស្រុងរបស់យើងនៅក្នុងសេចក្តីសង្គ្រោះរបស់យើង។ សេចក្តីសង្គ្រោះពិតត្រូវតែយល់ការពីរយ៉ាង ទាំងនោះមាន សេចក្តីសង្គ្រោះដែលពេញដោយសិរីល្អ និងសេចក្តីស្លាប់ទាំងស្រុង។ វាជាមុខពិតនៃសេចក្តីសង្គ្រោះពិត។ ដូច្នេះយើងគួរតែពិនិត្យជីវិតជាគ្រីស្ទានរបស់យើង ជាបទពិសោធន៍របស់អេសាយ 6:5, "នោះខ្ញុំពោលថា វរហើយខ្ញុំ ខ្ញុំត្រូវវិនាសជាពិត ដ្បិតខ្ញុំជាមនុស្សមានបបូរមាត់មិនស្អាត ហើយខ្ញុំនៅកណ្តាលមនុស្សដែលមានបបូរមាត់មិនស្អាតដែរ ពីព្រោះភ្នែកខ្ញុំបានឃើញមហាក្សត្រ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ។"

## ទីបី ហោរាដែលសង្កេតដើមយីថោដែលទេវតាបានឈរនៅកណ្តាល

1) តើមានន័យដូចម្តេច? ដើមយីថោចង្អុលទៅកាន់ព្រះវត្តមានរបស់ព្រះអម្ចាស់ដូចជាសួនច្បារអេដែន។ នៅពេលដែលព្រះគ្រីស្ទចុះទៅកាន់កន្លែងនោះ ព្រះវត្តមានរបស់ព្រះអម្ចាស់

នៅជាមួយនឹងទ្រង់។ បើទោះជាវាជាទីជម្រៅនៃសេចក្តីងងឹតសូន្យឈឹងក៏ដោយ ក៏ព្រះវត្តមានរបស់ទ្រង់គ្រប់គ្រងនៅទីនោះដែរ។ វាចង្អុលទៅកាន់កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដែលមានដូចជា ពន្លឺ សេរីភាព សង្ឃឹម និងសភាពដែលបានផ្លាស់ប្តូរ។ នៅពេលដែលព្រះវិញ្ញាណធ្វើការនៅពេលណា នៅកន្លែងណា នោះយើងអាចទទួលបាននូវព្រះវត្តមានយ៉ាងអស្ចារ្យ ជីវិតអស់កល្បជានិច្ច និងព្រះគុណខាងវិញ្ញាណ ហើយនឹងភាពបរិបូរណ៍មកពីស្ថានសួគ៌។ នេះជាសេចក្តីប្រោសលោះរបស់យើងនិងសេចក្តីសង្គ្រោះដែលពេញដោយសិរីល្អរបស់យើង។ តើអ្នកមើលឃើញសេចក្តីប្រោសលោះដែរឬទេ?

2) ព្រឹត្តិការណ៍នៃការផ្លាស់ប្រែអង្គរបស់ព្រះអម្ចាស់បង្ហាញពីសេចក្តីប្រោសលោះពេញដោយសិរីរុងរឿង។ បើទោះជាព្រះគ្រីស្ទត្រូវបានផ្លាស់ប្តូរដោយព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែពេត្រុសបានសារភាពថា "ទូលបង្គំស្នាក់នៅទីនេះ។" ហេតុអ្វី? ពីព្រោះគាត់បានឃើញសិរីល្អនៃសេចក្តីប្រោសលោះដែលទ្រង់បានធ្វើ។

នៅថ្ងៃនេះព្រឹត្តិការណ៍ដូចនោះជារបស់យើង។ យើងបានឃើញនិម្មិតរបស់សាការី ដែលបានចង្អុលទៅកាន់សេចក្តីប្រោសលោះដ៏ពិតប្រាកដនិងសិរីល្អនៃសេចក្តីប្រោសលោះនោះ។ នៅក្នុងព័ន្ធកិច្ចជាគ្រូគង្វាលរបស់យើង យើងត្រូវការបទពិសោធន៍បែបនេះ។ យើងគួរតែសារភាពដោយផ្ទាល់ថាការស្នាក់នៅទីនេះ ខ្ញុំស្រឡាញ់ខ្លាំងណាស់។

## សរុបសេចក្តី៖

យើងត្រូវតែមើលឃើញនិម្មិត។ យើងត្រូវតែស្គាល់អត្ថន័យនៅក្នុងជីវិតរបស់យើង។ បន្ទាប់មកយើងស្គាល់សេចក្តីកំសាន្តចិត្តពិត ព្រះអង្គសង្គ្រោះពិត និងសេចក្តីសង្គ្រោះពិត។

## 2. ចៅក្រមនៃប្រវត្តិសាស្ត្រ (សាការី 1:18-21)

## សេចក្តីណែនាំ៖

1) មនុស្សហៅថាជា "និម្មិតនៃជាងដែកបួននាក់"។ ជាបន្តសាការីបានឃើញនិម្មិតមួយទៀតដែលគ្រប់គ្រងប្រវត្តិសាស្ត្រពិភពលោក។ តើវាមានន័យយ៉ាងណា? យើងត្រូវការការបក

ស្រាយនូវនិមិត្តនេះ។ នៅក្នុងពាក្យមួយទៀត វាបង្ហាញពីព្រះហស្តដ៏មានគ្រប់អំណាចចេស្តានៃព្រះប្រាជ្ញាញាណរបស់ព្រះអម្ចាស់។ ប្រវត្តិសាស្ត្ររបស់កម្ពុជានៃវាលពិឃាតត្រូវបានរាប់បញ្ចូលនៅក្នុងព្រះហស្តនោះ។

2) ប្រវត្តិសាស្ត្រនៅក្នុងបេសកកម្មប្រទេសកម្ពុជា យើងអាចអានពីព្រះហស្តដែលមានការកំរិតរបស់ព្រះអម្ចាស់ ដើម្បីនឹងប្រកាសដំណឹងល្អដល់ប្រជារាស្ត្រ។ នៅក្នុងចំណោមការទាំងនោះ ខ្ញុំបានអានថារដ្ឋាភិបាលកម្ពុជាបានបដិសេធគ្រប់បេសកជនដែលនៅក្រោមបារាំង។ បន្ទាប់មកបុរសម្នាក់ដែលរស់នៅម៉ននថាណាបានអធិស្ឋានអស់រយៈពេល២៥ឆ្នាំសំរាប់ការផ្សាយដំណឹងល្អដល់ប្រទេសកម្ពុជា។ បន្ទាប់មកមិត្តភក្តិរបស់នាង ដែលជាកូនស្រីរបស់ស្តេចបារាំង បានដឹងពីសេចក្តីពិតហើយបានជួយឲ្យបេសកជនបរទេសនោះអាចចូលទៅប្រទេសកម្ពុជា នៅពេលនោះទ្វារនៃដំណឹងល្អនៅកម្ពុជាត្រូវបានបើកចំហរ។ ដែលវាជាព្រះហស្តរបស់ព្រះអម្ចាស់។

3) សម្រាប់ការសាងសង់ឡើងវិញរបស់អ៊ីស្រាអែល ព្រះអម្ចាស់បានធ្វើការនៅក្នុងស្ថានភាពអន្តរជាតិសំរាប់បំណងព្រះហឫទ័យរបស់ទ្រង់។ ដូច្នេះសព្វថ្ងៃនេះ យើងនឹងសង្កេតមើលព្រះហស្តរបស់ព្រះ ព្រះដែលមើលមិនឃើញ។ ព្រះហស្តនេះធ្វើការនៅក្នុងចិត្តយើង នៅក្នុងជីវិតផ្ទាល់ខ្លួន និងជីវិតនៃការសិក្សារបស់យើង។ តើអ្នកជឿលើការនេះទេ?

នៅទីនេះ តើនរណាជាជាងដែកទាំងបួននាក់នោះ? តើពួកគេធ្វើអ្វីខ្លះ? តើអ្វីទៅជាលទ្ធផលនៃកិច្ចការរបស់ពួកគេ?

## I. ព្រះអម្ចាស់ជាចៅក្រមដ៏ពិតតែមួយនៅក្នុងលោកិយ

1) តើនរណាដែលបានបង្គាប់ទៅកាន់ជាងដែកទាំងបួន? ព្រះអម្ចាស់ដែលមានគ្រប់អំណាចចេស្តាបានបង្គាប់មក។ ការបង្គាប់របស់ទ្រង់នោះជាការបង្គាប់ទាំងស្រុងនៅក្នុងប្រវត្តិសាស្ត្រ ពីព្រោះទ្រង់ជាព្រះអាទិករ ចៅក្រម និងអ្នកសំរេច។

បើទោះជាពួកអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាប ហើយត្រូវបានធ្លាក់ចុះក្នុងសភាពដ៏អាក្រក់ក៏ដោយ តែសេចក្តីស្រឡាញ់ដ៏នៅស្ថិតស្ថេររបស់ព្រះអម្ចាស់មិនអាចផ្លាស់ប្តូរបានទេ។ នៅក្នុងចំណោមសេចក្តីក្រោធដ៏ខ្លាំងរបស់ទ្រង់ ទ្រង់ក៏មិនបានភ្លេចសេចក្តីមេត្តារបស់ទ្រង់ដល់រាស្ត្ររបស់ទ្រង់ដែរ។ ប៉ុន្តែការប្រៀនប្រដៅជាការដែលឈឺចាប់។ ហេព្រើរ 12:7-11 មានបន្ទូលថា "បើសិនជាអ្នករាល់គ្នាត្រូវសេចក្តីផ្ចាញ់ផ្ចាល នោះគឺព្រះអង្គទ្រង់ប្រព្រឹត្តនឹងអ្នករាល់គ្នា ដូចជាកូនហើយ ដ្បិតតើមានកូនឯណាដែលឪពុកមិនវាយផ្ចាលនោះ។ តែបើសិនជាអ្នករាល់គ្នាមិនដែលត្រូវផ្ចាញ់ផ្ចាលសោះ ជាសេចក្តីដែលគ្រប់គ្នាទ្រូវរងទ្រាំ នោះអ្នករាល់គ្នាជាកូនឥតខាន់ស្លាទេ មិនមែនជាកូនពិតប្រាកដឡើយ។ មួយទៀតយើងរាល់គ្នាមានឪពុកខាងសាច់ឈាមដែលវាយផ្ចាលយើង ហើយយើងក៏កោតខ្លាចដល់គាត់ដែរ ដូច្នេះតើមិនត្រូវឲ្យយើងចុះចូល ចំពោះព្រះវរបិតាខាងវិញ្ញាណជាជាងទៅទៀត ដើម្បីឲ្យបានរស់នៅទេឬអី។ ដ្បិតឪពុកយើងតែងវាយប្រដៅយើង តាមតែខណៈចិត្តរបស់គាត់ប៉ុណ្ណោះ តែមិនមែនជាយូឆ្នាំទេ ចំណែកព្រះដែលទ្រង់វាយផ្ចាល នោះសំរាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឲ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់។ កាលណាយើងត្រូវសេចក្តីផ្ចាញ់ផ្ចាល នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយមក នោះទើបបង្កើតផលដ៏សុខសាន្ត នៃសេចក្តីសុចរិត ដល់អស់អ្នកណាដែលត្រូវរងទ្រាំនោះវិញ។"

2) ដូច្នេះអ្នកបំរើដែលទ្រង់បញ្ជូនមកលោកិយ មានអំណាចចេស្តាដែលពេញលេញ។ ហើយព្រះបន្ទូលរបស់ទ្រង់ក៏មានអំណាចចេស្តាទាំងស្រុងដែរនៅក្នុងព័ន្ធកិច្ច។

(1) អ្នកនាំសារមានអំណាចរបស់ស្តេច។ អ្នកអធិប្បាយជាអ្នកព្យាបាលរបស់ស្តេច។ ប្រសិនបើមនុស្សមិនអាចស្តាប់តៅការបង្គាប់របស់គាត់ទេ គេនឹងបដិសេធស្តេចនិងការបញ្ជារបស់ទ្រង់។ ក្នុងន័យមួយទៀត អ្នកអធិប្បាយទទួលនូវជំណែងយ៉ាងសំខាន់ ពីព្រោះគាត់មានអំណាចរបស់ស្តេច។ ប៉ុន្តែទំនួលខុសត្រូវនៅជាប់នឹងគាត់។

(2) អេសាយ 55:8-11 មានបន្ទូលថា "ព្រះអម្ចាស់មានព្រះបន្ទូលថា: គំនិតយើងខុសប្លែកពីគំនិតអ្នករាល់គ្នា រីឯរបៀបដែលយើងប្រព្រឹត្ត ក៏ខុសប្លែកពីរបៀបដែលអ្នករាល់គ្នាប្រព្រឹត្តដែរ។[៩] មេឃខ្ពស់ជាងផែនដីយ៉ាងណារបៀបដែលយើងប្រព្រឹត្តក៏ខុសប្លែកពីរបៀបដែលអ្នករាល់

គ្នាប្រព្រឹត្តហើយគំនិតរបស់យើងក៏ខុសប្លែកពីគំនិតរបស់អ្នករាល់គ្នាយ៉ាងនោះដែរ។[១០] ទឹកភ្លៀង និងទឹកសន្សើមធ្លាក់ពីលើមេឃមកស្រោចស្រពផែនដី។ទឹកទាំងនេះមិនវិលត្រឡប់ទៅវិញឡើយដរាបណាទាល់តែបានធ្វើអោយដំណាំដុះឡើងបង្កើតភោគផល ផ្តល់ពូជសំរាប់អ្នកសាបព្រោះនិងផ្តល់អាហារអោយគេបរិភោគ។[១១] រីឯពាក្យរបស់យើងក៏ដូច្នោះដែរគឺពាក្យដែលចេញពីមាត់របស់យើងនឹងមិនវិលត្រឡប់មករកយើងវិញឡើយដរាបណាទាល់តែបានសំរេចតាមបំណងរបស់យើងជាមុនសិនគឺបំពេញកិច្ចការដែលយើងចាត់អោយមកធ្វើរួចរាល់សព្វគ្រប់។

(2) តើអ្វីទៅជាលក្ខណៈនៃអំណាចចេស្តារបស់ព្រះបន្ទូលព្រះអម្ចាស់? វាជាចេស្តាទាំងអស់។ ជាងដែកមានន័យថាប្រទេសទាំងបួនមាន បាប៊ីឡូន មីឌី ភើសៀ និងក្រិក។ បើទោះជាពួកគេជាជាតិសាសន៍ដែលមានកំលាំងខ្លាំងនៅក្នុងប្រវត្តិសាស្រ្តក៏ដោយ ចុងក្រោយពួកគេត្រូវបានបំផ្លាញដោយព្រះហស្តរបស់ព្រះអម្ចាស់ ដោយសារអំពើបាបរបស់គេ។ ឧទាហរណ៍ តើអ្នកបានដឹងទេថា បាប៊ីឡូនត្រូវបានបំផ្លាញនៅក្នុងលោកិយដោយរបៀបណា? ស្តេចបេសាស្សាបានប្រារព្ធពិធីជប់លៀងជាមួយនឹងមន្រ្តីរបស់ទ្រង់ដោយការស៊ីផឹកជាមួយនឹងរបស់របរព្រះវិហារនៅក្នុងដំណាក់។ ភ្លាមនោះដៃមួយបានលេចមកនៅលើជញ្ជាំងហើយបានសរសេរអក្សរមួយចំនួន។ "នេះជាពាក្យដែលបានសរសេរ៖ mene, mene, tekel, parsin" "នេះជាអត្ថន័យនៃពាក្យនោះ៖ *Mene*: ព្រះបានរាប់ថ្ងៃនៃរាជ្យរបស់ឯងហើយទ្រង់បាននាំទីបញ្ចប់ដល់ថ្ងៃនោះ។ *Tekel*: ឯងត្រូវបានថ្លឹងនៅលើជញ្ជីងនិងបានរកឃើញកំពុងចង់បាន។ 28 *Peres*: នគររបស់ឯងត្រូវបានបំបែកហើយឲ្យដល់ មីឌី និងភើសៀ។" (ដានីយ៉ែល 5:25-28)

ជាចុងក្រោយនៅយប់នោះ សាសន៍នោះត្រូវបានបំផ្លាញដោយមន្រ្តីផ្សេងទៀត។ ព្រះបានកាត់ទោសស្តេចនោះដោយព្រះហស្តរបស់ទ្រង់។ នៅក្នុងប្រវត្តិសាស្រ្ត គ្រប់ជាតិសាសន៍ត្រូវបានគ្រប់គ្រងដោយព្រះហស្តដែលមើលមិនឃើញរបស់ព្រះអម្ចាស់។

1) នៅគ្រារបស់យើង នៅកម្ពុជា យើងត្រូវតែភ័យខ្លាចដល់ព្រះហស្តរបស់ព្រះ ដែលកំពុងធ្វើការក្នុងមនុស្សទាំងអស់ គ្រប់សេដ្ឋកិច្ចទាំងអស់ គ្រប់វប្បធម៌ទាំងអស់ និងគ្រប់ស្ថានភាពនយោបាយទាំងអស់។ ព្រះហស្តដែលមើលមិនឃើញរបស់ព្រះអម្ចាស់កំពុងធ្វើការនៅ

លើយើង។តើអ្នកជឿការនេះទេ? នៅពេលដែលយើងបានឃើញព្រះហស្តរបស់ព្រះអម្ចាស់នៅភូមិមួយពីសប្តាហ៍មុន ខ្ញុំមានការភ្ញាក់ផ្អើលចំពោះការនោះ។ រំពេចដែលយើងទៅដល់នោះ មានតែមនុស្សប្រាំនាក់ប៉ុណ្ណោះបានមក។ ជាបន្តបន្ទាប់ចំនួនមនុស្សបានកើនឡើងលើសជាង៥០នាក់បានប្រមូលមក។ ភ្លាមនោះក្រុមជំនុំមួយត្រូវបានបង្កើតឡើងលើកទីមួយនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំបានដឹងថាព្រះបានប្រើពួកគេ។ ខ្ញុំរំពឹងថាក្រុមជំនុំនឹងផ្សាយដំណឹងល្អគ្រប់ភូមិទាំងអស់ក្នុងកំឡុងប៉ុន្មានឆ្នាំនេះ។ ប្រសិនបើព្រះអម្ចាស់ធ្វើការនេះ ការអស្ចារ្យនឹងកើតឡើង។ តើអ្នកជឿលើការនេះទេ?

## II. ព្រះអម្ចាស់ជាចៅក្រមដែលពេញលេញ

1) ចៅក្រមពិតទាំងស្រុងជាចៅក្រមដែលពេញលេញ។ចៅក្រមដែលពេញលេញបំផ្លាញគ្រប់ការទាំងអស់ ហើយសាងសង់គ្រប់ការទាំងអស់ ពីព្រោះទ្រង់មានអំណាចចេស្តាធ្វើការទាំងអស់។ តើអ្នកជឿលើការនេះទេ?

2) សេចក្តីសង្រ្គោះរបស់យើងត្រូវបានសំរេចដោយព្រះអម្ចាស់ដែលមានគ្រប់អំណាចចេស្តា។ បើទោះជាទ្រង់បានបំផ្លាញគ្រប់ទាំងអំពើបាប គ្រប់សេចក្តីជំនឿ និងគ្រប់ការផ្តន់ទាទោសទាំងអស់ ទ្រង់បានស្តារគ្រប់ការទាំងអស់ជាការថ្មីនៅក្នុងយើង។ ប៉ូលបានស្គាល់វានោះ។ រ៉ូមជំពូក 5 បង្ហាញពីសេចក្តីពិតជាក់ស្តែងមកកាន់យើង។ រ៉ូម 5:17-19 មានបន្ទូលថា "ដ្បិតបើសេចក្តីស្លាប់បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តសេចក្តីរំលង ដូច្នេះប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ នឹងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យលើជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រីស្ទ។ ដូច្នេះ ដែលមនុស្សទាំងអស់ត្រូវទោស ដោយព្រោះអំពើរំលងតែមួយ នោះមនុស្សទាំងអស់ក៏បានរាប់ជាសុចរិតឲ្យបានជីវិតវិញ ដោយសារអំពើសុចរិតតែមួយបែបដូច្នោះដែរ។ ដ្បិតដូចជាមនុស្សជាច្រើន បានត្រឡប់ជាមានបាប ដោយសារមនុស្សតែម្នាក់មិនបានស្តាប់បង្គាប់ជាយ៉ាងណានោះមនុស្សជាច្រើននឹងបានត្រឡប់ជាសុចរិត ដោយសារម្នាក់បានស្តាប់បង្គាប់វិញយ៉ាងនោះដែរ។"

3) យើងត្រូវតែយល់សេចក្តីសង្គ្រោះពិតដែលផ្ទុកនូវការវិជ្ជមាននិងការអវិជ្ជមាន។ ដូច្នេះពួកគ្រីស្ទានកំណែទម្រង់ចង់ដើរតាមសេចក្តីសង្គ្រោះយ៉ាងពេញលេញនៅក្នុងលោកិយ។ ប្រវត្តិសាស្រ្តបានប្រាប់យើងនូវអាកប្បកិរិយាបួនប្រភេទទៅកាន់វប្បធម៌ ទាំងនោះមាន (1) សាសនាគ្រីស្ទដែលបានបំផ្លាញគ្រប់វប្បធម៌ (2) សាសនាគ្រីស្ទដែលបានចាកចេញពីវប្បធម៌ (3) សាសនាគ្រីស្ទដែលបានបន្ទូរបន្ថយជាមួយនឹងវប្បធម៌ (4) សាសនាគ្រីស្ទដែលផ្លាស់ប្រែដោយការបំផ្លិចបំផ្លាញដែលមកតាមក្រោយ។នៅពេលដែលពួកបរិសុទ្ធធ្វើផ្ទះ ពួកគេចង់សង់ផ្ទះដែលព្រះអម្ចាស់របស់ពួកគេគង់នៅ។ ពួកគេចង់បានព្រះអម្ចាស់នៅគ្រប់ទីកន្លែងទាំងអស់ ដែលនឹងទទួលបានការកំសាន្តដោយសារមនុស្ស ពីព្រោះពួកគេជឿលើចៅក្រមដែលពេញលេញ។ ដូច្នេះនៅពេលយើងរិះគន់អ្វីមួយ យើងគួរតែផ្តល់នូវគំនិតមួយជាចម្លើយជំនួសទៅកាន់ការនោះ។ ប្រសិនបើគេចេះតែរអ៊ូពីការណាមួយ នោះគាត់ជាមនុស្សអវិជ្ជមាន។ យើងត្រូវតែក្លាយជាមនុស្សដែលវិជ្ជមាននៅក្នុងព្រះគ្រីស្ទ។

### III. ព្រះអម្ចាស់ធ្វើការកាត់ទោសដោយលំអិត

1) ព្រះអម្ចាស់របស់យើងជាចៅក្រមដែលពិតប្រាកដនិងជាចៅក្រមពេញលេញ។ ហើយទ្រង់ជាចៅក្រមដែលលំអិតនៅក្នុងការតូចនិងការធំផង។ ទ្រង់ជាចៅក្រមដែលម៉ត់ចត់។ទ្រង់បានចាត់ទុកគ្រប់ជាតិសាសន៍ទាំងអស់ គ្រប់មនុស្សទាំងអស់ និងគ្រប់គំនិតទាំងអស់។ ដូច្នេះយើងត្រូវញាប់ញ័រនៅចំពោះទ្រង់។

នៅក្នុងព័ន្ធកិច្ចរបស់គ្រូគង្វាល យើងត្រូវរៀនចិត្តដែលស្អាត់ហើយលំអិត។ ចូរដកការគិតជាមួយនឹងជំនួយមួយចំនួន ដោយមិនយកការផ្តត់ផ្តង់ណាឡើយ។ យើងអាចបង្កើតប្រវត្តិសាស្រ្តថ្មីនៅក្នុងព្រះអម្ចាស់របស់យើង។ បន្ទាប់មកយើងនឹងក្លាយជាមនុស្សប្រុសនិងមនុស្សស្រីដែលខ្លាំង។ បន្ទាប់មកយើអាចផ្លាស់ប្រែប្រទេសកម្ពុជា។នៅពេលដែលយើងរស់នៅជាមួយនឹងជំនួយមួយចំនួន នោះយើងភ្ញាក់ឡើងចេញពីចិត្ត។ យើងត្រូវគិតនូវការអរគុណ។ ចូរមានសេចក្តីស្រមៃដើម្បីជួយដល់អ្នកជិតខាងរបស់យើង។ តើយើងអាចជួយពួកគេដោយលុយដោយអំណាច និងដោយប្រាជ្ញាបានយ៉ាងដូចម្តេច? វាមិនមែនជាគោលបំណងរបស់យើងទេ ប៉ុន្តែវាជាវិធីសាស្រ្តមួយរបស់យើង។ ប៉ុន្តែការដែលសំខាន់ជាងនេះទៀតនោះគឺការបំរើពួក

គេដោយដំណឹងល្អ។ យើងត្រូវផ្លាស់ប្រែពួកគេដោយគំនិតនិងជីវិតដែលគោរពកោតខ្លាចដល់ព្រះរបស់យើង។ ចូរមានក្តីស្រមៃបែបនេះនៅក្នុងចិត្តរបស់អ្នក។

**សរុបសេចក្តី៖**

ប្រទេសកម្ពុជាស្រែកហៅយើង និងអាស៊ីអាគ្នេយ៍ស្រែកហៅមកកាន់យើងថា "ជួយយើងផង!" ពួកគេស្នាក់នៅក្នុងស្រមោលនៃបណ្តាសារបស់ព្រះ ដោយមិនបានយល់ពីដំណឹងល្អ។ យើងត្រូវតែឆ្លើយតបទៅកាន់ពួកគេជាបន្ទាន់។

1) ចូរថ្វាយខ្លួនរបស់អ្នកទៅលំនាំនៃកិច្ចការនៃការប្រោសលោះ ហោះហើរដោយបានគ្រប់គ្រងដោយព្រះអម្ចាស់នៃព្រះគម្ពីរ។ ទ្រង់ជាព្រះពិតប្រាកដ ពេញលេញហើយជាព្រះដែលលំអិត។

**3. មនុស្សដែលកាន់ខ្សែរង្វាស់នៅដៃ (សាការី 2:1-13)**

## សេចក្តីណែនាំ

នៅទីនេះ បុរសនេះជាអ្នកជិះលើសេះក្រហម ព្រះគ្រីស្ទមុនពេលចាប់កំណើតជាមនុស្ស។ តើទ្រង់នឹងសំរេចអ្វីនៅក្រុងយេរូសាឡិម? យើងអាចរកឃើញបញ្ហាសំខាន់បីដែលទាក់ទងទៅនឹងសេចក្តីប្រោសលោះ។ ទីមួយបង្អស់ យើងត្រូវសារភាពថាទ្រង់ជាទេវតារបស់ព្រះយេហូវ៉ា។ សាការីឃើញសេចក្តីប្រោសលោះរបស់ទេវតារបស់ព្រះអម្ចាស់សំរាប់ប្រជារាស្ត្ររបស់គាត់ផ្ទាល់។ ការប្រៀបប្រដូចបង្ហាញពីសិរីល្អនៃសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទយ៉ាងច្បាស់ទៅកាន់យើង។

I. វាជាការសង់យេរូសាឡិមថ្មីជាទីជម្រករបស់យើងពិតប្រាកដ

1) ខ 3-5 មានបន្ទូលថា "នោះឃើញទេវតាដែលពោលនឹងខ្ញុំក៏ចេញទៅ ហើយទេវតាមួយទៀតបានមកជួបគ្នា។ ដោយប្រាប់ថាចូររត់ទៅប្រាប់មនុស្សកំឡោះនោះថា ក្រុងយេរូសាឡិមនឹងមានមនុស្សអាស្រ័យនៅ ដូចជានៅអស់ទាំងភូមិតដែលឥតមានកំផែង ដោយព្រោះមានមនុស្ស នឹងសត្វយ៉ាងសន្ធឹកនៅក្នុងនោះ។ ដ្បិតអញនឹងបានជាកំផែងភ្លើងដល់ទីក្រុងនៅព័ទ្ធជុំវិញ ហើយនឹងជាសិរីល្អនៅកណ្តាលនោះដែរ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា។"

2) ការផ្តោតរបស់សេចក្តីប្រៀបធៀបត្រូវបានដាក់នៅក្នុងការការពាររបស់យេរូសាឡិម ដូចជាទីក្រុងដែលគ្មានជញ្ជាំង ជាមួយនឹងជញ្ជាំងភ្លើង។ ហើយព្រះអម្ចាស់នឹងជាសិរីល្អនៃទីក្រុងនោះ។ ការបញ្ជាក់នេះប្រាប់យើងអំពីសេចក្តីពិតដែលបរិបូរនៃសេចក្តីប្រោសលោះ។ តើវាជាអ្វី? ពួកគេចង្អុលទៅកាន់ការថែរក្សាយ៉ាងពិតប្រាកដដូចជាសួនច្បារអេដែន (លោកុប្បត្តិ 3:24) ហើយដូចជាការការពារនៃស្រុកសាម៉ារីនៃអ៊ីស្រាអែលខាងជើង ដែលការពារពីការវាយប្រហាររបស់ពួកស៊ីរី (II របាក្សត្រ 6:15-19) ព្រះអម្ចាស់ជាអង្គការពារទ្វេនៃយេរូសាឡិម។ បន្ទាប់មកនៅក្នុងសញ្ញាថ្មី ព្រះយេស៊ូវបានសង្កត់លើការពារទ្វេរដងសំរាប់រាស្ត្ររបស់ទ្រង់ យ៉ូហាន10:28-29។ "ខ្ញុំឲ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកអាចឆក់យកវាពីដៃខ្ញុំបានទេ។ ព្រះវរបិតាខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់យកវាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ។" នៅពេលនេះយើងរស់នៅក្នុងជញ្ជាំងភ្លើងនៅក្នុងលោកិយ ដូចដែលយើងបានដឹងហើយថានៅពេលដែលពួកអ៊ីស្រាអែលបានចេញពីអេស៊ីបតាមរយៈសសរភ្លើងដែលបានថែរក្សាអ៊ីស្រាអែល ចេញពីការវាយប្រហាររបស់ពួកសាសន៍អេស៊ីប។ វាជាជញ្ជាំងភ្លើង។ អេសាយបានសង្កត់ថាជាការការពារដ៏ពិតសំរាប់រាស្ត្ររបស់គាត់។ (អេសាយ 41:8-10) "តែឯង ឱអ៊ីស្រាអែល ជាអ្នកបំរើអញអើយ ព្រមទាំងយ៉ាកុប ដែលអញបានរើស ជាពូជអ័ប្រាហាំ ដ៏ជាសំឡាញ់របស់អញផង។ គឺឯងដែលអញបានចាប់នាំមកពីចុងផែនដី ហើយបានហៅមកពីទីឆ្ងាយបំផុត ដោយនិយាយនឹងឯងថា ឯងជាអ្នកបំរើរបស់អញ អញបានរើសឯង មិនបាន

បោះបង់ចោលឯងទេ។ កុំឲ្យភ័យខ្លាចឡើយ ដ្បិតអញនៅជាមួយនឹងឯង អញនឹងចំរើនកំឡាំងដល់ឯង អើអញនឹងជួយឯង អើអញនឹងទ្រឯង ដោយស្តាំដ៏សុចរិតរបស់អញ។" ព្រះគម្ពីរសញ្ញាចាស់បានសង្កត់លើនិមិត្តសញ្ញាដូច្នេះចង្អុលទៅ ប៉ុន្តែពេលនេះយើងរស់នៅក្នុងគ្រឿងសឹកដ៏ពិតរបស់ព្រះគ្រីស្ទ។ (អេភេសូ 6:10-11) "ឯសេចក្តីឯទៀត បងប្អូនអើយ ចូរមានកំឡាំងឡើងក្នុងព្រះអម្ចាស់ ដោយឫទ្ធិបារមីរបស់ព្រះចេស្តាទ្រង់។ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអំបាលម៉ានរបស់អារក្ស។" អេម៉ាញូអែលជាការការពារលើអស់ទាំងការការពារ។ ព្រះអម្ចាស់របស់យើងនឹងរក្សាសេចក្តីសន្យារបស់ទ្រង់ដោយស្មោះត្រង់ "អញនឹងនៅជាមួយនឹងឯងអស់កល្បជានិច្ច។"

3) នៅពេលដែលយើងបំរើលោកិយនៅក្នុងព្រះនាមព្រះយេស៊ូវ យើងគួរតែអះអាងនូវការការពារនេះ។ មនុស្សជាច្រើនកំពុងតែវង្វេង ដោយសារការនៅក្នុងអនាគតរបស់គេពីបញ្ហា លុយ សុខភាព និងទំនាក់ទំនង។ បន្ទាប់មកយើងមើលទៅកាន់យេរូសាឡិមថ្មី ខ្ញុំយេស៊ូវគ្រីស្ទជាធាតុនៃការប្រោសលោះជាបរិបូរ។

## II. ព្រះអម្ចាស់នឹងគ្រប់គ្រងលើឯនគរ

1) ខ 6-9 មានបន្ទូលថា "ហឺយៗ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូររត់ចេញពីស្រុកខាងជើងមកដ្បិតអញបានបែងចែកឯងរាល់គ្នាទៅដូចជាខ្យល់ទាំង៤នៅលើអាកាស នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ា។ ហឺយ ពួកស៊ីយ៉ូន ដែលនៅជាមួយនឹងកូនស្រីក្រុងបាប៊ីឡូនអើយ ចូរដោះខ្លួនឲ្យរួចចុះ។ ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះថា ក្រោយសិរីល្អ នោះទ្រង់បានចាត់អញទៅសាសន៍ដទៃ ដែលប្លន់ឯងរាល់គ្នា ពីព្រោះអ្នកណាដែលពាក់ឯងរាល់គ្នា នោះគឺជាពាល់ដល់ប្រស្រីព្រះនេត្រនៃទ្រង់ហើយ។ ដ្បិតមើលអញនឹងារដៃពីលើគេ ហើយគេនឹងត្រឡប់ជារបឹបដល់ពួកអ្នកដែលបំរោះគេវិញ នោះឯងរាល់គ្នានឹងដឹងថា ព្រះយេហូវ៉ានៃពួកពល់បរិវារ ទ្រង់បានចាត់អញមក។"

2) ចេញពីអត្ថបទនោះ យើងអាចរកឃើញធាតុមួយទៀតនៃនគរ ដូចជាផ្នែកនៃសេចក្តីប្រោសលោះរបស់យើង។ តើវាជាអ្វី? វាជាអ្វីដែលព្រះទ្រង់ផ្ទាល់គ្រប់គ្រងលើនគររបស់ព្រះដូចជាចេស្តាដែលគ្រប់គ្រងរបស់ទ្រង់។ ទ្រង់នឹងផ្តល់សេរីភាពឲ្យរួចពីសភាពដែលត្រូវ

ជាឈ្លើយរបស់បាប៊ីឡូន។ ហើយទ្រង់នឹងបំផ្លាញសត្រូវរបស់ពួកគេដោយព្រះហស្តដ៏មានចេស្តារបស់ទ្រង់ (ខ្យល់ទាំងបួន) ព្រះអម្ចាស់នៅតែស្រឡាញ់ស៊ីយ៉ូនដូចជាប្រស្រីភ្នែករបស់ទ្រង់ ហើយព្រះហស្តដែលកាត់ទោសរបស់ទ្រង់នឹងធ្វើឲ្យពួកគេស្គាល់ព្រះអម្ចាស់ឲ្យបានជ្រាលជ្រៅ។ អាចនិយាយបានថា ចំណេះដឹងពីព្រះនឹងបានហូរហៀរនៅក្នុងផែនដីដោយការគ្រប់គ្រងរបស់ទ្រង់នៅលើនគរ។

3) យើងពេលនេះកំពុងរបស់នៅក្រោមការគ្រប់គ្រងគ្រប់ពេលវេលា គ្រប់ទីកន្លែងនៅលើផែនដី។ កម្ពុជាមិនអាចចាកចេញពីការគ្រប់គ្រងនៃរដ្ឋាភិបាលនេះឡើយ។ ប៉ុន្តែយើងគួរតែសង្កេតនូវការគ្រប់គ្រងដែលមានប្រសើរជាង ដែលជាព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងព្រះគម្ពីរ។ ដូច្នេះយើងត្រូវស្វែងរកនគរនិងសេចក្ដីសុចរិតរបស់ទ្រង់ជាមុននៅក្នុងជីវិតជាក់ស្ដែងរបស់យើង។ (ម៉ាថាយ 6:33) ពីព្រោះយើងជាកម្មសិទ្ធិរបស់សេចក្ដីប្រោសលោះនៃនគរនោះ។

### III. គ្រប់ជាតិសាសន៍ទាំងអស់នឹងចូលរួមនៅក្នុងទីក្រុង

1) ហើយសេចក្ដីប្រោសលោះចង្អុលទៅកាន់ធាតុដ៏អស្ចារ្យមួយទៀត។ វាជាចំនុចនៃសេចក្ដីប្រោសលោះនៃសកលលោក លើកលែងតែជាតិសាសន៍ស៊ីយ៉ូន។ ដូច្នេះ ខ 10-13 មានបន្ទូលថា "ឱកូនស្រីស៊ីយ៉ូនអើយ ចូរច្រៀង ហើយមានចិត្តអរសប្បាយឡើង ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា មើលអញមកហើយ អញនឹងនៅកណ្ដាលឯងរាល់គ្នា។ នៅគ្រានោះសាសន៍ជាច្រើននឹងចូលពួកខាងព្រះយេហូវ៉ា គេនឹងបានជារាស្ត្ររបស់អញ ហើយអញនឹងនៅកណ្ដាលឯងរាល់គ្នា នោះឯងនឹងដឹងថា ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានចាត់ឲ្យអញមកឯឯង។ ព្រះយេហូវ៉ាទ្រង់នឹងបានស្រុកយូដាទុកជាចំណែកមរតកនៃទ្រង់នៅក្នុងស្រុកបរិសុទ្ធ ហើយទ្រង់នឹងរើសយកក្រុងយេរូសាឡិមទៀត។ មនុស្សទាំងឡាយអើយ ចូរនៅស្ងៀមចំពោះព្រះយេហូវ៉ាចុះ ដ្បិតទ្រង់បានតើនឡើង ចេញពីទីលំនៅបរិសុទ្ធរបស់ទ្រង់ហើយ។"

2) អត្ថបទទាំងនេះសង្កត់លើភាពជាសកលនៃសេចក្ដីប្រោសលោះ ដែលជារាស្ត្រ

ដែលត្រូវបានរើសតាំងក្នុងចំណោមជាតិសាសន៍ទាំងអស់ ដែលនឹងត្រឡប់មកកាន់ស៊ីយ៉ូន។ ពិតណាស់ទំនាយត្រូវបានសំរេចនៅក្នុងសញ្ញាថ្មី។ កិច្ចការបានបង្ហាញថាមនុស្សជាតិបានប្រមូលផ្តុំនៅយេរូសាឡិមនៅក្នុងពិធីបុណ្យទីហាសិប។ ពួកគេជាក្រុមជំនុំសកលដំបូងនៅក្នុងប្រវត្តិសាស្រ្ត ដែលផ្ទុកដោយសាសន៍ដទៃនិងសាសន៍អ៊ីស្រាអែល។ នេះជាការសំរេចបំពេញលំអិតនៃសេចក្តីប្រោសលោះ ដោយព្រះហស្តដែលគ្រប់គ្រង។ ហើយពេលនេះយើងកំពុងតែរស់នៅក្នុងការនោះ។

3) នៅពេលដែលយើងរៀនពីព្រះគម្ពីរនៅសាលានេះ យើងគួរតែមើលឃើញសេចក្តីប្រោសលោះពេញដោយសិរីល្អ ការការពារដ៏ពិត ការគ្រប់គ្រងដ៏មានអំណាចចេស្តារបស់ព្រះ និងសេចក្តីប្រោសលោះជាសកល។ ដោយសារគោលបំណងនេះ យើងត្រូវតែថ្វាយខ្លួនរបស់យើងដាច់ទៅកាន់ទ្រង់។ បន្ទាប់ពីយើងបានបញ្ចប់ការប្រកាសព្រះគុណដ៏បរិបូរនេះទៅកាន់អ្នកជិតខាងរបស់យើង យើងនឹងទៅកាន់ពិភពលោកដ៏នៅអស់កល្ប។

## សរុបសេចក្តី ៖

សូមកុំមើលទៅកាន់រូបភាពដែលអាក្រក់ ដែលជាគំនិតរបស់អ្នកប្រាជ្ញ។ ប៉ុន្តែយើងត្រូវផ្តោតទៅលើនិម្មិតដែលពេញសិរីល្អ ជាសេចក្តីប្រោសលោះដែលបរិបូរនៅក្នុងព្រះគ្រីស្ទ។ នៅទីនេះយើងត្រូវដាក់ទុនពេញមួយជីវិតរបស់យើងនៅក្នុងព្រះហឫទ័យរបស់ព្រះ។ នេះជាសេចក្តីស្កប់ស្កល់របស់យើង ការឆ្អែតឆ្អន់របស់យើង នឹងជាប្រភពរបស់យើង និងជាចេស្តារបស់យើងនៅក្នុងលោកិយ។

**4 "អ្នកបំរើរបស់អញ មែករបស់អញ" (សាការី 3:1-10)**

## សេចក្តីណែនាំ៖

ការនិម្មិតនេះបង្ហាញពីលក្ខណៈនៃព្រះអម្ចាស់ដែលប្រោសលោះ ដែលបានដកថ្មជំពប់ចេញទាស់នឹងការងារថ្មី។ យ៉ូស្វេដែលជាអ្នកពាក់ក្រណាត់កខ្វក់ មានន័យថាជាសភាពដ៏អាក្រក់របស់អ៊ីស្រាអែល។ ទីមួយ គ្រប់ទាំងអស់ព្រះអម្ចាស់មិនអើពើនឹងការចោទប្រកាន់របស់

សាតាំងនហើយបានពាក្យមកុដថ្មីរបស់ទ្រង់នៅលើព្រះសិរសា។ ហើយទ្រង់បានសន្យាថា នៅអនាគតមែកថ្មីនឹងត្រូវចេញមក។ (8) នៅក្នុងអត្ថបទយើងស្គាល់នរណាជាមែកនិងអ្វីដែលយើងនឹងទទួល? ប្រសិនបើយើងស្គាល់អព្រះពរដែលពេញដោយសិរីរុងរឿង។ តើព្រះពរប្រភេទនេះជាអ្វី?

## I. ទ្រង់បានដកបាបទាំងអស់អស់កល្បជានិច្ច

1) អត្ថបទនេះស្រដៀងទៅនឹងយ៉ូប 1:1-3 (1) យ៉ូស្វេដែលបានក្រោកឈរនៅចំពោះអង្គសរនាការស្ថានសួគ៌ដែលត្រូវបានចោទប្រកាន់ដោយសាតាំង។ព្រះយេហូវ៉ាបានស្តីបន្ទោស សាតាំងពីរដង ហើយទ្រង់បានដោះសំលៀបំពាក់កខ្វក់របស់គាត់ ហើយបានពាក់មកុដថ្មីនិងសំលៀកបំពាក់ថ្មីទៅដល់គាត់ (4-5)។ នៅពេលដែលព្រះអម្ចាស់បានប្រាប់ការដូច្នេះដល់គាត់ ហើយបន្ទាប់មកគាត់បានឆ្លើយថា គាត់នឹងរក្សាច្បាប់របស់គាត់ ហើយនឹងឆ្លើយតបនឹងព្រះផ្ទះរបស់ខ្ញុំនិងដីរបស់ខ្ញុំ។ (6-7)

2) នៅទីនេះយើងអាចរៀនការពីរយ៉ាងអំពីការទូលអង្វរ។ 1) អំពើបាបបាននាំមកនូវការបរាជ័យទាំងស្រុងទោកាន់យើង។ សេចក្តីវិនាសអន្តរាយរបស់អ៊ីស្រាអែលចេញមកពីអំពើបាប។ វាមិនមែនជាអំពើបាបអវិជ្ជមាន ប៉ុន្តែជាអំពើបាបវិជ្ជមាន។ អំពើបាបខាងវិញ្ញាណរបស់អ្នកដឹកនាំមានគ្រោះថ្នាក់ជាង។ 2) មានតែទេវតារបស់ព្រះអម្ចាស់អាចសំអាតគ្រប់ទាំងអំពើបាប។ ដោយសារការដាក់ទោសរបស់ព្រះយេហូវ៉ា ការចោទប្រកាន់របស់សាតាំងមិនត្រូវបានទទួលស្គាល់ដោយព្រះអម្ចាស់ទេ។ ព្រះអម្ចាស់បានស្តីបន្ទោស ដែលពួកគេមិនអាចចោទប្រកាន់ពួកគេម្តងទៀត។ ទេវតាបាននិយាយទៅកាន់អ្នកទាំងនោះដែលកំពុងឈរនៅចំពោះទ្រង់ថា "សូមយកសំលៀកបំពាក់កខ្វក់របស់គេចេញ។" បន្ទាប់មកទ្រង់មានបន្ទូលទៅកាន់យ៉ូស្វេ "មើល អញបានដកអំពើបាបរបស់ឯងចេញហើយ ហើយអញនឹងពាក់សំលៀកបំពាក់ថ្មីលើឯង។"

3) "ទេវតារបស់ព្រះយេហូវ៉ា ឬព្រះយេហូវ៉ាចង្អុលទៅសេចក្តីពិតរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង។ ការសុគតរបស់ព្រះអម្ចាស់ អាចអត់ទោសបាបរបស់យើងបាន។ (ហេព្រើរ

10:17) យើងមិនគួរស្វែងរកហេតុផលដែលត្រូវបាត់បង់ចេស្តានិងការរីករាយឡើង។ តើយើងមានដោយរបៀបណានៅពេលដែលយើងមិនបានធ្វើការដែលវិជ្ជមាន? យើងត្រូវតែត្រឡប់ទៅរកភាពពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ សេចក្ដីស្រឡាញ់និងជំនួយដែលតែងតែប្រែប្រួលទៅកាន់អ្នកជិតខាងយើង នោះចេញមកពីការអធិស្ឋានដោយរសាយ។

## II. ទ្រង់យាងមកដូចជាមែករបស់យើង

1) នៅក្នុងខ 8-10 យើងអាចមើលឃើញកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងការនិមិ្មត។ វាជាកិច្ចការរបស់ខ្នែងថ្មីដែលនៅក្នុងការនិមិ្មតនៃការយាងមករបស់ព្រះគ្រីស្ទនៅថ្ងៃចុងក្រោយ។ "ឱយេសួរជាសម្ដេចសង្ឃអើយចូរស្ដាប់ឥឡូវព្រមទាំងពួកអ្នកដែលអង្គុយនៅជាមួយនឹងឯងផងពីគេជាពួកដែលជាទីអស្ចារ្យ ដ្បិតមើល អញនឹងឲ្យអ្នកបំរើរបស់អញឈ្មោះ លំពង់ ចេញមក។" (8, អេសាយ 11:1 យេរេមា 23:5)

2) តើខ្នែងនោះត្រូវធ្វើដូចម្ដេច? 1) ទ្រង់នឹងចាប់ផ្ដើមព័ន្ធកិច្ចថ្មី។ ដូចជាបុរសទីពីរ ឬអ័ដាមចុងក្រោយដែលនឹងសំអាតអស់អំពើបាប ហើយសំរេចបំពេញការថ្មី។ ទ្រង់នឹងសំរេចបំពេញនូវការចលនារបស់ខ្នែងថ្មី ចលនារបស់គ្រាប់ពូជដ៏ល្អិត និងចលនារបស់មេដំបែ មិនមែនជាឈើដែលឆេះត្រូវបានដកចេញពីភ្លើងនោះទេ (II កូរិនថូស 5:17)។ នៅពេលដែលយើងភ្ជាប់ទៅនឹងព្រះគ្រីស្ទ នោះទ្រង់អាចបង្កើតផលផ្លែជាបរិបូរ។ (យ៉ូហាន 15:5)

3) តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលជាប្រសិទ្ធិភាពនៃការអត់ទោសបាបត្រូវបានធ្វើឡើងជាអស់កល្ប។ ថ្មដែលត្រូវបានបង្កើតឡើងនៅចំពោះយ៉ូស្វេចង្អុលទៅកាន់ព្រះគ្រីស្ទ។ នៅខ 9 ភ្នែកទាំងប្រាំពីរនៅថ្ម និងពាក្យដែលបានចំណានៅនៅលើថ្មនោះ មានន័យថាជាព្រះវិញ្ញាណបរិសុទ្ធដែលត្រូវបានបញ្ជូនមកនៅលើពិភពលោកទាំងមូល។ ទ្រង់បានបង្កើតឲ្យកិច្ចការរបស់ព្រះគ្រីស្ទមានប្រសិទ្ធិភាព។ "ចូរមើលថ្មដែលអញបានដាក់នៅមុខយេសួរចុះ នៅថ្មតែមួយនោះមានភ្នែក៧ ព្រះយេហូវ៉ានៃពួកបរិវារ ទ្រង់មានបន្ទូលថា មើលអញនឹងចរឹកចម្លាក់ដែលត្រូវឆ្លាក់នៅថ្មនោះ ហើយនឹងដកយកសេចក្ដីទុច្ចរិតពីស្រុកនេះចេញក្នុងមួយថ្ងៃ។"

1) កិច្ចការប្រាំពីររបស់អារក្សនឹងទៅក្លែងក្លាយ ប៉ុន្តែកិច្ចការរបស់វិញ្ញាណទាំងប្រាំពីរវិញនឹងបានជាពិតប្រាកដវិញ។ ឈើឆ្កាងរបស់ព្រះគ្រីស្ទនឹងត្រូវបានបង្ហាញនូវប្រសិទ្ធិភាពដោយចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ។ 3) ការថ្វាយបង្គំខាងវិញ្ញាណពិតប្រាកដនឹងត្រូវបានសំរេចដោយព្រះអម្ចាស់។ ខ 10 មានបន្ទូលមកកាន់យើងពីជីវិតពេញបរិបូរនៅថ្ងៃនោះ។ នៅថ្ងៃនោះមានបន្ទូលថា "ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលថា នៅថ្ងៃនោះ ឯងរាល់គ្នានឹងអញ្ជើញអ្នកជិតខាងរបស់ឯងមក នៅក្រោមដើមទំពាំងបាយជូរ ហើយក្រោមដើមល្វារៀងខ្លួន។"

2) មនុស្សនឹងចង្អុលទៅកាន់គ្រីស្ទាននៅសញ្ញាថ្មី។ ថ្ងៃនោះនឹងបង្ហាញពីការប្រកបខាងវិញ្ញាណនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអម្ចាស់ដែលទ្រង់ត្រូវបានហៅជាអ្នកបំរើរបស់ព្រះយេហូវ៉ា ជាទេវតារបស់ព្រះយេហូវ៉ា ឬជាព្រះយេហូវ៉ា បានធ្វើការមុន២០០០ឆ្នាំ ហើយឥឡូវនេះធ្វើការនៅក្នុងព្រះវិញ្ញាណ។ ចូររំពឹងការថ្មី។ ចូរទទួលការអត់ទោសបាប។ ចូររំពឹងការប្រកបគ្នាជាបរិបូរនៅក្នុងព្រះគ្រីស្ទ។ ចូរយើងទៅកាន់ទីដែលពេញដោយព្រះពរនេះ។

## III. យើងគួរតែនាំមកនូវផលផ្លែដោយការនៅជាប់នឹងខ្នែង

1) ដូចជាខ្នែងដែលខ្សោយព្រះយេស៊ូវគ្រីស្ទបានយាងមកនៅក្នុងផែនដី ដើម្បីនឹងនាំមកនូវផលផ្លែដែលបរិបូរណ៍នៅក្នុងពិភពលោក។ បើទោះជាទ្រង់ជាខ្នែងដ៏ខ្សោយហើយមានមុខមាត់ដ៏អាក្រក់ក៏ដោយ គង់តែទ្រង់នឹងបានខ្លាំងបំផុតនិងស្អាតបំផុតនៅក្នុងលោកិយនិងនៅលើស្ថានសួគ៌។ ដូច្នេះគ្រប់ទាំងខ្នែងតូចៗដូចជាពួកជំនុំ ដែលយើងអាចនាំមកនូវផលផ្លែជាបរិបូរនៅក្នុងលោកិយ។ (យ៉ូហាន 15:5) តើអ្វីទៅជាលក្ខខណ្ឌ? នោះគឺត្រូវតែនៅជាប់នឹងទ្រង់។ តើវាមានន័យដូចម្តេច? វាជាការទាក់ទងនឹងព្រះគ្រីស្ទហើយនៅជិតស្និតជាមួយនឹងទ្រង់។

2) តើជាប្រភេទផលផ្លែអ្វី? វាមានពីរប្រភេទ។ មួយជាផលផ្លែខាងលក្ខណៈ។ ហើយមួយទៀតជាផលផ្លែនៃការផ្សាយដំណឹងល្អ។ វាមានន័យថាជាការនាំយកនូវសិស្សនៅក្នុងលោកិយ។ តើយើងអាចនាំមកនូវផលផ្លែដោយរបៀបណា? នោះជាការនៅជាប់នឹងខ្នែង។

3) ជាពិសេសយើងរស់នៅក្នុងថ្ងៃចុងក្រោយនៅក្នុងលោកិយ។ គោលដៅរបស់យើងត្រូវតែបង្កើតផលផ្លែឲ្យបានច្រើន។ ជាការស្តារនូវរូបឆ្លុះរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពបរិសុទ្ធ។ តាមរយៈការអធិស្ឋានជាច្រើននិងការសញ្ជឹងគិតព្រះបន្ទូល នោះយើងនឹងអាចភ្លក់នូវការបង្កើតនូវផលផ្លែជាបរិបូរនៅក្នុងជីវិតរបស់យើង។

## សរុបសេចក្តី៖

យោងតាមទំនាយរបស់សាការី ខ្នែងបានមកលើផែនដី។ ទ្រង់បានសំរេចគ្រប់ផែនការទាំងអស់របស់ព្រះអម្ចាស់ដែលមានគ្រប់អំណាចចេស្តារបស់យើង។ នៅក្នុងខ្នែងនោះយើងអាចនឹងផ្លាស់ប្តូរទៅជារូបឆ្លុះរបស់ព្រះ។ដូច្នេះយើងត្រូវតែខិតចូលជិតនូវបេសកកម្មផ្សាយដំណឹងល្អដើម្បីនឹងផ្សាយដំណឹងល្អនៅតាមភូមិ។ចូរយើងឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះ។

## 5 និម្មិតនៃជើងចង្កៀងមាស (សាការី 4:1-14)

## សេចក្តីផ្តើម៖

1) នៅពេលនេះយើងមើលឃើញសេចក្តីសង្គ្រោះដ៏បរិបូរអស្ចារ្យនៅក្នុងព្រះគ្រីស្ទតាមរយៈនិម្មិតទាំងប្រាំមួយរបស់សាការី។ នៅពេលដែលយើងអាននូវនិម្មិតនោះ យើងមើលឃើញការបើកសំដែងជារូបភាព ដែលផ្តោតលើព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការប្រៀបធៀបទៅកាន់ការនិម្មិតទីបួនដែលផ្តោតទៅលើព្រះគ្រីស្ទ។ យើងមើលឃើញកិច្ចការរបស់ព្រះគ្រីស្ទ ក៏ដូចជាកិច្ចការរបស់ព្រះវិញ្ញាណនៅក្នុងសេចក្តីពិតនៃសេចក្តីប្រោសលោះរបស់យើង។ តើអ្នកអាចមើលឃើញការនេះនៅក្នុងនិម្មិតរបស់សាការីឬទេ?

2) ជាពិសេសការនិម្មិតនៅក្នុងអត្ថបទសង្កត់ធ្ងន់ថា មានតែព្រះវិញ្ញាណបរិសុទ្ធអាចផ្លាស់ប្តូរភ្នំធំទៅជាទីរាបស្មើបាន។ នៅខ 7 មានបន្ទូលថា "ភ្នំធំអើយ តើឯងជាអ្វី? នៅចំពោះ

សេរូបាបិល ឯងនឹងទៅជាដីដែលរាបស្មើ។" នៅទីនេះ ជើងចង្កៀងមាសចង្អុលទៅក្រុមជំនុំ និងប្រេងមាសជាព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងខ្មែងពីរនៃដើមឈើប្រេងជា យ៉ូស្វេនិងសេរូបាបិល ដែលជាអ្នកបានត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។

I. ព្រះវិញ្ញាណបរិសុទ្ធធ្វើឲ្យភ្នំធំទៅជាដីដែលរាបស្មើ

1) ដំបូងបង្អស់ យើងមើលឃើញជើងចង្កៀង (ម៉ែរេណា) នៅក្នុងនិមិត្ត។ តើអ្នកយល់ពីអត្ថន័យនោះទេ? រូបភាពនៃជើងចង្កៀងមាសសុទ្ធចង្អុលទៅកាន់ការលូតលាស់នៃក្រុមជំនុំ ដែលនឹងត្រូវកើតឡើងដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ កិច្ចការនេះបានកើតឡើងទាំងនៅក្នុងសញ្ញាចាស់នឹងសញ្ញាថ្មី។ យើងជឿគ្រប់កិច្ចការទាំងអស់ដែលនៅក្នុងសញ្ញាចាស់ ដែលបានផ្តោតទៅលើសេចក្តីប្រោសលោះដោយព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានបញ្ជាក់នៅក្នុងនិមិត្តរូប ឬដោយសេចក្តីពិតផ្ទាល់។

ហើយនៅក្នុងការរំលឹករបស់កណ្ឌគម្ពីរកិច្ចការ យើងអាចយល់ព្រះវិញ្ញាណបរិសុទ្ធ ដែលអាចសំរេចសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទ។

- នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងចុះមកលើក្រុមជំនុំ នោះពួកគេបានទទួលព្រះអម្ចាស់ជាម្ចាស់។ (កិច្ចកា 1:8 "ប៉ុន្តែកាលណាព្រះវិញ្ញាណបរិសុទ្ធ បានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនឹងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង។")
- នៅក្នុងថ្ងៃបុណ្យទីហាសិប ព្រះវិញ្ញាណបរិសុទ្ធបានមកលើពួកជំនុំ (2:1-2 "កាលបុណ្យទីហាសិបបានមកដល់ នោះគេមានចិត្តព្រមព្រៀងប្រជុំទាំងអស់គ្នានៅកន្លែងតែមួយ។ ស្រាប់តែមានឮសូរពីលើមេឃ ដូចជាខ្យល់បក់គំហុកយ៉ាងខ្លាំងមកពេញក្នុងផ្ទះដែលគេអង្គុយនៅ។")
- ហើយនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធមកលើគេ ហ្វូងមនុស្សបានទទួលព្រះចេស្តាមួយទៀត។ And when (4:26-29 "ពួកមហាក្សត្រនៅផែនដីលើកគ្នាឡើង ពួកគ្រប់គ្រង

ទាំងប៉ុន្មានក៏ប្រឹក្សាគ្នាទាស់នឹងព្រះអម្ចាស់ ហើយទាស់នឹងព្រះគ្រីស្ទនៃទ្រង់។ ប្រាកដមែនហើយដ្បិតនៅក្រុងនេះ ស្តេចហេរ៉ូឌនឹងលោកប៉ុនទាសពីឡាត់បានប្រជុំគ្នា ព្រមទាំងពួកសាសន៍ដទៃ និងសាសន៍អ៊ីស្រាអែល ទាស់នឹងព្រះយេស៊ូវ ជាអ្នកបំរើបរិសុទ្ធរបស់ទ្រង់ ដែលទ្រង់បានចាក់ប្រេងតាំងឲ្យ។ ដើម្បីធ្វើអស់ទាំងការដែលព្រះហស្តទ្រង់ និងព្រះដំរិះទ្រង់ បានគិតសំរេចជាមុន។ ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមទតមើលសេចក្តីកំហែងរបស់គេ ហើយសូមប្រទានឲ្យពួកអ្នកបំរើទ្រង់បានផ្សាយព្រះបន្ទូលដោយសេចក្តីក្លាហានដ៏ពោរពេញ។")

- នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកលើក្រុមជំនុំ ទ្វារដំណឹងល្អត្រូវបានបើកទៅកាន់ពួកសាសន៍ដទៃ ដោយចាប់ផ្តើមពីក្រុមគ្រួសាររបស់លោកកូនីលាស។ (10:45 "ឯពួកអ្នកជឿក្នុងពួកកាត់ស្បែកទាំងប៉ុន្មាន ដែលមកជាមួយនឹងពេត្រុស គេក៏មានសេចក្តីអស្ចារ្យជាខ្លាំងពីដំណើរដែល អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ បានចាក់មកលើសាសន៍ដទៃដូច្នេះដែរ។")
- ហើយព្រះវិញ្ញាណបានផ្តល់ទិសដៅនៃការបញ្ជូនបេសកជននៅក្រុមជំនុំអាន់ទីយ៉ុក (13:2 "កំពុងដែលអ្នកនោះធ្វើការងារ ថ្វាយព្រះអម្ចាស់ទាំងតម នោះព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលប្រាប់ថា ចូរញែកបាណាបាសនឹងសុលចេញឲ្យខ្ញុំ សំរាប់ការងារដែលខ្ញុំហៅគេឲ្យធ្វើ។")
- ហើយទ្វារនៃដំណឹងល្អក៏បានបើកទៅកាន់អឺរ៉ុប។ ក្រុមជំនុំបានទទួលការបញ្ជានៃព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ។ (16:6-7 "កាលបានដើរកាត់ស្រុកព្រីគា និងដែនខេត្តកាឡាទី នោះព្រះវិញ្ញាណបរិសុទ្ធទ្រង់ឃាត់មិនឲ្យផ្សាយព្រះបន្ទូលនៅស្រុកអាស៊ីទេ។ បានជានាំគ្នាចុះទៅឯស្រុកមីស៊ាវិញ ហើយខំចូលទៅក្នុងស្រុកប៊ីធូនា ប៉ុន្តែព្រះវិញ្ញាណមិនអនុញ្ញាតឲ្យចូលទេ។")
- កាលដែលគ្រប់ទាំងបញ្ហាត្រូវបានដកចេញដោយចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ ដោយសារនយោបាយ នោះដោយសាសនានិងវិញ្ញាណបានចូលទៅក្នុងដីផង។ នៅចំពោះពួកជំនុំគ្រប់ទាំងថ្មជំពប់នឹងត្រូវប្តូរជាដីរាបស្មើវិញ។

ព្រះអម្ចាស់បានបង្ហាញសេចក្តីប្រោសលោះរបស់ទ្រង់តាមរយៈសកម្មភាពនៃភ្នែកទាំងប្រាំពីរ (10, 3:9)។ វិញ្ញាណដែលត្រូវបានបញ្ជូនទៅកាន់គ្រប់ទីកន្លែងនឹងក្លាយជាដីដែលរាបស្មើ។ កិច្ចការរបស់ទេវតាដែលគ្រប់គ្រងគ្រប់កន្លែងទាំងអស់ ជាកិច្ចការដែលដកនូវស្មែងចេញ ជាកិច្ចការនៃការការពាររបស់ព្រះអម្ចាស់និងកិច្ចការដោះបាបទាំងអស់ (3:9) ត្រូវបានសំរេចដោយការទំនាក់ទំនងនៃព្រះវិញ្ញាណបរិសុទ្ធ។ វាជាសេចក្តីសន្យានៃគ្រាចុងក្រោយ។ (អេសាយ 40:4.42:16 ម៉ាថាយ 17:20, 21:21-22 ម៉ាកុស 11:22-23 លូកា 17:6 ១កូរិនថូស 13:2)។ពីព្រោះគ្រប់ទាំងភ្នំនៃអំពើបាបរបស់យើងត្រូវបានបំផ្លាញនៅចំពោះយើង គ្រប់ទាំងបញ្ហាត្រូវបានអន្តរាយរួចហើយ។ នៅពេលដែលអ្នកជួបភ្នំនៃបញ្ហាមួយចំនួន ចូរបង្គាប់វានៅក្នុងព្រះនាមព្រះយេស៊ូវ។ នោះវានឹងត្រូវបានដោះស្រាយនៅចំពោះអ្នកយ៉ាងអស្ចារ្យ។

## II. ព្រះសំរេចបំពេញព្រះហឫទ័យទ្រង់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ

វិញ្ញាណត្រូវការអ្នកដឹកនាំខាងវិញ្ញាណដើម្បីនឹងការលូតលាស់នៃក្រុមជំនុំ។ ពួកគេជាមនុស្សដែលឈររឹងមាំបំរើព្រះអម្ចាស់។ (14 ដូច្នេះទ្រង់មានបន្ទូលថា "មនុស្សពីរនាក់នេះដែលទទួលការចាក់ប្រេងតាំងដើម្បីនឹងបំរើព្រះអម្ចាស់នៃផែនដីទាំងមូល។") សេរូបាបិលនិងយ៉ូស្វេ ដែលជាអ្នកដឹកនាំខាងវិញ្ញាណ ជាប្រព័ន្ធបង្ហូរនៃព្រះវិញ្ញាណបរិសុទ្ធ។ បើទោះជាមានប្រមានពាន់អគ្គីសនីឆ្វាចរត់ក៏ដោយ ប្រសិនបើគ្មានប្រព័ន្ធដឹកនាំអគ្គិសនីទេ នោះវាមិនមានប្រយោជន៍ឡើយ។

តើអត្ថបទសន្យាអ្វីតាមរយៈព្រះវិញ្ញាណបរិសុទ្ធ? ទ្រង់ធ្វើឲ្យភ្នំធំទៅជាដីដែលរាបស្មើ។ (គោលបំណង-ការសំរេចបំពេញ) ហើយបានចាប់ផ្តើមវិហារ (ប្រេងមានដែលជម្រុញ-ព្រះវិញ្ញាណបរិសុទ្ធ) ហើយបានសំរេចនូវវិហារ (វិធីសាស្រ្ត-សេចក្តីស្មោះត្រង់)។ ដោយអ្នកដឹកនាំខាងវិញ្ញាណរបស់គេ កិច្ចការរបស់ព្រះនៅក្នុងព័ន្ធកិច្ចរបស់យើង នឹងត្រូវបានសំរេច។ ដូច្នេះយើងត្រូវតែអធិស្ឋាន ឲ្យអ្នកដឹកនាំខាងវិញ្ញាណរបស់យើងពេញដោយព្រះវិញ្ញាណបរិសុទ្ធ។

III. ព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងព័ន្ធកិច្ចតាមរយៈការស្ដាប់បង្គាប់នៃការអធិស្ឋាន

1) ទៅកាន់កិច្ចការរបស់សេរូបាបិល ហ្វូងមនុស្សបានឆ្លើយតបការស្តាប់បង្គាប់ ការឯកភាព និងការសហការ។ ព្រះអម្ចាស់បានប្រកាសថា សេរូបាបិលនូវព្រះគុណ ព្រះគុណ។ វាមានន័យថា ពួកគេអធិស្ឋានទៅកាន់ព្រះអម្ចាស់។ ព្រះអម្ចាស់បានធ្វើការតាមរយៈមនុស្សតែម្នាក់គត់។ ព្រះអម្ចាស់បានទាមទារការឆ្លើយតបនៃគ្រប់រូបកាយទាំងអស់។ ខ 7 មានបន្ទូលថា "ឱភ្នំធំអើយ តើឯងជាអ្វី ឯងនឹងត្រូវត្រឡប់ជាដីរាបស្មើវិញ នៅចំពោះសូរ៉ូបាបិល ហើយលោកនឹងនាំយកថ្ម ជាកំពូលចេញមក ដោយមានសំរែកស្រែកហ៊ោថា សូមឲ្យបានប្រកបដោយព្រះគុណ អើដោយព្រះគុណចុះ។" ហើយនៅខ 10 មានបន្ទូលថា "ដ្បិតតើអ្នកណាបានមើលងាយក្នុងថ្ងៃនៃការបន្តិចបន្តួចនោះ ពីព្រោះទាំង៧នាក់នោះនឹងរីករាយឡើង ហើយនឹងមានកូនតឹង នៅក្នុងដៃរបស់សូរ៉ូបាបិលផង ទាំងអស់នេះជាព្រះនេត្រនៃព្រះយេហូវ៉ា ដែលទតចុះឡើងនៅពេញលើផែនដីទាំងមូល។" ការស្តាប់បង្គាប់របស់ពួកបរិសុទ្ធជាផ្លូវកាត់នៃកិច្ចការដ៏អស្ចារ្យ។ ដូច្នេះការស្តាប់បង្គាប់ប្រសើរជាងដង្វាយ។ ជាពិសេសការអធិស្ឋានរបស់ពួកបរិសុទ្ធជាឧបករណ៍ ដែលសំរេចបំពេញកិច្ចការរបស់ព្រះ។ មិនមានការអធិស្ឋានមិនមានកិច្ចការអ្វីឡើយ។ .

2) ថ្ងៃនេះយើងនឹងត្រួតពិនិត្យការស្តាប់បង្គាប់របស់យើងនៅក្នុងការអធិស្ឋានទៅកាន់ព្រះម្តងទៀត។ បន្ទាប់មកបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់នឹងត្រូវបានសំរេចនៅក្នុងជីវិតរបស់យើង។

**សរុបសេចក្តី៖**

តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ក្រុមជំនុំនឹងត្រូវបានផ្លាស់ប្រែជាថ្មី។ ចូរយើងប្រថ្នានូវសេចក្តីពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដែលកិច្ចការបើកសំដែងមកកាន់យើងគ្រប់ពេលដើម្បីឲ្យមានលំហូរនៅក្នុងចិត្តរបស់យើង។ ចូរយើងជឿការនោះ ហើយខិតចូលទៅកាន់ការនោះ ដើម្បីនឹងផ្លាស់ប្តូរទៅកាន់ដីដែលរាបស្មើនៅមុខអ្នក។ ពីព្រោះគ្រប់ភ្នំទាំងអស់នឹងក្លាយទៅជាដីដែលរាបស្មើនៅចំពោះក្រុមជំនុំ។

## 6. ប្រាជ្ញារបស់ព្រះនៅក្នុងការកាត់ទោស (សាការី 5:1-11)

### សេចក្តីផ្តើម៖

1) អត្ថបទបង្ហាញពីប្រាជ្ញានៃការកាត់ទោសរបស់ព្រះតាមរយៈការពីរយ៉ាង និមិត្តនាំគម្ពីរដែលកំពុងឆា និងនិមិត្តនៃស្រ្តីនៅក្នុងអេផាមួយនៅក្នុងនិមិត្តមួយ។ ពីព្រោះនិមិត្តរូបពីរពន្យល់ពីការកាត់ទោសដល់ពួកអ៊ីស្រាអែល ដែលត្រូវបានពុករលួយដោយអំពើបាបដ៏ធ្ងន់របស់គេ (ការថ្វាយបង្គំព្រះក្លែងក្លាយ និងសាហាយស្មន់)។
2) តើអ្វីទៅជាប្រាជ្ញានៃការកាត់ទោសដែលព្រះអម្ចាស់ប្រើ?

### I. ព្រះអម្ចាស់គ្រប់គ្រងអំពើបាប

1) តើស្រ្តីនៅក្នុងអេផាមានន័យយ៉ាងណា? វាមានន័យថាជាអំពើបាបរបស់លោកិយ។ ខ 6 មានបន្ទូលថា "តើវាជាអ្វី?" គាត់ឆ្លើយទៅថា "វាជាកន្ត្រក" ហើយគាត់បាបបន្ថែមថា "នេះជាសេចក្តីទុចរិតរបស់ប្រជារាស្រ្តនៅពាសពេញទឹកដីទាំងអស់។"

ខ 7-8 "រួចឃើញមានគេលើកសំណទំងន់មួយហាបឡើង ហើយឃើញមានស្ត្រីម្នាក់អង្គុយក្នុងរង្វាល់នោះ។ ទេវតាប្រាប់ថា នេះគឺជាអំពើអាក្រក់ រួចក៏សង្កត់នាងចុះទៅក្នុងរង្វាល់ ព្រមទាំងដាក់ដុំសំណនោះ គ្របនៅមាត់រង្វាល់ផង។"

គំរបនៃរង្វាល់មានន័យថា ការគ្រប់គ្រងនូវសតិបញ្ញារបស់រាស្រ្តយូដា។ នេះជាប្រាជ្ញាដែលព្រះហាមនូវអំពើបាបដ៏អាក្រក់នៅក្នុងលោកិយពេលនេះ។
ទឹកជំនន់របស់ណូអេបានគ្រប់គ្រងនូវសេចក្តីពុករលួយដ៏អាក្រក់របស់អំពើបាបលោកិយ។ (លោកុប្បត្តិ 6 :)
1) អំពើបាបពេលបច្ចុប្បន្នដែលបានរាលដាលយ៉ាងរហ័សទៅកាន់លោកិយ នឹងត្រូវបានគ្រប់គ្រងដោយព្រះហស្តរបស់ព្រះអម្ចាស់ ដូចជាសូរសំលឹងរបស់មាន់រងាយ (ពេត្រុស)

ការនិយាយរបស់សត្វលា (បាឡាម) តាមរយៈការទុក្ខលំបាបមួយចំនួន។ យើងគួរតែស្តាប់ទៅកាន់សូរសៀងនៃសតិបញ្ញាដែលល្អ។

## II. ព្រះបែងចែករវាងសេចក្តីល្អនិងសេចក្តីអាក្រក់

1) ខ 9 មានបន្ទូលថា "នោះខ្ញុំបានងើបភ្នែកឡើងទៅ ហើយឃើញមានស្ត្រី២នាក់ចេញមក មានស្លាបដូចជាកុក ដែលជក់ដោយខ្យល់ គេក៏លើករង្វាល់នោះឡើង នៅកណ្តាលផែនដីនឹងផ្ទៃមេឃ។" ព្រះអម្ចាស់គ្រប់គ្រងអំពើបាបហើយក៏បែងចែកនូវសេចក្តីល្អនិងសេចក្តីអាក្រក់។

ខ 10-11 មានបន្ទូលថា "រួចខ្ញុំសួរទៅទេវតាដែលពោលនឹងខ្ញុំថា ស្ត្រីទាំងពីរនេះនាំយករង្វាល់ទៅឯណា។ ទេវតាក៏តបថា គេយកទៅធ្វើផ្ទះឲ្យនាងនៅក្នុងស្រុកស៊ីណើរ កាលណាផ្ទះបានស្រេចហើយ នោះនាងនឹងបានតាំងនៅទីនោះ ក្នុងកន្លែងរបស់ខ្លួន។"

2) នៅក្នុងលោកិយយើងបែងចែកការពីរយ៉ាងដោយច្បាស់លាស់នៅក្នុងចិត្តរបស់យើង។ នេះជាប្រាជ្ញានៃព្រះវិញ្ញាណបរិសុទ្ធ។

## III. ព្រះអម្ចាស់បានប្រទានសេរីភាពដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ

1. ព្រះអម្ចាស់គ្រប់គ្រងបំណងខាងអំពើបាបដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ខ 9 មានបន្ទូលថា "នោះខ្ញុំបានងើបភ្នែកឡើងទៅ ហើយឃើញមានស្ត្រី២នាក់ចេញមក មានស្លាបដូចជាកុក ដែលជក់ដោយខ្យល់ គេក៏លើករង្វាល់នោះឡើង នៅកណ្តាលផែនដីនឹងផ្ទៃមេឃ។" ស្លាបដូចជារទេះរបស់ចេរូប៊ីននៅក្នុងអេសេគាល 1:23-25។

2. សេរីភាពនៃព្រះវិញ្ញាណបរិសុទ្ធធ្វើឲ្យយើងដកសេរីភាពចេញពីអំពើបាប ការស្តុប់ស្តល់ចេញពីសេចក្តីត្រូវការនិងព្រះគុណចេញពីបន្លានៅក្នុងជីវិតជាគ្រីស្ទានរបស់យើង។

## សរុបសេចក្តីៈ

នៅក្នុងព័ន្ធកិច្ចនិងបេសកកម្មគ្រូគង្វាលរបស់យើង យើងត្រូវរៀនពីប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ។ គ្រូគង្វាលច្បងនិងចាស់ទុំ គួរតែប្រើប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងលោកិយនេះ។ ដោយសារផ្នែកបេសកកម្មរបស់យើង ពោរពេញដោយឧបករណ៍ខាងលោកិយច្រើន ដែលទាស់ទទឹងនឹងប្រាជ្ញាមកពីស្ថានសួគ៌។ យើងគួរតែស្វែងរកប្រាជ្ញាដែលនៅខាងលើដូចជាយ៉ាកុបបានបញ្ជាក់ (យ៉ាកុប 3:13-18)។

## 7. និម្មិតរទេះបួន (សាការី 6:1-15)

### សេចក្តីណែនាំៈ

និម្មិតនៃរទេះទាំងបួនជានិម្មិតចុងក្រោយនៅក្នុងសាការី ជាពិសេសត្រូវបានបញ្ចប់ពីខ 1-8។ ចាប់ពីខ 9 ពិធីអភិសេកបានបង្ហាញឲ្យឃើញ។ បើទោះជាការអភិសេកគ្រាន់តែជាសញ្ញាសំគាល់ តែវាសំខាន់ខ្លាំងណាស់ ដោយបានចង្អុលទៅកាន់ការគ្រប់គ្រងរបស់ព្រះមេស្ស៊ីជាស្តេច។ (9-14) "មនុស្សដែលត្រូវបានហៅថាជាមែក" មកដើម្បីសាងសង់ជាថ្មីនូវព្រះវិហារ ហើយសោយរាជ្យលើដោយសន្តិភាព។ ទីនេះយើងស្តាប់ ដែលសារដែលជាចំនុចកណ្តាលរបស់សាការីគឺ ជាការកើតជាថ្មីដែលពួកគេគួរតែដេញតាម តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ដូចជានៅក្នុងព្រះបន្ទូល រ៉ូម 8:28 សេចក្តីសប្បុរសដែលព្រះអម្ចាស់នឹងសម្រេចបំពេញនៅក្នុងយើង គឺចង្អុលទៅកាន់ការកើតជាថ្មីខាងវិញ្ញាណ ដោយការនិយាយការពីរយ៉ាងនៅក្នុងអត្ថបទ។ តើការទាំងនោះជាអ្វីទៅ?

### I វាមានន័យថាជាព័ន្ធកិច្ចដែលស្កប់ស្កល់

សកម្មភាពរបស់រទេះទាំងបួននៅក្នុងអត្ថបទមានទាក់ទងនឹងការនិម្មិតទីមួយ។ សកម្មភាពនៃសេះក្រហម សេះស សេះខ្មៅ និងសេះចម្រុះពរ បង្ហាញពីគ្រប់ជាតិសាសន៍ដែលបានបំផ្លាញពួកសាសន៍អ៊ីស្រាអែល ដូចជាសាសន៍ស៊ីរី បាប៊ីឡូន និងអេស៊ីប។ តាមរយៈប្រវត្តិសាស្ត្រ

សាសន៍ទាំងនេះត្រូវបានវិនាសជាពិតប្រាកដ។ វាជាការសំរេចបំពេញនៃខ 8 "មើល សេះដែលចេញទៅឯស្រុកនៅទិសខាងជើង បានរំងាប់ចិត្តអញចំពោះស្រុកខាងជើងនោះហើយ។" នេះជាសេចក្តីចំរុងចម្រើនរបស់ព្រះមេស៊ី និងវាក៏ចង្អុលប្រាប់ថា នៅចំពោះសេរ៉ូបាបិល ភ្នំដ៏សម្បើមនឹងត្រូវប្រែជាដីរាបស្មើ។

ទីនេះ យើងអាចរៀនការអស្ចារ្យពីរនៃព្រះអម្ចាស់

1) ទីមួយ ប្រាជ្ញារបស់ព្រះអម្ចាស់ទាំងស្រុងដូចដែលបានបង្ហាញនៅក្នុងរូបភាព "រទេះចេញមកពីភ្នំលង្ហិន"។ កិច្ចការរបស់ទ្រង់ និងប្រាជ្ញារបស់ទ្រង់ ដូចដែលរទេះចេញមកពីភ្នំដ៏ខ្លាំងខ្លា នឹងត្រូវបានសំរេចបំពេញដោយម្ចាស់រទេះនោះ។

2) ទីពីរ ហើយយើងក៏សង្កេតឃើញកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលខ្យល់ទាំងបួននៃស្ថានសួគ៌ចង្អុលបង្ហាញ។ ទ្រង់ធ្វើការសំរាប់សេចក្តីសង្គ្រោះ ក៏ដូចជាសំរាប់ការកាត់ទោស។ ទ្រង់ធ្វើការដូចជាខ្យល់ ហើយកិច្ចការរបស់ទ្រង់នឹងសំរេចទាំងស្រុងនិងស្កប់ស្កល់។ ព្រឹត្តិការណ៍នៃឈើឆ្កាងផ្តល់ដល់យើងនូវសេចក្តីសង្គ្រោះដ៏ស្កប់ស្កល់ពិត តាមរយៈកិច្ចការដ៏ពេញដោយប្រាជ្ញារបស់ព្រះវិញ្ញាណបរិសុទ្ធ។ ជាពិសេសយើងអាចមានអារម្មណ៍ថា សេចក្តីសង្គ្រោះរបស់យើងល្អគ្រប់គ្រាន់នៅក្នុងចិត្តរបស់យើង។ យើងរីករាយនឹងការស្កប់ស្កល់ពិត ដែលចេញមកពីឈើឆ្កាង សេចក្តីរស់ឡើងវិញ និងព្រះវិញ្ញាណ។

អាថ៌កំបាំងដែលដាវីតយកឈ្នះលើគ្រប់ខ្មាំងសត្រូវរបស់គាត់ គឺដោយសេចក្តីសប្បុរសរបស់ព្រះអម្ចាស់ ដែលជាឧទាហរណ៍សំរាប់ជីវិតរបស់គ្រីស្ទាន។ បើទោះជាគាត់ត្រូវបានបៀតបៀនដោយសូលយ៉ាងខ្លាំង ហើយគាត់បានព្យាយាមសំលាប់ដាវីតជាច្រើនដង តែដាវីតមិនបានប្រើវិធីសាស្រ្តដែលខុសឆ្គងនោះឡើយ។ ជាចុងក្រោយ គាត់បានក្លាយជាបណ្តាញមួយដែលមានប្រយោជន៍សំរាប់ព្រះនៅក្នុងជីវិតរបស់គាត់។

1) តើអ្នកជឿថាព្រះធ្វើការអស្ចារ្យនៅក្នុងយើងឬទេ? យើងត្រូវតែធ្វើគ្រប់ការទាំងអស់

ទៅតាមកិច្ចការដែលគ្រប់គ្រាន់របស់ព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងសប្តាហ៍នេះ យើងគួរតែដេញតាមព័ន្ធកិច្ចដែលស្កប់ស្កល់ពិតប្រាកដ ចិត្តដែលស្កប់ស្កល់នៅក្នុងជីវិតនៅក្នុងសាលារបស់យើង។ ដូច្នេះយើងត្រូវស្វែងរកកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើង។ សូមបញ្ឈប់ការទុកចិត្តលើចំនុចល្អរបស់មនុស្ស ប៉ុន្តែចូរដេញតាមដើម្បីទុកចិត្តដល់ព្រះវិញ្ញាណនៅក្នុងព្រះបន្ទូលរបស់ព្រះវិញ។

## II. វាមានន័យថាការសំរេចនូវសេចក្តីសុខសាន្ត

1) នៅក្នុងខ 5, ទស្សនិយភាពនៃការធ្វើការឡើងគ្រងរាជ្យត្រូវបានបង្ហាញ។ "នោះទេវតាតបមកខ្ញុំថា នេះគឺជាខ្យល់ទាំងបួនទិសនៅលើអាកាស ដែលចេញពីចំពោះព្រះអម្ចាស់នៃផែនដីទាំងមូល។" ដោយសារការនេះ សេចក្តីជំនឿរបស់អ្នកដែលវិលត្រលប់ ហោលដាថូបៀ យ៉ូយ៉ាដា និងយ៉ូសៀ ត្រូវបានស្តារឡើងវិញដោយព្រះគុណរបស់ព្រះ។ ជាពិសេសព្រះមេស៊ី ជាមែកថ្មីដែលចេញមកក្នុងលោកិយ ហើយសង់ឡើងវិញនូវព្រះវិហារ ហើយសំរេចកិច្ចការនៃសេចក្តីសុខសាន្ត។ (12 ហើយប្រាប់លោកថា ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះ មើលមនុស្សដែលឈ្មោះថា "លំពង់" នឹងពន្លកដុះឡើងពីកន្លែងរបស់ខ្លួន ហើយនឹងសង់ព្រះវិហាររបស់ព្រះយេហូវ៉ាឡើង។) ទ្រង់ជាមហាសង្ឃនិងជាស្តេច ដែលទ្រង់សំរេចកិច្ចការខាងសេចក្តីសុខសាន្ត។ ពិតណាស់ទ្រង់សំរេចបំពេញគ្រប់កិច្ចការទាំងអស់។ នេះជាសេចក្តីសុចរិត សេចក្តីសុខសាន្ត និងសេចក្តីអំណរនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។ វាជាការសំរេចបំពេញនៃ 3:10, "ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា នៅថ្ងៃនោះឯងរាល់គ្នានឹងអញ្ជើញអ្នកជិតខាងរបស់ឯងមក នៅក្រោមដើមទំពាំងបាយជូរ ហើយក្រោមដើមល្វារៀងខ្លួន។"

2) ថ្ងៃនេះពិភពលោករបស់យើងត្រូវការសេចក្តីសុខសាន្តពីស្ថានសួគ៌។ គ្រប់សេចក្តីសុខសាន្តទាំងអស់របស់បុគ្គល ក្រុមគ្រួសារ និងប្រទេសជាតិ ចេញមកពីជីវិតដែលមានព្រះគ្រីស្ទជាកណ្តាល។ ហេតុអ្វី? ពីព្រោះសេចក្តីសុខសាន្តពិតប្រាកដចេញមកពីមែក ជាព្រះយេស៊ូវគ្រីស្ទ។ ដូច្នេះយើងត្រូវតែនៅជាប់នឹងព្រះយេស៊ូវគ្រីស្ទ។ មានន័យថាត្រូវទទួល

ស្គាល់ភាពជាព្រះអម្ចាស់របស់ទ្រង់គ្រប់ពេលគ្រប់ទីកន្លែង។ដូច្នេះយើងត្រូវទំលាប់អធិស្ឋាន និងសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ។

ដូចជាយើងបានដឹងហើយថា ភាពអស្ចារ្យរបស់ដាវីតចេញមកពីការនៅជាប់នឹងភាពជាព្រះអម្ចាស់របស់ព្រះយេហូវ៉ា។ ដូច្នេះគាត់មិនបានចង់សំលាប់ស្តេច សូលបានធ្វើទាស់នឹងភាពជាព្រះអម្ចាស់។ នៅពេលដែលមិត្តរបស់គាត់បានជម្រុញនូវភាពជាព្រះអម្ចាស់របស់គាត់ គាត់មិនចូលចិត្តធ្វើជាម្ចាស់នៅពេលដែលមានឱកាសល្អនោះទេ។ ហេតុអ្វី? ពីព្រោះគាត់ដឹងថាព្រះអម្ចាស់ពិតនៅក្នុងស្ថានភាពរបស់គាត់ នោះគាត់អាចបំរើព្រះអម្ចាស់នៅក្នុងចិត្តរបស់គាត់។ នេះជារបៀបនៃសេចក្តីសុខសាន្តពិតដែលចេញមកពីព្រះដ៏មានព្រះជន្មរស់។

យើងត្រូវតែពិនិត្យលើចិត្តដែលស្កប់ស្កល់និងសន្តិភាពនៅក្នុងព័ន្ធកិច្ចរបស់យើង។តើអ្នកមានចិត្តដូចនេះនៅក្នុងជីវិតនៅក្នុងសាលារបស់អ្នកទេ? ពីម្សិលមិញ ខ្ញុំបានជួបមនុស្សពីរនាក់នៅក្នុងភូមិ។ ពួកគេមិនមានចិត្តដែលស្កប់ស្កល់និងសុខសាន្តនៅក្នុងជីវិតរបស់គេទេ។ មនុស្សម្នាក់មានជីវិតអាពាហ៍ពិពាហ៍ដែលមិនធម្មតានៅក្នុងជីវិតរបស់គាត់។ គាត់មានប្រពន្ធប្រាំដូចស្ត្រីសាសន៍សាម៉ារីនៅក្នុងយ៉ូហាន 4: វាជាជីវិតមួយដែលពេញដោយទុក្ខសោក។ ហើយខ្ញុំក៏បានជួបនឹងសង្ឃមួយអង្គនៅវត្ត ដែលចង់នឹងផ្តល់ដល់គាត់នូវសេចក្តីសុខសាន្តពិតប្រាកដរបស់ព្រះគ្រីស្ទ។ បើទោះជាទឹកមុខរបស់គាត់ហាក់ដូចជាមានសេចក្តីសុខសាន្តណាស់ តែខ្ញុំអាចមើលឃើញចិត្តដ៏សែនលំបាករបស់គាត់ចេញពីអកប្បកិរិយារបស់គាត់។ ខ្ញុំអធិស្ឋានឲ្យគាត់បានវិលត្រឡប់មកកាន់ព្រះគ្រីស្ទ ជាមេកដ៏ពិតរបស់យើង ដោយការលន់តួបាបនិងសេចក្តីជំនឿ ហើយទទួលបានចិត្តដែលស្កប់ស្កល់និងសេចក្តីសុខសាន្តនៃស្ថានសួគ៌។

## សរុបសេចក្តី:

រហូតមកដល់ពេលនេះ យើងបានគិតពីសេចក្តីប្រោសលោះដ៏អស្ចារ្យនៅក្នុងការនិម្មិតប្រាំពីរនៅក្នុងសាការី។ យើងនៅជាប់នឹងព្រះពរ សេចក្តីប្រោសលោះដែលបរិបូរនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង និងព័ន្ធកិច្ចគ្រូគង្វាល។ លើសពីនោះទៀត យើងចង់ប្រកាសការជាក់ស្តែងទៅកាន់លោកិយ។ ដូច្នេះដូចជាសាការីបានបង្ហាញនៅក្នុងចំណុចចុងក្រោយរបស់

គាត់ យើងត្រូវតែស្តាប់ទៅកាន់ការបង្គាប់ដែលបន្ទាន់ "ចូរត្រឡប់មកកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់វិញ" ហើយក៏ឃើញសិរីល្អនៃការប្រោសលោះដ៏ពេញលេញ។

### 1. ចូរត្រឡប់មកកាន់ព្រះបន្ទូលរបស់ព្រះវិញ! (សាការី 7:1-8)

នៅពេលដែលយើងដេញតាមការដែលថ្មីជារឿយៗ ព្រះអម្ចាស់របស់យើងមានបន្ទូលថា យើងត្រូវតែត្រឡប់ទៅកាន់ព្រះបន្ទូលជាមុនសិន។ ពីសំណួរដែលពួកនៅបេតអែលបានសួរទៅកាន់ព្រះអម្ចាស់ "តើខ្ញុំគួរតែទួញសោកនិងតមនៅខែទីប្រាំ ដូចដែលខ្ញុំធ្លាប់បានធ្វើជាច្រើនឆ្នាំហើយនោះឬទេ?" (4) ព្រះអម្ចាស់បានតបថា ឯងត្រូវត្រឡប់ទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់។ "ចូរប្រាប់បណ្តាជននៅក្នុងស្រុកនិងពួកសង្ឃថា កាលឯងរាល់គ្នាបានតមអត់ ហើយយំសោកនៅខែស្រាពណ៍ និងខែអស្សុជ ទាំង៧០ឆ្នាំមកហើយនោះ នោះបានតមអត់ដោយការគោរពដល់អញ ឬគឺដល់អញមែនឬអី? ហើយកាលណាឯងរាល់គ្នាស៊ី ឬកាលណាផឹក នោះតើមិនមែនស៊ីនិងផឹក ជាប្រយោជន៍ដល់ខ្លួនទេឬ? តើមិនមែនជាសេចក្តីនោះទេឬ ដែលព្រះយេហូវ៉ាបានប្រកាសប្រាប់ ដោយសារពួកហោរាជាន់មុខ ក្នុងកាលដែលក្រុងយេរូសាឡិមមានមនុស្សអាស្រ័យនៅៗឡើយ ហើយមានសេចក្តីចម្រើន ព្រមទាំងក្រុងនៅជុំវិញផង ហើយស្រុកត្បូង នឹងស្រុកទំនាបក៏មានមនុស្សអាស្រ័យនៅដែរ។" (7)

### I. តើយើងគួរប្រកាសព្រះបន្ទូលរបស់ព្រះដោយរបៀបណា?

ទីនេះយើងសង្កេតឃើញពីរបៀបដែលការបើកសំដែងរបស់ព្រះអម្ចាស់មកកាន់យើង។

(1) នៅក្នុងគម្ពីរសញ្ញាចាស់ បានចេញមកដូចជាប្រភេទនៃការបើកសំដែងជារូបភាព សុបិននិម្មិត ការអស្ចារ្យ គែម និងគំរូដើម្បីនឹងពន្យល់ពួកគេ។ និម្មិត 8បើកសំដែងពីសភាពនៃការអស្ចារ្យរបស់អ៊ីស្រាអែល ដែលបង្ហាញពីការពុករលួយ ជាមូលហេតុនៃសេចក្តីពុករលួយ និងការដាក់ទោស និងសេចក្តីសង្គ្រោះ។ និមិត្តសញ្ញា ការប្រៀបធៀប និងរូបភាពបានផ្តល់នូវការបើកសំដែងដែលបរិបូរណ៍និកាន់យើង។

ឧទាហរណ៍ពីព្រឹត្តិការណ៍នៃសមុទ្រក្រហម មានន័យថាជាការជ្រមុជរបស់ក្រុមជំនុំ។ ការធ្លាក់ចុះរបស់នំម៉ាន៉ាមានន័យថាជាអាហារប្រចាំថ្ងៃរបស់គ្រីស្ទាន ដែលជាព្រះគ្រីស្ទនិងព្រះបន្ទូលរបស់ទ្រង់។ដូច្នេះគ្រីស្ទានដែលទទួលការបើកសំដែងដោយការទាំងនោះអាចប្រកាសពីបំណងព្រះហឫទ័យរបស់ព្រះ។ (កិច្ចការ 2:17) ហើយទ្រង់ក៏បានផ្តល់ការបើកសំដែងដោយសារពួកហោរា។"តើមិនមែនជាសេចក្តីនោះទេឬ ដែលព្រះយេហូវ៉ាបានប្រកាសប្រាប់ដោយសារពួកហោរាជាន់មុខ ក្នុងកាលដែលក្រុងយេរូសាឡិមមានមនុស្សអាស្រ័យនៅៗឡើយ ហើយមានសេចក្តីចម្រើន ព្រមទាំងក្រុងនៅជុំវិញផង ហើយស្រុកត្បូង នឹងស្រុកទំនាបក៏មានមនុស្សអាស្រ័យនៅដែរ។" (7) ពួកគេបានធ្វើចិត្តរបស់គេឲ្យទៅជារឹងដូចថ្ម ហើយមិនព្រមស្តាប់ក្រិត្យវិន័យឬព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលព្រះអម្ចាស់បានផ្តល់មកដោយោព្រះវិញ្ញាណរបស់ទ្រង់តាមរយៈហោរាពីដើមមក។ (12)

(2) វាត្រូវបានបង្ហាញដោយពួកហោរា (7,12) ដូច្នេះដាវីតត្រូវបានគ្រប់គ្រងដោយហ្កាតនិងណាថាន់និងប៉ុលតាមរបៀបព្រះគម្ពីរសញ្ញាថ្មី អាណានាសនិងក្រុមជំនុំទាំងប្រាំពីរនៅក្នុងអាស៊ីមីណាដោយទេវតា (គ្រូគង្វាល)នៃក្រុមជំនុំ។ ក្រុមជំនុំត្រូវបានសង់ឡើងនៅលើហោរានិងពួកសាវ័កនៅលើថ្មជ្រុងដែលជាព្រះយេស៊ូវគ្រីស្ទ។ (អេភេសូ 2:20) ដូច្នេះពួកគេសារភាពទទួលស្គាល់អំណាចចេស្តារបស់ម៉ូសេថាជាអំណាចរបស់ព្រះអម្ចាស់។ នៅក្នុងអត្ថន័យនេះ គ្រូគង្វាល់បច្ចុប្បន្នមានអំណាចដូចគ្នានៅពេលដែលពួកគាត់ឈរនៅលើការបើកសំដែង ដូចជាអ្នកប្រកាសនូវការបើកសំដែង។

3) វាត្រូវបានប្រកាសដោយព្រះវិញ្ញាណបរិសុទ្ធ។ "ពួកគេបានធ្វើឲ្យចិត្តរបស់ពួកគេទៅជារឹងដូចថ្ម ហើយមិនព្រមស្តាប់ក្រឹត្យវិន័យឬព្រះបន្ទូលរបស់ព្រះ ដែលព្រះដែលមានគ្រប់ព្រះចេស្តាបានផ្តល់មកដោយព្រះវិញ្ញាណរបស់ទ្រង់ តាមរយៈពួកហោរាពីដើម។ ក្រិត្យវិន័យរបស់ម៉ូសេជា ព្រះសូរសៀងរបស់ព្រះវិញ្ញាណបរិសុទ្ធនិងគម្ពីរជាសូរសៀងនៃព្រះវិញ្ញាណបរិសុទ្ធ។ បច្ចុប្បន្នព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលតាមរយៈព្រះគម្ពីរនិងនៅក្នុងព្រះគម្ពីរ។ នៅក្នុងអត្ថន័យរបស់ព្រះគម្ពីរជា ព្រះនិងអកប្បកិរិយាដោយផ្ទាល់។ ពិតណាស់នៅពេលដែលយើងទទួលសេចក្តីពោរពេញនៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចរៀនថា វាជាដាវនៃវិញ្ញាណ។

មានតែមួយនេះទេដែលជាការបើកសំដែងពិតហើយផ្តល់ដល់ជីវិតយើងនូវសេចក្តីពេញបរិបូរណ៍។"

## II. តើយើងត្រឡប់ទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់ដោយរបៀបណា?

ហើយម្តងទៀតព្រះអម្ចាស់បង្រៀនពីរបៀបដែលយើងត្រូវប្រព្រឹត្តទៅកាន់ព្រះបន្ទូលរបស់ទ្រង់នៅក្នុងផ្នែកខាងប្រវត្តិសាស្រ្ត។ និយាយមួយម៉ាត់ថាជាការស្តាប់បង្គាប់ទាំងស្រុង។ ហេតុអ្វីបានជាការស្តាប់បង្គាប់មានសារៈសំខាន់ខ្លាំង? យោងទៅតាមខ 10-14 ដោយការមិនស្តាប់បង្គាប់ ផែនដីដ៏ស្រស់ស្អាតត្រូវបានប្តូរទៅជាវាលរហោស្ថាន។ "ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលថា ដូច្នេះ ទ្រង់បានស្រែកទៅ តែគេមិនព្រមស្តាប់យ៉ាងណា គេក៏នឹងស្រែកដែរ តែអញមិនព្រមស្តាប់ដូចគ្នា។ គឺអញនឹងបំបាត់កំចាយគេ ដោយខ្យល់កួច អោយទៅកណ្តាលអស់ទាំងសាសន៍ ដែលគេមិនបានស្គាល់ឡើយ ដូច្នេះស្រុកក៏បានស្ងាត់ច្រៀប នៅខាងក្រោយគេ ដល់ម៉្លេះបានជាឥតមានអ្នកណាដើរកាត់ ឬវិលត្រឡប់មកវិញទៀតទេ ដ្បិតគេធ្វើឲ្យស្រុកដ៏លំអរទៅជាទីខូចបង់។" (14) តើអ្វីទៅជាមូលហេតុនៃការបរាជ័យរបស់សូល? បន្ទាប់ពីគាត់បានយកឈ្នះសង្គ្រាមជាមួយនឹងអាម៉ូលេក គាត់មិនអាចគ្រប់គ្រងសេចក្តីលោភលន់របស់គាត់បានទេ។ ដោយសារការមិនស្តាប់បង្គាប់ដ៏តូចរបស់គាត់ គាត់ត្រូវបានបំពេញដោយសភាពដែលអាក្រក់ ដែលរហូតដល់គាត់ខំស្វែងរកអ្នកព្យាបាលអារម្មណ៍។ (សាំយ៉ូអែល 28:18) ការអន្តរាយរបស់អ៊ីស្រាអែលត្រូវបាននាំមកដោយការមិនស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ។ ការកើតជាថ្មីរបស់ពួកគេនឹងត្រូវបានបង្កើតឡើងដោយការស្តាប់បង្គាប់វិញ។ ដូច្នេះប្រតិកម្មនៃការត្រឡប់មកព្រះគម្ពីរវិញ គួរតែមិនត្រូវបានដាក់កំណត់នៅត្រឹមពួកអ៊ីស្រាអែលឡើយ។ហើយយើងគួរតែត្រឡប់ទៅកាន់ព្រះគម្ពីរ ហើយព្យាយាមពិនិត្យមើលដោយកញ្ចក់នៃព្រះគម្ពីរ។

## 2. ថ្ងៃនៃព្រះយេហូវ៉ាដ៏ពេញដោយសិរីរុងរឿង (សាការី 14:1-21)

## សេចក្តីផ្តើម

ជាចុងក្រោយ បញ្ហានៃការកសាងព្រះវិហារជាថ្មីនិងបញ្ហាខាងវិញ្ញាណរបស់ពួកគេអស់រយៈពេល១៨ឆ្នាំ ត្រូវបានដោះស្រាយនៅពេលដែលព្រះអម្ចាស់ត្រឡប់មកពួកអ៊ីស្រាអែលវិញ។ ពិតណាស់សាការីបាន ឃើញសិរីល្អនៃសញ្ញាថ្មី។ អត្ថបទបានបង្ហាញពីសិរីល្អនិងការសន្យានៃថ្ងៃមួយនោះ។

### I. ព្រះអម្ចាស់បង្កើតក្រុមជំនុំដែលខ្ពង់ខ្ពស់នៅក្នុងលោកិយ

យោងទៅតាមខ 1-7 ព្រះយេហូវ៉ាផ្ទាល់ដែលបានបង្កើតពួកអ៊ីស្រាអែលទាស់នឹងសាសន៍ដទៃទៀត ទ្រង់ផ្ទាល់នឹងវាយប្រហារពួកគេជំនួសអ៊ីស្រាអែល។ នៅពេលដែលទ្រង់ឈរនៅលើភ្នំអូលីវ នោះវានឹង ត្រូវបំបែកជាពីរផ្នែក។ នៅពេលងងឹត នោះនឹងមានពន្លឺជះមក។ នៅក្នុងថ្ងៃនៃល្បាយ នោះពន្លឺនឹងរះនៅ ក្នុងលោកិយ។ ហើយនៅយេរូសាឡិម ទឹករស់នឹងក្លាយជាប្រភពទឹក។ ព្រះគុណដ៏បរិបូរណ៍នឹងមកកាន់ ក្រុមជំនុំនៅក្នុងសញ្ញាថ្មី។ ជាពិសេសព្រះអម្ចាស់ជាអ្នកមានជ័យជំនះ ដែលទ្រង់បានវាយទាស់នឹងខ្មាំង សម្រាប់ក្រុមជំនុំ។ ការបំពាក់ដោយគ្រប់ទាំងអាវុធនៅក្នុងអេភេសូជំពូក 6 មានន័យថាអាវុធដែលពេញ លេញដែលជាព្រះគ្រីស្ទ។ ពីព្រោះគ្រប់ទាំងរបស់ទាំងនេះនឹងត្រូវបានសំរេចនៅក្នុងព្រះគ្រីស្ទយេស៊ូវ យើងអាចយកឈ្នះគ្រប់ទីកន្លែងនិងគ្រប់វេលា នៅក្នុងជ័យជំនះរបស់ព្រះអម្ចាស់របស់យើង។ ដូច្នេះប៉ុ លបានស្រែកឡើងថា យើងលើសជាងអ្នកដែលមានជ័យជំនះទៅទៀត។ តើអ្នកណាដែលអាចយក ឈ្នះលើកូលីយ៉ាតនាសតវត្សទី២០នេះ? មានតែព្រះយេស៊ូវគ្រីស្ទដែលអាចយកឈ្នះគេបាន ព្រះយេហូ វ៉ាដែលជាព្រះយេស៊ូវគ្រីស្ទ។ នៅពេលដែលយើងវាយប្រឆាំងនឹងពួកគេ យើងតែងតែមានជ័យជំនះពួក គេនៅក្នុងព្រះនាមព្រះយេស៊ូវ។ យើងអាចជឿលើសេចក្តីមួយនេះរហូតទៅ។

## II. នៅថ្ងៃនោះព្រះអម្ចាស់នឹងគ្រប់គ្រងលោកិយដូចជាស្តេចលើអស់ទាំងស្តេច

យើងបានឃើញរួចហើយថា ការគ្រប់គ្រងរបស់ព្រះអម្ចាស់មានពេញដោយ សេចក្តីស្មោះត្រង់ និងសេចក្តីសុខសាន្តនៅក្នុងជំពូក 8 របស់សាការី។ នៅទីនេះយើងឃើញពីចំនុចខ្ពស់បំផុត។ ទ្រង់នឹងក្លាយជាស្តេចនៅលើសកលលោកនេះ (9-11)។ នៅពេលដែលទ្រង់សោយរាជ្យលើពួកគេ វានឹងក្លាយជាសញ្ញាតិមួយដែលគ្មានការកាត់ (11)។ គ្មាន Canute រស់នៅទីនោះ។ បណ្តាសារបស់ព្រះអម្ចាស់នឹងធ្លាក់មកលើពួកគេដែលបានវាយប្រហារពួកយូដា។ ព្រះដែលមានគ្រប់ព្រះចេស្តាគ្រប់គ្រងលើពួកគេដោយចេស្តាដែលមានព្រំកំណត់របស់ទ្រង់។ ដូច្នេះយើងអាចយកឈ្នះលើលោកិយដែលច្របូកច្របល់នេះដោយចេស្តាខាងវិញ្ញាណយ៉ាងពេញលេញ។ រួចមកយើងអាចរីករាយនឹងព្រះពរដែលព្រះអម្ចាស់ផ្តល់ទៅកាន់រាស្រ្តដែលស្តាប់បង្គាប់ដល់ទ្រង់។ ពិតណាស់ទៅកាន់ប្រជារាស្រ្ត ក្រុមគ្រួសារ និងសហាគមន៍ដែលយកព្រះគ្រីស្ទជាម្ចាស់របស់គេ។

## III. ជាការសន្យាដែលរក្សាពិធីបុណ្យនៃរោងឧបោសថ

ព្រះអម្ចាស់បានសន្យាថា ទ្រង់នឹងបង្កើតក្រុមជំនុំ ហើយទ្រង់ផ្ទាល់នឹងគ្រប់គ្រងលើពួកគេដូចជាស្តេច ហើយថ្ងៃនៅពេលដែលពួកគេរស់នៅជារាស្រ្តបរិសុទ្ធនឹងមកដល់នៅលើលោកិយ។ ខ 16-21 គ្រប់ជាតិសាសន៍ទាំងអស់នឹងមកដើម្បីនឹងធ្វើបុណ្យនៃរោងឧបោសថ។ ពួកគេនឹងរក្សាពិធីបុណ្យនៃរោងឧបោសថឲ្យបានបរិសុទ្ធនៅក្នុងព្រះគ្រីស្ទ។ ខ 20 មានបន្ទូលជាពាក្យថា ទៅកាន់ព្រះយេហូវ៉ាទ្រង់បរិសុទ្ធ នឹងត្រូវបានសរសេរនៅកណ្តឹងរបស់សេះ។ អក្សរ "ទៅកាន់ព្រះយេហូវ៉ាទ្រង់បរិសុទ្ធ" នឹងត្រូវបានសរសេរនៅលើជីវិតទាំងអស់របស់ក្រុមជំនុំ។ ប្រពៃណីនៃសេចក្តីបរិសុទ្ធនឹងត្រូវសំរេចនៅក្នុងព្រះគ្រីស្ទ ដែលជារោងឧបោសថពិត។ (រ៉ូម 12:1-2)

ដូច្នេះយើងរីករាយនឹងប្រភពនៃទឹករស់នៅក្នុងព្រះគ្រីស្ទ ដែលទ្រង់ជាពិធីជប់លៀងនៃរោងឧបោសថពិតប្រាកដ។ ហើយយើងបានបទពិសោធន៍នូវចេស្តានៃពិភពខាងវិញ្ញាណ។ (យ៉ូហាន 7:38-39) យើងពិតជាបានឃើញការអស្ចារ្យជាច្រើនថែមទៀតនៅក្នុងវិញ្ញាណ ពីព្រោះនៅក្នុងថ្ងៃដ៏មានតម្លៃនេះបានមកនៅក្នុងថ្ងៃនៃការចាប់កំណើតរបស់ព្រះគ្រីស្ទហើយនឹងមកនៅក្នុងថ្ងៃនៃការយាងមកជាលើកទីពីរ

របស់ព្រះយេស៊ូវគ្រីស្ទ។ យើងគួរតែរីករាយដែលការនៅជាប់នឹងព្រះគុណនិងការរួបរួមគ្រប់គ្រងលើពួកយើងនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។

## សរុបសេចក្ដី

និមិ្មតរបស់សាការីបង្ហាញយ៉ាងច្បាស់នូវការប្រោសលោះរបស់ព្រះគ្រីស្ទនៅក្នុងសញ្ញាថ្មី។ នៅពេលដែលយើសញ្ជឹងគិតការនិមិ្មតទាំងនេះនៅក្នុងព័ន្ធកិច្ចគ្រូគង្វាលរបស់យើង យើងអាចមើលឃើញសិរីល្អដែលអស្ចារ្យនិងបរិបូរណ៍នៅក្នុងព្រះគ្រីស្ទ។ នេះជានិមិ្មតដូចគ្នា ដែលអេសាយបានឃើញនៅឯព្រះវិហារ (អេសាយ 6)។ បន្ទាប់មកគាត់បានអោនចុះលត់ជង្គង់ ហើយលន់តួបាបដ៏អាក្រក់របស់គាត់ទៅកាន់ព្រះអម្ចាស់។ ដូច្នេះការរកឃើញរបស់សាការី ដែលបានឃើញសិរីល្អរបស់ព្រះអម្ចាស់និងសេចក្ដីខ្វះខាតរបស់មនុស្ស គួរតែជាគ្រឹះ ដំណើរការ និងលទ្ធផលនៃព័ន្ធកិច្ចរបស់គ្រូគង្វាល។ មានតែសិរីល្អរបស់ព្រះអម្ចាស់ដែលអាចយកឈ្នះលើបញ្ហាជាច្រើនសព្វថ្ងៃរបស់យើង។ (យ៉ូហាន 1:14)

## ការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះបន្ទាប់ពីការត្រឡប់វិញរបស់អ៊ីស្រាអែល

### 1. អែសរ៉ា

### 1. កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ (អែសរ៉ា1:1-11)

អែសរ៉ាជាហោរានិងជាបណ្ឌិតខាងក្រឹត្យវិន័យ ដែលព្រះអម្ចាស់បានប្រើបន្ទាប់ពីអ៊ីស្រាអែលប្រឡប់មកពីបាប៊ីឡូនវិញ។ តើជាកិច្ចការប្រភេទណារបស់ព្រះវិញ្ញាណបរិសុទ្ធ? ទីមួយ យើងឃើញកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់ផ្ទាល់បានចាប់ផ្ដើម។ ព្រះវិញ្ញាណដែលបានធ្វើការយ៉ាងអស្ចារ្យ ដូចដែលការទាយទុករបស់ហោរាយេរេមា នៅពេលដែលសមរម្យព្រះអម្ចាស់បានធ្វើឲ្យគូរេសជាស្ដេចបង្គាប់ឲ្យពួកគេត្រឡប់មកយេរូសាឡិមវិញហើយសាងសង់ព្រះវិហារនៅទីនោះ។ គ្រប់កិច្ចការរបស់ព្រះអម្ចាស់ត្រូវបានចាប់ផ្ដើមដោយព្រះវិញ្ញាណ

។ ព្រះវិញ្ញាណដែលបានធ្វើការល្អៗនៅក្នុងយើង ទ្រង់ពិតជានឹងសំរេចការនេះរហូតដល់ថ្ងៃរបស់ព្រះយេស៊ូវគ្រីស្ទ (ភីលីព 1:6)។ ទីពីរ ទ្រង់នឹងលើកមនុស្សខាងវិញ្ញាណឡើង។ បើទោះជាព្រះវិញ្ញាណធ្វើការនៅក្នុងយើង នោះមិនបានបដិសេធសកម្មភាពរបស់មនុស្សដែលគ្មានគម្រោងមួយចំនួនដោយស្វ័យប្រវត្តិនោះឡើង។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការ ដូចជាអែសរ៉ាធ្វើការតាមរយៈមនុស្សរបស់ព្រះវិញ្ញាណបរិសុទ្ធនិងមនុស្សដែលមានការកោសរសើរដោយព្រះអម្ចាស់។ (5) ទីបី មានតែព្រះវិញ្ញាណបរិសុទ្ធដែលសំរេចនូវរូបឆ្លុះរបស់ព្រះគ្រីស្ទដូចជាព្រះវិហារ។ សំរាប់កិច្ចការនេះ យើងគួរតែទៅទទួលសេចក្ដីពោរពេញនៃព្រះវិញ្ញាណបរិសុទ្ធ។ ចិត្តរបស់អ្នកជឿគួរតែក្លាយជាទីដែលព្រះទទួលយកនិងមានវត្តមាន។ (១កូរិនថូស 3:16)

**2. អ្នកធ្វើការដែលបានត្រៀមទុក (អែសរ៉ា** 2:1-54)

- ដើម្បីនឹងសំរេចបេសកកម្មសំរាប់ការសាងសង់ព្រះវិហារ ព្រះអម្ចាស់បានរៀបចំគ្រប់វិធីសាស្ត្រទាំងអស់ដោយម៉ត់ចត់។ តើអត្ថបទបានបង្ហាញអ្វីខ្លះ? ទីមួយ ព្រះអម្ចាស់បានត្រៀមកូនចៅរបស់ពួកអន្តោប្រវេសន៍ជំនាន់ទីមួយ។ (1-2) អ្នកដឹកនាំខាងវិញ្ញាណ សេរូបាបិល នេហេមា អែសរ៉ាជាដើម ដែលជាបុគ្គលដែលទទួលការបើកសំដែងដោយព្រះវិញ្ញាណបរិសុទ្ធ។ អ្នកដែលស្រឡាញ់ព្រះបន្ទូលនិងជឿព្រះបន្ទូលដោយផ្ទាល់ ជាមនុស្សដែលមានតម្លៃ។ ទីពីរ ព្រះអម្ចាស់បានត្រៀមអ្នកចម្រៀង (41)។ ពួកគេបានថ្វាយការថ្វាយបង្គំដែលជាចំណុចមូលដ្ឋាននៃ រាស្ត្ររបស់ទ្រង់។ នៅពេលដែលអ័ប្រាហាំថ្វាយពពែញីទៅកាន់ព្រះយេហូវ៉ាជំនួសឲ្យអ៊ីសាក់ ពួកគេគួរតែក្លាយជាម្នាក់ ដែលទ្រង់បានត្រៀមទុកការសរសើរដំកើងនៅក្នុងសេចក្ដីពិតនិងនៅក្នុងវិញ្ញាណ។ ទីបី ពួកគេបានរៀបចំអ្នករក្សាទ្វារ (42) មានន័យ៧ថា មនុស្សដែលរក្សាព្រះវិហារនិងរៀបចំទ្វារ។ ដូចព្រះអម្ចាស់បានត្រៀមអ្នកគង្វាល នៅពេលដែលព្រះយេស៊ូវបានយាងមកលើលោកិយជាទីមួយ ព្រះអម្ចាស់បានធ្វើកិច្ចការរបស់ទ្រង់តាមរយៈទ្រង់ផ្ទាល់បានត្រៀមសំរាប់ទ្រង់ផ្ទាល់។ ការបង្កើតក្រុមជំនុំ ព្រះទ្រង់បានប្រើមនុស្សដែលទ្រង់បានត្រៀមទុករួច។

### 3. ព្រះអម្ចាស់ប្រើរបស់របរដែលបរិសុទ្ធ (អែសរ៉ា 2:55-70)

- នៅក្នុងការច្របូកច្របល់ជាច្រើន ព្រះអម្ចាស់បានប្រើមនុស្សដែលគោរពកោតខ្លាចដល់ទ្រង់ តើអ្វីដែលអត្ថបទបានបង្ហាញមកកាន់យើង? ទីមួយ ប្រើស៊ីឡាបានហាមមនុស្សដែលមិនមែនជាគ្រួសារជាក់ស្តែងនៅក្នុងការងាររបស់សង្ឃឡើយ ហើយក៏បានបញ្ឈប់ការបរិភោគម្ហូបដែលថ្វាយនៅក្នុងទីបរិសុទ្ធ រហូតដល់សង្ឃដែលបានដែលបានយកយូរីមនិងថាមីមបានលេចមក។ (62-63) ព្រះអម្ចាស់ប្រើមនុស្សដែលស្មោះត្រង់។ ទីពីរ ព្រះអម្ចាស់បានត្រៀមអ្នកធ្វើការដែលរក្សារដង្វាយដែលបរិសុទ្ធដែលបានថ្វាយសំរាប់ការសាងសង់ព្រះវិហារឡើងវិញ។ (69) រហូតដល់ការថ្វាយចាប់ផ្តើម ហើយដង្វាយទាំងអស់ត្រូវបានប្រើប្រាស់យ៉ាងជាក់លាក់ត្រឹមត្រូវ។ ព្រះអម្ចាស់ទទួលរបស់ដែលបរិសុទ្ធនៅក្នុងការកសាងក្រុមជំនុំ។ ដូច្នេះសេចក្តីបរិសុទ្ធនឹងត្រូវបានបញ្ជាក់និងពិសោធន៍ខ្លួនឯងជានិច្ច។ ព្រះអម្ចាស់ស្វែងរកចិត្តដែលថ្វាយដោយស្ម័គ្រអស់ពីចិត្តដោយអំណរ។ យើងគួរតែទៅតាមព្រះលោហិតដ៏មានតម្លៃរបស់ព្រះគ្រីស្ទដើម្បីឲ្យបានបរិសុទ្ធ។

### 4. ការបង្កើតអាសនា (អែសរ៉ា 3:1-13)

- នៅពេលដែលសាឡូម៉ូនហៅអ្នកធ្វើការ100000នាក់ដើម្បីបង្កើតព្រះវិហារ ដំបូងបង្អោះវាបញ្ជាក់ថា អាសនាត្រូវបានស្តារឡើងវិញ ហើយដង្វាយដុតត្រូវបានទទួលយក។ តើវាជាការសាងសង់ដូចម្តេច? ទីមួយ វាជាការសាងសង់ឡើងវិញដើម្បីនឹងដើរតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលជាមូលដ្ឋានគ្រឹះនៃព្រះវិហារ។ ផ្អែកលើក្រឹត្យវិន័យរបស់ម៉ូសេវាត្រូវបានស្តារឡើងវិញ។ វាជារឿងធម្មតាដែល អាទិភាពនៃព្រះបន្ទូលរបស់ព្រះអម្ចាស់ជាមូលដ្ឋានគ្រឹះរបស់ព្រះវិហារ (អេភេសូ 2:20)។ ទីពីរ អាសនាត្រូវបានស្តារឡើងវិញ ពីព្រោះការសាងសង់នៅលើព្រះបន្ទូលរបស់ព្រះអម្ចាស់គួរតែមកដោយការស្តារឡើងវិញនូវការថ្វាយបង្គំ។ ការធ្វើអាសនានិងការថ្វាយដង្វាយដុត ដង្វាយមេត្រី និងពីធីថ្វាយដង្វាយត្រូវបានអនុវត្តដោយគោលការណ៍ទាំងនេះ។ ទីបី វាជាការស្តារឡើងវិញនូវឥរិយាបថល្អ។ ការស្តារឡើងវិញដោយបញ្ឈរជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធនិងជាចរន្តនៃព្រះគុណ។

## 5. សេចក្ដីល្បួងដែលយើងអាចយកឈ្នះ (អែសរ៉ា 6:1-12)

- បើទោះជាការសាងសង់ឡើងវិញនៃព្រះវិហារអាចនឹងត្រូវបញ្ឈប់ ដោយសារការចោទប្រកាន់ពីអ្នកជិតខាងក៏ដោយ ក៏ព្រះអម្ចាស់អនុញ្ញាតនូវការលំបាក់ដែលល្មមដែលធ្វើឲ្យកិច្ចការរបស់ព្រះអម្ចាស់ចំរើនដោយព្រះគុណរបស់ទ្រង់។តើភស្តុតាងអ្វីដែលអត្ថបទបាបង្ហាញ? ទីមួយ ស្ដេចដារាសបានអនុញ្ញាតឲ្យថែរក្សាពួកគេដោយមហិទ្ធិឫទ្ធិរបស់ស្ដេច (1-5)។ ស្ដេចបានផ្ដល់ឯកសារជាផ្លូវការឲ្យដាក់សំភារៈព្រះវិហារនៅកន្លែងដើម។ ព្រះអម្ចាស់ជាព្រះដែលមានគ្រប់ទាំងចេស្ដាដែលទ្រង់បានសំរេចព្រះហឫទ័យរបស់ទ្រង់ បោះទោះជាដោយការប្រើអ្នកដែលមិនជឿក៏ដោយ។ ទីពីរ ពួកគេត្រូវបាននាំយកមកដោយការព្រមាននិងការកំសាន្តចិត្ត (11-12)។ ស្ដេចបានបង្គាប់ថា ពួកគេគួរតែមានទំនួលខុសត្រូវនៅក្នុងការផ្គត់ផ្គង់សំភារៈរហូតដល់បញ្ចប់ការសាងសង់ព្រះវិហារ ហើយក៏ផ្ដល់ការដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅកាន់អ្នកដែលធ្វើខុសនឹងក្រឹត្យក្រម។ ថ្មជំពប់នៅចំពោះគ្រីស្ទានមានន័យថា ព្រះអម្ចាស់បានត្រៀមព្រះគុណជាច្រើនជាងមុនទៀត។នេះជាព្រះហឫទ័យដែលលាក់បាំងរបស់ព្រះអម្ចាស់។យើងគួរតែទុកចិត្តព្រះអម្ចាស់ ដែលទ្រង់អនុញ្ញាតការលំបាក ហើយផ្ដល់ផ្លូវដើម្បីនឹងគេចផុតពីសេចក្ដីទុក្ខវេទនា។(១កូរិនថូស10:13)

## 6. មនុស្សដែលបានត្រៀមទុក (អែសរ៉ា 7:1-10)

- ការសាងសង់ព្រះវិហារពិតប្រាកដ គួរតែបង្កើតឡើង មិនមែននៅលើរូបរាងខាងក្រៅឡើយ ប៉ុន្តែជាទិដ្ឋភាពខាងក្នុងវិញ។ សេចក្ដីពិតដែលគម្ពីរសញ្ញាចាស់និងសញ្ញាថ្មីបានសង្កត់ធ្ងន់ ជាផ្នែកខាងក្នុង ដែលចេញមកពីការផ្ដោតទៅលើសារៈសំខាន់នៃផ្នែកខាងក្នុងរបស់យើង។ ទីមួយ គាត់ជាកូនចៅជំនាន់ទី១៨របស់អើរ៉ុន(15)។ ដូនតារបស់គាត់ បីនេហាស បានឈប់នូវគ្រោះចង្រៃមកលើអ៊ីស្រាអែលដោយ បានថ្វាយទង្វើដែលសុចរិតរបស់គាត់ទៅកាន់ព្រះអម្ចាស់ ដែលគាត់បានធ្វើឲ្យទ្រង់ Israel by offered his righteous activity to God, which he made God coolly. តាមរយៈទង្វើសុចរិតរបស់គាត់ ព្រះអម្ចាស់បានត្រៀមភាជន៍នៃសេចក្ដីប្រោសលោះនៃកិច្ចការប្រោសលោះនៅក្នុងប្រវត្តិសាស្ត្រ។ ទីពីរ គាត់ជាបុរសដែលបាន

លះបង់ដើម្បីរក្សាក្រឹត្យវិន័យ(10)។ គាត់មានពិសោធន៍ខាងបញ្ញានិងការពិសោធន៍។ ការសំរេចចិត្តរបស់គាត់ដែលគាត់បានសិក្សាក្រត្យវិន័យ បានស្តាប់តាមនិងបង្រៀនក្រឹត្យវិន័យដោយអស់ពីចិត្ត ជាការដែលមានតម្លៃបំផុត។ វាបានបញ្ជាក់ថា គាត់បានទទួលព្រះគុណរបស់ព្រះយ៉ាងធំ។ ទីបី គាត់បានចាប់ផ្តើមផ្លាស់ប្រែចេញពីខ្លួនគាត់ផ្ទាល់។ មុនពេលគាត់បង្រៀនព្រះបន្ទូលរបស់ព្រះអម្ចាស់ ចិត្តរបស់គាត់ដែលរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់គាត់ មានន័យថាជាដង្វាយត្រៀមទុកសំរាប់ព្រះអម្ចាស់។

### 7. ការបញ្ឆេះឡើងរបស់បុគ្គលម្នាក់ (អែសរ៉ា 7:11-28)

- ការសំរេចចិត្តរបស់មនុស្សម្នាក់ធ្វើឲ្យមានការអស្ចារ្យឡើង។ នៅពេលដែលបុគ្គលម្នាក់ ជាអែសរ៉ាដែលបានថ្វាយខ្លួនរបស់គាត់រៀនព្រះបន្ទូលរបស់ព្រះអម្ចាស់ បានធ្វើឲ្យគ្រប់ការទាំងអស់មានសេរីភាព ដោយការផ្តល់អំណាចខាងនយោបាយនិងថវិកា។ តើជំនួយរបស់ព្រះបង្ហាញមកដោយរបៀបណា? ទីមួយ ព្រះអម្ចាស់បានកាន់គាត់រហូតដល់ថ្ងៃនៃការកំណែទម្រង់សំរេចដោយការប៉ះពាល់ដល់ស្តេច អាថាសាស្តា សំរាប់ការការពារដែលឥតខ្ចោះ(11-22)។ អ្នកដែលស្វែងរកនគរនិងសេចក្តីសុចរិតរបស់ព្រះជាទីមួយ នឹងមានពិសោធន៍ថា ព្រះអម្ចាស់បន្ថែមការផ្សេងទៀតទៅគេ( ម៉ាថាយ 6:33)។ ទីពីរ វាជាការអស្ចារ្យ ដែលបុគ្គលម្នាក់សំរេចចិត្តទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ពីព្រោះគាត់មានតួនាទីដុតពួកគេសំរាប់ការកំណែទម្រង់ខាងវិញ្ញាណ ការសាងសង់ព្រះវិហារជាថ្មីពិតប្រាកដ។ រាស្រ្តដែលនៅជាប់នឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលតែងតែមានជីវិតរស់នៅនិងចេស្តាខាងព្រះគុណ នឹងត្រូវបានប្រើប្រាស់សំរាប់កិច្ចការរបស់ព្រះអម្ចាស់។ នៅពេលដែលជ្រុងគែមបញ្ឆេះភ្នំទាំងអស់ ភ្លើងដ៏តូចមួយរបស់ព្រះបន្ទូលនៅក្នុងចិត្តរបស់ខ្ញុំអាចដុតគ្រប់ការទាំងអស់នៅក្នុងលោកិយ។

### 8. ការកំណែទម្រង់នៃការថ្វាយបង្គំ (អែសរ៉ា 8:1-20)

- អែសរ៉ាបានថ្វាយខ្លួនទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយគាត់ក៏បានថ្វាយបង្គំទៅកាន់ព្រះអម្ចាស់។ ការផ្លាស់ប្រែដ៏ពិតមិនត្រូវបានបញ្ចប់ត្រឹមដែលស្គាល់ព្រះបន្ទូលប៉ុណ្ណោះទេ

ប៉ុន្តែដោយការអនុវត្តព្រះបន្ទូលនៅក្នុងជីវិតរបស់គាត់ដើម្បីបង្កើតឲ្យមានមនុស្សនៃថ្វាយបង្គំ (ម៉ាថាយ 28:19-20)។ ក្រុមជំនុំគួរតែថ្វាយសិរីល្អដល់ព្រះអម្ចាស់ ហើយរីករាយនឹងទ្រង់អស់កល្បជានិច្ច ដែលនោះជា ការថ្វាយជីវិតរបស់គាត់ទាំងអស់ទៅកាន់ព្រះអម្ចាស់។ ប៉ុន្តែសង្ឃណាដែលធ្វើការនៅក្នុងព័ន្ធកិច្ចដ៏មានតម្លៃរបស់គាត់ត្រូវបាត់ទៅ។ បន្ទាប់មកអែសរ៉ាបានស្វែងរកបុគ្គលដែលសាកសមអស់រយៈពេលបីថ្ងៃ ហើយបានដាក់តួនាទីឲ្យពួកគេធ្វើ។ បើទោះជាពួកលេវីត្រូវចាកចេញនៅពេលនោះក៏ដោយ ក៏គាត់នៅតែរកបានមនុស្សដើម្បីនឹងបំរើដែរ(16-19)។ បន្ទាប់មកអែសរ៉ាបានប្រកាសការតមនិងស្វែងរកសេចក្តីជំនួយរបស់ព្រះអម្ចាស់ (21)។ នៅពេលដែលយើងថ្វាយបង្គំព្រះអម្ចាស់ បើទោះជាយើងមានស្ថានភាពអាក្រក់យ៉ាងណាក៏ដោយ តែយើងមិនថ្វាយបង្គំព្រះអម្ចាស់ដោយវិធីសាស្ត្រខាងក្រៅនោះទេ ប៉ុន្តែដោយនៅក្នុងវិញ្ញាណនិងសេចក្តីពិតដែលយើងអាចជួបព្រះអម្ចាស់ (យ៉ូហាន 4:23)។

### 9. **ការសំរេចចិត្តនៃការកំណែទម្រង់ (អែសរ៉ា 10:1-15)**

- ដូចដែលស្ត្រីសាសន៍សាម៉ារីបានផ្លាស់ប្រែជីវិតរបស់គាត់ចេញពីជីវិតអាពាហ៍ពិពាហ៍ដ៏អាក្រក់របស់គាត់ ដោយបានជួបព្រះយេស៊ូវ ការសំរេចចិត្តទទួលព្រះគ្រីស្ទ នៅក្នុងចំណុចកណ្តាលរបស់គាត់មានឥទ្ធិពលទៅលើជីវិតទាំងមូល។ អត្ថបទបង្ហាញពីការផ្លាស់ប្តូរជីវិតរបស់ស្ត្រីដែលរស់នៅដោយមិនជឿ។ តើព្រះបន្ទូល - ការផ្លាស់ប្រែ ការថ្វាយបង្គំ និងជីវិតអាពាហ៍ពិពាហ៍ កើតឡើងដោយរបៀបណា? ទីមួយ វាត្រូវបានលើកឡើងដោយបំណងដែលស្រឡាញ់របស់អែសរ៉ា។ សេចក្តីស្មោះត្រង់របស់អ្នកដឹកនាំខាងវិញ្ញាណ ឬការត្រាស់ហៅរបស់គាត់ អាចក្លាយជាចរន្តនៃការកែទម្រង់។ ទីពីរ ការសំរេចចិត្តរបស់មនុស្សនៅក្នុងចិត្តនាំមកនូវការផ្លាស់ប្រែ។ នៅពេលដែលអ៊ីស្រាអែលបានដើរតាមហិបសញ្ញាដោយស្ងៀមស្ងាត់ បានធ្វើឲ្យវិនាសដល់ក្រុងយេរីខូ ជាមនុស្សដែលបានស្តាប់បង្គាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះអាចទទួលបានបទពិសោធន៍នូវការផ្លាស់ប្រែនៅក្នុងលោកិយ។ ទីបី កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធជាស្នូលនៃការកែទម្រង់។ មានតែព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះដែលជាប្រធាននៃការផ្លាស់ប្រែនិងការកើតជាថ្មី។ អ្នកដែលដើរតួជាអ្នកប្រឹក្សាមួយផ្សេងទៀតជាវិញ្ញាណទាំងប្រាំពីរ

ដែលព្រះអម្ចាស់បានចាត់មកក្នុងលោកិយសំរាប់ការផ្លាស់ប្រែរបស់លោកិយ។ យើងគួរតែទ្រាំទ្រឈើឆ្កាងដើម្បីនឹងផ្លាស់ប្រែពិភពលោករបស់យើងឲ្យទទួលបានការផ្លាស់ប្រែដ៏អស្ចារ្យ។

**10. ការប្រែចិត្តពិតប្រាកដ (អែសរ៉ា 10:16-44)**

- តាមរយៈអត្ថបទ មនុស្សសំខាន់នៅក្បែរអែសរ៉ាបានធ្វើបាបលើសជាងអ្នកផ្សេងទៅទៀត។ យើងរៀនពីសារៈសំខាន់នៃការប្រែចិត្ត។ តើអ្វីទៅជាការប្រែចិត្ត? ទីមួយ វាជាការរំលឹងគេទាន់ពេល។ គាត់បានរំលឹកពួកគេអស់រយៈពេលបួនខែពីគ្រួសាររបស់ពួកគេ។ ការប្រែចិត្តដូចជាពន្លឺចែងចាំងដែលកើតឡើងនៅក្នុងជីវិត។ អ្នកដែលត្រួតពិនិត្យខ្លួនឯងឲ្យអស់ពីចិត្ត នឹងមានវិធីទៅកាន់ក្តីសង្ឃឹម។ ទីពីរ គាត់បានរំលឹកពីមនុស្សដែលនៅក្បែរ។ លើសពីទំនាក់ទំនងរបស់មនុស្ស ក្រុមសរសើរដំកើងនិងសង្ឃ ដែលមានទំនួលខុសត្រូវថ្វាយបង្គំ។ ការឈរនៅចំពោះព្រះបន្ទូលរបស់ព្រះអម្ចាស់នឹងត្រូវបានសង្កត់ធ្ងន់ជានិច្ច។ ទីបី គាត់បានសរសេរឡើងនូវកិច្ចការ។ គាត់បានធ្វើឲ្យពួកគេខិតចូលជិតការប្រែចិត្តពិតនិងការស្តាប់បង្គាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការរីករាយពិតប្រាកដត្រូវបានកត់ត្រានៅក្នុងសៀវភៅជីវិតនិងសៀវភៅអនុស្សាវរីយ៍។ យើងគួរតែមានតម្លៃទៅនឹងរង្វាន់របស់ព្រះអម្ចាស់ លើសជាងរង្វាន់បច្ចុប្បន្នដោយមើលឃើញវារហូតនោះទៅទៀត។

## 2. នេហេមា

**1.ការអធិស្ឋានរបស់នេហេមា (នេហេមា 1:1-11)**

- ប្រសិនបើអែសរ៉ាជាហោរ៉ាដែលស្មោះត្រង់ម្នាក់ ប៉ុន្តែនេហេមាបានជួសជុលជញ្ជាំងក្រុងហើយគ្រប់គ្រងលើរាស្ត្រ ដោយសារពួកគេត្រូវការការសាងសង់ឡើងវិញនៃព្រះវិហារនិងជញ្ជាំងក្រុង ដើម្បីនឹងការពារពីការវាយប្រហាររបស់ពួកលុកលុយ។ តើនរណាជានេហេមា

ហើយគាត់ធ្វើដូចម្តេចខ្លះ? ទីមួយ គាត់ជាមនុស្សម្នាក់ដែលត្រូវបានត្រៀមទុកជាមុន។ (2-3) សេចក្តីខ្វល់ខ្វាយរបស់គាត់ដែលបានឮពិការវិនាសរបស់ជញ្ជាំងយេរូសាឡិមនោះចេញមកពីមនសិការល្អរបស់គាត់។ គាត់ស្រឡាញ់អាណាចក្ររបស់ព្រះដែលនៅល្អ ហើយគាត់បារម្ភពីការនោះនឹងត្រូវកាត់បន្ថយទៅ ពីព្រោះចិត្តរបស់គាត់នៅជាប់នឹងបំណងព្រះហឫទ័យរបស់ព្រះ។ ទីពីរ គាត់មានទំនួលខុសត្រូវ ហើយបានលន់តួនៅចំពោះព្រះអម្ចាស់ ពីព្រោះនោះជាគន្លឹះតែមួយដើម្បីដោះស្រាយបញ្ហា។ ទីបី គាត់ពឹងលើសេចក្តីសន្យារបស់ព្រះអម្ចាស់ (5-11)។ ការលន់តួបាបពិតប្រាកដតែងតែកើតឡើងនៅពេលដែល ពួកគេពឹងផ្អែកលើព្រះអម្ចាស់និងសេចក្តីសន្យារបស់ទ្រង់។ ការសូមរបស់ពួកសុចរិតដែលព្យាយាមលន់តួមានចេស្តាធ្វើការយ៉ាងខ្លាំង។ យើងគួរតែដើរតាមឧទាហរណ៍នៃការអធិស្ឋានរបស់នេហេមា។

2. **ការឆ្លើយតបរបស់ព្រះអម្ចាស់ (នេហេមា 2:1-10)**

- ព្រះអម្ចាស់បានធ្វើការតាមរយៈ ស្តេចអាដាសាស្តា ដែលជាស្តេចដែលបានឃើញនេហាមាមានពេញដោយសេចក្តីខ្វល់ខ្វាយ។ តើការនោះកើតឡើងដោយរបៀបណា? ទីមួយ វាត្រូវបានកើតឡើងដោយសេចក្តីសោកសង្រេងរបស់អ្នកដែលគោរពកោតខ្លាចដល់ព្រះ (1-3)។ សេចក្តីខ្វល់ខ្វាយដែលនេហេមាមាន បង្ហាញច្បាស់ពីកិច្ចការរបស់ព្រះអម្ចាស់។ កិច្ចការរបស់ព្រះអម្ចាស់រួមបញ្ចូលទាំងទុក្ខលំបាកនិងសេចក្តីខ្វល់ខ្វាយ។ ទីពីរ វាត្រូវបានបង្ហាញដោយការផ្តល់នូវការកោតសរសើរយ៉ាងខ្លាំងទៅកាន់ស្តេចរបស់សាសន៍ដទៃ (4-5)។ នេះជាភស្តុតាងនៃកិច្ចការរបស់ព្រះអម្ចាស់។ ក៏ដូចជាការអធិស្ឋានតមរបស់នាងអេសធើ ស្តេចអាហាស៊ូរើសមានសេចក្តីកោតសរសើរជាខ្លាំង (អែសធើ 5:1-3) តាមរយៈការអធិស្ឋានពេញមួយយប់របស់យ៉ាកុប អេសាវមានសេចក្តីកោតសរសើរ (លោកុប្បត្តិ 33:3-4) ព្រះអម្ចាស់មានការប្តូរចិត្តរបស់សត្រូវ ហើយមានប្រាជ្ញាជាច្រើនដើម្បីនឹងសំរេចបំណងព្រះហឫទ័យរបស់ទ្រង់។ ទីបី ព្រះអម្ចាស់បានធ្វើការតាមរយៈសេចក្តីជំនឿ។ (5, 7-8) នេហេមាបានបើកចិត្តរបស់កាត់នៅចំពោះស្តេច ហើយបានទាមទារនូវអ្វីដែលគាត់ចង់បានដោយសេចក្តីជំនឿហើយគាត់បានទទួលមកយ៉ាងអស្ចារ្យ។ យើងគួរតែខិតចូលក្បែរព្រះអម្ចាស់ដោយសេចក្តីអធិស្ឋាននៃសេច

ក្តីសំណូមយ៉ាងខ្លាំងក្លា។ មានតែសេចក្តីអធិស្ឋានដោយជំនឿទេដែលអាចផ្លាស់ប្រែភ្នំដ៏ធំបាន។

### 3. **ភាពជាអ្នកដឹកនាំរបស់នេហេមា (នេហេមា 2:11-20)**

- រំពេចដែលនេហេមាបានមកដល់ក្រុងយេរូសាឡិមក្នុងកំឡុងពេលបីថ្ងៃ។ នេហេមាចាប់ផ្តើមបេសកកម្មរបស់គាត់ដោយ ការត្រួតពិនិត្យស្ថានភាពជាក់ស្តែង។ តើគាត់ធ្វើកិច្ចការនោះដោយរបៀបណា? ទីមួយ គាត់បានប្រាប់គេឲ្យដឹងពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ (11-17)។ គាត់បានជម្រុញថា ពួកគេគួរតែស្តាប់បង្គាប់ទៅកាន់ការព្រះអម្ចាស់ ដោយប្រាប់ពួកគេពីសេចក្តីប្រកាសរបស់ស្តេច ដែលបានផ្តត់ផ្គង់គ្រប់ទាំងថវិកានិងអំណាចទៅកាន់មនុស្សគ្រប់គ្នា។ គាត់បានបង្រៀនថា អ្វីដែលយើងធ្វើតាមបំណងព្រះហឫទ័យទ្រង់ដោយការចុះចូលបំណងរបស់យើង មានន័យថាជាសេចក្តីចម្រុងចម្រើន។ ទីពីរ នេហេមាបានធ្វើការតាមរយៈចិត្តដែលស្មោះត្រស្មោះលើសជាងន័យដែលក្លែងក្លាយ (18)។ ប៉ុន្តែនេហេមាបានរងចាំ ថាពួកគេនឹងថ្វាយមិនមែនដោយគោលបំណងរបស់មនុស្សឡើយ ប៉ុន្តែដោយវិធីសាស្រ្តរបស់ព្រះអម្ចាស់ ដែលស្តាប់បង្គាប់ព្រះអម្ចាស់ ទ្រង់តែងតែរៀបចំយញ្ញបូជារស់សំរាប់កិច្ចការល្អវិញ។ ទីបី គាត់បានគ្រប់គ្រងលើពួកមនុស្សដែលមានការប្រឆាំងទៅកាន់ការសំរេចតាមបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ភ្លាមៗ (19-20)។ បើទោះជាការប្រឆាំងខ្លាំងក្លាក៏ដោយក៏ការទាំងនោះមិនអាចបំបាក់បំបែកបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់បានឡើយ។ តាមរយៈព្យុះព្រះអម្ចាស់ធ្វើឲ្យពួកគេរលាយបាត់មួយរំពេច។ អ្នកដឹកនាំខាងវិញ្ញាណត្រូវការឥរិយាបថបែបដូច្នេះ។

### 4. **ការសាងសង់សេចក្តីជំនឿជាថ្មី (នេហេមា 3:1-32)**

- ជញ្ជាំងដែលនេហេមាជួសជុលជាជញ្ជាំងប្រាំពីរ (ចៀមត្រីអេប្រាអ៊ីមចាស់ អណ្តូង សម្រស់) និងប៉មចាំយាម។អ្នកណាដែលស្មោះត្រង់ក្នុងការរក្សាតួនាទីនីមួយៗក្នុងការសាងសង់ជញ្ជាំង (1-2)។ ទីមួយ យើងគួរតែបង្កើតនូវជញ្ជាំងសេចក្តីជំនឿដែលហិនហោចនោះ (1-2) យើងគួរតែស្គាល់នូវរនាំងដែលធ្វើឲ្យជំពប់របស់យើង ហើយអនុវត្តនូវការលន់តួបាបនិងសេចក្តីជំ

នឿ។យើងគួរតែដកនូវសំភារៈរបស់សាតាំងនិងលោកិយព្រមទាំងសេចក្តីប្រាថ្នាខាងសាច់ឈាម ហើយគួរតែបានពេញដោយចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធវិញ។ ទីពីរ មានតែព្រះគ្រីស្ទទេដែលជាជញ្ជាំងរបស់យើង (យ៉ូហាន 10:28-29)។ យើងគួរតែរីករាយនឹងព្រះគ្រីស្ទ ហើយបង្កើតផលផ្លែយ៉ាងបរិបូរណ៍ដោយការដើរតាមទ្រង់យ៉ាងស្មោះត្រង់។ គ្មាននរណាម្នាក់អាចអាចឆក់យកយើងចេញពីព្រះហស្តរបស់ទ្រង់បានឡើយ។

5. **របៀបយកឈ្នះសេចក្តីល្បួង (នេហេមា 4:1-14)**

- កិច្ចការរបស់ព្រះអម្ចាស់ក៏ជួបជាមួយសេចក្តីល្បួងមួយចំនួនដែរ។ ដូចជាសាប៉ាបាសនិងថូបៀបានរំខានដល់កិច្ចការរបស់ព្រះ តើនេហេមាធ្វើយ៉ាងដូចម្តេច? ទីមួយ គាត់បានអធិស្ឋាន (4) គាត់បានថ្វាយពីសភាពបច្ចុប្បន្នរបស់គាត់ទៅកាន់ព្រះ ហើយស្វែងរកសេចក្តីជំនួយមកពីព្រះ។ នៅពេលដែលយើងថ្វាយបញ្ហាណាមួយទៅកាន់ព្រះ ហើយបំរើសភាពនាពេលបច្ចុប្បន្នជាមួយរបស់ដ៏ល្អបំផុតរបស់យើង នោះយើងអាចទទួលបាននូវចេស្តាមួយចំនួននិងផ្លូវដើម្បីគេចផុត(9)។ ទីពីរ គាត់បានលើកទឹកចិត្តកុំឲ្យភ័យក្លាចការនោះឡើយ។ (14) គោលបំណងរបស់សត្រូវដែលអ្នកមិនគួរខ្លាចឡើយ តែអ្នកគួរកោតខ្លាចទៅកាន់ព្រះអម្ចាស់វិញ។ នៅពេលដែលយើងអានគម្ពីរ នោះចូរសញ្ជឹងគិតព្រះបន្ទូលហើយធ្វើតាម។ គាត់អាចស្គាល់ព្រះនិងប្រាជ្ញារបស់ទ្រង់ជាជាងការណាផ្សេងទៀត ពីព្រោះព្រះអម្ចាស់ដែលទ្រង់អាចយកឈ្នះគ្រប់សេចក្តីល្បួងទាំងអស់ នោះទ្រង់ស្មោះត្រង់។ (១កូរិនថូស 10:13)

6. **កិច្ចការនៃសេចក្តីជំនឿ (នេហេមា 4:15-5:5)**

- នៅពេលដែលសេចក្តីជំនឿជួបនឹងសេចក្តីរងទុក្ខវេទនា នោះកាន់តែភ្លឺថែងចាំងថែមទៀត។ បើទោះជាសត្រូវរំខានដល់ការសាងសង់ទ្វារក្រុងឡើងវិញដោយវិធីសាស្រ្តជាច្រើនក៏ដោយ តើនេហេមាមានប្រតិកម្មយ៉ាងណាដែរ? ទីមួយ គាត់បានកាន់សព្វាវុធនៅដៃរបស់គាត់ ហើយកាន់សំភារៈសាងសង់នៅដៃម្ខាងទៀត (4:15-20)។ បន្ទាប់ព្រះហឫទ័យរបស់ព្រះអម្ចាស់ត្រូវបានតាំងនៅ នោះគាត់នៅតែរក្សាជានិច្ច។ អ្វីដែលមនុស្សត្រូវស្វែងរកគួរតែជាភាពស្មោះត្រង់ពីព្រោះព្រះអម្ចាស់ផ្ទាល់ទ្រង់ធ្វើដូច្នោះ។ ទីពីរ វាដោះស្រាយគ្រប់ទាំងសេចក្តីក្រីក្ររបស់បង

ប្អូនដោយព្រះបន្ទូលរបស់ព្រះអម្ចាស់ (5:1-5)។ គាត់បានកាត់បន្ថយនូវចន្លោះដែលខុសគ្នារវាងអ្នកមាននិងអ្នកក្រ ដោយដើរតាមគំរូនៃព្រះបន្ទូល ពីព្រោះសេចក្តីជំនឿនៃការកោតខ្លាចដល់ព្រះ រាប់បញ្ចូលទាំងសេចក្តីមេត្តាករុណាផងដែរ។ សេចក្តីជំនឿពិតធ្វើឲ្យមានការល្អកើតឡើងដោយការធ្វើតាមព្រះបន្ទូល។ នៅពេលយើងខិតជិតដោយសេចក្តីជំនឿ នោះយើងនឹងចម្រុងចម្រើនឡើង។

7. **ភាពជាអ្នកដឹកនាំនៃការបម្រើ (នេហេមា 5:6-19)**

- នេហេមាបានបង្ហាញពីភាពជាអ្នកដឹកនាំនៃការបម្រើ។ ទីមួយ គាត់បានសង្កត់លើសេចក្តីស្រឡាញ់បែបជាបងប្អូន (6-9)។ គាត់បានហាមមិនឲ្យនរណាម្នាក់ដាក់បន្ទុកទៅដល់អ្នកក្រឡើយ។ នៅក្នុងការប្រជុំមួយចំនួន គាត់បានស្តីបន្ទោសពួកគេដោយ ប្រាប់ឲ្យគេដឹងពីសកម្មភាពមិនសមរម្យមួយចំនួនដែលទាស់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកដែលមានសេចក្តីលោភមិនអាចក្លាយជាអ្នកដឹកនាំពិតប្រាកដឡើយ។ ទីពីរ គាត់បានព្រមានថា អ្នកដែលមើលងាយបងប្អូនរបស់ខ្លួន នឹងរស់នៅដោយវេទនា (13)។ ពីព្រោះសេចក្តីបង្គាប់នៃសេចក្តីស្រឡាញ់ជាផលផ្លែនៃសេចក្តីកោតខ្លាចដល់ព្រះ។ ទីបី ហេតុផលដែលគាត់បានបដិសេធអភ័យឯកសិទ្ធិរបស់គាត់ ជាអ្វីដែលបង្ហាញថាកិច្ចការរបស់ព្រះអម្ចាស់សំខាន់ខ្លាំងណាស់។ គាត់មិនបានមើលងាយសិទ្ធិរបស់រដ្ឋាភិបាល ហើយបានបង្ហាញពីឧទាហរណ៍របស់អ្នកដឹកនាំទៅកាន់លុយ (15-116 18)។ សាវ័កប៉ូលបានព្រមានដល់សេចក្តីលោភលន់របស់ពួកគេនៅក្នុងព័ន្ធកិច្ចគ្រូគង្វាល (កិច្ចការ 20:33)។ អ្នកដែលមានសេចក្តីកោតខ្លាចដល់ព្រះអម្ចាស់នឹងត្រូវបានចងចាំដោយព្រះអម្ចាស់។ យើងគួរតែបំពាក់ការបែបនេះនៅក្នុងជីវិត។

8. **នៅពេលយើងជួបនឹងការមិនជឿ (នេហេមា 6:1-14)**

- មនុស្សដែលទាស់នឹងការសាងសង់ជញ្ជាំងត្រូវបានកើតឡើង។ អំពីការបះបោររបស់សាប៉ាឡាសនិងថូបៀនិងហ្គេសិម តើនេហេមាមានប្រតិកម្មដូចម្តេច? ទីមួយ គាត់នៅស្ងៀម (10)។ ដូច្នេះនៅពេលដែលពួកគេហៅទៅកាន់នេហេមាប្រាំដង (4-5) គាត់មិនបានប្រឈមមុននឹងពួកគេដោយផ្ទាល់នោះទេ ប៉ុន្តែគាត់បានគេចវេសពីពួកគេ ជាចុងក្រោយគាត់បានយកឈ្នះ

គ្រប់ពាក្យអាចាមរាមអាក្រក់ៗដោយសេចក្ដីស្ងៀមស្ងាត់។ ជាជាងនោះទៅទៀត បើទោះជាពួកគេបានរៀបគម្រោងដោយប្រើហោរាស្រីនិងហោរាដែលនៅសេសសល់ក៏ដោយ គាត់នៅតែអាចយកឈ្នះដោយការសេចក្ដីសំណូមនូវកិច្ចការរបស់ព្រះអម្ចាស់។ ទីពីរ គាត់បានឃើញព្រះដ៏អស្ចារ្យ (10)។ អារក្សផ្ដោតលើកិច្ចការដែលពួកគេត្រូវបានធ្លាក់ចុះក្នុងសេចក្ដីបាក់ទឹកចិត្ត។ នៅពេលដែលគាត់បានឃើញភាពធំឧត្ដមរបស់ព្រះអម្ចាស់ សេចក្ដីបាក់ទឹកចិត្តនោះក៏រលាយបាត់មួយរំពេច។ យើងគួរតែប្រឆាំងជាមួយនឹងអារក្សនៅក្នុងការបាក់ទឹកចិត្តនិងការអន់ចិត្តដោយសេចក្ដីជំនឿ ដោយមើលទៅកាន់ព្រះអម្ចាស់។

### 9 ឥទ្ធិពលនៃកិច្ចការរបស់ព្រះអម្ចាស់ (នេហេមា 6:15-7:4)

- នៅក្នុងកំឡុង៥២ថ្ងៃ ជញ្ជាំងត្រូវបានសង់ឡើង តើមានលទ្ធផលអ្វីដែលបានកើតឡើង? ទីមួយ សត្រូវត្រូវបានលុបបំបាត់ (6:16)។ បើទោះជាមានបញ្ហាច្រើនបានកើតឡើងតាមរយៈបំណងប្រាថ្នាដ៏មាំរបស់ពួកគេ ការសំរេចធ្វើជញ្ជាំងក្នុងកំឡុងពេលយ៉ាងខ្លីធ្វើឲ្យពួកគេមានការបាក់ទឹកចិត្ត។ ពួកគេបានបោះបង់ចោលការសម្លឹងទៅមើលព្រះហស្ដដ៏ធំរបស់ព្រះអម្ចាស់។ ជ័យជម្នះនៃសង្គ្រាមស្ថិតនៅក្នុងព្រះហស្ដរបស់ព្រះយេហូវ៉ា គ្រប់ខ្មាំងសត្រូវទាំងអស់នឹងត្រូវបំផ្លាញ។ ទីពីរ សេចក្ដីជំនឿដែលមានចេស្ដានៃសេចក្ដីកោតខ្លាចដល់ព្រះជាម្ចាស់ត្រូវបានបង្ហាញមក (7:2)។ អ្វីដែលគាត់កាន់ខ្ជាប់នៅក្នុងកិច្ចការដ៏លំបាកនោះជាសេចក្ដីជំនឿនៃការកោតខ្លាចដល់ព្រះអម្ចាស់។ នៅពេលដែលអំណាចត្រូវបានប្រាប់ទៅដល់សត្រូវ ពួកគេភ័យខ្លាចយ៉ាងខ្លាំងនៅក្នុងចិត្តរបស់ពួកគេ។ ដូចគ្នាទៅនឹងព្រឹត្តិការណ៍សេចក្ដីសង្គ្រោះនៅក្នុងនិក្ខមនំ ដែលព្រះបានធ្វើឲ្យមានដីស្ងួតនៅក្នុងសមុទ្រក្រហម ដែលសត្រូវត្រូវវិនាស រាស្ត្ររបស់ទ្រង់បានសរសើរដល់ទ្រង់ពីព្រោះរាស្ត្ររបស់ទ្រង់បានទទួលចិត្តដែលមានសេចក្ដីគោរពកោតខ្លាចនិងអរព្រះគុណ។ (និក្ខមនំ14: -15: Refer)

### 10. ក្រុមជំនុំនាវាលរហោស្ថានបានត្រឡប់មក (នេហេមា 7:5-73)

- នៅក្នុងបញ្ជីឈ្មោះដែលត្រូវបានត្រឡប់ តើយើងរៀនអ្វីខ្លះ? ទីមួយ កិច្ចការរបស់ព្រះអម្ចាស់ត្រូវបានចាប់ផ្ដើមដោយព្រះវិញ្ញាណបរិសុទ្ធ (5)។ យើងឃើញថាព្រះអម្ចាស់ផ្ទាល់បាន

សំរេចនូវការពាក្យទំនាយរបស់ទ្រង់តាមរយៈយេរេមាដែលធ្វើការនៅក្នុងពេលមានបញ្ហាលំបាក។កិច្ចការរបស់ព្រះអម្ចាស់បានចាប់ផ្តើមឡើងដោយដានរបស់ព្រះវិញ្ញាណបរិសុទ្ធទាំងស្រុង ហើយជាចេស្តារបស់ព្រះវិញ្ញាណ (ភីលីព 1:7)។ ទីពីរ សរុបមនុស្សចំនួន 42360 នាក់ត្រូវបានរាប់ទៅតាមពូជពង្ស ដោយមិនមានឋានៈខ្ពស់ឬទាប។ បើទោះជាអំណោយមួយចំនួនបង្ហាញមកក្តី ក៏ចំនុចនៃការរួបរួមបង្ហាញពីរូបរាងនៃក្រុមជំនុំពិត។ ពួកគេជាក្រុមជំនុំនៅក្នុងសញ្ញាចាស់។ ក្រុមជំនុំគួរតែលូតលាស់ឡើងដូចជាការប្រជុំរបស់ព្រះ នៅក្នុងមជ្ឈដ្ឋាននៃការតាំងសញ្ញារបស់ព្រះ ដោយការជឿនិងស្គាល់ការរីករាយនឹងសេចក្តីសុចរិត សេចក្តីសុខសាន្ត និងអំណរនៃនគរ ពីព្រោះវាជាបំណងព្រះហឫទ័យរបស់ព្រះ។ (អេភេសូ 4:13)

## 11. ការចាប់ផ្តើមនៃការលូតកើតជាថ្មី (នេហេមា 8:1-8)

- អត្ថបទដែលបង្ហាញសភាពនៃការកើតជាថ្មីយ៉ាងអស្ចារ្យនៅលើដីនៅខាងមុខខ្លោងទ្វារទឹកបង្រៀនមេរៀនពីការកើតជាថ្មីតាមព្រះគម្ពីរ។ តើវាជាអ្វី? ទីមួយ ពួកគេបានរៀបចំការអធិស្ឋាន។ ដួងចិត្តដែលមនុស្សមកប្រជុំគ្នាហើយចង់ស្តាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះជាកិច្ចការរបស់ព្រះ (1)។ នេះជាអំណោយរបស់ពួកបរិសុទ្ធដែលពួកគេបានអធិស្ឋានទៅកាន់ព្រះអម្ចាស់នៅក្នុងទីសំងាត់ដោយស្មោះត្រង់។ ទីពីរ នៅពេលដែលពួកគេស្តាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះ ការកើតឡើងជាថ្មីបានកើតឡើង (3)។ ពួកគេស្តាប់ទៅកាន់សំលេងអានក្រឹត្យវិន័យចាប់ពីពេលព្រលឹមរហូតដល់ល្ងាយ បន្ទាប់មកពួកគេលន់តួបាបរបស់ពួកគេ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់ផ្ទាល់មានចេស្តា ពីព្រោះព្រះវិញ្ញាណធ្វើការតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលគឺជាដាវរបស់ព្រះវិញ្ញាណបរិសុទ្ធ (អេភេសូ 6:17)។ ទីបី នៅពេលដែលពួកគេបង្រៀនព្រះបន្ទូលរបស់ព្រះដោយលំអិតទៅកាន់ប្រជារាស្ត្រ មានការនោះកើតឡើង (8-9)។ ជាមួយនឹងការលន់តួបាបរបស់ហ្វូងមនុស្ស ពួកសង្ឃដែលបានរៀនព្រះបន្ទូលរបស់ព្រះដោយអែសរ៉ា ជាបែបបទនៃការបង្វឹកបង្រៀនសិស្ស បានបកប្រែព្រះបន្ទូលនោះទៅកាន់ប្រជារាស្ត្រ ហើយធ្វើឲ្យគេបានដឹងនឹងប្រាប់ដល់អ្នកផ្សេងទៀត (7)។ ភ្លើងនៃព្រះវិញ្ញាណបរិសុទ្ធធ្វើការដូចជាដុំថ្មដែលត្រូវបានទង្គិចគ្នាទៅវិញទៅមក។ យើងគួរតែព្យាយាមថ្វាយខ្លួនរបស់យើងក្នុងការបង្កើតសិស្ស។ (ម៉ាថាយ 28:19-20 ២ធីម៉ូថេ 2:2)

### 12. ភស្តុតាងនៃការកើតជាថ្មី (នេហេមា 8:9-18)

- តាមលំនាំប្រវត្តិសាស្រ្តនៃការកើតជាថ្មីដ៏ពិតនោះដើរតាមខ្សែតែមួយ។ នៅក្នុងចំនុចណាដែលដូចការកើតជាថ្មីនៅក្នុងក្រុមជំនុំដើម? ទីមួយ គាត់មានចិត្តក្នុងការស្គាល់ព្រះបន្ទូលរបស់ព្រះអម្ចាស់ជាក់លាក់ (12-13)។ ដូចជាការកើតជាថ្មីរបស់ក្រុមជំនុំដើមដូចជា ការទទួលការបង្រៀនរបស់ពួកសាវ័ក ការភ្ជាប់ខ្លួនរបស់ពួកគេនៅក្នុងការអធិស្ឋាន និងការប្រកបគ្នាការទទួលព្រះបន្ទូលរបស់ព្រះជាបន្ត នោះជាភស្តុតាងនៃការកើតជាថ្មី (កិច្ចការ 2:42-47)។ ហើយពួកគេប្រថ្នាចង់ស្គាល់ព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ទីពីរ សកម្មភាពដែលព្យាយាមឲ្យបានស្មោះត្រង់ទៅកាន់ព្រះបន្ទូលរបស់ព្រះអម្ចាស់ (14-18)។ ហើយការបង្កើតត្រសាលបង្ហាញដើម្បីនឹងដើរតាមការបង្គាប់របស់ព្រះអម្ចាស់។ ពិធីនៃការបង្កើតត្រសាលបញ្ជាក់ពីរូបភាពស្មោះត្រង់របស់ពួកគេទៅកាន់ព្រះបន្ទូលរបស់ទ្រង់។ ការកើតជាថ្មីត្រូវបានបង្ហាញដោយបំណងចិត្តដែលស្មោះត្រង់ដែលបានរស់នៅទៅតាមព្រះគម្ពីរ។ ទីបី ហ្វូងមនុស្សដែលបរិសុទ្ធត្រូវបានលេចមក។ ការប្រមូលផ្តុំគ្នាជាភស្តុតាងនៃការកើតជាថ្មី ពីព្រោះពួកគេបានស្គាល់ថាព្រះអម្ចាស់ទ្រង់ល្អ ព្រះបន្ទូលរបស់ទ្រង់មានតម្លៃ។ ការកើតជាថ្មីគួរតែកើតចេញពីចិត្តរបស់ខ្ញុំ។

### 13. ដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ (នេហេមា 9:1-22)

- ការកើតជាថ្មីបានកើតឡើងដោយការជួបជុំតម ការហាមប្រាមជាមួយនឹងទំនាក់ទំនង និងការថ្វាយបង្គំព្រះអម្ចាស់។ ជាពិសេសការឆ្លើយតបពីរបានកើតឡើង។ ទីមួយ ការអធិស្ឋានដោយយំត្រូវបាននាំយកមក (4)។ ការអធិស្ឋានដែលសង្ឃ៨នាក់ អ្នកដឹកនាំរបស់ប្រជារាស្រ្តបានក្រោកឡើងនៅលើអាសនាហើយស្រែក នោះបានចេញមកទីការដឹកនាំខាងវិញ្ញាណពីព្រោះកិច្ចការរបស់ព្រះអម្ចាស់ត្រូវបានចាប់ផ្តើមជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ និងសំរេចដោយព្រះវិញ្ញាណ។ ព្រះវិញ្ញាណដែលធ្វើការនៅក្នុងការបង្កបង្កើត (លោកុប្បត្តិ 1:3)។ បានធ្វើការដូចគ្នានៅក្នុងការបង្កើតជាថ្មី (កិច្ចការ 2:17-21)។ ទីពីរ ការចងចាំពីអតីតកាលពួកគេបានសរសើរដំកើងដល់ព្រះអម្ចាស់ (5)។ នៅក្នុងគ្រាដើម ព្រះអម្ចាស់ដែលបានយាងចុះនៅ

ក្នុងលើភ្នំស៊ីណៃបានដឹកនាំអ៊ីស្រាអែលក្នុងជីវិតនៅវាលរហោស្ថានដោយព្រះវិញ្ញាណ (13)។ តាមរយៈព្រះវិញ្ញាណល្អនៅក្នុងខ 20 ពួកគេត្រូវបានការពារដោយការទទួលគ្រប់សេចក្តីត្រូវការដោយព្រះវិញ្ញាណ។ ក្រោយមកប៉ុលបានពន្យល់ថាព្រះគ្រីស្ទបានដើរជាមួយពួកអ៊ីស្រាអែលនៅវាលរហោស្ថាន ( ២កូរិនថូស 10:1-4)។ ហើយនៅតាមផ្លូវដែលពួកគេត្រឡប់ពីបាប៊ីឡូន ព្រះត្រៃឯកបាននៅជាមួយពួកគេ ការដឹកនាំរបស់ទ្រង់មកតាមយើងជានិច្ចនៅក្នុងព្រះគ្រីស្ទ។ យើងគួរតែទទួលស្គាល់ការដឹងនាំរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។

### 14. ព្រះដែលស្មោះត្រង់ (នេហេមា 9:23-37)

- តើព្រះបានដឹកនាំអ៊ីស្រាអែលយ៉ាងណា នៅពេលក្រុមជំនុំនាវាលរហោស្ថានបានដឹកនាំពួកគេនៅក្នុងការគៀបសង្កត់របស់បាប៊ីឡូន? ទីមួយ ព្រះអម្ចាស់បានដឹកនាំពួកគេដោយការរក្សាការតាំងសញ្ញាយ៉ាងស្មោះត្រង់ (32)។ ព្រះដែលស្មោះត្រង់បានដឹកនាំពួកគេទៅតាមការតាំងសញ្ញា។ ពេលខ្លះដោយការអស្ចារ្យ (21), ពេលខ្លះដោយការរងទុក្ខលំបាក (29-30) ដើម្បីរៀនពីការស្តាប់បង្គាប់របស់រាស្ត្ររបស់ព្រះអម្ចាស់។ ទីពីរ វាត្រូវបានបង្ហាញដោយការរក្សាសេចក្តីស្រឡាញ់យ៉ាងស្មោះត្រង់។ ព្រះអម្ចាស់បានដឹកនាំពួកគេជាមួយសេចក្តីស្រឡាញ់និងសេចក្តីពិត។ ជំនួសដែលពួកគេទទួលព្រះគុណអស្ចារ្យ ព្រះអម្ចាស់បានបង្ហាញសេចក្តីស្រឡាញ់ទ្រង់ទៅកាន់ពួកគេ ដែលជាមនុស្សមានអាកប្បកិរិយាប្រែប្រួលជាច្រើនបែបច្រើនយ៉ាង។ ជាចុងក្រោយព្រះអម្ចាស់បានផ្តល់ព្រះរាជ្យបុត្រាទ្រង់តែមួយទៅកាន់ពួកគេ ហើយធ្វើឲ្យពួកគេបានក្លាយជាកូនក្រមុំដែលស្រឡាញ់តែព្រះអម្ចាស់តែមួយប៉ុណ្ណោះ (ហូសេ 14:8)។ ព្រះអម្ចាស់នៅក្នុងព្រះគ្រីស្ទដឹកនាំពួកយើងដោយសេចក្តីស្រឡាញ់និងសេចក្តីពិតរបស់ទ្រង់។

### 15. ការស្តារឡើងវិញនូវការតាំងសញ្ញា (នេហេមា10:1-39)

– តើអត្ថបទបង្រៀនអ្វី ពីឈ្មោះទាំងនោះដែលបានបោះត្រាដោយការតាំងសញ្ញាត្រូវបានសរសេរចុះ ហើយពួកគេរក្សាទុកដើម្បីបង្រៀនដល់យើង? ទីមួយ យើងរៀនពីសារៈសំខាន់នៃការថ្វាយខ្លួនរបស់អ្នកដឹកនាំខាងវិញ្ញាណ (10-27)។ ពួកមេក្រុម សង្ឃ និងពួកលេវីនៅក្នុង

ទីកណ្តាលរបស់នេហេមា ត្រូវបានចុះហត្ថលេខានៅលើនោះ។ កិច្ចការរបស់ព្រះអម្ចាស់ត្រូវបានសំរេចដោយអ្នកដែលបានថ្វាយខ្លួន។ ជីវិតដែលថ្វាយទៅកាន់ព្រះអម្ចាស់ដោយអស់ពីចិត្តជាអ្នកដែលមានពរបំផុត (28-39)។ ទីពីរ អត្ថន័យនៃការតាំងសញ្ញាទីមួយ ជាលំដាប់លំដោយនៃការរៀបអាពាហ៍ពិពាហ៍ ដើម្បីរក្សាថ្ងៃសប្ប័ថ ការថ្វាយដង្វាយមួយភាគក្នុងដប់ជាដើមត្រូវបានពង្រឹងម្តងទៀត (28-39)។ វិធីសាស្ត្រដែលរក្សាបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ មិនមែនជាការបន្ថែមការថ្មីមួយចំនួន ហើយមិនអើពើនឹងសេចក្តីសន្យាទីមួយនិងរក្សាដោយស្មោះត្រង់នោះឡើយ។ បញ្ហាដែលក្រុមជំនុំអេភេសូត្រូវបានទទួលការស្តីបន្ទោស គួរតែបានអនុវត្តនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ (វិវរណៈ 2:5)។ យើងគួរតែរស់នៅដូចជាអ្នកដែលត្រូវបានថ្វាយខ្លួនទៅក្នុងការតាំងសញ្ញានៃសេចក្តីស្រឡាញ់ដើម។

## 16. ទំនួលខុសត្រូវនៃអ្នកដែលតាំងទីលំនៅ (នេហេមា 11:1-12:26)

- យើងរៀនការពីរយ៉ាងចេញពីអត្ថបទ ដែលកត់សម្គាល់បញ្ជីឈ្មោះនៃកន្លែងស្នាក់នៅថ្មីនៅយេរូសាឡិម ពួកសង្ឃ និងពួកលេវី។ ទីមួយ អ្នកដឹកនាំរបស់ហ្វូងមនុស្សបានធ្វើឲ្យពួកគេស្នាក់នៅ ដើម្បីនឹងផ្តល់ទំនួលខុសត្រូវរបស់អ្នកផ្សេងទៀត (11:20-22)។ ពីព្រោះដើម្បីនឹងទ្រទ្រង់នូវទំនាក់ទំនងដ៏ល្អត្រឹមត្រូវនោះជាជីវិតនៃក្រុមជំនុំ។ ទីពីរ ប្រជាជនដែលស្នាក់នៅទីក្រុងផ្សេងទៀតគួរតែបំរើ ថ្វាយដង្វាយ និងរស់នៅទៅតាមការបង្រៀនរបស់ពួកគេសំរាប់ប្រជាជនរបស់ក្រុងយេរូសាឡិម (12:1-26)។ នេះជារូបរាងដែលក្រុមជំនុំសញ្ញាចាស់បានទទួលព្រះគុណរបស់ព្រះអម្ចាស់ ហើយបានផ្តោតលើព្រះគុណនៃក្រុមជំនុំសញ្ញាថ្មី។ ក្រុមជំនុំនៅក្នុងព្រះគ្រីស្ទមានទំនួលខុសត្រូវរស់នៅក្នុងកណ្តាលរបស់ព្រះគ្រីស្ទ ហើយរីករាយនូវអភ័យឯកសិទ្ធិដែលរីករាយនឹងព្រះដ៏បរិបូរណ៍នៃសេចក្តីប្រោសលោះ។ ហើយតួនាទីប្រកាសដំណឹងល្អទៅកាន់លោកិយ។ យើងគួរតែបង្ហាញនូវផលផ្លែនៃការប្រកាសដំណឹងល្អ។

## 17. ដង្វាយដែលទទួលយក (នេហេមា 12:27-47)

- តើការថ្វាយនូវជញ្ជាំងទីក្រុងជាការកោតសរសើរដ៏ខ្លាំងក្លាដែលសំរេចដោយបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់មែនទេ? ទីមួយ វាជាចំណុចកណ្តាល (17-29 36-38)។ ទ្រង់បានធ្វើឲ្យ

ពួកគេធ្វើការថ្វាយបង្គំយ៉ាងធំនៅក្នុងប្រារពពិធីជាមួយការសរសើរដោយអំណរនិងការអរគុណ។ វាជាភស្តុតាងនៃការផ្សះផ្សាជាមួយនឹងព្រះអម្ចាស់។ ទីពីរ វាជាជីវិតដែលមានសេចក្ដីបរិសុទ្ធជាចំណុចកណ្ដាល (17)។ ទ្រង់បានផ្ដល់នូវរបស់ដែលចាំបាច់របស់ពួកគេដើម្បីនឹងផ្ដោតទៅលើសេចក្ដីបរិសុទ្ធដោយសមាជិកអ្នកសរសើរដំកើង អ្នកយាមទ្វារនិងសង្ឃ និងពួកលេវីនៅក្នុងជីវិតប្រចាំថ្ងៃ។ ដូច្នេះពួកគេរក្សាជីវិតដែលមានសេចក្ដីបរិសុទ្ធជាកណ្ដាល។ នៅពេលដែលយើងផ្ដោតលើសេចក្ដីបរិសុទ្ធនិងសេចក្ដីសុខសាន្ត ព្រះអម្ចាស់នឹងទទួលយក។ យើងគួរតែដើរទៅតាមរបៀបដែលមិនមែនជារូបរាងខាងក្រៅ ប៉ុន្តែជាជីវិតដែលនៅខាងក្នុងនៅចំពោះព្រះអម្ចាស់ដែលយើងមើលមិនឃើញ (19:14)។ យើងគួរតែថ្វាយខ្លួនយើងនៅក្នុងការស្វែងរកសេចក្ដីសុខសាន្តនិងសេចក្ដីបរិសុទ្ធ។ (ហេព្រើរ 12:14)

**18. អ្នកដឹកនាំបង្កើតសេចក្ដីសុចរិត (នេហេមា13:1-14)**

- បន្ទាប់ពីការប្រារព្ធការថ្វាយបង្គំបញ្ចប់ ដង្វាយដើម្បីនឹងបង្កើតនូវសេចក្ដីសុចរិតត្រូវបានដំណើរការជាបន្ត។ តើគំរូដ៏ស្មោះត្រង់របស់នេហេមាបង្ហាញមកដោយរបៀបណា? ទីមួយពួកគេបានកាន់ខ្ជាប់នឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ ទុកជាគំរូនៃសេចក្ដីសុចរិត (1-3)។ គាត់បានអនុវត្តតាមគំរូនៃក្រឹត្យវិន័យរបស់ម៉ូសេដោយផ្ទាល់ទៅកាន់បញ្ហាដែលកើតមាននាពេលនោះ។ ពួកគេបានហាមប្រាមនូវរបៀបរបស់អាម៉ូន ម៉ូអាប់ និងបាឡាម ហើយដើរតាមយ៉ាងពិតប្រាកដនូវបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់។ អ្នកដែលស្រេកសេចក្ដីសុចរិតនឹងមានពរ។ ទីពីរ គាត់បានបង្កើតនូវសេចក្ដីសុចរិតយ៉ាងរឹងមាំ(17)។ នៅពេលដែលនេហេមាមិនបានចូលទៅកន្លែងនោះ គាត់មិនបានបដិសេធនូវកិច្ចការដែលបានកើតឡើងឡើយ។ គាត់បានកាត់ទោសវាដោយច្បាប់នៃសេចក្ដីសុចរិត។ គាត់បានបង្កើតសេចក្ដីសុចរិតជាផ្លូវការ ដោយការកាត់ចេញនូវអភ័យឯកសិទ្ធិនៃទំនាក់ទំនងជាសាច់ញាតិ ដែលអេលីស៊ីបផ្ដល់បន្ទប់មួយនៅក្នុងព្រះវិហារដល់ថូបៀ។ វាមិនអាចទៅរួចទេបើគ្មានការស្វែងរកព្រះអម្ចាស់និងនគររបស់ទ្រង់ជាទីមួយ (Mt 6:33)។ យើងគួរតែស្វែងរកសេចក្ដីសុចរិតនិងនគររបស់ទ្រង់ដូចជាអ្នកសុចរិតវិញ។

### 19. ការផ្លាស់ប្រែពិតប្រាកដ (នេហេមា13:15-31)

- តើអ្វីទៅជាឧទាហរណ៍ដែលអត្ថបទបង្ហាញថាព្រះអម្ចាស់បង្កើតសេចក្ដីសុចរិតរបស់ទ្រង់នៅក្នុងការមួយចំនួននៅក្នុងយើង? ទីមួយ នៅក្នុងថ្ងៃសប្ប័ទ កិច្ចការផ្ទាល់ខ្លួនត្រូវបានហាមឃាត់នៅក្នុងចំណោមមនុស្ស ព្រះអម្ចាស់ហាមមិនឲ្យ ពួកគេប្រមូលផលនៅក្នុងថ្ងៃសប្ប័ទនិងដឹកជញ្ជូនបន្ទុកណាឡើយ ដើម្បីនឹងគ្របបាំងសេចក្ដីក្រោធរបស់ព្រះអម្ចាស់ (15-18)។ ទ្រង់ចង់ឲ្យពួកគេស្ដាប់តាមការបង្គាប់នៃការបង្កបង្កើតដោយការថ្វាយបង្គំព្រះអម្ចាស់ ដើម្បីនឹងបានសំរាកខាងព្រលឹង។ ទីពីរ ការរៀបអាពាហ៍ពិពាហ៍របស់អ្នកដែលមិនជឿត្រូវបានហាមឃាត់ (23-28)។ នៅពេលដែលនេហេមាបានឃើញសូម្បីតែសង្ឃបានប្រគល់កូនស្រីរបស់ខ្លួនទៅសាន់បារាត់ គាត់បានដកដំណែងរបស់គាត់ក្នុងការរក្សាអ៊ីស្រាអែលឲ្យបានបរិសុទ្ធ។ ទីបី ពួកគេត្រូវបានបង្រៀនដោយការរក្សាជីវិតជាដង្វាយយ៉ាងស្មោះត្រង់ (13)។ ការផ្លាស់ប្រែពិតប្រាកដមិនបញ្ចប់ដោយកិច្ចការអវិជ្ជមាននោះទេ តែដោយការវិជ្ជមានវិញ។

## 3. អេសធើរ

### សេចក្ដីណែនាំ៖

រហូតមកដល់ពេលនេះយើងបានរំលឹកពីរបៀបនៃការស្ដារឡើងវិញនៃរូបផ្លុះរបស់ព្រះ ដែលត្រូវបានបង្ហាញតាមរយៈសកម្មភាពនៃភាពជាស្ដេច ជាសង្ឃ និងជាហោរានៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលក្នុងចំណោមកណ្ឌគម្ពីរប្រវត្តិសាស្ត្រនៃសញ្ញាចាស់មួយចំនួន។ នៅពេលនេះយើងសង្កេតពីរបៀបដែលព្រះអម្ចាស់ធ្វើការនៅក្នុងតំបន់របស់សាសន៍ដទៃ នៅពេលដែលអ៊ីស្រាអែលត្រូវបានចាប់ខ្លួនទៅរស់នៅទឹកដីនោះតាមរយៈកណ្ឌគម្ពីរអេសធើរ។ កណ្ឌគម្ពីរនេះជាប្រភេទនៃការបើកសំដែងបែបរូបភាព ដែលប្រវត្តិនៃការប្រោសលោះរបស់និក្ខមនំត្រូវបានកើតឡើងម្ដងទៀត នៅក្នុងការកម្រិតទុករបស់ព្រះអម្ចាស់។ ដូចជាអ្វីដែលព្រះអម្ចាស់បានសាបព្រោះគ្រាប់ពូជនៃសេចក្ដីប្រោសលោះនៅក្នុងការគៀបសង្កត់របស់អេស៊ីពអស់រយៈពេល 430ឆ្នាំ ហើយបានរក្សានូវត្រួយលាស់ថ្មី ហើយជាចុងក្រោយទ្រង់បានប្រទាននូវទឹកដីសន្យា ជាទឹកដីកាណានទៅដល់ពួកគេ នៅបាប៊ីឡូនរបៀបដែលព្រះអម្ចាស់

បានធ្វើការនៅក្នុងពួកគេ ដើម្បីនឹងបង្ហាញពីការគ្រងរាជ្យរបស់ព្រះនៅលើទឹកដីនោះ ដែលជាសេចក្ដីសុចរិត សេចក្ដីមេត្តា និងភាពស្មោះត្រង់តាមរយៈកណ្ឌគម្ពីរនោះ។ យើងរៀបចំការនោះតាមលំដាប់លំដោយរបស់ព្រះគម្ពីរ និងធ្វើការពិសោធនូវធាតុនៅក្នុងទស្សនៈនៃការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

**1. ភាពជាស្ដេចនៃគ្រប់ជាតិសាសន៍ទាំងអស់** (អេសធើរ 1:1-32)

គំនិតសំខាន់របស់អេសធើរគឺ ដើម្បីនឹងបង្ហាញថាព្រះអម្ចាស់ជាស្ដេចនៅក្នុងផ្ទៃករបស់អ្នកមិនជឿ និងអ៊ីស្រាអែលជារាស្ត្ររបស់ទ្រង់។ តើអត្ថបទបង្ហាញអ្វីខ្លះមកយើង? ទីមួយ ភាពជាស្ដេចនឹងត្រូវបានបន្តនៅក្នុងគ្រប់ជាតិសាសន៍លើកលែងតែអ៊ីស្រាអែល។ ពិភពលោកនេះដែលដំណឹងល្អបានមក ត្រូវបានគ្រប់គ្រងលើដោយភាពជាស្ដេចរបស់ព្រះគ្រីស្ទ។ ភាពជាស្ដេចរបស់អាហាស៊ូរូសបង្ហាញពីភាពជាស្ដេចរបស់ព្រះគ្រីស្ទដោយប្រយោល។ ភាពជាស្ដេចដែលជាការបើកសំដែងជារូបភាពរបស់ព្រះគ្រីស្ទ ចង្អុលទៅកាន់ភាពជាស្ដេចរបស់ព្រះគ្រីស្ទទាំងស្រុង ដែលទ្រង់ជាស្ដេចរបស់យូដា ជាស្ដេចលើអស់ទាំងស្ដេច និងជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ដែលគ្មានអ្នកណាអាចបំផ្លាញទ្រង់បានឡើយ។ ទីពីរ ភាពឆ្មើងឆ្មៃរបស់ព្រះនាងវ៉ាស់ធី និងសេចក្ដីកំហឹងរបស់ស្ដេចអ័ហាស៊ូរូស បង្ហាញពីរូបភាពដែលបានបាត់បង់នូវឱកាសល្អ។ នៅក្នុងចំណោមការនោះ ព្រះអម្ចាស់បានបង្កើតបំណងព្រះហឫទ័យរបស់ទ្រង់ ពីព្រោះទ្រង់ជាព្រះនៃប្រាជ្ញា។ ប៉ុន្តែការខុសឆ្គងគួរតែត្រូវបានកាត់ទោស។ យើងដែលត្រូវបានត្រាស់ហៅមកដោយព្រះអម្ចាស់ដើម្បីក្លាយជាស្ដេចនៅក្នុងព្រះគ្រីស្ទ នោះយើងអាចបង្ហាញពីភាពជាស្ដេចរបស់ទ្រង់ទៅកាន់ពិភពលោកគ្រប់ពេលវេលាគ្រប់ទីកន្លែង។

**2.ព្រះហស្តនៃសព្វញ្ញាណ(អេសធើរ**2:1-18)

កណ្ឌគម្ពីរអេសធើរមិនមានពាក្យ ព្រះអម្ចាស់ឬព្រះយេហូវ៉ាឡើយ បង្ហាញយ៉ាងខ្លាំងក្លាពីព្រះហស្តដែលសំងាត់នៃការគ្រប់គ្រងរបស់ព្រះអម្ចាស់។ ទីមួយ ព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងវាំងនោះជាព្រះហស្តរបស់ព្រះអម្ចាស់។ពិធីជប់លៀងយ៉ាងធំរបស់អ្នកដឹកនាំម្នាក់ព្រឹត្តិការណ៍ដែលម្ចាស់ក្សត្រីត្រូវបានដកចេញពីតំណែងរបស់ខ្លួន នោះជាព្រះហស្តរបស់ព្រះ

ជាម្ចាស់។ នេះជាប្រាជ្ញារបស់ព្រះអម្ចាស់។ បើទោះជាយើងបានជួបប្រទះនឹងការដែលធ្វើឲ្យមានការបាក់ទឹកចិត្ត ក៏ព្រះហស្តដ៏អាថ៌កំបាំងរបស់ព្រះអម្ចាស់នៅតែរៀបចំជានិច្ច (សាស្តា 7:14)។ ទីពីរ ព្រះហស្តដែលមានចេស្តាលើអស់ទាំងការអស្ចារ្យ។ មនុស្សដែលនៅក្នុងព្រឹត្តិការណ៍ដែលបានកើតឡើងត្រូវបានហ៊ុំព័ទ្ធដោយព្រឹត្តិការណ៍នោះ នឹងត្រូវបានទទួលការលួងលោមចេញពីព្រះអម្ចាស់។ នៅពេលដែលយើងខិតចូលជិតព្រះជាម្ចាស់ ហើយកាន់ព្រះហស្តរបស់ទ្រង់ដោយសេចក្តីជំនឿ នោះយើងនឹងឃើញការដ៏អស្ចារ្យ ដែលយើងមិនអាចមើលឃើញពីមុនមកនៅក្នុងជីវិតរបស់យើង (យេរេមា 33:3)។

**3.សេចក្តីជំនឿរបស់ម៉ រឌីកាយ (អេសធើរ2:16-3:6)**

នៅក្នុងជីវៈប្រវត្តិតាមរយៈអេសធើរ ភាពជាស្តេចរបស់ព្រះអម្ចាស់ត្រូវបានបង្ហាញមក ម៉ រឌីកាយបានធ្វើការ។ តើអត្ថបទបង្ហាញសេចក្តីជំនឿរបស់គាត់ជាអ្វី? ទីមួយ ភាពស្មោះត្រង់ទៅកាន់ព្រះអម្ចាស់ឆ្លុះបញ្ចាំងភាពស្មោះត្រង់ទៅកាន់មនុស្ស។ សេចក្តីស្មោះត្រង់ទៅកាន់ស្តេចអ័ហាស្វូរុសមានន័យថាជាម្នាក់ទៅកាន់ព្រះអម្ចាស់។ ជីវិតរបស់អ្នកជឿ គួរតែដើរតាមព្រះបន្ទូលរបស់ព្រះអម្ចាស់។ ព្រះអម្ចាស់ធ្វើការតាមរយៈអ្នកដែលធ្វើតាមព្រះបន្ទូលរបស់ទ្រង់។ ទីពីរ គាត់មានសេចក្តីជំនឿដែលស្មោះត្រង់ដោយមិនថ្វាយបង្គំនៅចំពោះហាម៉ាន់។ វាចង្អុលទៅកាន់អាកប្បកិរិយារបស់ម៉ឌីកាយដែលមិនបានលត់ជង្គង់ចុះនៅចំពោះហាម៉ាន់ បញ្ជាក់ពីសេចក្តីជំនឿរបស់យើងទៅកាន់ព្រះអម្ចាស់។ គាត់បានមើលឃើញពីអាកប្បកិរិយាដែលមិនកោតខ្លាចដល់ព្រះនៅក្នុងមនុស្សទាស់នឹងសេចក្តីកោតខ្លាចដល់ព្រះ។ វាដូចជាសេចក្តីជំនឿរបស់ដានីយ៉ែល (ដានីយ៉ែល 1:7)។ ព្រះអម្ចាស់របស់យើងបានតាំងព្រះហឫទ័យរបស់ទ្រង់ហើយទតមកលើសភាពដើររបស់យើង ហើយយំស្រែកទៅកាន់ព្រះអម្ចាស់ ហើយស្តាប់ទៅកាន់ការអង្វរលន់តួ។

**4.ឧបករណ៍របស់អារក្ស(អេសធើរ**3:7-15)

តើនៅត្រង់ចំណុចណាដែលមនុស្សជារូបតំណាងរបស់អារក្ស? ទីមួយ គាត់សង្កេតឃើញថាមនុស្សព្យាយាមបំផ្លាញគ្រប់មនុស្សទាំងអស់ដោយហេតុផលផ្ទាល់ខ្លួន។ ពួកយូដាជារាស្ត្រ

របស់ព្រះអម្ចាស់ ហើយជាពួកជំនុំសញ្ញាចាស់។ បើទោះជាអារក្សព្យាយាមបំផ្លាញក្រុមជំនុំជាមួយគ្រប់ច្រកល្ហក គ្រប់ចេស្តានៃស្ថាននរគមិនអាចបំផ្លាញនាងបានឡើយ។ ទីពីរ ពីព្រោះគាត់បានបះបោរនូវសេចក្ដីជំនឿនៃការកោតខ្លាចដល់ព្រះយេហូវ៉ា។សាតាំងដែលជាអ្នកស្គាល់នូវអាកប្បកិរិយាពិសេសរបស់ម័ឌីកៃដែលចេញមកពីការកោតខ្លាចដល់ព្រះអម្ចាស់ វាបានព្យាយាមសម្លាប់ម័ដឺកៃទាស់នឹងការស្គាល់ព្រះអម្ចាស់។ សាតាំងលផ្ដោតលើការបង្កើតនៅងរបស់សាតាំង។ ទីបី គាត់ប្រើចេស្ដាទាំងស្រុងដើម្បីនឹងសំរេចគោលបំណង។ មនុស្សបានថ្វាយអំណោយមួយចំនួនទៅកាន់ស្ដេច ហើយបានទទួលការអនុញ្ញាតរបស់ទ្រង់ដើម្បីនឹងសម្លាប់ពួកអ៊ីស្រាអែលទាំងអស់។គេបានរៀបគម្រោងយុទ្ធសាស្ត្រយ៉ាងលម្អិតដើម្បីសម្លាប់ពួកគេជាមួយនឹងវិធីដែលមិនស្របច្បាប់។ យើងគួរតែប្រយត្នទៅកាន់ការវាយប្រហាររបស់សាតាំង។

**5.សតិសម្បជញ្ញៈនៃបេសកកម្ម(អេសធើរ**4:1-16)

កណ្ឌគម្ពីរអេសធើរបង្ហាញនៅក្នុងចំណោមពួកសាសន៍ដទៃមានតែព្រះទេដែលជាស្ដេច។ នៅក្នុងចំណោមការទាំងនោះ សេចក្ដីក្រោធរបស់ស្ដេច ដែលបានដកជំណែងរបស់ម្ចាស់ក្សត្រីចោល ដោយជំនួសដោយព្រះនាងអេសធើរវិញ សេចក្ដីជំនឿដែលកោតខ្លាចទៅកាន់ព្រះយេហូវ៉ា និងការសម្លាប់នូវមហន្តរាយមកលើពួកយូដា ព្រះអម្ចាស់បានគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់។ ជាពិសេសសេចក្ដីជំនឿរបស់ម័ឌីកៃនៅក្នុងកណ្ឌគម្ពីរអេសធើរ 4:4 ដែលត្រូវបានបង្ហាញដោយការត្រាស់ហៅដោយសតិសម្បជញ្ញៈជាមួយភាពស្មោះត្រង់យ៉ាងពេញលេញ។ ទីមួយ គាត់មានការធានាអះអាងដែលព្រះអម្ចាស់នឹងសង្គ្រោះរាស្ត្ររបស់ទ្រង់ជាប្រាកដចេញពីទុក្ខលំបាក។ សេចក្ដីជំនឿដែលគិតថាប្រហែលជាអេសធើរអាចជាមិនជួយនូវហេតុការណ៍នោះ ក៏ព្រះអម្ចាស់អាចត្រាស់ហៅអ្នកផ្សេងដោយវិធីសាស្ត្រផ្សេងទៀត នោះហើយជាសេចក្ដីជំនឿពិត។ ហេតុផលដែលព្រះអម្ចាស់ផ្ដល់នូវស្ថានភាពដែលខ្លាំងក្លាមក នោះគឺព្រះអម្ចាស់ធ្វើឲ្យពួកគេពឹងផ្អែកលើទ្រង់តែមួយទាំងស្រុង (២កូរិនថូស 1:9)។ ទីពីរ គាត់មានការធានាអះអាងដែលថាជំណែងរបស់ម្ចាស់ក្សត្រីនោះចេញមកពីព្រះអម្ចាស់ដើម្បីនឹងសំរេចបំណងប្រាថ្នារបស់ទ្រង់។ នាងជាអ្នកបំរើដែលបំរើដល់លក្ខខណ្ឌដែលល្អពិតជាក់ស្ដែង ដូចជាបណ្ដា

ញដើម្បីនឹងបំរើព្រះអម្ចាស់អោយបានត្រឹមត្រូវ។ឱកាសដែលថ្វាយខ្លួនរបស់គាត់ទៅព្រះអម្ចាស់ជាព្រះពរលើអស់ទាំងព្រះពរ។យើងគួរតែថ្វាយខ្លួនរបស់យើងទៅកាន់ព្រះដើម្បីនឹងបង្កើតសេចក្តីសុចរិត។

**6.ការផ្លាស់ប្តូរនៃការអធិស្ឋាន(អេសធើរ5:1-14)**

តើការផ្លាស់ប្តូរអ្វីដែលការអធិស្ឋានរបស់អេសធើរបាននាំមក? ទីមួយ នាងផ្ទាល់ត្រូវបានផ្លាស់ប្តូរ។ គាត់មានសេចក្តីក្លាហានក្នុងការទៅកាន់ស្តេចបន្ទាប់ពីការតមអាហារអស់បីថ្ងៃ។ ប្រៀបដូចជាពេលដែលម៉ូសេប្រឈមនឹងព្រះភក្ត្ររបស់ព្រះជាម្ចាស់ មុខរបស់គាត់ត្រូវបានចែងចាំងដោយព្រះវត្តមានរបស់ព្រះអម្ចាស់នៅក្នុងព្រលឹងរបស់គាត់ (និក្ខមនំ 34:29-35)។ ហើយទីពីរ វាជាការផ្លាស់ប្តូររបស់ស្តេច។ ស្តេចដែលមិនដែលត្រាស់ហៅនាងសោះ បានដោះចញ្ចៀនរបស់ទ្រង់នៅចំពោះនាង ពីព្រោះទ្រង់បានចាញ់មន្តស្នេហ៍របស់នាងដោយសម្រស់ខាងវិញ្ញាណរបស់នាង។ ប្រៀបដូចជាអេសាវបានឃើញយ៉ាកុបអធិស្ឋាននៅពេនីអែល ការគុំគួនដ៏សាហាវរបស់គាត់ទៅកាន់យ៉ាកុបត្រូវបានរលាយបាត់ ហើយបានជួបគ្នា ការអធិស្ឋានធ្វើឲ្យសត្រូវត្រូវរលាយបាត់។ ទីបី ការផ្លាស់ប្តូរនូវស្ថានការណ៍។ សេចក្តីមេត្តារបស់ស្តេចបានសន្យានឹងផ្តល់រហូតដល់ទៅពាក់កណ្តាលប្រទេស ដែលត្រូវបានផ្តោតលើដំណោះស្រាយបញ្ហារបស់នាងអេសធើរ។ ការអធិស្ឋានធ្វើឲ្យគ្រប់ការទាំងអស់ប្តូរ ហើយក៏ជាមេសោដើម្បីនឹងនាំមកនូវគ្រប់ចេស្តាទាំងអស់។ ដោយការអធិស្ឋានជាសម្ងាត់ នោះទ្វារត្រូវបានបើកឡើង (ម៉ាថាយ 6:6)។ ពិតប្រាកដណាស់អ្នកដែលស្វែងរកនោះនឹងទទួលនូវការដ៏ល្អបំផុត ដែលជាព្រះវិញ្ញាណបរិសុទ្ធជាប្រភពនៃព្រះពរ(លូកា11:13)។

**7.ការអធិស្ឋានដោយជំនឿ**(**អេសធើរ**6:1-13)

តើស្ថានភាពអ្វីដែលការអធិស្ឋានរបស់ម៉ាឌីកៃនិងអេសធើរបានធ្វើនៅចំពោះកល់ល្បិចរបស់ហាម៉ាន់ដែលបានព្យាយាមសម្លាប់ពួកយូដាទាំងអស់នៅក្នុងថ្ងៃតែមួយ? ទីមួយ គាត់បានសំរេចនៅក្នុងការផ្លាស់ប្រែចិត្តរបស់អ្នកផ្សេងទៀត។ ការអធិស្ឋានដោយជំនឿដោះស្រាយការ

លំបាកជាច្រើនហើយសំរេចនូវកិច្ចការយ៉ាងធំថែមទៀត (យ៉ាកុប 5:16)។ ទីពីរ បន្ទាប់ពីការអធិស្ឋានគ្រប់ទាំងរបស់នៅជុំវិញត្រូវបានទេរទៅរកអេសធើរ។ ដោយសារការផ្ទុំមិនលក់របស់ទ្រង់ នោះស្តេចបានរលឹកពីកម្រងកំណត់ហេតុនៅក្នុងវាំង ហើយបានស្វែងរកកិច្ចការល្អរបស់ម៉ឌីកៃនៅក្នុងចំណោមកំណត់ហេតុជាច្រើន។ វាមិនមែនជាការចៃដន្យឡើយ ហើយព្រះអម្ចាស់ធ្វើការដោយសារការអធិស្ឋានរបស់គាត់។ កិច្ចការដែលហាម៉ាន់ ដែលបានទទួលការអនុញ្ញាតរបស់ស្តេច បានទទួលនូវកាតព្វកិច្ចយ៉ាងសំខាន់ដោយសារស្តេចជាព្រះហស្តរបស់ព្រះ។ ការដែលទ្រង់ត្រូវបានចូលរួមទៅកាន់កិច្ចការរបស់អេសធើរនោះជាការឆ្លើយតបទៅនឹងការអធិស្ឋាន។ ព្រឹត្តិការណ៍ដែលរហ័សបែបនេះត្រូវបានដឹកនាំដោយព្រះអម្ចាស់។ បើទោះជាពួកគេត្រូវបានជួបដោយចៃដន្យតែព្រះអម្ចាស់បានដាក់ពួកគេនៅក្នុងប្រភេទនៃការអធិស្ឋានរបស់ពួកបរិសុទ្ធ។ វាជាចេស្តានៃការអធិស្ឋាន។

**8.សេចក្តីស្លាប់ដើម្បីនឹងសម្លាប់សេចក្តីស្លាប់(អេសធើរ**6:14-7:10)

នៅពេលដែលយើងសញ្ជឹងគិតពីបណ្តាញនៃព្រឹត្តិការណ៍នៅក្នុងពន្លឺនៃដំណឹងល្អនៅក្នុងកណ្ឌគម្ពីរអេសធើរ យើងគិតពីការសុគតរបស់ព្រះគ្រីស្ទ។ ទីមួយ ការអាក្រក់របស់ហាម៉ាន់ ជាអារក្សដែលបានគ្រោងដើម្បីនឹងសម្លាប់រាស្ត្ររបស់ព្រះទាំងអស់។ ព្រឹត្តិការណ៍ដែលព្រះគ្រីស្ទត្រូវសុគតមួយដងសម្រាប់ទាំងអស់ជាដំណឹងល្អ (ហេព្រើរ 2:14)។ ទីពីរ បើទោះជាអារក្សធ្វើឲ្យគាត់ធ្លាក់ចុះទៅក្នុងសេចក្តីស្លាប់ខាងវិញ្ញាណក៏ដោយ ក៏ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើងបានសំរេចនូវការសង្គ្រោះយ៉ាងពេញលេញ។ ការសុគតរបស់ទ្រង់បានបំផ្លាញសេចក្តីស្លាប់ (រ៉ូម 5:8)។ នៅពេលដែលយើងមើលទៅកាន់ព្រះជាម្ចាស់ដោយសេចក្តីជំនឿ យើងអាចទទួលបានសេរីភាពដោយទទួលបានការដោះស្រាយចេញពីសេចក្តីកំសោយនិងជំងឺ អំពើបាប បណ្តាសា និងសេចក្តីស្លាប់ទាំងអស់ចេញ។ ដូច្នេះយើងអាចរស់នៅក្នុងការធានាអះអាងរបស់ប៉ូល ដែលព្រះអម្ចាស់ទ្រង់នឹងជាន់ក្បាលរបស់សាតាំងដោយជើងរបស់ទ្រង់ (រ៉ូម16:20)។

**9.ច្បាប់ថ្មីត្រូវបានប្រកាសមក (អេសធើរ**8:1-17)
បើទោះជាហាម៉ាន់បានស្លាប់ ច្បាប់របស់បាសាដែលសម្លាប់ពួកយូដានៅតែបន្ត។ បន្ទាប់មក អេសធើរមិនបានបញ្ឈប់សេចក្ដីស្លាប់របស់ហាម៉ាន់ឡើយហើយបានស្វែងរកដើម្បីនឹងបំផ្លាញច្បាប់វិញ ជាចុងក្រោយច្បាប់ថ្មីត្រូវបានប្រកាសមក ដែលថា ពួកយូដានឹងត្រូវបានលើកឡើងនៅក្នុងថ្ងៃនោះ។ កិច្ចការនៃការសង្គ្រោះរបស់ព្រះអម្ចាស់នឹងមិនត្រូវសម្លាប់សត្រូវដែលជាសាតាំងឡើយ មនុស្សចាស់ សេចក្ដីស្លាប់ បណ្ដាសានឹងត្រូវបានសម្លាប់ចោលដោយសារព្រះអម្ចាស់ (កាឡាទី 5:24)។ ព្រះអម្ចាស់បានលើកនូវការផ្លាស់ប្រែជាអស់កល្បមកដោយការដាំក្រឹត្យវិន័យរបស់ទ្រង់នៅក្នុងចិត្តរបស់ពួកគេដោយការបញ្ជូនព្រះវិញ្ញាណមក (យេរេមា 33:3)។ សេចក្ដីស្លាប់ ការរស់ពីស្លាប់ ការយាងឡើងទៅរបស់ព្រះគ្រីស្ទយេស៊ូវបានសំរេចនូវសេចក្ដីសង្គ្រោះរបស់យើងយ៉ាងពេញលេញ។ នៅពេលដែលពួកយូដាត្រូវបានលើកឡើង គ្រីស្ទានដែលកើតជាថ្មីនឹងត្រូវបានអង្គុយនៅបល្ល័ង្គដ៏ខ្ពស់បំផុតនៅពេលអនាគតដោយការរួបរួមជាមួយនឹងព្រះគ្រីស្ទ។

**10.ការប្រយុទ្ធដោយបរិសុទ្ធ(អេសធើរ**9:1-19)
អត្ថបទបង្ហាញថាសត្រូវបីរបស់យើងជា សាតាំង លោកិយនិងសាច់ឈាមយ៉ាងប្រាកដ។ ទីមួយ ការស្លាប់របស់ហាម៉ាន់ ជាសាតាំងដែលត្រូវបានបំផ្លាញដោយការសុគតរបស់ព្រះគ្រីស្ទ។ ដោយសារសេចក្ដីពិតនេះប៉ូលបានបង្រៀនថា យើងគួរតែរស់នៅក្នុងកណ្ដាលព្រះគ្រីស្ទនិងឈើឆ្កាងរបស់ទ្រង់ (១កូរិនថូស 1:23)។ ទីពីរ ពេលដែលកូនប្រុសៗរបស់គាត់ត្រូវបានសម្លាប់ លោកិយនិងសាច់ឈាមបានស្លាប់នៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទ។ ពេលនេះគ្រីស្ទានត្រូវបានសន្យានូវជ័យជម្នះលើអស់ទាំងជ័យជម្នះ និងមកុដលើអស់ទាំងមកុដ។ យើងគួរតែអះអាងថា យើងនឹងទទួលមកុដ ពីព្រោះយើងនឹងយកឈ្នះនូវការប្រយុទ្ធនេះនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវ។ ពិតណាស់ព្រះអម្ចាស់នឹងធ្វើឲ្យយើងរីករាយនូវជ័យជម្នះរបស់មួយអង្គដែលយាងនៅលើសេះសរ។ ប្រៀបដូចជាការមួយនេះដែរ បើទោះជាតាមការសូមរបស់ម៉ឌីកៃថា ត្រូវឲ្យសត្រូវទាំងអស់ស្លាប់ប៉ុន្តែគ្មាននរណាម្នាក់អាចប៉ះពាល់ទ្រព្យសម្បត្តិរបស់ពួកគេបានឡើយ។ ប្រសិនបើគ្រីស្ទានមិនថែរក្សានូវជ័យជម្នះរបស់ពួកគេ ពួកគេអាចចាកចេញពី

ព្រះគ្រីស្ទ ដោយសារកិត្តិយសនិងសេចក្ដីលោភដូចជាអាណានា សាហ្វីរ៉ា អាកាន ហ្កេហាស៊ី និងបាឡាម។ ដូចជាប៉ូលបានធ្វើ នោះយើងគួរតែបំរើព្រះអម្ចាស់ជាមួយការស្ដាប់បង្គាប់និងភាពបរិសុទ្ធ។

**11.ចេញពីសេចក្តីស្លាប់ទៅកាន់ជីវិត(អេសធើរ**9:20-10:3)

ព្រះអម្ចាស់បានធ្វើការដ៏អស្ចារ្យនោះដោយការផ្លាស់ប្ដូរទុក្ខសោកទៅជាអំណរ ហើយការទួញសោកទៅជាថ្ងៃនៃសេចក្ដីរីករាយ។ តើអ្វីជាលក្ខណៈរបស់ដំណឹងល្អដែលអត្ថបទបង្ហាញមកកាន់យើង? ទីមួយ សេចក្ដីស្លាប់ត្រូវបានប្ដូរទោជាជិវិត។ ដំណឹងល្អតែងតែធ្វើឲ្យមានការអស្ចារ្យយ៉ាងខ្លាំង។ ប្រសិនបើនរណាម្នាក់ជឿលើព្រះគ្រីស្ទតែមួយគត់ នោះអ្នកដែលស្លាប់នឹងត្រូវរស់ឡើងវិញ ពីព្រោះព្រះអម្ចាស់ផ្លាស់ប្រែពួកគេពីការស្លាប់ទៅជាជីវិត និងពីសេចក្ដីងងឹតទៅជាពន្លឺ (កិច្ចការ 26:18)។ ទីពីរ តាមរយៈម៉ាឌីកៃនិងអេសធើរ កិច្ចការដ៏អស្ចារ្យបានកើតឡើង (ភីលីព 4:5-6)។ ការលើកឡើងរបស់ម៉ាឌីកៃបង្ហាញពីការលើកឡើងរបស់ព្រះគ្រីស្ទនិងការយាងចុះមករបស់ទ្រង់។ម៉ាឌីកៃបានគ្រប់គ្រងលើពិភពលោកទាំងមូលដោយព្រះគុណរបស់ព្រះអម្ចាស់ គ្រីស្ទានបានក្លាយជាអ្នកដែលគ្រប់គ្រងលើពិភពលោកនៅក្នុងព្រះគ្រីស្ទ។ យើងគួរតែរស់នៅដោយព្រះគុណជាបរិបូរណ៍នៅក្នុងពិភពលោកទាំងមូលនៅក្នុងព្រះគ្រីស្ទ។ យើងគួរតែរស់នៅដោយព្រះគុណជាបរិបូរណ៍នៅក្នុងពិភពលោកដោយការជឿលើដំណឹងល្អ។

**សរុបសេចក្តីៈ**

នៅក្នុងជាតិសាសន៍ដែលមិនជឿ ដែលពួកអ៊ីស្រាអែលត្រូវបានគេបៀនបៀន ព្រះហស្តរបស់ព្រះអម្ចាស់តែងតែការពាររាស្ត្ររបស់ទ្រង់ ហើយសំរេចគោលបំណងរបស់ទ្រង់ការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។ ព្រឹត្តិការណ៍មួយចំនួនដែលជា ការខ្វល់ខ្វាយ មហន្តរាយ ការឈឺចាប់ ការបាក់ទឹកចិត្ត ការរអ៊ូរទាំ ការទួញសោក និងតានតឹងបានធ្វើឲ្យពួកគេបានបន្សុតចេញពីកិច្ចការដែលកខ្វក់របស់ពួកគេនៅក្នុងចិត្តរបស់ពួកគេដោយព្រះហស្តរបស់ព្រះអម្ចាស់។ ដូចជាសប្បុករដែលដកយកផ្នែកដែលកខ្វក់ចេញពីប្រាក់នៅក្នុងភ្លើងរងចាំរហូត

ទាល់តែផ្ទៃព្រះភក្ត្រទ្រង់ចេញមកនៅលើផ្ទៃនៃប្រាក់សុទ្ធ ព្រះអម្ចាស់ធ្វើការនៅក្នុងយើងដើម្បីនឹងបង្ហាញលក្ខណៈរបស់ទ្រង់នៅក្នុងជីវិតយើងដោយប្រាជ្ញាដ៏អស្ចារ្យរបស់ទ្រង់។ជាចុងក្រោយព្រះអម្ចាស់បង្ហាញរូបឆ្លុះរបស់ទ្រង់ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់នៅក្នុងយើង រហូតទាស់តែយើងទៅដល់កម្រិតខ្ពស់បំផុតនៃអាណាចក្ររបស់ព្រះសំរាប់សិរីល្អរបស់ទ្រង់។

## F. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងកណ្ឌគម្ពីររបស់កវីនិពន្ធ

### 1. ទំនុកដំកើង

**សេចក្តីណែនាំ៖**

ខ្ញុំបាននិយាយពីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ឬ ការប្រោសលោះនៅក្នុងគម្ពីរសញ្ញាចាស់ នៅក្នុងទស្សនៈរបស់ខ្ញុំអំពីព្រះគម្ពីរទុកដូចជាគោលគំនិតយ៉ាងសំខាន់នៃជីវិតរបស់អ្នកដែលកំនែទម្រង់។

ការយល់ដឹងពីសេចក្តីប្រោសលោះនៅក្នុងទំនុកដំកើង នឹងនាំមកនូវជីវិតពេញបរិបូរណ៍។ ពេលយើងយល់ពីសេចក្តីពិតនៃនិម្មិតរូបជាច្រើន និងប្រភេទជាច្រើន ហើយបទពិសោធច្រើននៃមនុស្សដែលនៅក្នុងការតាំងសញ្ញា ដែលរលាយនៅក្នុងភាគទាំងប្រាំនៅក្នុងទំនុកដំកើង យើងគួរតែមើលឃើញនូវពន្លឺដ៏ភ្លឺនៃសេចក្តីពិតនៃសេចក្តីប្រោសលោះនៅក្នុងទំនុកដំកើង។ ដូច្នេះមេរៀនរបស់យើងមានព្រំដែនកំណត់ដោយវត្ថុបំណងសំខាន់បួន មានដូចជា៖ 1) ភាពជាស្តេចរបស់ព្រះមេស៊ី ដែលជាសិរសានៃការប្រោសលោះ 2) ការសុគតរបស់ព្រះមេស៊ីដែលជាគ្រឹះនៃសេចក្តីប្រោសលោះ 3) ការបើកសំដែងរបស់ព្រះមេស៊ី ជាលក្ខណៈជីវិតនៃព្រះគម្ពីរ ដែលជាការអនុវត្តនូវសេចក្តីប្រោសលោះ 4) និងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ជាចំនុចដ៏ខ្ពស់បំផុតនៃសេចក្តីប្រោសលោះ។

**1 –** ទំនុកដំកើង 2:1-10 ទំនុកដំកើងរបស់ព្រះមេស៊ី– ភាពជាស្តេចរបស់ព្រះគ្រីស្ទ

**2 –** ទំនុកដំកើង 22:1-13 ទុក្ខវេទនារបស់ព្រះមេស៊ីនិងការសុគតរបស់ព្រះគ្រីស្ទ

**3 –** ទំនុកដំកើង 119:33-40 ការបើកសំដែងរបស់ព្រះមេស៊ី - លក្ខណៈនៃជីវិត

**4 –** ទំនុកដំកើង 17:1-33 ការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ (1)

**5 –** ទំនុកដំកើង 17:1-33 ការស្តាឡើងវិញនូវរូបឆ្លុះរបស់ព្រះ (2)

1. ចូរថើបព្រះរាជបុត្រា (ទំនុកដំកើង 2:1-10)

១ហេតុអ្វីបានជាអស់ទាំងសាសន៍ជ្រួលជ្រើមឡើងហើយជនជាតិទាំងពួងមានគំនិតជាឥត
សារដូច្នេះ២ពួកមហាក្សត្រនៅផែនដីលើកគ្នាឡើង ពួកគ្រប់គ្រងទាំងប៉ុន្មានក៏ប្រឹក្សាគ្នាទាស់
នឹងព្រះយេហូវ៉ា ហើយទាស់នឹងព្រះអង្គ ដែលទ្រង់បានលាបប្រេងឲ្យដោយពាក្យថា៣ចូរយើង
ផ្តាច់ចំណងទ្រង់ ហើយបោះខ្សែចងរបស់ទ្រង់ពីយើងចេញ៤ឯព្រះដែលគង់នៅស្ថានសួគ៌
ទ្រង់នឹងសើច ព្រះអម្ចាស់ទ្រង់នឹងចំអកឲ្យគេ៥រួចទ្រង់នឹងមានបន្ទូលដល់គេ ដោយសេចក្តី
ក្រោធនៃទ្រង់ ព្រមទាំងបំភ័យគេ ដោយសេចក្តីឃោឃៅផង ថា៦អញបានតាំងស្តេចរបស់
អញឡើងហើយ គឺនៅស៊ីយ៉ូន ជាភ្នំបរិសុទ្ធរបស់អញ។៧អញនឹងថ្លែងប្រាប់ពីច្បាប់នេះ គឺព្រះ
យេហូវ៉ាទ្រង់មានបន្ទូលនឹងអញថា ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ៨ចូរសូមពី
អញ នោះអញនឹងឲ្យសាសន៍ទាំងឡាយដល់ឯង ទុកជាមរតក ហើយអស់ទាំងចុងផែនដីទុក
ជាកេរ្តិ៍អាកររបស់ឯង៩ឯងនឹងបំបាក់បំបែកគេ ដោយដំបងដែក ព្រមទាំងបោកកំទេចគេទៅ
ដូចជាភាជនៈរបស់ជាងស្មូន១០ដូច្នេះឱពួកមហាក្សត្រទាំងប៉ុន្មានអើយ ចូរប្រព្រឹត្តដោយប្រាជ្ញា
ចុះ ឱពួកអស់ទាំងចៅក្រមនៅផែនដីអើយ ចូរទទួលសេចក្តីផ្ចាលចុះ។

**សេចក្តីផ្តើម៖**

អត្ថបទបានផ្តល់គំនិតពិការការឡើងសោយរាជ្យរបស់ស្តេច ដាវីតបានប្រកាសថា អ្នកដែលមានពរគួរតែជាអ្នកដែលគោរពដល់ព្រះមេស៊ី។ (ឯកសារយោង – ទំនុកដំកើង 18:, 20:,21:, 45:,72:, 89:,101:, 110:, 132:, 144: ជាទំនុកដំកើងរបស់ស្តេចនៅផែនដី) តើពេលណាដែលព្រះមេស៊ីនឹងមកនៅលើផែនដីហើយតើយើងស្រឡាញ់ព្រះមេស៊ីដោយរបៀបណា?

**ទីមួយ ទ្រង់នឹងមកក្នុងលោកិយនៅពេលដែលមានសេចក្តីទុក្ខវេទនា**

**1) គ្រប់ជាតិសាសន៍ទាស់នឹងព្រះមេស៊ី**

ដូចនៅខ 1-3 បង្ហាញថា ទ្រង់ជាស្តេចនៅក្នុងចំណោមជាតិសាសន៍ដែលទាស់នឹងទ្រង់ ហើយបានរំដោះរាស្ត្ររបស់ទ្រង់ចេញពីសេចក្តីទុក្ខវេទនារបស់ពួកគេ។ ហេតុអ្វីបានជាជាតិសាសន៍រួបរួមហើយមនុស្សរៀបគម្រោងជាអសារឥតការ? ពួកស្តេចនៅលើផែនដីបានក្រោកឡើង ហើយអ្នកដឹកនាំរួមគ្នាទាស់នឹងព្រះអម្ចាស់នឹងអ្នកដែលទ្រង់បានចាក់ប្រេងតាំងដោយនិយាយថា "ចូរយើងផ្តាច់ចំណងទ្រង់ ហើយបោះខ្សែចងរបស់ទ្រង់ពីយើងចេញ"។

**2) ប៉ុន្តែព្រះមេស៊ីបានបំបែកពួកគេជាមួយនឹងព្រះហស្តដ៏មានចេស្តារបស់ទ្រង់**

វាជាចាំបាច់ណាស់ក្នុងការទ្រង់សុគតនៅលើឈើឆ្កាងដើម្បីនឹងសំរេចនូវការប្រោសលោះដល់រាស្ត្ររបស់ទ្រង់ តាមរយៈលំនាំដែលបង្ហាញជាព្រះមេស៊ីដ៏ពិត ទាំងនោះមាន ស្តេច សង្ឃ និងហោរា (4-6)។ ព្រះអម្ចាស់របស់យើង ជាព្រះយេស៊ូវគ្រីស្ទជាព្រះមេស៊ីដែលសុចរិត។

**ទីពីរ តើយើងអាចស្រឡាញ់ព្រះមេស៊ីដោយរបៀបណា?**

យើងត្រូវតែបំរើទ្រង់ដោយសេចក្តីកោតខ្លាច និងអំណរ(11) និងភាពជិតស្និតដោយស្រឡាញ់(12)។ "ចូរគោរពដល់ព្រះយេហូវ៉ា ដោយកោតខ្លាច ហើយមានសេចក្តីអំណរ ដោយញ័ររន្ធត់។ ចូរថើបព្រះរាជបុត្រា ក្រែងទ្រង់ខ្ញាល់ឡើង ហើយឯងរាល់គ្នាត្រូវវិនាសតាមផ្លូវ ដ្បិតបន្តិចទៀត សេចក្តីខ្ញាល់របស់ទ្រង់នឹងឆួលឡើង។ មានពរហើយអស់អ្នកណាដែលយកទ្រង់ជាទីពឹងជ្រក។"

1) **ជាមួយសេចក្ដីកោតខ្លាច (សេចក្ដីញាប់ញ័រ)**

ពាស្រ្តរបស់ព្រះមេស៊ីគួរតែបំរើព្រះមេស៊ីជាមួយការសេចក្ដីជំនឿដែលឆេះឆួល ដែលទាក់ទងទៅនឹងសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់។ យែរេ មានន័យថា "សេចក្ដីកោតខ្លាច" "ផិតភ័យ" "ភាពឆេះឆួល" និង "សេចក្ដីភ័យខ្លាចដ៏ខ្លាំង" "ការគោរព"។ វាមានន័យថា អាកប្បកិរិយាដែលញាប់ញ័រដែលរួមបញ្ចូលនឹងការរីករាយ (ភីលីព 2:12)។ ព្រះមេស៊ីគួរតែត្រូវបានទទួលជាមួយនឹងចិត្តដែលគោរពកោតខ្លាចយ៉ាងខ្លាំងពីពាស្រ្តរបស់ទ្រង់ផ្ទាល់។

ពិតណាស់ "សេចក្ដីកោតខ្លាច" ជាគ្រឹះនៃប្រាជ្ញា និងចំណេះដឹង (សុភាសិត 1:7) ហើយវាមានលក្ខណៈដូចគ្នានឹងសេចក្ដីជំនឿរបស់គ្រីស្ទាននៅក្នុងគម្ពីរសញ្ញាថ្មី។ ដូច្នេះវាមានន័យថា ទាល់តែគាត់មានសេចក្ដីកោតខ្លាច សេចក្ដីជំនឿរបស់គាត់នឹងជាសេចក្ដីជំនឿដែលខុសឆ្គង។ ដំណឹងល្អដែលគ្មានសេចក្ដីកោតខ្លាចដោយការគោរពមិនមែនជាដំណឹងល្អទេ។ ដូចជាអ្នកសរសេរទំនុកដំកើងបានធ្វើ យើងគួរតែបំរើព្រះអម្ចាស់ជាមួយសេចក្ដីកោតខ្លាចដោយស្រឡាញ់ ការគោរព និងសេចក្ដីសប្បុរស។ ហេតុអ្វីបានជាយើងត្រូវមានសេចក្ដីកោតខ្លាចដោយគោរពដល់ព្រះអម្ចាស់? ពីព្រោះយើងបំរើនៅចំពោះព្រះដែលបរិសុទ្ធបំផុតជាមួយសេចក្ដីពិតដ៏រស់របស់ទ្រង់ យើងមិនអាចមានការឆ្លើយតបដោយគួរឲ្យផិតភ័យឡើយ ប៉ុន្តែជាចិត្តដែលសរសើរដោយគោរព នៅពេលដែលមើលឃើញភាពពិតនៃសេចក្ដីបរិសុទ្ធ ដោយសារការបើកសំដែងរបស់ព្រះវិញ្ញាណបរិសុទ្ធ ដូចជាការបំរើរបស់សេរ៉ាភីមដែលត្រូវបានព័ទ្ធជុំវិញដោយបល្ល័ង្ករបស់ព្រះអម្ចាស់នៅក្នុង អេសាយ 6:2-3។ "នៅពីលើទ្រង់មានពួកសេរភីម គ្រប់គ្នាមានស្លាប៦ កំបាំងមុខដោយស្លាប៣២ បាំងជើងដោយស្លាប២ ហើយប្រើ២សំរាប់ហើរ។ មួយបន្លឺទៅកាន់មួយថា បរិសុទ្ធ បរិសុទ្ធ គឺព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បរិសុទ្ធ ផែនដីទាំងមូលមានពេញដោយសិរីល្អនៃទ្រង់។"ពួកគេបានគ្របមុខរបស់ពួកគេដោយស្លាបពីរ គ្របជើងដោយស្លាប២ ហើយពួកគេហើរដោយស្លាប២។ សេចក្ដីកោតខ្លាចរបស់ពួកគេចេញមកពីការបដិសេធខ្លួនឯង" (លូកា 9:23)។

2) **ជាមួយនឹងមេត្រីភាព (ការថើប)**

ពិតណាស់សេចក្តីកោតខ្លាចរួមបញ្ចូលទាំងសេចក្តីមេត្រីនៅក្នុងការបម្រើព្រះមេស៊ី។ ដូច្នេះអ្នកសរសេរទំនុកដំកើងបានជម្រុញឲ្យថើបដល់ព្រះរាជ្យាបុត្រា។ ណាសាក់ (ថើប) នៅក្នុងភាសាហេព្រើរមានន័យថាការប៉ះ។ ហើយវាមានន័យថា សូឡិម ថូខិន ឬជាសញ្ញានៃការគោរព ដែលជាអ្នកដែលត្រូវគេចង់បានដើម្បីនឹងបង្កើតអំណាចរបស់ពួកគេ *(Calvin)*។ វាធ្វើឲ្យយើងគិតពីការប្រកបអស់កល្បជានិច្ច។ តាមរយៈទំនាក់ទំនងស្និតស្នាលដូច្នេះជាមួយព្រះរាជ្យបុត្រា យើងអាចរួបរួមគ្នាបានជាមួយទ្រង់ ហើយរីករាយនឹងព្រះគុណដ៏បរិបូររបស់ទ្រង់។ បន្ទាប់មកយើងអាចយកឈ្នះគ្រប់សេចក្តីវេទនាទាំងអស់នៅក្នុងការបំរើដល់ព្រះមេស៊ី។ បើទោះជាសត្រូវរបស់យើងវាយប្រហារយើងដោយកម្លាំងដ៏ខ្លាំងក៏ដោយ ព្រះបុត្រា ជាព្រះមេស៊ី (អ្នកដែលត្រូវបានចាក់ប្រេងតាំង) នឹងជាន់ក្បាលរបស់ពួកគេ ដូចជាម៉ូសេបានកត់សម្គាល់នៅក្នុង លោកុប្បត្តិ 3:15។ បន្ទាប់មកចេស្តារបស់ទ្រង់នឹងធ្វើការដោយការប្រកបនៅខាងក្រៅរវាងព្រះអម្ចាស់និងពួកយើង។ ដូច្នេះកិច្ចការចម្បងរបស់យើងគួរតែជាការប្រកបដូច្នេះនៅក្នុងសមរភូមិ។ នៅពេលដែលយើងរីករាយក្នុងព្រះគុណនិងចេស្តារបស់ទ្រង់ ទុកដូចជារំពាត់ដែកដែលអាចបំបែកភាជន៍ដីបាន នោះយើងនឹងអាចបង្កើតសេចក្តីប្រោសលោះ ជាគោលបំណងចម្បងរបស់ព្រះមេស៊ី។ "រួចទ្រង់នឹងបំបែកពួកគេដោយដំបងដែក ទ្រង់នឹងកំទេចពួកគេទៅជាបំណោកដូចជាភាជន៍ដី។" (9)

## សរុបសេចក្តី៖

សិរសានៃការប្រោសលោះ ព្រះមេស៊ីជាព្រះយេស៊ូវគ្រីស្ទ ជាអ្នកដែលប្រកាសភាពជាស្តេចរបស់ទ្រង់ដែលជា នគររបស់ព្រះអម្ចាស់។ តាមប្រវិត្តសាស្ត្រទ្រង់បានមកនៅក្នុងពេលលំបាកនាពេលបច្ចុប្បន្ននៅក្នុងលោកិយ ទ្រង់បានបង្កើតអាណាចក្ររបស់ទ្រង់នៅក្នុងពួកគេ ពេលនេះភាពជាស្តេចរបស់ទ្រង់នៅតែបន្តធ្វើដោយចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធរហូតដល់ទីបញ្ចប់នៃលោកិយ។ ជាចុងក្រោយ ទ្រង់នឹងបង្កើតភាពជាស្តេចរបស់ទ្រង់នៅក្នុងលោកិយជាមួយនឹងអំណាចចេស្តាដ៏ខ្លាំងក្លា។ ពេលនេះយើងរស់នៅក្នុងថ្ងៃនោះ ហើយបំរើស្តេចនៅក្នុងព័ន្ធកិច្ចរបស់យើង។ ដូចជាការដូច្នេះ កណ្ឌគម្ពីរទំនុកដំកើងបង្ហាញព្រះមេស៊ីជា

សិរសានៃសេចក្ដីប្រោសលោះរបស់យើងជាពិតប្រាកដ។ចូរយើងកោតខ្លាចដល់ព្រះមេស៊ី ហើយស្រឡាញ់ទ្រង់ឲ្យអស់ពីចិត្ត។ ហើយវាក៏បង្ហាញពីវិធីសាស្ត្រនៃការប្រកបគ្នាដែរ។ សេចក្តីកោតខ្លាចនិងសេចក្តីស្រឡាញ់។

**សង្ខេបៈ**

1. សេចក្ដីកោតខ្លាចដល់ព្រះជាម្ចាស់
2. ព្រះមេស៊ីបានយាងមកលើពិភពលោកហើយសោយរាជ្យលើរាស្ត្ររបស់ទ្រង់។
3. ការឆ្លើយតបរបស់រាស្ត្ររបស់ព្រះមេស៊ី

ការញាប់ញ័រនិងការមើលព្រះមេស៊ីជារូបភាពនៃការស្ដារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។

## 2. ការរងទុក្ខលំបាករបស់មេស៊ី (ទំនុកដំកើង 22:1-31)

**សេចក្តីផ្ដើមៈ**

1. យើងគួរតែឃើញឈើឆ្កាងនៅក្នុងទម្រង់នៃកំណើតរបស់ព្រះគ្រីស្ទ ដែលបានយាងមកដើម្បីនឹងសង្គ្រោះរាស្ត្ររបស់ទ្រង់ផ្ទាល់ចេញពីអំពើបាបដ៏អាក្រក់ តាមរយៈសេចក្ដីស្លាប់របស់ទ្រង់។ ជាមួយនឹងព្រឹត្តិការណ៍នោះ គ្រប់ទាំងព័ន្ធកិច្ចរបស់ព្រះគ្រីស្ទផ្ដោតទៅលើឈើឆ្កាងរបស់ទ្រង់។ ទំនុកដំកើងនោះក៏ត្រូវបានហៅថាសំណុំរូបរាងរបស់ព្រលឹងរបស់យើងដោយគ្មានការលើកលែង។ មិនតែប៉ុណ្ណោះជីវៈប្រវត្តិរបស់ទំនុកដំកើងជាសេចក្ដីស្លាប់របស់ព្រះគ្រីស្ទ ដែលជាសិរសានៃការតាំងសញ្ញា។ ព្រះវិញ្ញាណបរិសុទ្ធបានរៀបរាប់តាមរយៈសេចក្ដីទុក្ខលំបាករបស់ដាវីត នូវសេចក្ដីពិតជាក់ស្ដែងនៃទុក្ខលំបាករបស់ឈើឆ្កាងរបស់ព្រះគ្រីស្ទនៅកាល 1200ឆ្នាំមុននៅក្នុងអត្ថបទ។ សេចក្ដីប្រោសលោះនៅក្នុងទំនុកដំកើងមិនដែលបាត់រស្មីនៃពន្លឺពេលដោយសិរីល្អទៅលើសេចក្ដីរងទុក្ខវេទនាដ៏លំអិតនៃឈើឆ្កាងរបស់ទ្រង់ឡើយ។ ដូច្នេះអ្នកអធិប្បាយនាពេលសព្វថ្ងៃគួរតែប្រតិកម្មទៅលើអត្ថន័យនៃសេចក្ដីប្រោសលោះនៃឈើឆ្កាងរបស់ព្រះគ្រីស្ទនៅក្នុងទំនុកដំកើង។ ឥឡូវនេះ ចូរយើងគិតពីសេចក្ដីរងទុក្ខវេទនា

របស់ព្រះមេស៊ីនៅក្នុងទំនុកដំកើង22 (ជាញឹកញាប់វាត្រូវបានហៅតថាជាទំនុកដំកើងបែបទូញសោកជាមួយនឹង 6,13, 30,31,32 35,39,51,69,71,91,102,103)។

2. តើទំនុកដំកើងជំពូក22 បង្ហាញពីសេចក្ដីទុក្ខវេទនារបស់មេស៊ីមកកាន់យើងដូចម្ដេចខ្លះ?

**ទីមួយ សេចក្ដីទុក្ខវេទនាដ៏ពិបាករបស់ព្រះមេស៊ីត្រូវបានបញ្ជាក់ដោយព្រះវិញ្ញាណបរិសុទ្ធ**

1. បើទោះជាដាវីតត្រូវបានរងទុក្ខវេទនាដោយសារការដែលពេញដោយសេចក្ដីធ្វើឲ្យមិនសប្បាយមួយចំនួននៅក្នុងជីវិតរបស់គាត់ តែការទាំងនោះមិនអាចខិតចូលដល់សេចក្ដីទុក្ខលំបាករបស់ព្រះគ្រីស្ទឡើយ។ព្រះវិញ្ញាណបរិសុទ្ធបានប្រើសេចក្ដីវេទនារបស់ទ្រង់នៅក្នុងជីវិតរបស់ទ្រង់។ដូច្នេះយើងទេរទៅគិតសភាពដែលនៅអាក្រាតនៃសេចក្ដីទុក្ខវេទនារបស់ទ្រង់នៅលើឈើឆ្កាងដូចតទៅ។

1) ខ1 មានបន្ទូលថា "ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ ហើយគង់ឆ្ងាយឥតជួយទូលបង្គំ ឬស្ដាប់សេចក្ដីដំងូររបស់ទូលបង្គំដូច្នេះ?"

- ព្រះគ្រីស្ទត្រូវបានទទួលការបដិសេធមកពីព្រះជាម្ចាស់ ពីព្រោះទ្រង់ត្រូវបានរាប់ទុកដូចជាមនុស្សមានបាបម្នាក់នៅចំពោះព្រះជាម្ចាស់សំរាប់សេចក្ដីសង្គ្រោះរបស់យើង(ម៉ាថាយ 27:46) "ប្រហែលជាម៉ោងបី នោះព្រះយេស៊ូវទ្រង់បន្លឺឡើង ជាសំលេងខ្លាំងថា អេលីៗឡាម៉ាសាបាច់ថានី គឺស្រាយថាឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ?"

2) ខ12-14 មានបន្ទូលថា "មានគោឈ្មោលជាច្រើនបានព័ទ្ធទូលបង្គំជុំវិញ គឺគោឈ្មោលយ៉ាងខ្លាំងពីស្រុកបាសាន វាបានឡោមទូលបង្គំជុំវិញ។ វាហាមាត់ដាក់ទូលបង្គំប្រៀបដូចជាសិង្ហ

ដែលហែកស៊ីទាំងគ្រហឹម។ ទូលបង្គំត្រូវច្រូចចេញ ដូចជាទឹក ហើយអស់ទាំងឆ្អឹងនៃទូលបង្គំសណ្តកចេញពីគ្នា ចិត្តទូលបង្គំទុកជាក្រមួនដែលរលាយនៅក្នុងខ្លួនហើយ។"

- ទង្វើដ៏គ្មានមេត្តាជាមួយនឹងដំណាក់កាលមួយចំនួន ដែលមនុស្សបានធ្វើទៅកាន់ព្រះគ្រីស្ទត្រូវបានរៀបរាប់នៅទីនេះ។ ព្រះគ្រីស្ទត្រូវបានចំអកដោយមនុស្សដែលដើរកាត់មក។ (ម៉ាថាយ 27:39-43) "ឯមនុស្សដែលដើរតាមទីនោះ គេជេប្រមាថដល់ទ្រង់ ទាំងគ្រវីក្បាល ហើយនិយាយថា ឯងដែលបំផ្លាញព្រះវិហារ ហើយសង់ឡើងវិញក្នុងរវាងបីថ្ងៃអើយ ចូរជួយសង្គ្រោះខ្លួនឯងចុះ បើឯងជាព្រះរាជបុត្រានៃព្រះមែននោះ ឲ្យចុះពីឈើឆ្កាងមក។ ឯពួកសង្គ្រាជ ព្រមទាំងពួកអាចារ្យ និងពួកចាស់ទុំ គេក៏ចំអកឲ្យទ្រង់បែបដូច្នោះដែរ ដោយថា វាជួយសង្គ្រោះមនុស្សឯទៀតបាន តែមិនអាចជួយសង្គ្រោះដល់ខ្លួនវាបានទេ បើសិនណាវាជាស្តេចសាសន៍អ៊ីស្រាអែលមែន ចូរឲ្យវាចុះពីលើឈើឆ្កាងមក នោះយើងនឹងជឿដល់វា។ វាបានទុកចិត្តនឹងព្រះ ដូច្នេះបើព្រះសព្វព្រះហឫទ័យនឹងវា សូមទ្រង់ជួយដោះវាឥឡូវចុះ ដ្បិតវាបានថា ខ្ញុំជាព្រះរាជបុត្រានៃព្រះ។"

3) ហើយគ៏ដូចជា៖15 មានបន្ទូលថា "កំឡាំងរបស់ទូលបង្គំហួតខ្សោះទៅដូចអំបែងឆ្នាំង អណ្តាតទូលបង្គំជាប់នៅក្រអូមមាត់ ទ្រង់បាននាំទូលបង្គំចុះទៅក្នុងធូលីនៃសេចក្តីស្លាប់។"

- (យ៉ូហាន19:29:) "រីឯនៅទីនោះមានក្រឡជាក់ទឹកខ្មេះពេញ គេក៏យកសារាយរំហួតជ្រលក់ទឹកខ្មេះជោក រួចចងភ្ជាប់នឹងមែកហីសុប ហុចទៅដល់ព្រះឱស្ឋទ្រង់។"

4) ៖18 មានបន្ទូលថា "គេយកសំលៀកបំពាក់ទូលបង្គំចែកគ្នា ឯអាវវែងទូលបង្គំ គេក៏ធ្វើឆ្នោតចាប់យក។"

- តាមន័យត្រង់ទ្រង់រៀបរាប់ពីហេតុការពិតជាក់ស្តែងដោយការបើកសំដែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។

- (យ៉ូហាន 19:24) "ដូច្នេះ គេនិយាយគ្នាថា កុំហែកអាវនេះឡើយ ចូរយើងចាប់ឆ្នោតវិញ ឲ្យបានដឹងជាអាវនេះនឹងទៅជារបស់របអ្នកណា នោះដើម្បីឲ្យបានសំរេចបទគម្ពីរ ដែលថា គេបានយកសំលៀកបំពាក់ទូលបង្គំចែកគ្នា ឯអាវវែងទូលបង្គំ គេក៏ធ្វើឆ្នោតចាប់យក ពួកទាហានក៏ធ្វើដូច្នោះ។"

**ទីពីរ សេចក្តីទុក្ខលំបាករបស់ទ្រង់ត្រូវបានសង្កត់ធ្ងន់ដោយសេចក្តីទុក្ខលំបាកដ៏ធ្ងន់ធ្ងរ**

1. ខ 16-17 មានបន្ទូលថា "ព្រោះមានឆ្កែមកឡោមព័ទ្ធទូលបង្គំហើយ មានពួកមនុស្សអាក្រក់ដើរក្រវែលជុំវិញទូលបង្គំ គេបានចាក់ទំលុះដៃជើងរបស់ទូលបង្គំ។ អស់ទាំងឆ្អឹងក្នុងរាងកាយទូលបង្គំរាប់បានទាំងអស់ គេគន់មើល ហើយសំឡឹងមកទូលបង្គំ។" ទ្រង់ត្រូវបានធ្មេញរបស់សត្រូវខាំដូចជាសិង្ហ។ ហើយចិត្តរបស់ទ្រង់ត្រូវបានរលាយដូចជាទឹក ហើយចិត្តទ្រង់ដូចជាក្រមួន។ ហើយដាវីតក៏បានប្រៀបធៀបជាមួយនឹងសត្រូវរបស់គាត់ដូចជាដាវ ជាឆ្កែព្រៃ ដូចជាសិង្ហ និងដូចជាស្នែងនៃគោព្រៃ។

ហើយយ៉ូហាន19:32-37 មានបន្ទូលថា "ដូច្នេះពួកទាហានក៏បំបាក់ជើងអ្នកមួយ រួចអ្នកមួយទៀត ដែលជាប់ឆ្កាងជាមួយនឹងទ្រង់។ តែកាលគេមកដល់ព្រះយេស៊ូវ ក៏ឃើញថា ទ្រង់សុគតផុតហើយ បានជាគេមិនបំបាក់ព្រះបាទទ្រង់ទេ។ ប៉ុន្តែ ទាហានម្នាក់យកលំពែងចាក់ត្រង់ចំហៀងទ្រង់ នោះក៏ចេញឈាម ហើយនឹងទឹកមក។ អ្នកដែលឃើញបានធ្វើបន្ទាល់ ហើយសេចក្តីបន្ទាល់របស់អ្នកនោះក៏ពិតប្រាកដ អ្នកនោះដឹងថា ខ្លួននិយាយត្រូវដើម្បីឲ្យអ្នករាល់គ្នាបានជឿ។ ដ្បិតការទាំងនោះបានកើតមក ដើម្បីឲ្យបទគម្ពីរបានសំរេច ដែលថា គ្មានឆ្អឹងទ្រង់ណាមួយត្រូវបាក់សោះ។ ក៏មានបទមួយទៀតថា គេនឹងមើលព្រះអង្គដែលគេបានចាក់។"

2. ដូចដែលយើងបានដឹងព ប្រហែលជា 2000 ឆ្នាំមុន ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាងសំរាប់សេចក្តីសង្គ្រោះរាស្ត្ររបស់ទ្រង់ផ្ទាល់ ដែលរាប់បញ្ចូលទាំងយើងរាល់គ្នា។ ការសុគត

របស់ទ្រង់ជាចំណុចកណ្តាលដើម្បីនឹងសំរេចនូវសេចក្តីប្រោសលោះនៅក្នុងលោកិយ។ ដូច្នេះ ក្រុមជំនុំគ្រីស្ទានគួរតែផ្តោតលើព្រឹត្តិការណ៍នោះ ហើយចងចាំវានៅក្នុងចិត្ត ពីព្រោះសេចក្តីសង្គ្រោះរបស់យើងនឹងត្រូវបានចម្រើនដោយឈើឆ្កាងរបស់ព្រះគ្រីស្ទ។

ជាទូទៅ ក្រុមជំនុំបានស្គាល់ពាក្យ៧ដែលព្រះយេស៊ូវបានស្រែកឡើងនៅលើឈើឆ្កាង។ (វាត្រូវបានបញ្ចប់ហើយ ខ្ញុំស្រែកណាស់ ខ្ញុំជាបុត្រារបស់ទ្រង់ អេលីៗឡាម៉ាសាបាតថានី អ្នកនឹងនៅជាមួយខ្ញុំនៅឯស្ថានបរមសុខ ព្រះបិតាអើយ សូមអត់ទោសដល់ពួកគេ)។ នៅក្នុងចំណោមពាក្យទាំងនោះ យើងគិតពីព្រះបន្ទូលសំខាន់ៗ "វាត្រូវបានបញ្ចប់" ដែលទ្រង់បានស្រែកឡើង មុនពេលដែលទ្រង់រៀបនឹងសុគត ពីព្រោះវាបានប្រកាសពីការសំរេចដ៏ពេញលេញនៃសេចក្តីប្រោសលោះ យ៉ូហានបានសរសេរនូវព្រឹត្តិការណ៍នោះបែបនេះ "30 កាលព្រះយេស៊ូវទទួលទឹកខ្មេះរួចហើយ ក៏មានបន្ទូលថា ការស្រេចហើយ នោះទ្រង់ឱនព្រះសិរប្រគល់វិញ្ញាណទ្រង់ទៅ។"

ព្រឹត្តិការណ៍ដូចគ្នានោះត្រូវបានសរសេរដោយអ្នកផ្សាយដំណឹងល្អផ្សេងទៀតដូចតទៅៈ លូកា 23:46 មានបន្ទូលថា "នោះព្រះយេស៊ូវស្រែកឡើងជាខ្លាំងថា ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណ ដល់ព្រះហស្តទ្រង់វិញ កាលមានបន្ទូលពាក្យទាំងនោះរួចហើយ នោះទ្រង់ផុតដង្ហើយទៅ។" ម៉ាថាយ 27:50 មានបន្ទូលថា "កាលព្រះយេស៊ូវ ទ្រង់ស្រែកជាខ្លាំងម្តងទៀត នោះទ្រង់ប្រគល់វិញ្ញាណទ្រង់ទៅវិញ។" ហើយនៅម៉ាកុស 15:37 មានបន្ទូលថា "រួចព្រះយេស៊ូវ ទ្រង់ស្រែកជាខ្លាំង ហើយក៏ផុតដង្ហើមទៅ។"

បើទោះជាយើងមិនបានដឹងពីសេចក្តីពិតដ៏លំអិតនៅក្នុងព្រឹត្តិការណ៍ឲ្យបានជាក់ច្បាស់ ប៉ុន្តែទ្រង់ហាក់បីដូចជាត្រូវសុគតនៅក្នុងពេលតែមួយ រំពេចដែលទ្រង់ត្រូវបានបញ្ចប់នូវពាក្យពីរម៉ាត់ ពាក្យទីមួយគឺ វាសំរេចហើយ និងពាក្យចុងក្រោយ "ឱព្រះបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណរបស់ទូលបង្គំទៅទ្រង់វិញ។" យើងជឿថាទ្រង់បានស្លាប់នៅក្នុងចំណុចមួយនៅក្នុងផែនដី ដោយយោងតាមការកត់ត្រានៅក្នុងព្រះគម្ពីរ។

ប៉ុន្តែយើងប្រាកដថា ទ្រង់បានសំរេចបេសកកម្មរបស់ទ្រង់ ដែលនោះជា សេចក្តីប្រោសលោះដែលត្រូវបានសំរេចដោយការសុគតពិតប្រាកដដែលបញ្ជាក់ដោយពាក្យមួយម៉ាត់ "ការបានសំរេចហើយ" ទៅតាមការគ្រោងទុករបស់ព្រះវរបិតា។

**ទីបី ទ្រង់បានយកភាពទំនុកចិត្តបូននៃសង្ឃឹមនៅក្នុងសេចក្ដីរងទុក្ខដ៏លំបាករបស់ទ្រង់។**

1. ទ្រង់ជាមួយអង្គដែលបានសរសើរព្រះអម្ចាស់ (22-23 ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន ទូលបង្គំនឹងសរសើរដំកើងទ្រង់ នៅកណ្ដាលពួកជំនុំ។ ឯអ្នករាល់គ្នាដែលកោតខ្លាចដល់ព្រះយេហូវ៉ាអើយ ចូរសរសើរទ្រង់ចុះ អស់អ្នកដែលជាពូជយ៉ាកុបអើយ ចូរដំកើងទ្រង់ឡើង អស់ពូជពង្សនៃអ៊ីស្រាអែលអើយ ចូរកោតខ្លាចនៅចំពោះទ្រង់ចុះ។ គាត់បានទទួលជីវិតអស់កល្បជានិច្ច។ (25-26 "ទ្រង់ជាដើមហេតុនៃការដែលទូលបង្គំសរសើរនៅក្នុងជំនុំធំ ទូលបង្គំនឹងលាបំណាន់របស់ទូលបង្គំ នៅចំពោះមុខពួកអ្នកដែលកោតខ្លាចដល់ទ្រង់។ ឯមនុស្សរាបទាប គេនឹងបានបរិភោគឆ្អែត អស់អ្នកដែលស្វែងរកព្រះយេហូវ៉ា និងសរសើរដល់ទ្រង់ សូមឲ្យចិត្តអ្នករាល់គ្នាប្រកបដោយសេចក្ដីចំរើនជានិច្ច។")ជាការប្រកាសដែលផ្ដល់ដំណឹងពីការផ្លាស់ប្រែចិត្តទៅកាន់លោកិយ។ (27-31) "គ្រប់ទាំងទីបំផុតនៃផែនដីនឹងនឹកដល់ព្រះយេហូវ៉ា ហើយត្រឡប់បែមកឯទ្រង់ អស់ទាំងពូជពង្សនៃនគរទាំងឡាយ នឹងថ្វាយបង្គំនៅចំពោះទ្រង់។ ដ្បិតអំណាចគ្រប់គ្រងជារបស់ព្រះយេហូវ៉ា ទ្រង់ជាចៅហ្វាយលើអស់ទាំងនគរ។ អស់អ្នកមានចិត្តស្កប់ស្កល់នៅផែនដីនឹងបរិភោគ ព្រមទាំងថ្វាយបង្គំផងអស់អ្នកដែលចុះទៅក្នុងធូលី នឹងឱនក្រាបនៅចំពោះទ្រង់ ហើយទាំងអ្នកដែលមិនអាចនឹងរក្សាជីវិតខ្លួនបានផង។ នឹងមានពូជពង្សមួយប្រតិបត្តិដល់ទ្រង់ គេនឹងថ្លែងប្រាប់ពីព្រះអម្ចាស់ដល់ដំណមនុស្សក្រោយតទៅ។ គេនឹងមក ហើយនឹងប្រាប់ពីសេចក្ដីសុចរិតរបស់ទ្រង់ ដល់មនុស្សមួយពួក ដែលមិនទាន់កើតមកថា គឺទ្រង់ដែលបានធ្វើការនោះ។"

**សរុបសេចក្ដី៖**

ដាវីតជាស្រមោលរបស់ព្រះគ្រីស្ទនៅក្នុងការទាក់ទងនឹងឈើឆ្កាងរបស់ទ្រង់និងសិរីល្អរបស់ទ្រង់។ បើទោះជាយើងអាចយល់ស្របជាមួយសេចក្ដីពិត ដែលថា ទ្រង់ត្រូវបានរងទុក្ខដោយពិតៗនៅក្នុងជីវិតរបស់ទ្រង់ ភាពពិតរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទត្រូវបានរងទុក្ខទាំងស្រុងដោយឈើឆ្កាង ជាដង្វាយជំនួសសំរាប់រាស្ត្ររបស់ទ្រង់ផ្ទាល់។ ការសុគតរបស់ទ្រង់

តែមួយបានធ្វើឲ្យការសំរេចរបស់សេចក្តីប្រោសលោះអស់កល្បជានិច្ចដែលនឹងនាំនូវឥទ្ធិពល
យ៉ាងពេញលេញនៅក្នុងរាស្ត្រដែលទ្រង់បានជ្រើសរើស។

**សង្ខេប៖**

1. ភាពពិតនៃការរងទុក្ខលំបាករបស់ព្រះមេស៊ី
2. លទ្ធផលនៃការរងទុក្ខលំបាករបស់ព្រះមេស៊ី

ការរងទុក្ខលំបាកនិងការសុគតរបស់ព្រះមេស៊ីជាប្រភពនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់
ព្រះ។

**3. លក្ខណៈជីវិតនៃព្រះគម្ពីរ (ទំនុកដំកើង 119:33-40)**

[៣៣]ឱព្រះយេហូវ៉ាអើយ សូមបង្រៀនផ្លូវនៃអស់ទាំងបញ្ញាត្តិទ្រង់មកទូលបង្គំ នោះទូលបង្គំនឹង
កាន់តាមដរាបដល់ចុងបំផុត[៣៤]សូមប្រទានឲ្យទូលបង្គំមានយោបល់នោះទូលបង្គំនឹងកាន់
តាមក្រឹត្យវិន័យទ្រង់ អើ ទូលបង្គំនឹងរក្សាទុកឲ្យអស់ពីចិត្តផង[៣៥]សូមបណ្តាលឲ្យទូលបង្គំដើរ
ទៅតាមផ្លូវច្រកនៃសេចក្តីបង្គាប់របស់ទ្រង់ ដ្បិតទូលបង្គំមានសេចក្តីរីករាយក្នុងផ្លូវនោះ[៣៦]
សូមធ្វើឲ្យចិត្តទូលបង្គំល្អៀងទៅតាមសេចក្តីបន្ទាល់របស់ទ្រង់កុំឲ្យល្អៀងទៅខាងសេចក្តី
លោភឡើយ[៣៧]សូមបង្វែរភ្នែករបស់ទូលបង្គំមិនឲ្យមើលការឥតប្រយោជន៍ ហើយប្រោសឲ្យ
ទូលបង្គំមានកំឡាំងឡើងក្នុងផ្លូវទ្រង់[៣៨]សូមសំរេចដល់អ្នកបំរើទ្រង់តាមព្រះបន្ទូល ជាសេចក្តី
ដែលទុកសំរាប់ពួកអ្នកកោតខ្លាចដល់ទ្រង់[៣៩]សូមបង្វែរសេចក្តីដំនៀលដែលទូលបង្គំខ្លាច
នោះ ចេញពីទូលបង្គំទៅ ដ្បិតច្បាប់នៃទ្រង់សុទ្ធតែល្អ[៤០]មើល ទូលបង្គំបាននឹកអាល័យដល់
បញ្ញាត្តិទាំងប៉ុន្មានរបស់ទ្រង់ សូមប្រោសឲ្យទូលបង្គំមានកំឡាំងឡើង ដោយសេចក្តីសុចរិត
របស់ទ្រង់។

**សេចក្តីផ្តើម៖**

1. យើងបានឃើញសិរីល្អនៃការប្រោសលោះសម្រាប់រាស្ត្រនៃការតាំងសញ្ញា តាមរយៈ
និមិត្តរូបនិងប្រភេទមួយចំនួនរបស់ព្រះគ្រីស្ទ ហើយយើងឃើញលក្ខណៈដ៏សំខាន់របស់ព្រះ

គម្ពីរ លក្ខណៈជីវិត ដែលអ្នកសរសេរទំនុកដំកើងបានកោតសរសើរ នៅពេលដែលគាត់បានធ្វើទៅកាន់ព្រះអម្ចាស់។ ហេតុអ្វី? ពីព្រោះគាត់បានយល់ពីជីវិតអស់កល្បជានិច្ច ជីវិតរបស់ព្រះអម្ចាស់នៅក្នុងព្រះបន្ទូលរបស់ព្រះ ដែលជាប្រភពនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងជីវិតរបស់ពួកគេ។ សិរីល្អនៃការប្រោសលោះគួរតែត្រូវបានបង្ហាញនៅក្នុងជីវិតដែលមានសីលធម៌របស់រាស្ត្រនៃសេចក្តីសញ្ញា។

2. ទំនុកដំកើង 119: បញ្ជាក់ពីសេចក្តីពិតយ៉ាងខ្លាំងទៅកាន់យើងអំពី ភាពឆ្លាតវៃនៃសេចក្តីប្រោសលោះ។ ដូច្នេះខ្ញុំចង់ហៅជំពូកនេះជាការពិសោធនៅក្នុងព្រះគម្ពីរ។ ជំពូកនេះរួមបញ្ចូលទាំង22ឃ្លា ដែលត្រូវបានហៅថា ជាទំនុកដំកើងរបស់អក្សរក្រមដែលរួមបញ្ចូលទាំងភស្តុតាងជាច្រើននៃលក្ខណៈពិសេសនៃព្រះបន្ទូលរបស់ព្រះអម្ចាស់។ បើទោះជាមានអ្នកប្រាជ្ញជាច្រើនបានអះអាងថា អ្នកនិពន្ធនោះជាដាវីត ឬអែសរ៉ាជាដើម កង្វល់របស់យើងនោះជា លក្ខណៈជីវិតវិញ។ ពិតណាស់លក្ខណៈជាលក្ខណៈនៃសេចក្តីប្រោសលោះរបស់យើងដែលជា លក្ខណៈជីវិត។ ដូច្នេះយើងដោះស្រាយជាមួយនឹងឃ្លាទី៥៣នៅទីនេះ។

3. ការសំរេចចិត្តរបស់មនុស្សម្នាក់មានសារៈសំខាន់ណាស់នៅក្នុងការដើរតាមព្រះអម្ចាស់របស់យើង ដោយការខិតចូលនៅក្នុងជីវិតដែលមានជ័យជំនះខាងវិញ្ញាណ។ ប៉ូលបានធ្វើការសំរេចចិត្តភ្លាមនៅពេលដែលគាត់ទទួលបានការត្រាស់ហៅដោយព្រះជាម្ចាស់ ដើម្បីនឹងដើរតាមទ្រង់អស់កល្បជានិច្ច ជាមួយនឹងពេញមួយជីវិតរបស់គាត់ ដើម្បីនឹងសំរេចនូវបេសកកម្មនៃការត្រាស់ហៅនៅក្រុងដាម៉ាស់។ បន្ទាប់ពីគាត់បានសារភាពថា ខ្ញុំបានបញ្ចប់ការរត់របស់គាត់ ហើយរង្វាន់នៅស្ថានសួគ៌របស់ខ្ញុំកំពុងរងចាំខ្ញុំ។ ការសំរេចចិត្តដំបូងរបស់គាត់មានឥទ្ធិពលលើបេសកកម្មដ៏រឹងមាំរបស់គាត់រហូតដល់ចំនុចនៃសេចក្តីស្លាប់។ កិច្ចការ 20: មានបន្ទូលថា "គាត់បានគិតពីបេសកកម្មរបស់គាត់មានតម្លៃលើសជាងជីវិតរបស់គាត់ទៅទៀត។ ការសំរេចចិត្តខាងវិញ្ញាណធ្វើឲ្យយើងមានបទពិសោធន៍ការដ៏អស្ចារ្យនៅក្នុងលោកិយ។ កាលៈទេសៈដូចគ្នាដែលបានកើតឡើងនៅក្នុងអត្ថបទ។ ដូចដែលអ្នកបានដឹងថាទំនុកដំកើង 119 បានផ្តោតលើការសរសើរដំកើងព្រះបន្ទូលរបស់ព្រះអម្ចាស់។ ដូច្នេះនៅពេលដែលយើងអាចអានអត្ថបទដោយលំអិត យើងអាចរកឃើញទីបន្ទាល់ជាច្រើននៃតម្លៃរបស់ព្រះគម្ពីរ ដោយទីបន្ទាល់ជាច្រើនតាមរយៈការទំនាក់ទំនងនឹងព្រះគម្ពីរ។ លើសពីនោះ

ទៅទៀត អ្នកនិពន្ធបានធ្វើការសំរេចចិត្តនៅក្នុងពេលដែលមានកំណាត់នៅក្នុងជីវិតរបស់គាត់ ។ តើការសំរេចចិត្តអ្វីដែលអ្នកបរិសុទ្ធមាននៅក្នុងទំនាក់ទំនងទៅនឹងព្រះគម្ពីរ ជាព្រះបន្ទូលរបស់ព្រះ?

**ទីមួយ វាជាការរក្សាព្រះបន្ទូលរបស់ព្រះរហូតដល់ទីបញ្ចប់**

"ព្រះអម្ចាស់អើយ សូមបង្រៀនក្រឹត្យវិន័យរបស់ទ្រង់ដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំដើរតាមរហូតដល់ទីបញ្ចប់" អ្វីដែលពួកបរិសុទ្ធត្រូវរៀននៅក្នុងជីវិតរបស់គេ គឺដើម្បីរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់គេ។ អែសរ៉ាបានរៀនព្រះបន្ទូលរបស់ព្រះអម្ចាស់ ដើម្បីនឹងរស់នៅទៅព្រះបន្ទូលនោះ។ (អែសរ៉ា 7:10 ពីព្រោះអែសរ៉ាបានតាំងចិត្តស្វែងរកក្នុងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ដើម្បីនឹងប្រព្រឹត្តិតាម ហើយបង្ហាត់បង្រៀនតាមបញ្ញាត្ត នឹងសេចក្តីយុត្តិធម៌ក្នុងពួកអ៊ីស្រាអែល។) ពីព្រោះព្រះគម្ពីរការពារភាពអស់កល្បរបស់យើង គាត់ស្តាប់បង្គាប់ដោយស្មោះត្រង់។ យើងត្រូវរៀនការបីយ៉ាង ការសិក្សា ការស្តាប់បង្គាប់ និងការប្រកាសរបស់អែសរ៉ាដែលធ្វើនៅក្នុងព័ន្ធកិច្ចរបស់គាត់។

បើទោះជាយ៉ូហាន ម៉ាកុសមិនបានរក្សាការសំរេចចិត្តរបស់គាត់នៅក្នុងព័ន្ធកិច្ចរបស់គាត់ដោយសារបញ្ហាមួយចំនួនក៏ដោយ។ ដូច្នេះគាត់បានបោះបង់ព័ន្ធកិច្ចរបស់គាត់ចោល។ កាន់តែពិបាកថែមទៀតគាត់ត្រូវបានហៅថាជាកូនដោយប៉ូល នៅពេលនោះអាកប្បកិរិយារបស់គាត់ពេញដោយសេចក្តីសោកសៅ។ ជាពិសេសយើងត្រូវធ្វើការសំរេចចិត្តដើម្បីនឹងរក្សាពេញស្បៀមស្វាត់ជារៀងរាល់ថ្ងៃ។ ប្រសិនបើអ្នកធ្វើការសំរេចចិត្តទៅកាន់ព័ន្ធកិច្ចរបស់អ្នកនៅចំពោះព្រះ នោះអ្នកនឹងជួបការដ៏អស្ចារ្យ។

**ទីពីរ វាជាការរក្សាពួកគេដោយអស់ពីចិត្ត (34)**

សូមទ្រង់ផ្តល់ឲ្យទូលបង្គំមានការយល់ដឹង ដើម្បីឲ្យទូលបង្គំរក្សាក្រឹត្យវិន័យនិងរក្សាព្រះបន្ទូលរបស់ទ្រង់នៅក្នុងចិត្តរបស់ទូលបង្គំ។ហើយគាត់បានថ្វាយខ្លួនរបស់គាត់ក្នុងការរៀនព្រះបន្ទូលរបស់ព្រះ។ ចិត្តដែលថ្វាយបង្គំមានន័យថា ជាការរក្សាព្រះបន្ទូលរបស់ព្រះ។ បន្ទាប់ពីនោះមក ភាពជោគជ័យនឹងបានដើរតាមនៅក្នុងជីវិតរបស់អ្នក។ (ម៉ាថាយ 6:33) "ចូរស្វែង

រកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង។" ការសំរេចចិត្តរបស់យើងមិនមែនបង្កើតមកដោយការសំរេចចិត្តរបស់មនុស្សទេ ប៉ុន្តែដោយចិត្តរបស់ខ្ញុំ និងគតិដ៏ល្អរបស់ខ្ញុំ។ បន្ទាប់ចេញពីចិត្តរបស់យើង នឹងបំភ្លឺនឹងពេញដោយសេចក្ដីសង្ឃឹមនិងនិម្មិតដ៏អស្ចារ្យ។ នៅពេលដែលយើងស្ដាប់ទៅកាន់ការអធិប្បាយនៅក្នុងទីបរិសុទ្ធ យើងត្រូវតែរៀនសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ។ នៅពេលនោះ នៅពេលយើងស្ដាប់នូវអត្ថបទព្រះគម្ពីរមួយចំនួននិងការបកស្រាយរបស់អ្នកអធិប្បាយផងនោះ យើងត្រូវតែជឿថា ជាព្រះបន្ទូលដែលខ្សឹបប្រកាសមកពីព្រះដ៏មានព្រះជន្មរស់។ ទទួលព្រះបន្ទូលរបស់ទ្រង់នៅក្នុងចិត្តរបស់អ្នក។ ការសំរេចនៅក្នុងចិត្តអាចគ្របគ្រងរូបកាយនិងជីវិតរបស់យើងទាំងមូល។ ដូច្នេះយើងត្រូវតែរៀបចំចិត្តរបស់យើងជាបល្ល័ង្គចម្បងនៃឥរិយាបថរបស់យើងទាំងស្រុង។ នៅពេលដែលយើងមានដីល្អ នោះមានន័យថាចិត្តដែលល្អការស៊ូទ្រាំនិងការស្ដាប់បង្គាប់ នឹងបង្កើតផលជា 30, 60 និង 100 នៅក្នុងជីវិតរបស់យើង។

**ទីបី គាត់បានទទួលការនោះទុក្ខដូចជាប្រភពនៃជីវិតរបស់គាត់ (36)**

"សូមធ្វើឲ្យចិត្តទូលបង្គំល្អៀងទៅខាងសេចក្ដីបន្ទាល់របស់ទ្រង់ កុំឲ្យល្អៀងទៅខាងសេចក្ដីលោភឡើយ"។ ដោយសារគាត់ប្រាកដថាគ្រឹះរបស់គត់ាជាការរក្សាព្រះបន្ទូលរបស់ព្រះ ហើយគាត់ចង់រក្សាដោយអស់ពីចិត្តយ៉ាងស្មោះត្រង់។ ហើយគាត់ដឹងថា វាជាជ័យជំនះនៅក្នុងជីវិតរបស់គាត់។ នៅថ្ងៃនេះ យើងគួរតែរក្សាព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរស់នៅរបស់យើង គោលបំណងនៃជ័យជំនះនៅក្នុងជីវិតដូចអ្វីដែលដានីយ៉ែលបានធ្វើ។ (ដានីយ៉ែល 1:8) "ប៉ុន្តែដានីយ៉ែលបានសំរេចនៅក្នុងចិត្តថា មិនព្រមឲ្យខ្លួនសៅហ្មង ដោយអាហាររបស់ស្តេច ឬដោយស្រាទំពាំងបាយជូរដែលទ្រង់ធ្លាប់សោយឡើយ បានជាលោកសូមចៅហ្វាយលើពួកកំរៀវ ដើម្បីមិនឲ្យខ្លួនត្រូវសៅហ្មង។"

**សរុបសេចក្ដី៖**

ចូររៀនពីឥរិយាបថដ៏ត្រឹមត្រូវរបស់ពួកបរិសុទ្ធ។ បន្ទាប់មកអ្នកនឹងបានពិសោធន៍នូវការដ៏អស្ចារ្យនៅក្នុងជីវិតរបស់អ្នក។ ចូរដើរតាមតួអង្គគំរូនៅក្នុងជីវិតរបស់អ្នក។ បើទោះជាអ្នក

មានទុក្ខលំបាកណាមួយក៏ដោយ សូមកុំបោះបង់ចោលការដើរតាមព្រះបន្ទូលរបស់ព្រះ។ ខ្ញុំជឿថា ពេលវេលារបស់យើងត្រូវការការសំរេចចិត្តរបស់ Richard Baxter ដែលបានធ្វើនៅក្នុងជីវិតរបស់គាត់។ គាត់ចង់បំរើក្រុមជំនុំមួយ។ ថ្ងៃមួយគាត់បានទៅទីក្រុង Kidderminster ជាកន្លែងដែលពេញដោយភាពក្រីក្រនិងអំពើបាបនៅក្នុងផ្ទះ។ បន្ទាប់ពីគាត់បានបញ្ចប់ព័ន្ធកិច្ចរបស់គាត់នៅទីក្រុងដ៏វេទនានោះវាត្រូវបានផ្លាស់ប្រែទៅជាទីដែលពេញដោយព្រះនិងមនុស្សល្អៗ។សូមឲ្យព្រះគុណរបស់ព្រះនៅជាមួយអ្នកនិងការសំរេចចិត្តរបស់អ្នកនៅចំពោះព្រះបន្ទូលរបស់ទ្រង់។

**សេចក្តីសង្ខេប**

1. ការបើកសំដែងរបស់ព្រះមេស៊ីជាព្រះគម្ពីរ
2. ការពិសោធន៍លើព្រះគម្ពីរ
3. លក្ខណៈរបស់ព្រះគម្ពីរ

## 4. និម្មិតនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ (ទំនុកដំកើង 96)

**សេចក្តីផ្តើម:**

1. នៅក្នុងជំណាក់កាលនេះ យើងកំពុងគិតអំពីការប្រោសលោះនៅក្នុងទំនុកដំកើងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ រហូតមកដល់ពេលនេះ យើងបានគិតថា សេចក្តីពិតនៃរូបឆ្លុះរបស់ខ្លួននៅក្នុងភាពជាស្តេចរបស់ព្រះមេស៊ី ការសុគតរបស់ទ្រង់ និងការបើកសំដែងរបស់ទ្រង់។ បច្ចុប្បន្ននេះ យើងគិតថាភាពជាស្តេចដ៏ពេញលេញរបស់ព្រះមេស៊ីដោយផ្អែកលើទំនុកដំកើង 96:។

2. ជាទូទៅ ទំនុកដំកើង 96: ត្រូវបានរៀបរៀងឡើងនៅក្នុងទំនុកដំកើងរបស់ភាពជាស្តេចដ៏នៅស្ថានសួគ៌ជាមួយទំនុកដំកើង 47: 93: 95: 97: 98: 99:មានន័យថាទ្រង់ដែលជាស្តេចដ៏មានឥទ្ធិឫទ្ធិគ្រប់គ្រងលើផែនដីនិងស្ថានសួគ៌។ មានន័យថា នៅពេលដែលទ្រង់គ្រប់គ្រងគ្រប់យ៉ាងនៅក្នុងយើង យើងបង្ហាញពីរូបឆ្លុះរបស់ព្រះ ដែលមាន សេចក្តីសុចរិត សេចក្តីមេត្តា

និងសេចក្តីស្មោះត្រង់។

3. ដោយការសង្កេតលើអត្ថបទយើងអាចយល់ភាពជាស្តេចនាស្ថានសួគ៌ភាពជអម្ចាស់ដែលមានគ្រប់ចេស្តារបស់របស់ទ្រង់នៅក្នុងគ្រប់ការទាំងអស់ ដោយការអនុវត្តគោលការណ៍ដប់យ៉ាងនៅក្នុងអត្ថបទ។

## I. ការសង្កេតនិងការបកស្រាយ

**2.** តើយើងគួរច្រៀងពីអ្វីដល់ព្រះអម្ចាស់**?** (ខ១) - បទចម្រៀងថ្មី - សេចក្តីសង្គ្រោះរបស់ទ្រង់ សេចក្តីសុចរិតនិង សេចក្តីមេត្តាករុណារបស់ទ្រង់។

**3.** តើយើងត្រូវធ្វើអ្វីខ្លះចំពោះព្រះអម្ចាស់**?** - ច្រៀង, ប្រាប់, ប្រកាស,

**4.** ហេតុអ្វីយើងគួរច្រៀងថ្វាយព្រះអម្ចាស់**?** - ដោយសារតែទ្រង់គឺជាព្រះអាទិករ, អង្គប្រោសលោះនិងព្រះដែលផ្គត់ផ្គង់។

## II. ការអនុវត្ត

ចូរច្រៀងបទថ្មីថ្វាយព្រះយេហូវ៉ា ចូរឲ្យជនទាំងឡាយនៅផែនដីច្រៀងថ្វាយព្រះយេហូវ៉ាចុះ។ ចូរច្រៀងថ្វាយព្រះយេហូវ៉ា ហើយក្រាបថ្វាយបង្គំដល់ព្រះនាមទ្រង់ ចូរសំដែងចេញនូវសេចក្តីសង្គ្រោះរបស់ទ្រង់រាល់តែថ្ងៃតទៅ។ ចូរថ្លែងប្រាប់ពីសិរីល្អទ្រង់ នៅកណ្តាលអស់ទាំងសាសន៍ ហើយពីការអស្ចារ្យរបស់ទ្រង់នៅកណ្តាលបណ្តាជនទាំងឡាយ។ ដ្បិតព្រះយេហូវ៉ាទ្រង់ធំប្រសើរ ហើយគួរសរសើរណាស់ ទ្រង់ជាទីគួរកោតខ្លាចលើសជាងអស់ទាំងព្រះ។ ពីព្រោះអស់ទាំងព្រះរបស់សាសន៍ដទៃសុទ្ធតែជារបស់ឥតប្រយោជន៍ តែព្រះយេហូវ៉ាវិញ ទ្រង់បានបង្កើតផ្ទៃមេឃ។ កិត្តិយសនិងតេជានុភាពនៅចំពោះទ្រង់ឥទ្ធិឫទ្ធិ និងភាពលំអរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់។ ចូរថ្លែងប្រាប់ពីព្រះយេហូវ៉ា អស់ទាំងពូជពង្សនៃសាសន៍ទាំងឡាយអើយ ចូរថ្លែងប្រាប់ពីព្រះយេហូវ៉ាថា ទ្រង់មានសិរីល្អនិងព្រះចេស្តា។ ចូរថ្លែងប្រាប់ពីព្រះយេហូវ៉ាថា ព្រះនាមទ្រង់មានសិរីល្អ ចូរនាំដង្វាយចូលមកទីលានរបស់ទ្រង់។ ចូរថ្វាយបង្គំដល់ព្រះយេហូវ៉ា ដោយពាក់គ្រឿងដ៏បរិសុទ្ធ ឱផែនដីទាំងមូលអើយ ចូរញាប់ញ័រនៅជំពោះទ្រង់ចុះ។ ចូរពោលនៅកណ្តាលអស់ទាំងសាសន៍ ថាព្រះយេហូវ៉ាទ្រង់គ្រប់គ្រងឯលោកិយ ក៏បានតាំងមាំ

មួននៅ នឹងរង្គើមិនបានឡើយ ទ្រង់នឹងជំនុំជំរះគ្រប់ទាំងសាសន៍ដោយទៀតត្រង់។ ចូរឲ្យផ្ទៃមេឃមានសេចក្តីអំណរ ហើយឲ្យផែនដីបានរីករាយឡើង ឲ្យសមុទ្រលាន់ឮរំពងឡើង ព្រមទាំងរបស់សព្វសារពើនៅក្នុងនោះដែរ។ ចូរឲ្យស្រែចំការ និងរបស់ទាំងប៉ុន្មាន ដែលមាននៅទីនោះ បានសប្បាយឡើងយ៉ាងក្រៃលែង នោះអស់ទាំងដើមឈើនៅព្រៃនឹងច្រៀងដោយអំណរដែរ។ គឺនៅចំពោះព្រះយេហូវ៉ា ដ្បិតទ្រង់យាងមក គឺទ្រង់យាងមក ដើម្បីនឹងជំនុំជំរះលោកិយ ដោយសេចក្តីសុចរិត ព្រមទាំងសាសន៍ទាំងប៉ុន្មាន ដោយសេចក្តីពិតត្រង់របស់ទ្រង់។

## គោលការណ៍

1) ព្រះអម្ចាស់សោយរាជ្យ [ខ10]

2) ព្រះអម្ចាស់ជាព្រះមានឥទ្ធិឫទ្ធិចេស្តានៅក្នុងសេចក្តីសុចរិតនិងយុត្តិធម៌ [ខ 10-13]

3) ព្រះអម្ចាស់ជាព្រះមានឥទ្ធិឫទ្ធិចេស្តាលើអស់ទាំងព្រះ [ខ 4-6]

4) ព្រះអម្ចាស់ជាព្រះមានឥទ្ធិឫទ្ធិចេស្តាក្នុងការបង្កើត [ខ 1-5] [ខ 10-13]

5) ព្រះអម្ចាស់ជាព្រះមានឥទ្ធិឫទ្ធិចេស្តាលើប្រជាជាតិ [ខ 1, 3, 9]

6) ព្រះអម្ចាស់ជាព្រះមានឥទ្ធិឫទ្ធិចេស្តានៅក្នុងការជំនុំជំរះ [ខ 13]

7) ព្រះអម្ចាស់ជាជាព្រះមានឥទ្ធិឫទ្ធិចេស្តាក្នុងភាពបរិសុទ្ធរបស់ទ្រង់ [ខ 9]

## III. សេចក្តីសង្ខេបៈ

1. មានតែព្រះត្រីឯកទេដែលមានអំណាចគ្រប់គ្រង និងសោយរាជ្យនៅផែនដីនិងនៅស្ថានសួគ៌។
2. គោលដៅចុងក្រោយរបស់ទ្រង់ត្រូវបានសំរេចបំពេញ ដោយតួអង្គរបស់ទ្រង់នៅក្នុងទាំងអស់។ (អេភេសូរ 3:19 "ហើយឲ្យបានស្គាល់សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដែលរកគិតមិនយល់ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានពេញដោយគ្រប់ទាំងសេចក្តីពោរពេញរបស់ផងព្រះ។")

3. ផលផ្លែនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះនឹងគ្រប់គ្រងលើផែនដីនិងស្ថានសួគ៌។ អ្នកនិពន្ធទំនុកដំកើងរីករាយនឹងការពិតនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ សេចក្តីសុចរិត សេចក្តីមេត្តាករុណា និងភាពស្មោះត្រង់។

## 5. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះបង្ហាញនៅក្នុងទំនុកដំកើង (ទំនុកដំកើង 17:13-15)

ឱព្រះយេហូវ៉ាអើយ សូមទ្រង់ក្រោកឡើងរាំងផ្លូវគេ សូមផ្តួលគេចុះ ហើយជួយព្រលឹងទូលបង្គំឲ្យរួចពីមនុស្សអាក្រក់ ដោយសារដាវនៃទ្រង់។ ឲ្យរួចពីមនុស្សដោយព្រះហស្តទ្រង់ ឱព្រះយេហូវ៉ាអើយ គឺឲ្យរួចពីមនុស្សនៅលើលោកិយនេះ ដែលមានចំណែករបស់គេនៅក្នុងជីវិតនេះប៉ុណ្ណោះ ហើយដែលពោះគេបានឆ្អែត ដោយសារទ្រព្យរបស់ទ្រង់ គេបានស្កប់ចិត្តដោយមានកូនច្រើន ហើយក៏ចែកសំណល់នៃទ្រព្យសម្បត្តគេដល់កូនចៅរបស់ខ្លួន។ ឯទូលបង្គំវិញ ទូលបង្គំនឹងរំពឹងមើលព្រះភក្ត្រទ្រង់ដោយសេចក្តីសុចរិត កាលណាទូលបង្គំភ្ញាក់ឡើង នោះនឹងបានស្កប់ចិត្តដោយឃើញរូបអង្គទ្រង់។

### សេចក្តីផ្តើម៖

ម្នាក់ដែលស្នាក់នៅភ្នំបរិសុទ្ធជាម្នាក់ដែលដើរជាមួយនឹងព្រះអម្ចាស់ (ទំនុកដំកើង15:1-5) ខ 2-5 បង្ហាញនូវរបស់ដែលមានលក្ខណៈគ្រប់គ្រាន់ដប់យ៉ាងដូចជាបញ្ញាត្តទាំងដប់ប្រការ។ តើទាំងនោះជាអ្វី?″ គឺជាអ្នកណាដែលដើរដោយទៀតត្រង់ (អ្នកដែលទៀងត្រង់) ហើយប្រព្រឹត្តដោយសុចរិត (អ្នកសុចរិត) ព្រមទាំងពោលសេចក្តីពិតពីក្នុងចិត្តផង (ជាមនុស្សដែលនិយាយដោយពិតត្រង់)។ ជាអ្នកដែលមិនពោលបង្កាច់ដោយអណ្តាត (មនុស្សដែលមិនចេះមួលបង្កាច់) ឬធ្វើអាក្រក់ដល់មិត្តសំឡាញ់ (មនុស្សដែលមានទំនាក់ទំនងល្អ) ឬយករឿងបកកេរពីអ្នកជិតខាងខ្លួនឡើយ (មនុស្សដែលមិនចេះរិះគន់)។ ជាអ្នកដែលមានភ្នែកមើលមនុស្សពាលដោយសេចក្តីស្អប់ខ្ពើម (មនុស្សដែលស្អប់សេចក្តីអាក្រក់) តែលើកមុខអស់អ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ាវិញ (អ្នកដែលស្រឡាញ់ដល់អ្នកដែលគោរពកោតខ្លាចដល់ព្រះ) ជាអ្នកដែលហ៊ានស្បថដល់បង់ប្រយោជន៍ខ្លួនផង (អ្នកដែលរក្សាសេចក្តីសន្យារបស់ខ្លួន) ឥតប្រែប្រួល

ឡើយ (អ្នកដែលមិនចេះប្រែប្រួល)។ ជាអ្នកដែលមិនបញ្ចេញប្រាក់ខ្លួន ដើម្បីយកការសោះ (អ្នកដែលផ្តល់ផល់ប្រយោជន៍ដល់អ្នកជិតខាងរបស់ខ្លួន) ក៏មិនទទួលសំណូកទាស់នឹងមនុស្សឥតមានទោស (ជាអ្នកដែលទទួលមនុស្សដែលមិនមានទោស)។"
ពាក្យមួយថា ពួកគេជាមនុស្សដែលបង្ហាញពីសេចក្តីសុចរិត សេចក្តីសប្បុរស និសភាពស្មោះត្រង់ ដោយសារសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា។ ខ្ញុំគិតពួកគេនៅក្នុងទស្សនៈមួយថាជាឧបករណ៍ដែលសាកសមដូចនឹងរូបឆ្លុះរបស់ព្រះ។

## I. មានតែអ្នកដែលមានការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះបុណ្ណោះដែលអាចឈរដោយរឹងមាំនៅលើភ្នំបរិសុទ្ធ

អ្នកដែលសរសេរទំនុកដំកើងបង្ហាញរបស់១០យ៉ាងទុកជាលក្ខខណ្ឌដែលសាកសមដែលអាចឈររឹងមាំនៅលើភ្នំបរិសុទ្ធ។

### 1. ទីមួយ ជាសេចក្តីសុចរិត

1) ខ2 បង្ហាញពីសេចក្តីសុចរិត។ "គឺជាអ្នកណាដែលដើរដោយទៀតត្រង់ ហើយប្រព្រឹត្តដោយសុចរិត ព្រមទាំងពោលសេចក្តីពិតពីក្នុងចិត្តផង។" តើសេចក្តីសុចរិតជាអ្វី?*Chadek* នៅក្នុងភាសាហេព្រើរមានន័យថាជា សេចក្តីសុចរិតនៅក្នុងគ្រប់ជ្រុងជ្រោយទាំងអស់សេចក្តីយុត្តិធម៌ សេចក្តីសុចរិតនៃសេចក្តីសង្គ្រោះ។ វាចង្អុលទៅកាន់គុណភាពទាំងស្រុង។ ព្រះអម្ចាស់ជាគំរូតែមួយគត់ និងជាព្រះបន្ទូលរបស់ព្រះ ជាស្តង់ដានៅក្នុងគ្រប់ការទាំងអស់។ នេះជាគ្រឹះនៃសីលធម៌ទាំងអស់ ប្រៀបដូចជាអាគារដែលឈរនៅលើគ្រឹះ។ ប្រសិនបើគ្មាគ្រឹះមួយនេះទេ គ្រប់ទាំងជីវិតដ៏ល្អនិងស្មោះត្រង់ទាំងអស់ នោះគ្មានអត្ថន័យអ្វីទាំងអស់។ សេចក្តីកំពុតនឹងត្រូវបានលេចមកនៅក្នុងទីខាងក្រៅ។ សេចក្តីសប្បុរសដែលគ្មានសេចក្តីសុចរិតមិនមែនជាសេចក្តីសប្បុរសទេ។ សេចក្តីស្មោះត្រង់ដោយគ្មានសេចក្តីសុចរិតមិនមែនជាសេចក្តីស្មោះត្រង់ទេ។ ដូច្នេះព្រះអម្ចាស់បានផ្តល់សេចក្តីសុចរិតដល់រាស្ត្ររបស់ទ្រង់ ដើម្បីនឹងសង្គ្រោះរាស្ត្រទ្រង់ចេញពីសេចក្តីទុច្ចរិតរបស់ពួកគេ។ បើទោះជាយើងមិនមានសេចក្តីសុចរិតក៏ដោយ

ដោយសារសេចក្តីជំនឿយើងបានទទួលសេចក្តីសុចរិតរបស់ព្រះគ្រីស្ទមកជារបស់យើង យើងអាចទទួលបានកម្មសិទ្ធិនូវសេចក្តីសុចរិតរបស់ព្រះជាម្ចាស់។ រ៉ូម 3:21 មានបន្ទូលថា "[21]ប៉ុន្តែ ឥឡូវនេះ ក្រៅពីក្រឹត្យវិន័យ សេចក្តីសុចរិតផងព្រះដែលមានទាំងក្រឹត្យវិន័យ នឹងពួកហោរាធ្វើបន្ទាល់ឲ្យផង នោះបានលេចចេញមកហើយ។ [22]គឺជាសេចក្តីសុចរិតរបស់ព្រះ ដែលបានដោយសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ក៏សំរាប់គ្រប់អស់អ្នកណាដែលជឿផង ដ្បិតគ្មានខុសអំពីគ្នាទេ។ [23]ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ។ [24]តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ ដោយសារសេចក្តីប្រោសលោះដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ។"

2) ដោយសារសេចក្តីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងបានសង្គ្រោះចេញពីអំពើបាបដ៏អាក្រក់របស់យើង។ ពិតណាស់យើងមិនអាចទៅកាន់ស្តង់ដាសេចក្តីសុចរិតរបស់ព្រះអម្ចាស់បានឡើយ ប៉ុន្តែព្រះអម្ចាស់បានទទួលសេចក្តីជំនឿរបស់យើង ដែលយើងបានទទួលសេចក្តីសុចរិតរបស់ព្រះគ្រីស្ទមកជាសេចក្តីសុចរិតរបស់យើង។ បន្ទាប់មកយើងនឹងក្លាយជាមនុស្សខាងសេចក្តីសុចរិតនៅក្នុងជីវិតរបស់យើង។ ដូច្នេះប៉ូលបានសង្កត់ថា "ហេតុនោះនៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសលោះ ដ្បិតអំណាចរបស់ព្រះវិញ្ញាណនៃជីវិត ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះបានប្រោសឲ្យខ្ញុំរួចពីអំណាចរបស់អំពើបាប នឹងសេចក្តីស្លាប់ហើយ។" (រ៉ូម 8:1-2)

អត្ថបទបង្ហាញសេចក្តីសុចរិតជា "គឺជាអ្នកណាដែលដើរដោយទៀតត្រង់ ហើយប្រព្រឹត្តដោយសុចរិត" "ហើយជាអ្នកស្អប់ខ្ពើមដល់មនុស្សពាល ប៉ុន្តែគោរពដល់អ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ាវិញ។" យើងគួរតែរស់នៅដោយស្មោះត្រង់ សុចរិតនៅចំពោះព្រះជាម្ចាស់និងនៅចំពោះអ្នកជិតខាងរបស់យើង ពីព្រោះយើងចាប់ផ្តើមដោយសេចក្តីសុចរិត ហើយដើរដោយសេចក្តីសុចរិត និងបញ្ចប់ដោយសេចក្តីសុចរិត និងទទួលមកុដនៃសេចក្តីសុចរិតនៅក្នុងនគរនៃសេចក្តីសុចរិត។ ព្រះអម្ចាស់នឹងប្រទានពរដល់យើង ដើម្បីនឹងបំភ្លឺរស្មីនៃសេចក្តីសុចរិតចេញមកពីព្រះគ្រីស្ទ។

2. **ទីពីរ ជាសេចក្ដីសប្បុរស**

1) អត្ថបទពន្យល់សេចក្ដីសប្បុរសថា"ជាអ្នកដែលមិនពោលបង្កាច់ដោយអណ្ដាតឬធ្វើអាក្រក់ដល់មិត្តសំឡាញ់ឬយករឿងបកកេរពីអ្នកជិតខាងខ្លួនឡើយ។" ហើយ"ជាអ្នកដែលមិនបញ្ចេញប្រាក់ខ្លួន ដើម្បីយកការសោះ ក៏មិនទទួលសំណូក ទាស់នឹងមនុស្សឥតមានទោស"។

តើអ្វីទៅជាសេចក្ដីសប្បុរស? ជាទូទៅ ប្រជាជនកម្ពុជាល្អ។ ក្មេងភាគច្រើនជាមនុស្សល្អខ្លាំងណាស់។ សិស្សរបស់យើងជាមនុស្សល្អណាស់។ តើខ្ញុំអាចជឿដល់ការនោះទេ? ប៉ុន្តែខ្ញុំមានន័យថា សេចក្ដីសប្បុរសមិនមែននៅចំពោះមនុស្សទេ ប៉ុន្តែនៅចំពោះព្រះនេត្ររបស់ព្រះវិញ។ គ្រីស្ទានត្រូវតែមានចិត្តដែលល្អនិងចរិតល្អនៅចំពោះព្រះ។ ម៉ាថាយ 5:16 មានបន្ទូលថា "ដូច្នេះចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរដំកើង ដល់ព្រះបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌។" ១ពេត្រុស 2:12 មានបន្ទូលថា "ទាំងប្រព្រឹត្តដោយទៀងត្រង់នៅក្នុងពួកសាសន៍ដទៃ ដើម្បីនៅកន្លែងណា ដែលគេនិយាយដើម ពីអ្នករាល់គ្នាទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ នោះឲ្យគេបានសរសើរដល់ព្រះ នៅថ្ងៃដែលទ្រង់យាងមកប្រោស ដោយគេឃើញការល្អរបស់អ្នករាល់គ្នាវិញ។" ហើយប៉ូលក៏បាននិយាយថា "កុំឲ្យសេចក្ដីអាក្រក់អ្នកឈ្នះឡើយ ត្រូវឲ្យអ្នកឈ្នះសេចក្ដីអាក្រក់ ដោយសារសេចក្ដីល្អវិញ។" (រ៉ូម 12:21)

2) ជាពិសេសសេចក្ដីសប្បុរសជាផលផ្លែនៃទំនាក់ទំនងរវាងមនុស្សនិងមនុស្ស។ យើងត្រូវតែមានចិត្តដែលល្អដែលអាចបង្កើតផលជា 30, 60 និង 100 ផលផ្លែល្អនៅក្នុងទំនាក់ទំនងរបស់យើង។ វាមានន័យថា យើងត្រូវតែរស់នៅមានឥរិយាបថជាដង្វាយ។ ដូចជាបាណាបាស់ជាមនុស្សដែលល្អម្នាក់។ (កិច្ចការ 12:24) "គាត់ជាមនុស្សល្អ ពេញដោយព្រះវិញ្ញាណបរិសុទ្ធនិងសេចក្ដីជំនឿ ហើយមនុស្សជាច្រើនត្រូវបាននាំមកព្រះអម្ចាស់។" ព្រះវិញ្ញាណបរិសុទ្ធទ្រង់ជាវិញ្ញាណល្អ (រ៉ូម 8:26-27) "ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្ដីកំសោយរបស់យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាអធិស្ឋានសូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានឡើយ។ ប៉ុន្តែព្រះអង្គដែលស្ទង់ចិត្ត ទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ។" ដំណឹងល្អជាដំណឹងដែលល្អ។ដូច្នេះអ្នកដែលស្គាល់ដំណឹងល្អពិតនឹងស្រឡាញ់ការនោះជាពិត។

តើអ្វីទៅជាគោលដៅនៃការសិក្សារបស់យើង? វាជាការសំរេចនូវសេចក្តីសប្បុរស។ បើទោះជាយើងត្រូវបានការបៀតបៀនដោយគ្មានហេតុផលក៏ដោយ ក៏យើងត្រូវតែឲ្យពរដល់ពួកគេ។ "វេទនាដល់អ្នករាល់គ្នា កាលណាមនុស្សទាំងអស់និយាយល្អពីអ្នករាល់គ្នា ពីព្រោះកាលពីដើម ពួកឰយុកោបានប្រព្រឹត្តនឹងពួកហោរាក្លែងក្លាយយ៉ាងដូច្នោះដែរ។ ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរអ្នករាល់គ្នាស្រឡាញ់ពួកខ្មាំងសត្រូវ ហើយប្រព្រឹត្តល្អនឹងពួកអ្នក ដែលស្អប់អ្នករាល់គ្នាវិញ។" (លូកា 6:27-28) នេះជាចេស្តាដ៏ពិត។ មនុស្សល្អនេះអាចឈរនៅចំពោះព្រះអម្ចាស់ដោយរឹងមាំ។

### 3. ចុងក្រោយជាសេចក្តីស្មោះត្រង់

1) អត្ថបទនិយាយពីសេចក្តស្មោះត្រង់ថា "អ្នកដែលពោលសេចក្តីពិតនៅក្នុងចិត្ត" អ្នកដែលរក្សាសម្បថបើទោះជានាំឲ្យខ្លួនឈឺចាប់ក៏ដោយ ហើយមិនផ្លាស់ប្តូរឡើយ។ "សេចក្តីសុចរិតនិងសេចក្តីសប្បុរសត្រូវបានពឹងទៅលើសេចក្តីស្មោះត្រង់។ បើគ្មានសេចក្តីស្មោះទ្រង់ គ្មានសេចក្តីសុចរិតនិងសេចក្តីសប្បុរសឡើយ។" នាពេលអនាគត ប្រសិនបើអ្នកជ្រើសរើសដៃគូរជីវិតរបស់អ្នក ត្រូវស្វែងរកមនុស្សដែលស្មោះទ្រង់តែមួយប៉ុណ្ណោះ។ បន្ទាប់មកគ្រួសាររបស់អ្នកនឹងឈររឹងមាំនៅចំពោះព្រះ។ អត្ថបទបង្រៀនថា មនុស្សស្មោះត្រង់អាចឈររឹងមាំនៅចំពោះព្រះជាម្ចាស់។ គាត់នឹងបរិភោគនៅចំពោះព្រះ គាត់អាចឈររឹងមាំនៅលើភ្នំបរិសុទ្ធ។ តើអ្វីទៅជាភ្នំបរិសុទ្ធ? វាជាបល្ល័ង្ករបស់ព្រះជាម្ចាស់ដែលពេញដោយព្រះវត្តមានរបស់ទ្រង់។ នៅក្នុងពាក្យមួយទៀតថាជាស្ថានសួគ៌។

នៅក្នុងលោកិយ តើស្ថានសួគ៌នៅឯណា? តើវាជាកន្លែងដែលមានលុយច្រើនឬ? ជាកេរ្តិ៍ឈ្មោះ ឬជាអំណាច ឬជាប្រាជ្ញា? ទេ មានតែសេចក្តីស្មោះត្រង់ប៉ុណ្ណោះដែលមាននៅទីនោះគឺជាស្ថានសួគ៌។ នៅក្នុងចិត្តរបស់អ្នកដោយគ្មានសេចក្តីស្មោះត្រង់ អ្នកមិនអាចភ្លក់ព្រះគុណនៃស្ថានសួគ៌បានឡើយប៉ុន្តែនឹងត្រូវស្ថិតស្ថេរនៅក្នុងសេចក្តីទុក្ខវេទនានៃស្ថាននរកវិញ។

ដូច្នេះផលផ្លែនៃពន្លឺជាសេចក្តីសុចរិត សេចក្តីសប្បុរស និងសេចក្តីស្មោះត្រង់។ នៅថ្ងៃនេះចូរយើងដេញតាមផលផ្លែទាំងនេះដោយជាប់លាប់។

## សរុបសេចក្តី

នៅពេលដែលយើងគិតថាចរិតជីវិតនៃព្រះគម្ពីរ ជាបន្ទាត់តែមួយនឹងជីវិតនិងសេចក្តីរស់ឡើងវិញរបស់ទ្រង់។ កម្លាំងដ៏ខ្លាំងនៅក្នុងព្រះគ្រីស្ទនឹងធ្វើការនៅក្នុងការយល់ដឹងលើព្រះគម្ពីរ។ សេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទនឹងត្រូវបានបង្ហាញដោយជីវិតដែលរស់ពីស្លាប់ឡើងវិញនៅក្នុងលោកិយ។ ដូច្នេះយើងមានការភ្ញាក់ផ្អើលដោយសារជីវិតនេះ។
ប្រសិនបើយើងជាមនុស្សដែលមិនដើរជាមួយនឹងព្រះជាម្ចាស់ នោះយើងមិនអាចទៅដល់ស្តង់ដារនោះឡើយ។ នៅពេលដែលយើងដើរតាមព្រះវិញ្ញាណដោយការជឿលើព្រះគ្រីស្ទ នោះនឹងអាចបង្កើតលក្ខណ:បី ជាសេចក្តីសុចរិត សេចក្តីសប្បុរស និងសេចក្តីស្មោះត្រង់ដោយសារកិច្ចការរបស់ព្រះវិញ្ញាណ។ ជារៀងរាល់ថ្ងៃ នៅពេលដែលយើងចូលជិតបល្ល័ង្គនៃព្រះគុណ យើងអាចត្រូវបានផ្លាស់ប្តូរជារៀយៗដូចទៅនឹងរូបឆ្លុះរបស់ព្រះជាម្ចាស់។ ប្រសិនបើយើងបាត់បង់នូវស្តង់ដារនេះ នោះយើងត្រូវតែនៅជាប់នឹងព្រះគ្រីស្ទយេស៊ូវ។ ពីព្រោះទ្រង់ជាស្តង់ដាតែមួយគត់ ដែលព្រះអម្ចាស់បានប្រទានពរដល់យើង ដើម្បីឲ្យឈររឹងមាំនៅលើភ្នំបរិសុទ្ធ និងរីករាយនូវព្រះគុណដ៏បរិបូរ។

## II. ប្រភពដើម្បីនឹងស្តារឡើងវិញនូវរូបឆ្លុះរបស់ ព្រះ

### 1. ការតាំងសញ្ញានៃព្រះគុណ (សេចក្តីប្រោសលោះ)

ប្រភពនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ជាការតាំងសញ្ញារបស់ទ្រង់។ ការតាំងសញ្ញានៃសេចក្តីប្រោសលោះដែលជាការសំរេចរបស់ព្រះត្រៃឯកបានធ្វើឡើងមុនពេលនៃការបង្កបង្កើតម្លេះ គឺជាប្រភពនៃការស្តារឡើងវិញទាំងអស់ (សេចក្តីប្រោសលោះ)។ ពួកបរិសុទ្ធនៅក្នុងសញ្ញាចាស់រីករាយនឹងប្រភពនេះ។ ការទូលអង្វររបស់ដាវីតតាមរយៈការលន់តួបាបដ៏ពិតនោះពឹងទៅលើការនោះឯង។ ទំនុកដំកើង 51:1-19 បង្ហាញយ៉ាងច្បាស់មកកាន់យើង។ ដាវីតដែលបានធ្វើអំពើបាបយ៉ាងធ្ងន់ បានលន់តួបាបទៅកាន់ព្រះ ដោយការទទួលការស្តីបន្ទោសរបស់ហោរា ណាថាន់។ តើគាត់បានអនុវត្តសេចក្តីប្រោសលោះទៅកាន់សភាពរបស់គាត់

ដោយរបៀបណា? ទីមួយ គាត់លន់តួទៅកាន់សេចក្ដីស្រឡាញ់និងសេចក្ដីសុចរិតរបស់ព្រះអម្ចាស់ (1)។ គាត់បានដឹងថា មានតែសេចក្ដីស្រឡាញ់និងសេចក្ដីមេត្តារបស់ព្រះអម្ចាស់ប៉ុណ្ណោះដែលអាចអត់ទោសឲ្យយើងបាន។ (1) ហើយបានរកឃើញថា គាត់បានជឿថា គាត់នឹងបានស្អាតពីអំពើបាបរបស់គាត់ដោយព្រះលោហិតរបស់ព្រះគ្រីស្ទ (7)។ ហើយគាត់បានពិសោធន៍នូវអំពើបាបរបស់គាត់នៅចំពោះសេចក្ដីសុចរិតរបស់ព្រះអម្ចាស់។

ទីពីរ គាត់បានទទួលស្គាល់អំពើបាបរបស់គាត់។ គាត់ដឹងពីអំពើបាបរបស់គាត់ដោយលំអិត (3, 14) ហើយមានអារម្មថាមានកំហុស (2) ហើយគាត់ក៏បានដឹងពីឥទ្ធិពលនៃអំពើបាបដែរ (9)។ ហើយគាត់បានសារភាពពីភាពពិតរបស់គាត់នៅក្នុងចិត្ត។ (6) គាត់ចង់ឲ្យគំនិតដែលខូចអាក្រក់របស់គាត់នឹងត្រូវផ្លាស់ប្ដូរទៅជាឧត្ដមគតិដែលល្អ។ (10)

ទីបី គាត់បានធ្វើការសំរេចចិត្តរស់នៅក្នុងជីវិតស្មោះត្រង់។ គាត់បានធ្វើការសំរេចចិត្តនូវជីវិតដែលស្មោះត្រង់ (10) ជីវិតដែលនៅជាប់នឹងព្រះវិញ្ញាណបរិសុទ្ធ (11) ជីវិតដែលថ្វាយដាច់ដោយឆន្ទ: (12) ជីវិតដែលជាបន្ទាល់ (13) ជីវិតដែលពេញដោយការសរសើរដំកើង (14) និងជីវិតដែលជាដង្វាយ (19)។

## 2. ការបើកសំដែង

ទំនុកដំកើង 19 ផ្តោតលើការសរសើរដំកើងនៃការបើកសំដែង ឬជាការសរសើរដំកើងរបស់ព្រះគម្ពីរ។ ខ 1-6 បើកសំដែងពីភាពបែបធម្មជាតិ ឬការបើកសំដែងទូទៅ ហើយខ 7-14 បើកសំដែងពីការបើកសំដែងនៃសេចក្ដីប្រោសលោះតាមរយ: Torah (ក្រឹត្យវិន័យ) គឺពិតជាច្បាស់លាស់និងស្អុប់ស្អល់ណាស។ ខ្ញុំផ្ទាល់ស្រឡាញ់ទំនុកដំកើងនេះណាស់ ពីព្រោះវាបានបង្ហាញពីបទពិសោធន៍នៅក្នុងព្រះគម្ពីរ។ ខ្ញុំអះអាងថា គ្រប់គ្រីស្ទានទាំងអស់គួរតែមានបទពិសោធន៍នូវការស្អុប់ស្អល់នៃព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់គេ។ ខ្ញុំចង់មានន័យថាចេស្ដារបស់ព្រះបន្ទូលរបស់ព្រះគួរតែត្រូវបានភ្លក់នៅក្នុងចិត្តរបស់គេដោយជំនួយរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូចជាបន្ទាល់របស់អ្នកសរសេរទំនុកដំកើងថា ព្រះគម្ពីរមានលក្ខណ:ដ៏មានតម្លៃ យើងអាចសារភាពនូវការនោះដូចគ្នានៅក្នុងការយល់ដឹងរបស់យើង។ តើអ្នកមានការសារភាពបែបដូច្នេះដែរឬទេ?

**ទីមួយ** ដាវីតបានពិចារណា "ស្ថានសួគ៌" និង "ផ្ទៃមេឃ" ដើម្បីនឹងប្រកាសពីសិរីល្អរបស់ព្រះអម្ចាស់ (1) "ផ្ទៃមេឃសំដែងសិរីល្អនៃព្រះ ហើយអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ។" ហើយគាត់ក៏បានសារភាពថា បើទោះជាគ្មានពាក្យសំដី ឬសំលេង តែចំណេះដឹងនិងសំលេងដែលបានទំនាក់ទំនងជាមួយលោកិយទាំងមូលបានធ្វើការសំដែងមកយ៉ាងច្បាស់លាស់ (2-4) "ថ្ងៃមួយពោលប្រាប់តដល់ថ្ងៃមួយទៀត ហើយយប់មួយក៏សំដែងចំណេះដល់យប់មួយទៀតដែរ។ ឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ គ្មានអ្នកណាដែលឮសំលេងរបស់ទាំងនោះទេ។ ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមក ក៏ចេញទៅលើគ្រប់ផែនដី ហើយសេចក្តីនោះបានឮទៅដល់ទីបំផុតលោកិយនៅលើមេឃ ទ្រង់បានដំឡើងត្រសាលសំរាប់ព្រះអាទិត្យ"។ ព្រះបានបង្ហាញពីការបើកសំដែងដ៏បរិបូរណ៍ ដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់តាមរយៈធម្មជាតិនិងការយល់ដឹង។ (រ៉ូម 1:19-20) ដាវីតត្រូវបានបើកភ្នែកខាងវិញ្ញាណរបស់គាត់ ហើយបានរកឃើញនូវសេចក្តីពិត ដែលជាចំណេះដឹងរបស់ព្រះត្រូវបានពោរពេញនៅក្នុងលោកីយ។

ពិតណាស់ពីមុខខ្ញុំមិនបានដឹងពីលក្ខណៈពិសេសរបស់ធម្មជាតិទេ បន្ទាប់ពីខ្ញុំបានទទួលនូវសភាពដែលគ្រោះថ្នាក់នៅក្នុងជំងឺខាងរូបកាយរបស់ខ្ញុំ ខ្ញុំបានរកឃើញពិភពលោកមួយថ្មីនៅក្នុងរបស់ធម្មជាតិនៅក្នុងផែនដី។ ខ្ញុំបានសិក្សាពីឱសថធម្មជាតិនៅក្នុងថ្នាំធម្មជាតិ ហើយខ្ញុំបានរៀនអំពីឱសថ៣០០ប្រភេទ នៅសកលវិទ្យាល័យនៅអាមេរិក។ នៅពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើលមែនទែនដោយសារចំណេះដឹងអំពីប្រភេទជាច្រើននៃរុក្ខជាតិ។ ខ្ញុំបានទទួលព្រះគុណមួយចំនួនពីការសង្កេតទៅលើរុក្ខជាតិ។ នៅកម្ពុជាខ្ញុំបានរកឃើញសេចក្តីស្រឡាញ់ដ៏អស្ចារ្យមកកាន់ពួកយើង។ កម្ពុជាមានឱសថជាច្រើននៅក្នុងផែនដីដូចជា ម្រះ ធុរេន ប៉ិគក់ ស្វាយ អំពិល ម្រុំ និងក្រអៅឈូកជាដើម។ ការដែលសំខាន់ជាងនេះទៀតនោះគឺការស្វែងរកនូវសេចក្តីស្រឡាញ់របស់ព្រះ សេចក្តីសប្បុរស និងប្រាជ្ញារបស់ព្រះ។ នៅពេលដែលព្រះបង្កើតលោកីយមក ទ្រង់បានលាក់សេចក្តីស្រឡាញ់ដ៏បរិបូររបស់ទ្រង់និងសេចក្តីពិតនៅក្នុងធម្មជាតិទាំងអស់។ បន្ទាប់ពីអ័ដាមបានធ្លាក់ចុះទៅក្នុងអំពើបាប យើងមិនអាចបើកឬឃើញ

សេចក្តីពិតទៀតឡើយ ទាំងនោះមាន សេចក្តីស្រឡាញ់ សេចក្តីសប្បុរស និងភាពស្មោះត្រង់។
ដាវីតបានឃើញពន្លឺនៃសេចក្តីសង្គ្រោះ។ ហើយយើងក៏បានឃើញពន្លឺនៃធម្មជាតិនៅក្នុងសេចក្តីប្រោសលោះដែរ។ ដូច្នេះយើងត្រូវតែសរសើរព្រះអម្ចាស់ពី ព្រះគុណទូទៅរបស់ទ្រង់នៅក្នុងជីវិតរបស់យើង។

**ទីពីរ** ដាវីតបានប្រាកដថាមានតែការបើកសំដែងដែលកត់ត្រាចុះទេដែលអាចសង្គ្រោះយើងចេញពីអំពើបាប ដែលនោះជាព្រះគម្ពីរ ហើយបានប្រកាសពីប្រសិទ្ធិភាពនិងលក្ខណៈរបស់ព្រះបន្ទូល ដែលមនុស្សត្រូវតែពឹងដល់។ ទីនេះ ក្រឹត្យវិន័យត្រូវបានបង្ហាញជាទីបន្ទាល់ បទបញ្ជា និងការបង្រៀន ដែលជាកណ្ឌគម្ពីរទាំង 66 នៅក្នុងព្រះគម្ពីរ។ ហើយគាត់ក៏បានប្រាកដថា ព្រះគម្ពីរនោះពេញលេញ ពិតប្រាកដ ស្មោះត្រង់ និងបរិសុទ្ធ។ វាបានបើកភ្នែករបស់យើងឲ្យបានមានប្រាជ្ញានិងបរិសុទ្ធ ហើយធ្វើឲ្យយើងបានភ្លក់នូវភាពផ្អែមល្ហែមនៃការបើកសំដែងអស់កល្បជានិច្ច។ អ្នកសរសេរទំនុកដំកើងជាអ្នកដែលមានបទពិសោធន៍នៅក្នុងព្រះគម្ពីរ។ ខ្ញុំមានន័យថា គាត់អាចភ្លក់ពីលក្ខណៈពិសេសដែលជា អំណាចចេស្តានិងជាលក្ខណៈនៃជីវិត។ ដូចជា ហេព្រើរ 4:12 មានបន្ទូលថា "ពីព្រោះព្រះបន្ទូលរបស់ព្រះនោះរស់នៅ ហើយពូកែផងក៏មុតជាងដាវណាមានមុខពីរទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹងនឹងវិញ្ញាណ ហើយសន្លាក់នឹងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិតដែលចិត្តគិត ហើយដែលសំរេចដែរ។" គាត់បានរកឃើញហើយរីករាយ ដែលព្រះបន្ទូលបាននិយាយពីទ្រង់ជាព្រះបន្ទូលរបស់ព្រះ។ ខ្ញុំប្រាកដថាអ្នកសរសេរទំនុកដំកើងមានបទពិសោធន៍ចិត្តដែលឆេះឆួល ទឹកដ៏ត្រជាក់ និងពន្លឺដ៏ភ្លឺនៅក្នុងការទំនាក់ទំនងនូវព្រះបន្ទូលរបស់ព្រះនៅក្នុងពិភពលោកនៃការសញ្ជឹងគិតនោះ។
នៅពេលដែលសិស្សរបស់ Emmaus ស្តាប់ទៅកាន់ការពន្យល់ពីព្រះយេស៊ូវដែលបានរស់ពីស្លាប់ឡើងវិញអំពីព្រះគម្ពីរ។ វាជាបទពិសោធន៍នៃព្រះគម្ពីរ។ ខ្ញុំសង្ឃឹមថា គ្រប់គ្រីស្ទានទាំងអស់គួរតែមានបទពិសោធន៍ការបែបនេះនៅក្នុងពេលសញ្ជឹងគិតរបស់គេ។ ពីព្រោះព្រះទ្រង់មានព្រះជន្មរស់នៅនិងធ្វើការ ហើយព្រះបន្ទូលរបស់ព្រះជាព្រះបន្ទូលដ៏រស់ជានិច្ច។ តើអ្នកមានបទពិសោធន៍បែបនេះនៅក្នុងជីវិតនៅសាលារបស់អ្នកដែរឬទេ?ជារៀងរាល់ថ្ងៃយើង

យើងប្រាថ្នាការបែបនេះ។ ដូចដែលម៉ូសេបានធ្វើ គាត់បានរីករាយសេចក្តីស្រឡាញ់របស់ទ្រង់ និងសេចក្តីពិតនៅវេលាព្រឹកព្រលឹម។ ប្រសិនបើយើងបានភ្លក់នូវសេចក្តីដូច្នេះ យើងត្រូវតែមានអារម្មណ៍ពីគំនិតដែលពិតប្រាកដនៅចំពោះព្រះ។ យើងត្រូវតែស្វែងរកសេចក្តីមេត្តារបស់ទ្រង់។

លើសពីនោះទៀតគាត់បានជឿថា មានតែផ្លូវមួយគត់ដើម្បីនឹងដោះបាប នោះជាការដើរតាមព្រះគម្ពីរ ហើយទទួលយកព្រះគម្ពីរ ដោយការសញ្ជឹងគិតនិងការស្តាប់បង្គាប់។ យើងត្រូវតែជឿថាសេចក្តីសង្គ្រោះចេញមកពីគំនិតដែលពឹងលើការបើកសំដែង។ ព្រះគម្ពីរជាការបើកសំដែងពិសេស។ យើងគួរតែអង្គុយចុះនៅក្រោមពន្លឺនៃការបើកសំដែងនិងរីករាយនឹងរស្មីដែលព្យាបាបនៃសេចក្តីសុចរិត។ នេះជាជីវិតពិតរបស់គ្រីស្ទាន។

## III. ចរន្តនៃការស្តារឡើញវិញនូវរូបឆ្លុះរបស់ព្រះ

### 1. ដោយការនៅជាប់នឹងព្រះគ្រីស្ទ

អត្ថបទបានប្រាប់ពីពិធីប្រារព្ធនូវបល្ល័ង្គរបស់ស្តេច ដាវីតបានប្រកាសថា មានពរហើយអ្នកដែលគោរពដល់ព្រះមេស៊ី។(2:1-12)តើអ្នកណាជាព្រះមេស៊ី?ហើយតើយើងត្រូវស្រឡាញ់ទ្រង់ដោយរបៀបណា? តើពេលណាដែលទ្រង់នឹងយាងមកកាន់យើង?

ទីមួយ ទ្រង់មកកាន់យើងនៅពេលនៃសេចក្តីទុក្ខវេទនា។ ដូចនៅខ 1-3 បង្ហាញថា ទ្រង់ជាស្តេចនៅក្នុងគ្រប់ជាតិសាសន៍ដែលទាស់នឹងទ្រង់ ហើយទ្រង់បានសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីអំពើបាបរបស់គេ។ "[1]ហេតុអ្វីបានជាអស់ទាំងសាសន៍ជ្រួលជ្រើមឡើង ហើយជនជាតិទាំងពួងមានគំនិតជាឥតសារដូច្នេះ?ពួកមហាក្សត្រនៅផែនដីលើកគ្នាឡើងពួកគ្រប់គ្រងទាំងប៉ុន្មានក៏ប្រឹក្សាគ្នាទាស់នឹងព្រះយេហូវ៉ា ហើយទាស់នឹងព្រះអង្គ ដែលទ្រង់បានលាបព្រេងឲ្យដោយពាក្យថា ចូរយើងផ្តាច់ចំណងទ្រង់ ហើយបោះខ្សែរចងរបស់ទ្រង់ពីយើងចេញ។" ពិតណាស់ប្រវត្តិសាស្ត្របង្ហាញថា ទ្រង់បានយាងមកនៅក្នុងពេលដែលច្របូកច្របល់។ នៅពេលដែលព្រះយេស៊ូវយាងមកនៅក្នុងលោកិយ នោះពួកអ៊ីស្រាអែលជ្រួលជ្រើមឡើង។ ម៉ាថាយ 2:2-3 មានបន្ទូលថា "តើព្រះអង្គដែលប្រសូត្រមក ធ្វើជាស្តេចសាសន៍យូដា ទ្រង់គង់នៅ

ឯណា ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់ ពីទិសខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់។ កាលស្តេចហេរ៉ូឌបានឮ នោះទ្រង់មានសេចក្ដីវិតក្កព្រួយ ព្រមទាំងអ្នកនៅក្រុងយេរូសាឡិមទាំងអស់ផង។" និង កិច្ចការ 4:24-26 មានបន្ទូលថា "កាលពួកជំនុំបានឮដូច្នោះ នោះក៏បន្លឺឧទានព្រមគ្នា ទូលដល់ព្រះថា ឱព្រះដ៏ជាម្ចាស់ធំបំផុតអើយ គឺទ្រង់ជាព្រះដែលបង្កើតផ្ទៃមេឃ ផែនដី និងសមុទ្រ ហើយរបស់ទាំងអស់ ដែលនៅស្ថានទាំងនោះផង។ ទ្រង់បានមានបន្ទូល ដោយសារព្រះឱស្ឋហ្លួងដាវីឌ ជាអ្នកបម្រើទ្រង់ថា ហេតុអ្វីបានជាអស់ទាំងសាសន៍ជ្រួលជ្រើម ហើយជនជាតិទាំងប៉ុន្មានមានគំនិតអសារឥតការដូច្នេះ? ពួកមហាក្សត្រនៅផែនដីលើកគ្នាឡើង ពួកគ្រប់គ្រងទាំងប៉ុន្មានក៏ប្រឹក្សាគ្នាទាស់នឹងព្រះអម្ចាស់ ហើយទាស់នឹងព្រះគ្រីស្ទនៃទ្រង់។ ប្រាកដមែន ដ្បិតនៅក្រុងនេះ ស្តេចហេរ៉ូឌ និងលោកប៉ុនទាស-ពីឡាត់ បានប្រជុំគ្នា ព្រមទាំងពួកសាសន៍ដទៃ និងសាសន៍អ៊ីស្រាអែល ទាស់នឹងព្រះយេស៊ូវជាអ្នកបំរើបរិសុទ្ធរបស់ទ្រង់ ដែលទ្រង់បានចាក់ប្រេងតាំងឲ្យ។" ពួកគេបានដកចេញពីទំនុកដំកើង 2:1-3 ដោយការបៀតបៀនរបស់សត្រូវ។ ហើយនៅពេលព្រះយេស៊ូវយាងមកនៅលើផែនដីនៅក្នុងការយាងមកជាលើកទីពីរ នោះស្ថានភាពបែបនេះនឹងកើតឡើងទៀត។ ដូច្នេះប៉ូលបាននិយាយថា "ចូរឲ្យយើងដឹងថា នៅជាន់ក្រោយបង្អស់ នឹងមានគ្រាលំបាកណាស់។ ដ្បិតនៅគ្រានោះ មនុស្សនឹងស្រឡាញ់តែខ្លួនឯង ទាំងស្រឡាញ់ប្រាក់ អួតអាងគឃរ មានឫកខ្ពស់ ប្រមាថមើលងាយ មិនស្តាប់បង្គាប់ឪពុកម្តាយ រមិលគុណ មានចិត្តមិនបរិសុទ្ធ។ មិនស្រឡាញ់តាមធម្មតា មនុស្សគ្មានសេចក្តីអធ្យោគ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិនចូលចិត្តនឹងការល្អ ក្បត់គេ ឥតបើគិត មានចិត្តធំ ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ។ មានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្តែមិនព្រមទទួលស្គាល់ព្រះចេស្តាដែលមកដោយការគោរពប្រតិបត្តិនោះទេ ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ។" (២ ធីម៉ូថេ 3:1-5)

ប្រសិនបើអ្នកនៅក្នុងបរិស្ថានដែលលំបាក ចូរទទួលយកសភាពពិតជាក់ស្តែងនោះដោយសេចក្តីជំនឿ។ បន្ទាប់មកអ្នកអាចធ្វើការថ្មីនៅក្នុងជីវិតរបស់អ្នកនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។ តើពេលណាដែលព្រះគុណរបស់ព្រះនឹងមកកាន់យើង? វាជាពេលដែលយើងរងទុក្ខនៅក្នុងជីវិតរបស់យើង។ ដូច្នេះយើងត្រូវតែពឹងលើព្រះមេស៊ីនិងសេចក្តីមេត្តារបស់ទ្រង់។ ហេតុអ្វី?

ពីព្រោះវាជាការចាំបាច់សម្រាប់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ត្រូវសុគតនៅលើឈើឆ្កាង ដើម្បីនឹងសម្រេចសេចក្តីប្រោសលោះកាលដែលទ្រង់ជាព្រះមេស៊ី ជាស្តេច ជាសង្ឃ និងជាហោរាដ៏ពិតនៅក្នុងនគររបស់ទ្រង់ (4-6)។ ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់របស់យើងជាព្រះមេស៊ី "អញបានតាំងស្តេចរបស់អញឡើងហើយ គឺនៅស៊ីយ៉ូន ជាភ្នំបរិសុទ្ធរបស់អញ។" (6)

ទីពីរ តើយើងស្រឡាញ់ព្រះមេស៊ីដោយរបៀបណា? យើងត្រូវតែបំរើទ្រង់ដោយសេចក្តីកោតខ្លាចនិងអំណរ ខ 11-12 មានបន្ទូលថា "ចូរគោរពដល់ព្រះយេហូវ៉ា ដោយកោតខ្លាច ហើយមានសេចក្តីអំណរ ដោយញ័ររន្ធត់។ ចូរថើបព្រះរាជបុត្រា ក្រែងទ្រង់ខ្ញាល់ឡើង ហើយឯងរាល់គ្នាត្រូវវិនាសតាមផ្លូវ ដ្បិតបន្តិចទៀត សេចក្តីខ្ញាល់របស់ទ្រង់នឹងឆួលឡើងមានពរអស់អ្នកដែលយកទ្រង់ជាទីពឹងជ្រក។" តាមរយៈការប្រកបស្និតជាមួយនឹងព្រះរាជបុត្រា ដែលជាព្រះមេស៊ី នោះយើងអាចយកឈ្នះលើគ្រប់សេចក្តីទុក្ខលំបាក ហើយខិតចូលទៅក្នុងពិភពលោកថ្មី។

តើអ្នកឃើញពិភពលោកដ៏អស្ចារ្យនៅក្នុងជីវិតជាក់ស្តែងដែរឬទេ?តើអ្នកចូលចិត្តការប្រកបស្និតជាមួយនឹងព្រះរាជបុត្រាប៉ុណ្ណា? នៅពេលណាដែលអ្នកសិក្សាព្រះគម្ពីរ ហើយស្វែងរកព្រះបន្ទូលរបស់ព្រះ នោះអ្នកនឹងរីករាយនឹងព្រះអម្ចាស់។ ប៉ូលបាននិយាយថា យើងត្រូវការការកោតខ្លាចដើម្បីនឹងសម្រេចបំពេញសេចក្តីសង្គ្រោះពិតនៅក្នុងជីវិតរបស់យើង។ ដូច្នេះខ្ញុំសូមលើកទឹកចិត្តយ៉ាងមុតមាំថា យើងត្រូវតែសំរេចបំពេញសេចក្តីសង្គ្រោះរបស់យើងជាមួយនឹងសេចក្តីកោតខ្លាចនិងញ័ររន្ធត់។

ខ្ញុំយល់ថា ពួកគ្រីស្ទានកំណែទម្រង់នឹងរិះគន់គ្រប់ការទាំងអស់ដោយលំអិត ប៉ុន្តែព្រមគ្នានោះ ពួកគេមានកូនសោដែលអាចដោះស្រាយគ្រប់បញ្ហាទាំងអស់។ ដូច្នេះពួកគេពិតជារឹងមាំពេញដោយព្រះគុណ និងសេចក្តីមេត្តាករុណា។ ពិតណាស់គេមិនអាចពួននៅក្នុងបន្ទប់សម្ងាត់ដោយសារការកោតខ្លាច ប៉ុន្តែផ្ទុយទៅវិញបែរជាឈរដោយរឹងមាំនៅលើថ្មដាទាស់នឹងសត្រូវដើម្បីនឹងព្រោះព្រះហឫទ័យរបស់ព្រះនៅក្នុងនរក។ ដូចជាសាសន៍សាម៉ារីម្នាក់ដែលបានធ្វើទៅកាន់បុរសដែលត្រូវចោរប្លន់វាយនៅលើភ្នំ។ នៅពេលដែលមនុស្សផ្សេងទៀតដើរហួសគាត់ដោយសេចក្តីភ័យខ្លាច ប៉ុន្តែសាសន៍សាម៉ារីបានមានសេចក្តីអាណិតដល់គាត់។ "កាល

បានឃើញហើយ នោះក៏មានចិត្តក្តួលអាណិតដល់គាត់" សេចក្តីមេត្តា (អាណិតអាសូរ) មានន័យថាជាសភាពដែលត្រូវកំទេចចិត្តរបស់គាត់ដោយសារស្ថានភាពដ៏អាក្រក់ ដោយសារចិត្តដែលពេញដោយសេចក្តីមេត្តា។ គាត់បានផ្តល់ទ្រព្យសម្បត្តិដើម្បីនឹងព្យាបាលគាត់ភ្លាម។ (លូកា 10:35) គាត់បានទទួលខុសត្រូវដើម្បីនឹងព្យាបាលគាត់ដោយមិនបានគិតពីការលះបង់របស់ខ្លួន "តើជាព្រះគុណដ៏អស្ចារ្យប៉ុណ្ណាហ្ន ដូច្នេះពួកគ្រីស្ទានកំណែទម្រង់គួរតែមានទំនួលខុសត្រូវទៅកាន់មនុស្សទាំងអស់និងស្ថានភាពរបស់ប្រទេសកម្ពុជា។"

2. **ដោយការសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ**

ទំនុកដំកើងជំពូកមួយ ដែលត្រូវបានហៅថាជាសេចក្តីផ្តើមរបស់ទំនុកដំកើង១៥០ជំពូក បានសង្ខេបថា មនុស្សមានពរជាអ្នកដែលសញ្ជឹងគិតពីក្រឹត្យវិន័យទាំងយប់ទាំងថ្ងៃ។ "អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ។ តើអ្នកណាជាមនុស្សមានពរ?

**1) មនុស្សមានពរត្រូវតែចាកចេញពីអំពើបាប** (1-2) "មានពរហើយអ្នកណាដែលមិនដើរតាមដំបូន្មានរបស់មនុស្សអាក្រក់ ក៏មិនឈរនៅក្នុងផ្លូវរបស់មនុស្សមានបាប ឬអង្គុយនៅជាមួយនឹងពួកមនុស្សមើលងាយ។ អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាវិញ ក៏រំពឹងក្នុងក្រឹត្យវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ។" គេដើរចេញពីដំបូន្មានរបស់មនុស្សអាក្រក់នៅក្នុងគំនិត។ ហើយគាត់ចាកចេញពីផ្លូវរបស់មនុស្សមានបាបនៅក្នុងទង្វើ ហើយក៏ចាកចេញពីអង្គុយរបស់សេចក្តីមើលងាយនៅក្នុងដំណែង។ និយាយដោយខ្លី ការវាយប្រឆាំងនឹងអំពើបាបនោះជាព្រះពរ។

តើអំពើបាបជាអ្វី?ជាសភាពដែលដាច់ចេញដែលបដិសេធព្រះនិងបំណងរបស់ទ្រង់ ដោយការមិនស្តាប់បង្គាប់ និងការបះបោរ។ ជាទូទៅ បំណងប្រាថ្នាខាងសាច់ឈាមបង្កើតជាអំពើបាប អំពើបាបធំឡើងជាសេចក្តីស្លាប់។ យ៉ាកុប 1:15 មានបន្ទូលថា "នោះកាលណាសេចក្តីប៉ងប្រាថ្នាជាប់មានជាផ្ទៃ នោះសំរាលចេញមកជាអំពើបាប ហើយកាលណាបាបបានពោរពេញឡើង នោះក៏បង្កើតជាសេចក្តីស្លាប់។"អំពើបាបបង្កើតសភាពដែលអាក្រក់និងមើលងាយ

នៅក្នុងជីវិតរបស់យើង អ្នកមានបាបជាអ្នកដែលមានសេចក្តីអំណួត។ លទ្ធផលនោះជាសេចក្តីអន្តរាយ។ តើអ្នកណាជាអ្នកដែលមានពរ? គេវាយប្រឆាំងនឹងអំពើបាបរហូតដល់មានឈាមនៅក្នុងជីវិតរបស់គាត់។

2) **តើអ្នកណាជាអ្នកដែលមានពរ?** ដោយអវិជ្ជមានគេជាអ្នកវាយប្រឆាំងនឹងបាប ដោយវិជ្ជមានគាត់រីករាយនឹងក្រឹត្យវិន័យ ដែលជាព្រះបន្ទូលរបស់ព្រះ ព្រះគម្ពីរ។ "ត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា" តើអ្នកចូរចិត្តអានព្រះគម្ពីរទេ? ពាក្យមួយទៀតថា តើអ្នកតែងតែសញ្ជឹងគិតព្រះបន្ទូលដែរទេ? "អ្នកដែលមានពរសញ្ជឹងគិតក្រឹត្យវិន័យ"។ តើការសញ្ជឹងគិតមានន័យយ៉ាងណា? ការសញ្ជឹងគិត (ខ្ពស់) មានន័យថាជាការទ្វញសោក ការថ្ងូរ ការប្រកាសនិយាយ និងធ្វើឲ្យសើច។ ហើយមានគំនិតខ្លះជាការពិចារណា ការសិក្សា (ការសង្កេត ការបកប្រែ និងការអនុវត្ត)។ ពាក្យមួយទៀតថា ជាការនៅជាប់នឹងព្រះបន្ទូលរបស់ព្រះ។ ដូចជាមេមាន់ដែលគ្របពងរបស់ខ្លួន ដើម្បីនឹងបង្កកូន ការសញ្ជឹងគិតមានន័យថាជាសភាពដែលនៅជាប់នឹងព្រះគម្ពីរព្រះបន្ទូលរបស់ព្រះ គំនិតនិងការបង្រៀន។ ដោយការដាក់ទន់នូវបំណងជាច្រើននិងពេលវេលាច្រើន នៅក្នុងការត្រួតពិនិត្យព្រះបន្ទូល ការបកស្រាយ និងការអនុវត្តនៅក្នុងចិត្តរបស់គេ។ ដូចជាក្រុមជំនុំបារៀបានធ្វើបន្ទាប់ពីស្តាប់ព្រះបន្ទូល ដែលបានអធិប្បាយមកដោយសារពួកសាវ័ក ពួកគេបានធ្វើការពិនិត្យរកសេចក្តីពិត ដើម្បីនឹងអនុវត្តការទាំងនោះនៅក្នុងជីវិតរបស់ពួកគេ។

(កិច្ចការ17:11) "រីឯពួកអ្នកស្រុកនោះ មានចិត្តល្អជាងពួកអ្នកនៅថែស្សាឡូនិច គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឲ្យបានដឹងជាសេចក្តីទាំងនោះត្រូវឬមិនត្រូវ។" ការនៅជាប់នឹងព្រះបន្ទូលនាំមកនូវការរីករាយនៅក្នុងព្រលឹង។ វាចង្អុលទៅកាន់ការរីករាយនឹងព្រះបន្ទូលរបស់ព្រះ។ដូច្នេះអ្នកដែលមានពររីករាយនឹងព្រះបន្ទូលរបស់ព្រះទាំងយប់ទាំងថ្ងៃ។

ដូច្នេះយើងត្រូវគិតពីព្រះបន្ទូលរបស់ព្រះដដែលៗ ហើយប្រៀបធៀបព្រះបន្ទូលទាំងនោះទៅនឹងជីវិតរបស់យើងនិងបរិស្ថានរបស់យើង តាមរយៈការសញ្ជឹងគិត។ បន្ទាប់មកយើងស្គាល់ពីចិត្តដែលឆេះឆួល ចិត្តត្រជាក់ ចិត្តដែលមានអំណរ និងចិត្តដែលសោកសង្រេងនៅ

ចំពោះព្រះអម្ចាស់។ ពិតណាស់វាជា Coram Deo (នៅក្នុងវត្តមានរបស់ព្រះអម្ចាស់)។ បន្ទាប់មកយើងស្គាល់ពីសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា។ ហើយយើងក៏អាចយល់ថា សេចក្តីកោតខ្លាចដល់ព្រះ ចង្អុលទៅកាន់ការសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ។

ឧទាហរណ៍ ការសមាធិរបស់យូហ្គា ផ្តោតលើគំនិតដែលគាត់ចូលចិត្តជាងគេ និងនិយាយខ្សឹបៗម្តងហើយម្តងទៀត ហើយសំរេចបានការឆ្លុះបញ្ចាំងលើខ្លួនឯង ប៉ុន្តែការសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ គឺជាការផ្តោតលើព្រះបន្ទូលរបស់ព្រះ គម្ពីរ ពាក្យ គំនិត ទស្សនៈ ហើយធ្វើឲ្យពួកគេតភ្ជាប់ទៅនឹងគំនិតរបស់ខ្លួន ហើយសូត្រវាតិចៗម្តងហើយម្តងទៀត និងដើម្បីទៅដល់ការយល់ដឹងនូវសេចក្តីពិត។ បន្ទាប់មកព្រះវិញ្ញាណបរិសុទ្ធបើកសម្តែងដល់យើងតាមរយៈសេចក្តីពិតមួយចំនួន ដើម្បីធ្វើឲ្យយើងស្គាល់សេចក្តីពិតយ៉ាងច្បាស់នៅក្នុងចិត្តរបស់យើង។ ហើយគេនឹងបង្កើតផលផ្លែដ៏បរិបូរនៅគ្រប់រដូវកាលនៅក្នុងជីវិតរបស់គេ។ "អ្នកនោះនឹងដូចជាដើមឈើ ដែលដុះនៅក្បែរផ្លូវទឹក ដែលបង្កើតផលផ្លែតាមរដូវកាល ហើយស្លឹកក៏មិនចេះស្រពោនឡើយ ឯការអ្វីដែលអ្នកនោះធ្វើ នោះនឹងចំរើនឡើងទាំងអស់។" អ្នកខ្លះចូលចិត្តគិតថា ជីវិតដែលមានភាពចម្រើន ជោគជ័យ និងមានជ័យជម្នះ ប៉ុន្តែយើងប្រាប់ថាវាជាជីវិតដែលស្កប់ស្កល់នៅក្នុងព្រះគ្រីស្ទវិញ។ ជាសភាពដែលមានពេញដោយព្រះវត្តមានរបស់ព្រះអម្ចាស់។ ប្រសិនបើអ្នកមានជីវិតពេញបរិបូរនៅក្នុងជីវិតរបស់អ្នក នោះត្រូវត្រឡប់មកធ្វើការសញ្ជឹងគិតព្រះបន្ទូលឥឡូវនេះភ្លាម។ អ្នកត្រូវតែស្វែងរកនូវរបកគំហើញដ៏អស្ចារ្យ។

ដូច្នេះ ពួកទុច្ចរិតនឹងត្រូវវិនាសដោយសារអំពើបាបរបស់ពួកគេ។ ពួកគេរស់នៅក្នុងសភាពដែលដាច់ចេញពីព្រះ។ "ចំណែកមនុស្សអាក្រក់ មិនដូច្នេះទេ គឺគេដូចជាអង្កាមវិញ ដែលខ្យល់ផាត់ខ្ចាត់ខ្ចាយទៅ។ ដូច្នេះ ពួកមនុស្សអាក្រក់មិនធន់នៅក្នុងគ្រាជំនុំជំរះទេ ឯពួកមានបាប ក៏ឈរក្នុងជំនុំមនុស្សសុចរិតមិនបានដែរ។ ដ្បិតព្រះយេហូវ៉ាទ្រង់ជ្រាបផ្លូវរបស់មនុស្សសុចរិត តែផ្លូវរបស់មនុស្សអាក្រក់នឹងវិនាសទៅវិញ។" នេះជាលទ្ធផលទាំងបួននៅក្នុងជីវិតរបស់ពួកគេ៖

1) គេនឹងទទួលនូវសេចក្តីទទេរនៅក្នុងជីវិតរបស់គេ - nihilism

2) គេនឹងមានអារម្មណ៍ (មានកំហុស)

3) គេនឹងមិនចូលរួមនៅក្នុងជំនុំរបស់មនុស្សសុចរិតឡើយ

4) គេនឹងទទួលនូវការវិនាសអស់កល្បជានិច្ច

បើទោះជាពួកគេរស់នៅមានសុខភាពល្អ ចំរុងចម្រើន ជោគជ័យ និងស្លាប់ដោយសុវត្ថិភាពក៏ដោយ ក៏ពួកទុច្ចរិតនឹងត្រូវវិនាសអស់កល្បជានិច្ច។

ទិសដៅ - អត្ថបទបង្រៀនសេចក្តីពិតដែល ប្រាថ្នាចង់បានព្រះអម្ចាស់នៅពេលដែលយើងធ្លាក់ចុះទៅក្នុងការបាក់ទឹកចិត្ត។ (5, 11)

**ទីមួយ** ការជំរុញនូវការប្រាថ្នាចង់បាន (3, 4)។ មានការចំអករបស់សត្រូវ ការបាក់ទឹកចិត្តខាងវិញ្ញាណ និងការខ្វល់ខ្វាយចិត្តនៅក្នុងការជំរុញនូវការប្រាថ្នានោះ។ នៅពេលដែលសត្រូវសួរមកគេ "តើព្រះរបស់ឯងនៅឯណា?" កំណាព្យបានធ្វើឲ្យគាត់ទួញសោកទុកដូចជាអាហាររបស់គេទាំងយប់ទាំងថ្ងៃ។

**ទីពីរ** អត្ថន័យនៃការប្រាថ្នា គេមិនប្រាថ្នាចង់បានរបស់របរឬអំណរខាងសាច់ឈាមឡើយ ប៉ុន្តែចង់បានព្រះអម្ចាស់វិញ។ ប្រាថ្នាទាំងនោះជាព្រះដែលមានព្រះជន្មរស់វិញ (2) ព្រះអម្ចាស់ជាថ្មដា (9) ព្រះអម្ចាស់ជាជីវិត (8)។ ហើយគេក៏ស្រេកឃ្លានព្រះអម្ចាស់ដូចជាចៀមដែលដង្ហក់រកទឹកជ្រោះ។ (1) យ៉ាងហោចណាស់ គេបានផ្លាស់ប្តូរបើកន្លែងហើយអធិស្ឋានទៅកាន់ព្រះអម្ចាស់។ (6)

**ទីបី** លទ្ធផលនៃការប្រាថ្នារបស់គេ គេត្រូវបានគ្រប់គ្រងដោយសេចក្តីស្រឡាញ់របស់ព្រះ (7-8) គេយល់ពីសេចក្តីស្រឡាញ់របស់ព្រះនៅក្នុងសំលេងនៃទឹកជ្រោះនិងរលកសមុទ្រ។ ហើយការអធិស្ឋានរបស់គេចេញពីមកពីការនោះនៅក្នុងចន្លោះនៃសេចក្តីងងឹតខាងវិញ្ញាណ។ វាធ្វើឲ្យយើងរីករាយនៅក្នុងជីវិតរបស់យើង។

**សរុបសេចក្តី៖**

ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងទំនុកដំកើង បង្ហាញពីផលផ្លែយ៉ាងច្បាស់ជាងគេថែមទៀតមកកាន់យើង។ បានពន្យល់ពីគ្រប់ការបើកសំដែងបែបរូបភាពអំពី R. G. I. យើងអាចរកឃើញអត្ថន័យដែលបរិបូរណ៍នៅក្នុងនោះ។ ទំនុកដំកើងជាកណ្តាគម្ពីរវ៉ូមនៅក្នុងសញ្ញាចាស់។ យើងអាចឃើញរូបភាពដែលពេញលេញរបស់ព្រះនៅក្នុងនោះ។ ធាតុសំខាន់នៃគម្ពីរគឺសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ បង្ហាញនៅក្នុងនោះ....ហើយវាក៏បានបង្រៀនយើងឲ្យទទួលបានការស្តារឡើងវិញនៅក្នុងជីវិតនៅក្នុងផែនដីរបស់យើងតាមរយៈ "ការនៅជាប់នឹងព្រះគ្រីស្ទ" "ការសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ" "គោលបំណងនៃព្រះគុណរបស់ព្រះ" (យ៉ូហាន 15:5, 10:10)។

3. **សុភាសិត**

**សេចក្តីណែនាំ៖**

ជាដំបូងគ្រោងរបស់សុភាសិតដែលមានការប្រមូលផ្តុំប្រាំពីរ(1:1,10:1 22:17, 24:23, 25:1, 30:1, 31:1) ( P9 Bruce Waltke, *the book of the proverbs chapter 1-15*) ជាសារដែលដឹកនាំយើងឲ្យយល់ច្បាស់ពីជិវិតដែលទទួលបានការប្រោសលោះនៅក្នុងសុភាសិត។ សំណេរមានបំណងបង្ហាញនូវអត្ថន័យនៃជីវិតដូចនោះនៅក្រោមពន្លឺនៃដំណឹងល្អ។ពាក្យមួយទៀតថា ជាការសិក្សានៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងសុភាសិត។យើងគួរតែមានគំនិតគោលពីសេចក្តីពិត ដែលសកម្មភាពប្រោសលោះរបស់ព្រះគ្រីស្ទត្រូវបានបើកសម្តែងនៅក្នុងប្រភេទមួយចំនួនច្បាស់បន្តិចម្តងៗមុនពេលព្រះគ្រីស្ទយាងមកនៅក្នុងផែនដីនេះ។ ការផ្លាស់ប្រែដែលមានរូបភាពដើមរបស់មនុស្ស ដែលជាការស្តារឡើងវិញនូវសិរីល្អនៃសេចក្តីប្រោសលោះ ត្រូវបានបង្ហាញដោយការបើកសំដែងនិស្ស័យជាព្រះ តាមរយៈជីវិតរបស់ពាស្ត្រនៃការតាំងសញ្ញា។

នៅក្នុងពាក្យមួយទៀត ពីព្រោះលក្ខណៈរបស់ព្រះ មានសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ គួរតែបង្ហាញតាមរយៈមនុស្ស មនុស្សដែលទាក់ទងទៅនឹងលក្ខណៈរបស់ព្រះ គួរ

តែឃើញសិរីល្អនៃរូបឆ្លុះរបស់ព្រះ។ការស្តាប់បង្គាប់នោះនឹងធ្វើឲ្យពួកគេផ្លាស់ប្រែដូចជារូបឆ្លុះរបស់ព្រះ។ (២ កូរិនថូស 3:18) សព្វព្រះចេស្តា និងសព្វព្រះវត្តមានរបស់ទ្រង់ ដែល លក្ខណៈពិតទាំងស្រុងរបស់ទ្រង់គឺស្ថិតនៅលើការបែបនោះ។ បើយោងតាមសាសនៈវិជ្ជារបស់របស់ប៉ូល តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ដែលជារូបរបស់មនុស្សថ្មីគួរតែមានទាំងធាតុទាំងបីមាន សេចក្តីសុចរិត សេចក្តីបរិសុទ្ធ និងភាពស្មោះត្រង់ ( កូល៉ុស 3:10, អេភេសូ 4:24) នៅក្នុងចំណុចគ្រឹះនៃជីវិតរបស់គេ។

ហើយយើងយល់ថា ការស្តារឡើងវិញនៃជីវិតដែលត្រូវបានប្រោសលោះ មានន័យថា ការផ្តោតលើគោលគំនិតនៃជីវិតមានសីលធម៌ដែលជាការបញ្ជាក់ពីសេចក្តីប្រោសលោះ។ វាអាចត្រូវហៅថាជា គោលការណ៍សេចក្តីប្រោសលោះ ដែលជាផលផ្លែនៃសេចក្តីប្រោសលោះ ដែលគួរតែបង្ហាញនៅក្នុងទំនាក់ទំនងដែលមានសីលធម៌ទៅកាន់របស់ដែលបានបង្កើតមក ដែលជាមនុស្សនោះឯង។

ដូចជាចំណងជើងដែលមានដែនកំណត់មួយ"គោលគំនិតនៃការប្រោសលោះនៅក្នុងសុភាសិត" មានន័យថាគោលលិទ្ធិនៃប្រាជ្ញាគួរតែបង្ហាញនូវជីវិតខាងប្រាជ្ញា ដែលចាក់ឬសនៅក្នុងសេចក្តីប្រោសលោះ។ ខ្ញុំនឹងខិតជិតគោលលិទ្ធិរបស់ព្រះអម្ចាស់ គោលលិទ្ធិរបស់មនុស្ស គោលលិទ្ធិនៃសេចក្តីសង្គ្រោះ និងគោលលិទ្ធិនៃព្រះគ្រីស្ទដោយទស្សនៈបែបសីលធម៌ មាន សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។

## I. ព្រះអម្ចាស់នៅក្នុងសុភាសិត

សេចក្តីពិតដែលព្រះយេហូវ៉ា ពាក្យដែលបង្ហាញប្រហែល89ដង ប៉ុន្តែពាក្យព្រះអម្ចាស់បង្ហាញតែ 5 ដងនៅក្នុងសុភាសិត បញ្ជាក់ថាព្រះអម្ចាស់នៃរាស្រ្តនៃសេចក្តីសញ្ញាស្មោះត្រង់នៅក្នុងការរក្សាសេចក្តីសន្យារបស់ទ្រង់។ ព្រះអម្ចាស់នៃសុភាសិតជាម្ចាស់នៃការតាំងសញ្ញាហើយនឹងជាអ្នកសំរេចការនោះ។ ដូច្នេះមានការនិយាយ (22:17-24:22) គួរតែបកប្រែដោយការប្រើពាក្យព្រះអម្ចាស់ ពីព្រោះការប្រើប្រាស់ប្រាជ្ញាចេញមកពីព្រះអម្ចាស់។ បន្ទាប់មកផលផ្លែខាងសីលធម៌ធ្វើឲ្យគោលលិទ្ធិកាន់តែច្បាស់និងបរិបូរណ៍ថែមទៀត។ ហើយចំណែកសេចក្តីកោត

ខ្លាចដល់ព្រះដែលសុភាសិតបាបបង្ហាញ នោះជាគ្រឹះនៃចំណេះដឹងនិងប្រាជ្ញា វាដឹកនាំយើងទៅកាន់សេចក្ដីជំនឿលើដំណឹងល្អ ហើយធ្វើឲ្យយើងកាន់មានព្រះគុណបរិបូរណ៍ និងមានកំលាំងថែមទៀត។ ព្រះអម្ចាស់នៅក្នុងសុភាសិតជាព្រះនៅក្នុងជីវិតដែលបានប្រោសលោះ។

ជីវិតនៃការស្ដារឡើងវិញនុវរូបឆ្លុះរបស់ព្រះគឺជាការបង្ហាញនូវលក្ខណៈរបស់ព្រះដោយការបើកសំដែងការទាំងនោះនៅក្នុងកញ្ចក់នៃលក្ខណៈរបស់មនុស្ស។

## II. មនុស្សដែលនៅក្នុងសុភាសិត

ហើយអ្វីជាមនុស្សនៅក្នុងសុភាសិត? ពិតណាស់វាបង្ហាញពីរូបឆ្លុះរបស់មនុស្សម្នាក់ដែលមានព្រលឹងនិងរូបកាយ។ (លោកុប្បត្តិ1:26-27) ដូច្នេះវាបង្ហាញជីវិតដែលមានព្រលឹងជាចំណុចកណ្ដាល ឬ ជីវិតដែលមានវិញ្ញាណជាកណ្ដាល ដោយសារទស្សនៈដ៏ពិតពីមនុស្ស គួរតែពឹងលើទស្សនៈដ៏ពិតរបស់ព្រះអម្ចាស់។ លើសជាងនេះនោះ ពួកគេគួរតែរក្សាចិត្ត។ ការរក្សាចិត្តនៅទីនេះជាការបញ្ជាក់មួយទៀតនៃជំនឿដែលត្រឹមត្រូវ។ (សុភាសិត 4:23)

ព្រលឹងនឹងក្លាយជាត្រឹមត្រូវ នៅពេលដែលវាស្ដាប់ទៅកាន់ប្រាជ្ញា និងដំណើរការវា ហើយដើរតាម និងរួបរួមជាមួយវា។ ដូច្នេះរូបឆ្លុះរបស់ខ្លួនរបស់បុគ្គលដែលនៅក្នុងសុភាសិត គួរតែត្រូវបានទទួលស្គាល់ដោយទស្សនៈដែលមានព្រលឹងជាចំណុចកណ្ដាល។ មនុស្សដែលត្រូវបានស្ដារឡើងវិញទៅកាន់រូបឆ្លុះរបស់ព្រះ ជាកម្មសិទ្ធិរបស់ប្រាជ្ញារបស់ព្រះ ពីព្រោះសីលធម៌នៃដែលត្រូវបានប្រោសលោះ ត្រូវតែមានដែនកំណត់ទៅកាន់វាស្រ្តនៃសេចក្ដីសញ្ញា ដែលជាគ្រីស្ទាន។ មនុស្សនៅក្នុងសុភាសិតគួរតែជាមនុស្សរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ យើងបកប្រែសុភាសិតនៅក្នុងពន្លឺនៃរូបឆ្លុះរបស់វាស្រ្តនៃការតាំងសញ្ញា។

## III. ចំណេះដឹងពីព្រះគ្រីស្ទនៅក្នុងសុភាសិត

រូបភាពនៃគោលលិទ្ធិរបស់ព្រះនិងគោលលិទ្ធិរបស់មនុស្សនៅក្នុងសុភាសិតបង្ហាញពីប្រវត្តិសាស្រ្តនៃសេចក្ដីប្រោសលោះ ដោយការណែនាំពីប្រាជ្ញាដ៏ពិត ដែលជាព្រះគ្រីស្ទ (ជំពូក 6)។ ជាពិសេស ស្រ្តីនៃប្រាជ្ញាត្រូវបានបង្ហាញដោយនិមិត្តសញ្ញា និងការប្រៀបធៀប ជាព្រះគ្រីស្ទដែលភាពជាមនុស្សជាមួយអង្គមុនការចាប់កំណើតជាមនុស្ស ជាព្រះអាទិករ ជាអង្គដែលផ្ដត់

ផ្តង់ និងជាអង្គដែលប្រោសលោះ។តើអ្នកណាជាអង្គប្រាជ្ញានៅក្នុងជំពូក៦?វាមិនមែនជាគំនិតអរូបិយទេ ប៉ុន្តែការពិតត្រូវបានបង្ហាញនៅក្នុងដំណឹងល្អ។ ពិតណាស់ ប្រាជ្ញាចង្អុលទៅកាន់ព្រះបន្ទូល (logos) នៅក្នុង យ៉ូហាន 1:14 ពីព្រោះព្រះគ្រីស្ទត្រូវបានបង្ហាញមកកាន់យើង (លូកា)។ រូបភាពដែលមានសីលធម៌នៅក្នុងសុភាសិត ត្រូវបានបង្ហាញនៅក្នុងព្រះគ្រីស្ទនៅក្នុងធម្មជាតិតែមួយប៉ុណ្ណោះ។ ក្រៅពីព្រះគ្រីស្ទ សេចក្តីប្រោសលោះនិងសីលធម៌នឹងត្រូវបានធ្លាក់ចុះទៅក្នុងសីលធម៌របស់មនុស្ស ហើយនឹងធ្វើឲ្យពួកគេបង្កើតជាសាសនាផ្សេងទៀត។ ដូច្នេះសុភាសិតសង្កត់ន័យថា មានតែផ្លូវមួយដែលអាចយកឈ្នះសេចក្តីល្បួងនៃស្រ្តីដែលផិតក្បត់ជាការទទួលយកប្រាជ្ញាហើយដើរតាមប្រាជ្ញា។ ជាចុងក្រោយ វាដឹកនាំយើងទៅកាន់សេចក្តីជំនឿដែលត្រឹមត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ ជាសេចក្តីពិតនៃប្រាជ្ញា។ ប្រាជ្ញាជាព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ជាអង្គសង្គ្រោះ ជាអង្គផ្គត់ផ្គង់ និងជាអង្គដែលផ្សះផ្សានៅក្នុងជីវិតដែលទទួលបានការប្រោសលោះ។

## IV. សេចក្តីសង្គ្រោះនៅក្នុងសុភាសិត

អំពើបាបដែលសុភាសិតមានបន្ទូល មានលក្ខណៈដែលជាក់លាក់។ សេចក្តីសង្គ្រោះនៅក្នុងព្រះគម្ពីរមិនមែនជាការធ្វើតាមចិត្តនោះទេ ប៉ុន្តែជា heteronomy, ដែលជា ការពឹងផ្អែកលើព្រះមួយអង្គប៉ុណ្ណោះ។ ដូច្នេះព្រះពរនិងសីលធម៌នៅក្នុងសុភាសិត គួរតែបានបកប្រែដោយទស្សនៈនៃសេចក្តីប្រោសលោះ។ ឧទាហរណ៍ អាយុវែង ការចំរុងចម្រើន និងការការពារនៅក្នុសុភាសិត គួរតែត្រូវបានអានដោយទស្សនៈនៃប្រវត្តិសាស្រ្តនៃសេចក្តីប្រោសលោះ ពីព្រោះពួកគេត្រូវបានចាក់ឫសនៅក្នុងជីវិតអស់កល្បជានិច្ច។ អាយុវែងពិតប្រាកដគួរតែត្រូវបានបង្កើតនៅក្នុងឫសគល់នៃជីវិតអស់កល្បជានិច្ច ដែលជា ការស្គាល់ព្រះគ្រីស្ទ (យ៉ូហាន 17:3)។ បើទោះជាសុភាសិតជាការបើកសម្តែងរបស់សញ្ញាចាស់ក៏ដោយ ក៏វាគួរតែបកប្រែដោយដំណឹងល្អនៅក្នុងព្រះគ្រីស្ទដែរ។

## V. ជីវិតដែលទទួលបានការប្រោសលោះនៅក្នុងសុភាសិត

សេចក្តីប្រោសលោះដ៏ត្រឹមត្រូវមានគោលបំណងទៅកាន់ជីវិតដែលទទួលបានការប្រោសលោះ។ វាជាខ្លឹមសារដ៏ពិតនៅក្នុងការបង្ហាញជីវិតដូច្នេះឲ្យបានលំអិត។ វាទាក់ទងទៅជីវិត

ដែលមានសីលធម៌របស់សាវ័កដ៏ជ្រាលជ្រៅ។ព្រះវិញ្ញាណបរិសុទ្ធមានគម្រោងនៅក្នុងការបើកសម្តែងជីវិតដែលទទួលបានការប្រោសលោះដ៏បរិបូរណ៍តាមរយៈសុភាសិត។នៅក្នុងពាក្យមួយទៀតជីវិតរបស់វាស្រ្តនៃការតាំងសញ្ញាបង្ហាញយ៉ាងលំអិតនៅក្នុងនោះ។សេចក្តីប្រោសលោះនៅក្នុងកណ្ឌគម្ពីរទាំងប្រាំរបស់ម៉ូសេ គួរតែត្រូវការជីវិតនៅក្នុងសុភាសិតនៅក្នុងវាស្រ្តនៃការតាំងសញ្ញា។ដូច្នេះអាយុវែងរបស់សុភាសិតទាក់ទងនឹងជីវិតអស់កល្បជានិច្ចរបស់ដំណឹងល្អ ការចម្រុងចម្រើនដោយគ្រប់ព្រះពរខាងវិញ្ញាណទាំងអស់នៅក្នុងព្រះគ្រីស្ទ (អេភេសូ 1:3) ហើយការការពារនៅក្នុងការស្ម័គ្រទាំងដ៏ពិតរបស់ព្រះគ្រីស្ទ (រ៉ូម 8:38-39)។ វិធីសាស្រ្តដែលវាស្រ្តនៃការតាំងសញ្ញា គួរតែបង្ហាញនូវសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់នៅក្នុងគ្រប់កន្លែង ជាការស្រឡាញ់ដល់ប្រាជ្ញា។ នេះជាគោលបំណង វិធីសាស្រ្ត និងលទ្ធផលនៃជីវិតយូរអង្វែង។ ពាក្យមួយទៀត វាជាការបង្ហាញមួយទៀតនៃជីវិតអស់កល្បជានិច្ច។ ប្រាជ្ញារំពឹងដល់ជីវិតនៃសេចក្តីប្រោសលោះ។

## សរុបសេចក្តី៖

លំនាំបច្ចុប្បន្ននៃការបកប្រែមិនបានយកតាមព្រះគម្ពីរនៅក្នុងសុភាសិត គួរតែត្រូវបានផ្លាស់ប្តូរនៅក្នុងការបកប្រែរបស់ពួកបរិសុទ្ធ ដែលពួកគេទទួលស្គាល់សុភាសិតជាស្តង់ដាជីវិតរបស់គ្រីស្ទាន ដូចជាលោក Jonathan Edwards ដែរ។ លើសពីនោះទៀត យើងត្រូវការយល់ពីសីលធម៌នៃសេចក្តីប្រោសលោះនៅក្នុងទស្សនៈជីវិតដែលមានព្រះគ្រីស្ទជាចំណុចកណ្តាល។ បន្ទាប់មកយើងអាចសង់ជីវិតនៃសេចក្តីប្រោសលោះដ៏ត្រឹមត្រូវ ដែលមិនអាចរង្គើបានឡើយ។ (កូល៉ុស 2:6-7)

## I. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងគម្ពីរសញ្ញាថ្មី

ហេតុផលដែលការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅសញ្ញាចាស់ត្រូវបានបង្ហាញនៅក្នុងសញ្ញាថ្មីយ៉ាងច្បាស់ គឺជាការបង្ហាញការបើកសម្តែងយ៉ាងច្បាស់ជារឿយៗ។ ការប្រោសលោះដែលត្រូវបានសង្កត់ធ្ងន់លើនិមិត្តរូបនិងប្រភេទ ត្រូវបានសង្ខេបនៅក្នុងព្រះគ្រីស្ទ ដែល

ទ្រង់ជាអ្នកសំរេចសេចក្តីប្រោសលោះជាពិត។ សាវ័កបានប្រាកដថា ឧទាហរណ៍នៃរូបឆ្លុះរបស់ព្រះ មានតែព្រះគ្រីស្ទប៉ុណ្ណោះ។ ខ្ញុំមានន័យថា នៅពេលដែលព្រះបង្កើតមនុស្ស ទ្រង់មានបំណងថាគ្រប់ទាំងកូនរបស់ព្រះនឹងត្រូវបានរូបរួមតែមួយជាមួយនឹងព្រះរាជបុត្រាទ្រង់តែមួយ។ ដូច្នេះការគ្រប់គ្រងរបស់ព្រះនៅសញ្ញាចាស់បានបង្ហាញនៅក្នុងអាណាចក្ររបស់ព្រះនៅសញ្ញាថ្មី។ នៅពេលដែលព្រះយេស៊ូវគ្រីស្ទដែលជាព្រះនៃនគរព្រះបានយាងមកនៅក្នុងលោកិយ អាណាចក្របានមកដែរ ហើយការយាងមកជាលើកទីពីរនឹងត្រូវបានសំរេចជាមួយគ្នានៅក្នុងការនោះ។ វាមានន័យថា សេចក្តីពិតនេះជាក់ច្បាស់ជាងការបើកសំដែងរូបឆ្លុះរបស់ព្រះ ទាំងនោះមាន សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ពីព្រោះព្រះគ្រីស្ទផ្ទាល់ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ បើគ្មានព្រះគ្រីស្ទ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់នឹងទៅជាការដែលក្លែងក្លាយ។ នៅពេលដែលដំណឹងល្អបង្ហាញគ្រប់ទាំងព្រះបន្ទូលរបស់ព្រះគ្រីស្ទ និងកិច្ចការរបស់ទ្រង់ ត្រូវបានផ្តោតលើភាពពិតនៃនគររបស់ទ្រង់ ដែលជារូបឆ្លុះរបស់ទ្រង់។ យើងបានរកឃើញសេចក្តីពិតនៅក្នុងការបង្រៀននៅលើភ្នំរបស់ព្រះយេស៊ូវនិងការបង្រៀនរបស់ពួកសាវ័ក។

## 1. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះបង្ហាញនៅក្នុងការបង្រៀននៅលើភ្នំ

ការបង្រៀននៅលើភ្នំត្រូវបានហៅថាជា magna karta នៃអាណាចក្ររបស់ព្រះ ហើយត្រូវបានបង្ហាញនៅក្នុងម៉ាថាយជំពូក 5-7 និងលូកាជំពូក 11។ មួយដែលត្រូវបានរៀបចំដោយការវិធីសាស្រ្តដ៏ពេញដោយហេតុផលត្រឹមត្រូវដោយម៉ាថាយ ប៉ុន្តែមួយទៀតត្រូវបានសរសេរបែបជាប្រវត្តិសាស្រ្តដោយលូកា។ គ្រោងនៃការបង្រៀននៅលើភ្នំមានព្រះពរប្រាំបី គោលការណ៍នៃជីវិតរបស់រាស្រ្តនៃនគរ ការទូន្មានទាក់ទងនឹងការប្រព្រឹត្តរបស់អ្នកមិនជឿ និងភាពស្របច្បាប់ និងសង្កត់ធ្ងន់លើការដែលក្រឹត្យវិន័យនឹងសំរេចនៅក្នុងព្រះគ្រីស្ទ។ នៅក្នុងចំណោមការនោះ ព្រះមួយនៅក្នុងព្រះពរទាំងប្រាំបី អ្នកដែលមានសេចក្តីកំសត់ខាងវិញ្ញាណជាគ្រឹះនៃគ្រប់ទាំងព្រះពរ និងជាឫសគល់នៃគ្រប់ទាំងគំនិតនិងគ្រប់ទាំងសកម្មភាព។ វាមានន័យថាការបង្ហាញរូបឆ្លុះរបស់ព្រះ មានសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ពឹងលើទង្វើរបស់មនុស្ស ប៉ុន្តែជាព្រះគុណរបស់ព្រះ។ មានតែអ្នកដែលរកឃើញសភាពផ្ទាល់របស់ខ្លួន

ត្រឹមត្រូវប៉ុណ្ណោះដែលអាចបង្ហាញពីរូបឆ្លុះរបស់ព្រះបាន។

នៅក្នុងព្រះពរទាំងប្រាំបី ដែលអ្នករកឃើញថាគេជាមនុស្សមានបាប បន្តិចមកគាត់នឹងខិតចូលទៅកាន់ការលន់តួបាបនៅចំពោះព្រះ។ ការលន់តួបាបបង្ហាញនៅក្នុងការទួញសោកនិងនៅក្នុងសេចក្តីស្លូតបូតនៅចំពោះព្រះនិងមនុស្ស។ នៅក្នុងពេលតែមួយ គេស្វែងរកនៅក្នុងការជឿលើសេចក្តីសុចរិតតែមួយរបស់ព្រះជាជីវិតរបស់ខ្ញុំនិងការដែលខ្ញុំទន្ទឹងរងចាំដោយចិត្តដែលស្រេកឃ្លាន។ ការពិតនោះ ចិត្តនេះជាផលផ្លែនៃការកើតជាថ្មី ដែលបានរកឃើញសភាពពិតរបស់ខ្លួននៅក្នុងការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកដែលបានទទួលព្រះគុណដែលជាអ្នកដែលបានស្តាររូបឆ្លុះរបស់ព្រះ ជាទូទៅស្វែងរកភាពបរិសុទ្ធ និងសេចក្តីមេត្តា ហើយបើទោះជាគាត់ត្រូវទទួលការបៀតបៀនពីអ្នកដទៃក៏គាត់មានទំនួលខុសត្រូវនិងលីឈើឆ្កាងរបស់ខ្លួនដើរតាមព្រះយេស៊ូវដែរ។ នេះជាគោលការណ៍នៃព្រះពរទាំងប្រាំបី។ ការនេះបង្ហាញពីដំណើរការទាំងមូលនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។អ្នកដែលមានទំនាក់ទំនងយ៉ាងត្រឹមត្រូវជាមួយនឹងព្រះ នោះតែងរស់នៅជាពន្លឺនិងអំបិលនៃលោកិយដោយឯកឯង។ វាមិនបានបង្ហាញរូបឆ្លុះរបស់ព្រះសំរាប់ខ្លួនឯងទេ ប៉ុន្តែយល់ពីសេចក្តីកំសោយរបស់ខ្លួនទុកចិត្តយ៉ាងពេញលេញនូវសេចក្តីប្រោសប្រណីរបស់ព្រះគ្រីស្ទហើយបង្ហាញពីទ្រង់ទ្រាយរបស់គេ។ ការប្រកាសដើម្បីនឹងសំរេចនូវចំនុចតូចមួយរបស់ព្រះអម្ចាស់ មានន័យថាការសំរេចការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ពីព្រោះគ្រឹះនៃក្រឹត្យវិន័យជាលក្ខណៈរបស់ព្រះ មានសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ នៅក្នុងពាក្យមួយទៀត គ្រឹះនៃក្រឹត្យវិន័យជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ដែលជាលក្ខណៈរបស់ព្រះ។ ហើយព្រះអម្ចាស់ តាមរយៈក្រឹត្យវិន័យមាស "ដូច្នេះអស់ទាំងការអ្វី ដែលអ្នករាល់គ្នាចង់ឲ្យមនុស្សលោកប្រព្រឹត្តនឹងខ្លួន នោះត្រូវឲ្យអ្នករាល់គ្នាប្រព្រឹត្តនឹងគេដូច្នោះដែរ ដ្បិតនេះជាក្រឹត្យវិន័យ ហើយជាសេចក្តីទំនាយរបស់ពួកហោរា។" (ម៉ាថាយ 7:12) បង្ហាញពីអ្នកដែលឆ្លាតវៃនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

## 2. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះបង្ហាញនៅក្នុងរ៉ូម

គ្រឹះនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះសង្កត់ធ្ងន់ម្តងទៀតនៅក្នុងការបង្រៀនរបស់ពួកសាវ័កនិងពួកហោរា។ ជាការធម្មតាដែលនៅក្នុងចំណោមពួកគេនៅក្នុងចំណេះដឹងពីព្រះរបស់ប៉ូល និងសេចក្តីជំនឿរបស់គាត់ គោលការណ៍ដូចគ្នានោះត្រូវបានបង្ហាញមកម្តងទៀត។ ពួកសាវ័កនៅពេលនោះ ជួបប្រទះការប្រឆាំងទាស់នឹងអ្នកដែលបង្រៀនខុសឆ្គងដែលត្រូវបានធ្លាក់ចុះទៅក្នុងការបង្កើតគោលការពីរដំណាលគ្នានៅក្នុងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ដោយការពន្យល់លក្ខណៈទាំងពីរនៃការបន្តនិងការផ្តាច់យ៉ាងច្បាស់។

ត្រង់ចំណុចនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងសញ្ញាចាស់និងសញ្ញាថ្មី ត្រូវពឹងលើលក្ខណៈរបស់ព្រះនិងបានចេញមកពីការនោះ វាមានលក្ខណៈដែលនៅតែបន្ត នៅក្នុងពេលតែមួយនោះ នៅពេលដែលយើងប្រៀបធៀបសញ្ញាចាស់និងសញ្ញាថ្មី ថាការពិតនោះមានភាពខុសគ្នាយ៉ាងខ្លាំង វាមានលក្ខណៈដែលមិននៅបន្ត។ ដូចជាសិរីល្អរបស់ព្រះអាទិត្យ ព្រះចន្ទ និងផ្កាយខុសគ្នាយ៉ាងណា នៅក្នុងដំណឹងល្អដែលសំរេចនៅក្នុងសញ្ញាថ្មី ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះមិនអាចនឹងប្រៀបធៀបទៅនឹងរូបភាពដើមឡើយ ពួកសាវ័កបានមើលឃើញសិរីល្អនោះ។ ប្រសិនបើគេបានឃើញវា ដោយមិនបានមើលដោយវ៉ែនតានៃការបន្តទេ ដូចជាសាវ័កទាំងបីនៅលើភ្នំនាពេលដែលទ្រង់ត្រូវបានផ្លាស់ប្រែ ពួកគេអាចជាមិនបានដាក់ព្រះយេស៊ូវចុះនៅក្នុងកម្រិតរបស់ម៉ូសេនិងអេលីយ៉ានៅក្នុងសភាពនោះទេ ហើយនឹងក្នុងរង្វាស់នៃអារម្មណ៍ដែលពួកគេត្រូវការបង្កើតតង់បីសម្រាប់ទ្រង់និងពួកគេទាំងពីរ ពីព្រោះពួកគេមិនអាចគ្រប់គ្រងនូវសិរីល្អរហូតដល់ពេលដែលព្រះវិញ្ញាណបរិសុទ្ធមកកាន់ពួកគេ។ នេះជាហេតុផលដែលពួកហោព្រើរជាអ្នកជឿនិងពួកកាឡាទីបានយល់ច្រឡំម្តងនូវភាពជាអធិបតីយរបស់ព្រះគ្រីស្ទដូចជាការនេះដែរ។

បើទោះជាពួកគេអះអាងពីការបន្តរបស់ក្រឹត្យវិន័យនិងដំណឹងល្អក៏ដោយ ក៏ពួកគេបានធ្លាក់ចុះទៅក្នុងគ្រោះថ្នាក់ដែលពួកគេបានចាប់ផ្តើមជាមួយព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែត្រូវបានបញ្ចប់ជាមួយសាច់ឈាម ពីព្រោះពួកគេមិនបានមើលឃើញព្រះគុណដែលមិនអាចបំបែក

ចេញពីគ្នានោះ។ ប៉ុន្តែសាវ័កប៉ូលជាអ្នកដែលលើកគោលគំនិតទីបី ហើយបានឃើញការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះយ៉ាងពេញលេញ ពីព្រោះគាត់ផ្ទាល់ត្រូវបានផ្លាស់ប្រែទៅជារូបឆ្លុះរបស់ព្រះ នោះគាត់អាចសារភាពថា "ខ្ញុំរាប់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែងមកឲ្យយើងរាល់គ្នាឃើញនោះទេ" (រ៉ូម 8:18) ។ ហើយនៅក្នុង ២កូរិនថូស ជំពូក 6 មានភាពផ្ទុយគ្នារវាងការតាំងសញ្ញានៅសញ្ញាចាស់និងការតាំងសញ្ញានៅសញ្ញាថ្មី ព្រះជាអង្គដែលបានប្រទានព្រះនៅក្នុងសញ្ញាចាស់សម្រាប់សេចក្តីសង្គ្រោះ បានបង្ហូរមកនូវព្រះគុណដ៏ពិសេសរបស់ទ្រង់ស្របគ្នាទៅនឹងនៅក្នុងសញ្ញាថ្មីទៅកាន់ពួកគេ។ គាត់បានសារភាពថា "ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះត្រូវបានសម្រេចនៅក្នុងព្រះយេស៊ូវគ្រីស្ទពេលនេះ ដែលជាការដែលនៅក្នុងសញ្ញាថ្មីត្រូវបានដំកើងលើងដោយសិរីល្អដែលពិសេស។

ដូច្នេះក្រុមជំនុំនៅក្នុងសញ្ញាថ្មី បើទោះជាហោរាដ៏ធំនៅក្នុងសញ្ញាចាស់ទទួលព្រះគុណដូចគ្នា ក៏ពួកគេបានទទួលព្រះគុណពិសេសចេញមកពីព្រះ។ ដូចជាសាវ័កយ៉ូហាន ពួកគេបានមើលទៅកាន់សិរីល្អនៃព្រះគុណនិងសេចក្តីពិត បានស្គាល់ បានភ្លក់ បានផឹក និងបានរីករាយជាមួយ ដែលពួកគេបានផ្សាយនូវព្រះគុណទៅគ្រប់ទីកន្លែង ហើយបានក្លាយជាប្រភពនៃព្រះពរ។ នៅក្រោយបទពិសោធន៍ដូចនេះ ដោយសារពួកគេបានទទួលអភ័យឯកសិទ្ធិដែលគ្រប់ជីវិតនិងកិច្ចការទាំងអស់ត្រូវបានសម្រេច តើជាការដែលពេញដោយសិរីល្អយ៉ាងណាទៅ! ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះត្រូវបានផ្លាស់ប្រែដោយសិរីល្អរបស់ព្រះ។

បើទោះជាយ៉ាងណាក៏ដោយ យើងត្រូវចងចាំថា ការដែលសម្រេចបាននូវការទាមទាររបស់ក្រឹត្យវិន័យ សេចក្តីបរិសុទ្ធរបស់ព្រះមិនត្រូវបានលុបបំបាត់នៅក្នុងដំណឹងល្អឡើយ។ សាវ័កបានប្រកាសថាអ្នកដែលធ្វើតាមច្បាប់ដែលព្យាយាមសម្រេចដោយកម្លាំងរបស់គេនោះមិនអាចគេចផុតពីអន្ទាក់នៃការរបស់មនុស្សឡើយប៉ុន្តែអ្នកដែលដេញតាមដំណឹងល្អត្រូវបានខិតចូលដល់ការទាមទារនោះវិញដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។វាមិនមែនដោយកម្លាំងរបស់ខ្លួនឯងឡើយ ប៉ុន្តែដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែលបានស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះដោយសារសេចក្តីជំនឿ។ដូច្នេះកត្តាជម្រុញនៃពួកអ្នកកែទម្រង់ ជាការរាប់ជាសុចរិតដោយសារសេចក្តីជំនឿ ជាវិធីសាស្រ្ត និងវិធីនៅក្នុងការស្តារឡើងវិញនូវរូប

ឆ្លុះរបស់ព្រះ។ លក្ខណៈនៃសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់របស់ព្រះចេញមកពីព្រះគុណនិងសេចក្តីជំនឿតែមួយប៉ុណ្ណោះ។

### 3. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងកិច្ចការ

បន្ទាប់ពីបានរំលឹងនូវដំណឹងល្អល្ងការូចមក ប្រវត្តិសាស្ត្រនៅក្នុងកិច្ចការ បង្ហាញពីវិធីនៅក្នុងការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រហ បង្ហាញតាមរយៈព្រឹត្តិការណ៍ជាច្រើន។ ដំណឹងល្អបានបង្ហាញថានៅក្នុងព្រឹត្តិការណ៍របស់ព្រះអម្ចាស់ នូវរបៀបដែលគោលបំណងនោះទាក់ទងគ្នា តែនៅគ្រានៃកិច្ចការរបស់ពួកសាវ័កពីរបៀបដែលព្រះគ្រីស្ទបានយល់ការនោះតាមរយៈពួកសាវ័ក។ ព្រះវិញ្ញាណបរិសុទ្ធដែលបានយាងចុះមកនៅក្នុងថ្ងៃបុណ្យទី៥០មកលើពួកជំនុំមានឥទ្ធិពលលើផ្នែកទាំងមូលដូចជាគ្រាប់ពូជដ៏ល្អិតនិងដំបែ។បើទោះជាកម្រិតនៃពេលវេលា និងបរិយាកាសខុសគ្នាក៏ដោយ ដូចជារដូវទាំងបួនមកកាន់យើងជាពិតប្រាកដនោះ ចេស្តានៃរូបឆ្លុះតាមរយៈចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធបានបង្កើតផលផ្លែយ៉ាងរឹងមាំជាក់ពិតនិយាយមួយបែបទៀតថា ព្រះហឫទ័យដែលព្រះបានបង្កើតនូវនគររបស់ព្រះនៅលើផែនដីត្រូវបានសម្រេចបំពេញរហូតដល់ក្រុងយេរូសាឡិម យូដា និងសាម៉ារី ហើយរហូតដល់ចុងផែនដីទាំងមូល។ បន្ទាប់ពីចេស្តានោះកន្លងផុតទៅ រនាំងនៃវប្បធម៌ ក្រុមកុលសម្ព័ន្ធ និងភាសាបានបង្ហាញនូវផលផ្លែនៃរូបឆ្លុះរបស់ព្រះ។ នៅក្នុងគ្រប់ព្រឹត្តិការណ៍រហូតដល់ពេលម្នាក់ដែលធ្វើការនៅក្នុងព្រះគ្រីស្ទ។ តាមរយៈកិច្ចការនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ គាត់បានបង្ហាញគោលបំណងដែលសំខាន់របស់ទ្រង់នៅក្នុងលោកិយបន្តិចម្តងៗ។

#### I. ទីមួយ វាត្រូវបានបង្ហាញនៅក្រុងយេរូសាឡិម

ការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធដែលជាអង្គដែលត្រូវបានបង្ហាញនៅបន្ទប់ខាងលើនៅយេរូសាឡិម ជាវត្តមានដូចគ្នានៃព្រះវិញ្ញាណរបស់ព្រះដែលបានគង់នៅមុនពេលនៃការបង្កបង្កើត។ នៅក្នុងពិភពលោកនៃភាពងងឹតខាងវិញ្ញាណ ភាពច្របូកច្របល់ និងភាពទទេរ មានវត្តមានរបស់ព្រះបានបង្ហាញមកនូវផលផ្លែដែលមានប្រសិទ្ធិភាពនៅក្នុងលោកិយ។ នៅពេល

ដែលទ្រង់បង្កើតនៅក្នុងអនុវត្តការបង្ករបង្កើតជាថ្មី (សេចក្តីប្រោសលោះ) មុខងាររបស់ព្រះវិញ្ញាណនោះមានចេស្តាខ្លាំងជាងទៀត។នៅក្រុងយេរូសាឡិមប្រៀបដូចជារូងរបស់ចោរ នោះសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់របស់ព្រះត្រូវបានបង្ហាញមកនូវការចាប់ផ្តើមថ្មី។ ដោយសារការផ្លាស់ប្រែរបស់សាវ័កទាំង១២យ៉ាងស្របពេល វាគ្រប់គ្រាន់នៅក្នុងការគ្រប់គ្រងលើលោកិយដោយដំណឹងល្អ។នៅការដែលស្របគ្នារវាងការតឹងរឹងខាងច្បាប់និងការដែលគោរពព្រះក្លែងក្លាយ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានបើកនូវផ្លូវដែលផ្តេកថ្មីមួយ។រូបភាពដើមនេះបង្ហាញនូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែលជាចេស្តាដំបូងនៅក្នុងប្រវត្តិសាស្ត្ររបស់ដំណឹងល្អ។ ការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធ នោះការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះត្រូវបានបង្ហាញមកយ៉ាងអស្ចារ្យ។

### II. ទីពីរ ជាសាម៉ារី

ការពង្រាយដែលកាន់តែរីកចម្រើនឡើងជាផ្លូវដែលព្រះប្រើប្រាស់។ បន្តិចម្តងៗទ្រង់បានសំរេចគោលបំណងរបស់ទ្រង់។ បន្ទាប់មករបៀបដែលទ្រង់ប្រើរួចហើយនោះជាកាតដែលដេញតាម។ ការលំបាកដែលព្រះអនុញ្ញាត្តតែងតែមានការបៀតបៀនដេញតាមមកជាប្រព័ន្ធដែលសំខាន់ ដើម្បីនឹងបើកសំដែងពីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។គ្រីស្ទានដែលបានភៀសខ្លួនទៅកាន់ស្រុកសាម៉ារី បានបង្ហាញពីរូបឆ្លុះនៅក្នុងការបៀតបៀននោះ។ នៅថ្ងៃនេះ ភូមិរបស់យើង គ្រួសារ និងទីកន្លែងធ្វើជំនួញរបស់យើងអាចជាស្រុកសាម៉ារី។ យ៉ាងណាក៏ដោយដំណឹងល្អគួរតែត្រូវបានប្រកាសយ៉ាងឆាប់រហ័ស ហើយបង្ហាញនូវសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់របស់ព្រះអម្ចាស់។ ភីលីពជាម្នាក់ដែលត្រូវបានប្រើដោយព្រះដើម្បីប្រកាសដំណឹងល្អ និងរីករាយនូវអភ័យឯកសិទ្ធិនោះ ដែលនគររបស់ព្រះត្រូវបានអនុវត្តនៅក្នុងចំណោមអ្នកថ្វាយបង្គំព្រះក្លែងក្លាយជាលើកដំបូង។

### III. ទីបី ទីបញ្ចប់របស់ផែនដី

ជំហានបន្ទាប់ ដំណឹងល្អគួរតែត្រូវបានប្រកាសនៅលើលោកិយទាំងមូល។ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះត្រូវបានបង្រាយទៅកាន់ស្រុកអាស៊ីមីណា រ៉ូម អឺរ៉ុប អាមេរិក និងអាហ្វ្រិក និងរហូតដល់អាស៊ីអាគ្នេយ៍។ នៅទីកន្លែងដែលសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះ

ត្រង់របស់ព្រះត្រូវបានមើលងាយជាចុងក្រោយព្រះវិញ្ញាណបរិសុទ្ធបានសម្រេចនូវគោលបំណងនោះ។នោះប្រៀបដូចជាព្រះទ្រង់វាយថ្មហើយធ្វើឲ្យមានថ្មនៅពាសពេញផែនដីទាំងមូល ព្រះគ្រីស្ទផ្ទាល់បានសម្រេចកិច្ចការនោះ។ និយាយម៉្យាងទៀតថា នគរដែលនឹងត្រូវបានសោយរាជ្យដោយអាណាចក្ររបស់ព្រះបន្តិចទៀតនឹងមកដល់នៅក្នុងលោកិយ បេសកកម្មនឹងត្រូវបានក្លាយជាទិសដៅនិងជាគោលបំណង។

**1, ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងការបើកសំដែងរបស់យ៉ូហាន**

ការបើកសំដែងបែបរូបភាពចុងក្រោយត្រូវបានបង្ហាញដោយការបើកសំដែងរបស់យ៉ូហាន ដែលបានគូសវាសនូវការសម្រេចបំពេញនៅការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ នៅក្នុងការបើកសំដែងដែលត្រូវបានរៀបរាប់ដោយនិមិត្តរូបជាច្រើន បុត្រមនុស្ស និងប្រព័ន្ធមកពីខាងលើ ដែលសាវ័កយ៉ូហានបានមើលឃើញ ដែលមានពេញដោយរូបឆ្លុះរបស់ព្រះ លក្ខណៈរបស់ព្រះ និងសិរីល្អរបស់ព្រះ។ រូបភាពរបស់មនុស្សម្នាក់ដែលបានអង្គុយចុះនៅលើបល្ល័ង្គ ទាំងនោះមាន ត្បូង ត្បូងមរកត ត្បូងកណ្តៀង ចង្អុលទៅកាន់លក្ខណៈនៃរូបឆ្លុះរបស់ព្រះ។ វាជាលោកិយដែលត្រូវបានគ្រប់គ្រងពីលើដោយសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ សេចក្តីសង្គ្រោះ និងការកាត់ទោស ដែលត្រូវបានបង្ហាញដោយការមួយនេះ ហើយសិរីល្អនឹងត្រូវចែងចាំងមកតាមរយៈការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវនៅក្នុងលោកិយ។ រូបភាពរបស់ស្ថានសួគ៌នឹងត្រូវបានពេញដោយនគររបស់ព្រះ ដែលជា ថ្ងៃដែលមានពេញដោយសេចក្តីពិតនៃរូបឆ្លុះរបស់ព្រះ ដែលយើងអាចរីករាយសេចក្តីពិតដោយការបរិភោគនិងផឹកផង។

## ជំពូកទី 5 ការរីកចម្រើនបែបប្រវត្តិសាស្ត្រនៃការសិក្សាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ (ការសិក្សាអំពីមនុស្សនិងគោលលិទ្ធិនៃសេចក្តីសង្គ្រោះ)

ឥលូវនេះ សេចក្តីពិតនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះគួរតែត្រូវបានបង្ហាញមក ពីរបៀបអភិវឌ្ឍក្រុមជំនុំបែបប្រវត្តិសាស្ត្រវិញ។ យើងគិតអំពីទស្សនៈពីរ "រូបឆ្លុះរបស់ព្រះបែបជាការសិក្សាអំពីមនុស្ស" និង "ការស្តារឡើងវិញ បែបនៃគោលការណ៍នៃសេចក្តីសង្គ្រោះ"។

តើក្រុមជំនុំនឹងកើតជាថ្មីដោយការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធមានអំពើរបែបណាលើទស្សនៈនេះ? តាមរយៈលំនាំនៃក្រុមជំនុំជាន់ដើម ក្រុមជំនុំសម័យកណ្តាល ក្រុមជំនុំបែបកំណែទម្រង់ និង ក្រុមជំនុំនាសម័យបច្ចុប្បន្នដែលយើងគិតអំពីការនោះ។ យើងឆ្លើយនឹងសំណួរបន្តបន្ទាប់នេះ 1) តើពួកគេបានយល់យ៉ាងណាពីរូបឆ្លុះរបស់ព្រះ? នៅក្នុងចំណោមរបស់របស់ពួកគេ តើដំណែងទាំងបីរបស់ព្រះគ្រីស្ទ ជាស្តេច ជាសង្ឃ និងជាហោរាដើម្បីនឹងស្គាល់ពីលំនាំនៃការអភិវឌ្ឍដែលទាក់ទងទៅនឹងសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់យ៉ាងដូចម្តេច? 2) តើទំនាក់ទំនងអ្វីដែលសេចក្តីសង្គ្រោះនិងការស្តារឡើងវិញមាននោះ?

1. តាមរយៈការយល់ពីគម្ពីរនិងរូបឆ្លុះរបស់ព្រះយើងអាចលាតនូវទស្សនៈរបស់យើង។ លោក Karl Barth ដែលជាអ្នកប្រាជ្ញរបស់ neo- orthodoxy បានប្រៀបធៀបអំពីការពន្យល់នូវរូបឆ្លុះរបស់ព្រះរបស់បិតាខាងជំនឿមួយចំនួន។ អាំប្រូសបានសង្កេតនូវព្រលឹង អាតាណាសើសភាពភាពសមហេតុផល និងអូហ្គាស្ទីនចង្អុលនៅក្នុងការប្រៀបធៀបនៃតួនាទីពីបីរបស់ព្រះត្រៃឯក ទាំងនោះមាន ព្រលឹង ការចងចាំ និងប្រាជ្ញា។ ប៉ុន្តែអ្នកប្រាជ្ញរបស់អ្នកការពារសេចក្តីជំនឿរបស់ពួកកំណែទម្រង់ លោក Herman Bavinck បានប្រកែកនឹងធាតុបីយ៉ាងនៅក្នុងការការពារសេចក្តីជំនឿរបស់គាត់។ 1. ព្រះត្រៃឯកបង្ហាញចេញនូវគំនិតទៅកាន់លោកិយ។ 2. រូបឆ្លុះរបស់ព្រះរួមបញ្ចូលនូវទំនាក់ទំនងបីដែលជា ទំនាក់ទំនងបែបបុគ្គល ទំនាក់ទំនងបែបប្រុសស្រី និងទំនាក់ទំនងរបស់មនុស្ស និង 3) រូបដែលត្រូវបានឆ្លុះឲ្យឃើញតាមរយៈលក្ខណៈដែលបានរៀបចំឡើងដោយអំពើបាបដើម។ ( លោកុប្បត្តិ 1:-2:, 9:6 I កូរិនថូស 15:12-58 រ៉ូម 5:12-19)

បើទោះជាវាអាចជារឿងដែលអាចិកំបាំង ពីព្រោះការយល់នូវរូបឆ្លុះរបស់ព្រះមានន័យថាការយល់ពីព្រះត្រៃឯក ដែលយើងអាចអោយនិយមន័យថាជា ការបើកសំដែងបែបជារូបភាពនៃការបង្កបង្កើតនិងសេចក្តីប្រោសលោះរបស់ព្រះ ដែលត្រូវបានយល់ពីរូបឆ្លុះរបស់ព្រះ ពីព្រោះការបើកសំដែងរបស់ព្រះគម្ពីរបង្ហាញពីការបើកសម្តែងបែបរូបភាពនិងការពន្យល់នូវការបើកសម្តែង ដើម្បីស្គាល់អំពីព្រះនិងបានស្គាល់ទ្រង់។

រូបឆ្លុះរបស់ព្រះដែលយើងបានសម្គាល់នៅខាងលើនៅក្នុង លោកុប្បត្តិ1:26-27 នៅពេលដែលសាវ័កប៉ូលបានចង្អុលថា លក្ខណ:សីលធម៌របស់ទ្រង់ សេចក្តីសុចរិត សេចក្តីមេត្តា (ម៉ាថាយ 23:23) ឬ សភាពដែលសេចក្តីសុចរិតនិងសេចក្តីស្រឡាញ់ត្រូវបានស្របជាមួយគ្នា (លូកា11:43)។ ដូច្នេះរូបឆ្លុះរបស់ព្រះចង្អុលទៅកាន់លក្ខណ:នៃសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ នៅទីនេះផលផ្លែដែលត្រូវបានប្រោសលោះត្រូវបានបង្ហាញជាផលផ្លែខាងសីលធម៌វិញ។ តើអ្វីទៅជាការស្តារឡើងវិញ? ការស្តារឡើងវិញមានន័យថាជាការប្រោសលោះ។ ជាទូទៅប្រសិបបើយើងយល់ពីសេចក្តីប្រោសលោះថាជាការប្រោសលោះសាមញ្ញ ហើយមិនរាប់បញ្ចូលការរួបរួមនិងការរីករាយនូវសិរីល្អរបស់ទ្រង់នោះ នៅពេលដែលយើងមិនអាចនិយាយពីការប្រោសលោះបែបបទគម្ពីរប្រសិនបើយើងឲ្យនិយមន័យការប្រោសលោះថាជាការត្រឡប់ទៅកាន់នូវបល្ល័ង្គដើមរបស់អ័ដាមដែលមិនមានអំពើបាបនោះ វាមិនមែនជាការស្តារឡើងវិញបែបរបស់គម្ពីរថាទេ។ លើសពីនោះទៀត ប្រសិនបើយើងមិនរាប់បញ្ចូលអត្តសញ្ញាណនៃបុត្ររបស់ព្រះនិងភាពបរិសុទ្ធនៃដំណាក់របស់ព្រះទេ វាមិនមែនជាការស្តារឡើងវិញបែបរបស់បទគម្ពីរទេ។ ដូច្នេះការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះជាការមើលឃើញពីសិរីល្អរបស់ព្រះហើយត្រូវបានផ្លាស់ប្រែទៅក្នុងរូបឆ្លុះរបស់ទ្រង់យ៉ាងពេញលេញ ហើយជាសភាពនៃការចូលរួមនៅក្នុងសិរីល្អរបស់ទ្រង់ (យ៉ូហាន 17:24)។

ដូច្នេះយើងត្រូវការការស៊ើបអង្កេតលើបញ្ហានេះពីរបៀបដែលអ្នកប្រាជ្ញដែលសិក្សាពីព្រះមានប្រតិកម្មទៅលើការស្តារឡើងវិញ នៅក្នុងទស្សន:នៃលិទ្ធិនៃសេចក្តីសង្គ្រោះ។ ពាក្យម៉្យាងទៀតថាការនេះធ្វើឲ្យយើងផ្លាស់ចូលទៅក្នុងការយល់ដឹងបែបខាងលិទ្ធិនៃសេចក្តីប្រោសលោះនៃសិរីល្អរបស់ព្រះ។

បើទោះជាបញ្ហារបស់យើង ការស្តារឡើងវិញត្រូវបានបង្ហាញជាដំបូង ដោយការបង្ហាញ

នៅក្នុងលោកុប្បត្តិ3:15 ការសន្យានិងការស្លៀកពាក់សំលៀកបំពាក់ស្បែកដែលជានិមិត្តសញ្ញានៃការប្រោសលោះ ដែលព្រះបានប្រាប់ឲ្យត្រឡប់ទៅកាន់សួនច្បារអេដែនបន្ទាប់ពីដំណោះស្រាយរបស់មនុស្សពីបញ្ហាបាបរបស់គេនៅក្នុងពាក្យសំដីរបស់ទ្រង់ (លោកុប្បត្តិ 3:22)។ចំណេះដឹងដំបូងដែលអ័ដាមបានរៀនជាផ្លូវតែមួយគត់ទៅកាន់ការទំនាក់ទំនងជាមួយនឹងព្រះ ជាអាសនានៃឈាមរហូតដល់ព្រះគ្រីស្ទយាងមកនៅលើលោកិយ តាមរយៈនិមិត្តសញ្ញាជាច្រើននៅក្នុងថ្ងៃចុងក្រោយ ព្រះគ្រីស្ទដែលជារូបឆ្លុះរបស់ព្រះត្រូវបានសុគតនៅលើឈើឆ្កាងជាជំនួសនិងជារបៀបនៃការស្តារឡើងវិញត្រូវបានសម្រេចតាមរយៈទ្រង់។ នៅក្នុងវិវរណៈនៃការបើកសំដែងរបស់លោកយ៉ូហាន យើងឃើញពីការស្តារឡើងវិញនៃអេដែនរបស់លោកុប្បត្តិ។

ប៉ុន្តែការស្តារឡើងវិញជាការស្តារឡើងវិញបែបខាងក្រៅ ការស្តារឡើងវិញពិតប្រាកដមានអត្ថន័យជ្រាលជ្រៅជាងនោះ។ ភាពស្រស់ស្អាតនៃរូបឆ្លុះរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពបរិសុទ្ធ ដែលអ័ដាមបានបាត់បង់ដោយសារអំពើបាប ហើយជាសេចក្តីពិតនៃការរួបរួមរវាងព្រះត្រៃឯកនិងរាស្ត្ររបស់ទ្រង់ ហើយជាការចូលរួមនៅក្នុងសិរីល្អរបស់ព្រះដោយការជួបប្រជុំនូវភាពបរិសុទ្ធនឹងភាពបរិសុទ្ធ ហើយមកកាន់ការស្តារឡើងវិញយ៉ាងពេញលេញ។ ពាក្យម៉្យាងទៀត វាមានន័យថា មុនពេលដែលអ័ដាមបានប្រព្រឹត្តបាប សភាពដែលត្រូវបានកន្លងផុតនូវភាពរបស់អ័ដាម សភាពដែលយើងមិនអាចនឹងប្រព្រឹត្តបាបដែលនៅក្នុងព្រះគ្រីស្ទ ពួកគេខិតចូលជិតសភាពនោះ សេចក្តីបរិសុទ្ធនិងសិរីល្អដែល ការគ្រប់ទាំងអស់របស់គេត្រូវបានរួបរួមជាមួយនឹងព្រះក្លាយជាការតែមួយ។

តាមរយៈការសិក្សាខ្ញុំបានរៀបចំបញ្ហានេះដោយការពឹងផ្អែកលើការយល់ដឹងរបស់លោក M. G. Kline អំពីបទគម្ពីរ។ គាត់បានបកប្រែវាជាអត្ថន័យពីរ មួយវាមានន័យថាជាបុត្រារបស់ព្រះ មួយទៀតជារោងឧបោសថរបស់ព្រះ។ គាត់បានពន្យល់យ៉ាងមុតមាំថា នៅក្នុងចំណុចកណ្តាលនៃលក្ខណៈរបស់មនុស្សនៃរូបឆ្លុះរបស់ព្រះពីរបៀបដែលព្រះទ្រង់មានមុខងារជាសង្ឃ ជាហោរាមានប្រតិកម្មដោយបែបចំណេះដឹងពីព្រះទៅតាមព្រះគម្ពីរ។ បន្ទាប់ពីនោះមកតាមរយៈដំណែងទាំងបីរបស់ព្រះមេស៊ី ភាពជាស្តេចដែលសាកសម ជាសេចក្តីពិត

ដែលព្រះបង្ហាញលក្ខណៈរបស់ទ្រង់ទៅកាន់លោកិយជាវិធីសាស្រ្តរបស់ព្រះ។

## ជំពូកទី 6 ការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះជាគោលបំណងនៃជីវិត

ពេលនេះយើងអនុវត្តនូវការសិក្សាអំពីព្រះនិងសេចក្ដីជំនឿនៃការស្ដារឡើងវិញនៃរូបឆ្លុះរបស់ព្រះអនុវត្តទៅកាន់សេចក្ដីសង្គ្រោះដោយផ្ទាល់ខ្លួននិងការលូតលាស់របស់វា។ ពីព្រោះវាជាគោលដៅចម្បងរបស់យើង។

### 1. សេចក្ដីសង្គ្រោះត្រូវបានចាប់ផ្ដើមជាមួយការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

សេចក្ដីសង្គ្រោះរបស់មនុស្សម្នាក់ៗបង្ហាញពីការដែលមានរូបឆ្លុះរបស់ព្រះ។ នៅទីនេះ រូបឆ្លុះរបស់ព្រះមានន័យថាជាព្រះវិញ្ញាណបរិសុទ្ធដែលបានដាំនូវជីវិតថ្មីនៅក្នុងយើងសម្រាប់ជាការកើតជាថ្មី ហើយធ្វើឲ្យយើងមានជីវិតថ្មីនៅក្នុងទ្រង់។ បន្ទាប់មកយើងបែបនៃការសិក្សាពីព្រះជាប្រព័ន្ធ នឹងត្រួតពិនិត្យលើដំណើរការនៃ ការតែងតាំងម្ដងទៀតនៃការដៅចំណាំទុកជាមុនការត្រាស់ហៅ និងបានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមក និងធ្វើឲ្យយើងលន់តួអំពើបាបហើយជឿតាមរយៈការប៉ះពាល់ចិត្ត។ ដោយសារព្រឹត្តិការណ៍នេះ ព្រះបានរាប់គាត់ជាសុចរិត ហើយទទួលគាត់ជាអ្នកដ៏សុចរិត។ តាមរយៈការនេះ គេមានជីវិតដូចគ្នា វិញ្ញាណនៃការរាប់ជាកូនចិញ្ចឹមរបស់ព្រះ ជាព្រះវិញ្ញាណបរិសុទ្ធ។ ការសារភាពរបស់គេជាការឆ្លើយតបបែបធម្មតានៃការរួបរួមជាមួយព្រះ ដូច្នេះបើទោះជាគេរស់នៅលើលោកិយនេះក៏ដោយ នោះគេមានលក្ខណៈដូចជាព្រះដោយសារការស្ដារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។ នៅក្នុងពាក្យមួយទៀតថា គេមានលក្ខណៈរបស់ព្រះដែលមានការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ ការនេះត្រូវបានចាប់ផ្ដើមដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។

## 2. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះត្រូវការការដំណើរការ

អ្នកដែលមានលក្ខណៈរបស់ព្រះត្រូវការដំណាក់កាលដើម្បីនឹងលូតលាស់ទៅកាន់លក្ខណៈដ៏ពេញលេញរបស់ព្រះ មិនមែនដោយសារព្រះទ្រង់មានចេស្តាតិចតួចនោះទេ ប៉ុន្តែដោយសារព្រះទ្រង់ចង់ឲ្យមានការបន្សុតដោយសារការត្រាប់តាមព្រះគ្រីស្ទបន្តិចម្តងៗ។ ដូចជានៅក្នុងទឹកដីកាណាន ព្រះបានទុកឲ្យកុលសម្ព័ន្ធរបស់ពួកកាណានដើម្បីនឹងបង្វឹកពួកអ៊ីស្រាអែល និងធ្វើឲ្យពួកគេស្គាល់ព្រះគ្រីស្ទឲ្យបានជ្រាលជ្រៅ ដោយការផ្លាស់ប្តូរសារជាតិរបស់ពួកគេឲ្យបានស្គាល់ព្រះ។ នោះព្រះអនុញ្ញាតនូវដំណើរការនៃការលូតលាស់របស់គ្រីស្ទានបែបដូច្នេះដែរ។ តើពួកគេគួរតែលូតលាស់បែបដូចម្តេច?

ប៉ូលបាននិយាយពីសីលធម៌ប្រាំពីរ មានសេចក្តីជំនឿ សីលធម៌ ចំណេះដឹង ការចេះទប់ចិត្តខ្លួនឯង ការអត់ធ្មត់ សេចក្តីសប្បុរស ភាពជាបងប្អូន និងសេចក្តីស្រឡាញ់។ ការទាំងនេះអាចសង្ខេបមកដោយសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ជាផលផ្លែដែលត្រូវបានស្តារមកនៃរូបឆ្លុះរបស់ព្រះ។ សេចក្តីជំនឿមានទំនាក់ទំនងនឹងសេចក្តីកោតខ្លាចដល់ព្រះ សេចក្តីមេត្តា ភាពជាបងប្អូន និងសេចក្តីស្រឡាញ់ និងភាពស្មោះត្រង់ទៅកាន់ចំណេះដឹងនិងសេចក្តីជំនឿ។

មនុស្សមួយចំនួនប្រៀបធៀបការលូតលាស់នៃសេចក្តីស្រឡាញ់ ជំហាននៃការពេញវ័យ សេចក្តីស្រឡាញ់ជាការសង្ខេបនៃអត្តចរិត ប៉ុន្តែផលផ្លែនៃវិញ្ញាណត្រូវបានចាប់ផ្តើមជាមួយសេចក្តីស្រឡាញ់ពីព្រោះសេចក្តីស្រឡាញ់រាប់បញ្ចូលនូវផលផ្លែនោះ។ដូច្នេះសភាទាំងស្រុងនៃផលផ្លែនីមួយៗរបស់ព្រះវិញ្ញាណជាសេចក្តីស្រឡាញ់។ លោក Billy Graham បង្ហាញផលផ្លែដំបូងបីរបស់ព្រះវិញ្ញាណដែលមានទំនាក់ទំនងទៅកាន់ព្រះ។ផលផ្លែបីទីពីរមានទំនាក់ទំនងនឹងលោកិយ ហើយផលផ្លែបីចុងក្រោយមានទំនាក់ទំនងមកកាន់យើង។ ដូច្នេះសេចក្តីស្រឡាញ់ជាលក្ខណៈស្របជាមួយនឹងសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ ប្រសិនបើសេចក្តីស្រឡាញ់មាន នោះសេចក្តីសុចរិតមិនមាននៅទីនោះទេ ឬសេចក្តីសុចរិតមាន នោះសេចក្តីស្រឡាញ់មិនមាននៅទៅនោះ នោះវាជាការខុសហើយ។

## 3. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះត្រូវបានបង្ហាញជារូបភាពរបស់ព្រះគ្រីស្ទ

ការស្តារឡើងវិញធ្វើឲ្យយើងខិតចូលទៅជាការពេញវ័យ។ ការពេញវ័យមានន័យថាអត្តចរិតរបស់យើងត្រូវបានត្រាប់តាមទៅកាន់លក្ខណៈរបស់ព្រះដោយសារកិច្ចការរបស់ព្រះ។ វាជាសភាពដែលរស់នៅដូចជាព្រះនៅក្នុងលោកិយតាមរយៈដំណើរការនៃការរងទុក្ខដោយការដើរតាមព្រះគ្រីស្ទបន្តិចម្តងៗ ដែលជារូបភាពដែលរស់នៅក្នុងនគររបស់ព្រះ។

ប៉ុន្មានថ្ងៃកន្លងមក យ៉ាកុបត្រូវបានបង្ហាញជាមនុស្សដែលពេញវ័យនៅក្នុងជីវិតរបស់គាត់។ ជីវិតដែលយកខ្លួនឯងជាកណ្តាលត្រូវបានផ្លាស់ប្តូរទៅជាជីវិតដែលយកអ្នកជិតខាងជាចំនុចកណ្តាល។ ព្រះបានបង្ហាញការមួយនេះតាមរយៈដំណើរការនៃការរងទុក្ខ។ តាមរយៈដំណើរការនៃការរងទុក្ខរបស់យ៉ាកុបដ៏យូរ គាត់បានបង្ហាញពីមនុស្សដែលបានផ្លាស់ប្រែ ដែលជារូបឆ្លុះរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ គ្រីស្ទានដែលមានគោលបំណងទៅកាន់ភាពពេញវ័យនៃគ្រប់ទាំងការបន្សុត និងផ្លាស់ប្រែទៅកាន់រូបឆ្លុះរបស់ព្រះអម្ចាស់ដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងសេចក្តីមេត្តារបស់ទ្រង់ និងក៏បង្ហាញពីរូបឆ្លុះរបស់ព្រះនៅលើលោកិយជាពិត។

## 4. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះគួរតែបានបង្ហាញនូវពន្លឺនៅក្នុងជីវិត

ជីវិតដែលប្រៀបធៀបនៃពន្លឺចេញពីបទគម្ពីរបង្ហាញមកកាន់យើង។ ពន្លឺដែលចេញមកពីពន្លឺដ៏ពិតនិងពន្លឺខាងវិញ្ញាណ ប៉ុន្តែបង្ហាញមកដូចជាពន្លឺនៃសីលធម៌។ "បង្ហាញនូវពន្លឺ" នៅក្នុងគម្ពីរផ្តោតលើសីលធម៌បែបរបស់ព្រះគម្ពីរ។ ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះមានន័យថាជាការដាក់គោលដៅចម្បងទៅកាន់ជីវិត។ វាមានន័យថាការផ្តោតលើជីវិតនិងសីលធម៌នៃជីវិត។ បើទោះជាការក្លាយទៅជាការនោះជាការសំខាន់ក៏ដោយ តែការបង្ហាញមករឹតតែសំខាន់ថែមទៀត។ នៅពេលដែលយើងយល់ការនោះហើយយើងធ្វើវាបានល្អ នោះយើងមានជីវិតសីលធម៌ទៅតាមព្រះគម្ពីរមែន។ ការបែងចែករបស់ពួកសាវ័កអំពីទស្សនៈពីរជាការសំខាន់។ ទស្សនៈមួយជាការត្រឡប់ទៅជាការនោះ។ បន្ទាប់ពីយើងយល់ពីអត្តសញ្ញាណរបស់យើង

និងបន្ទាប់មកជាជំហានដែលយើងផ្តោតលើការប្រព្រឹត្ត។

**សរុបសេចក្តី៖**

យើងបានរំឭកថាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះបង្ហាញពីរបៀបបង្ហាញនៅក្នុងជីវិតរបស់យើងតាមរយៈជំហានប្រាំយ៉ាង។ ដំណើរការមានលក្ខណៈសាមញ្ញដូចដែលយើងបានឃើញនៅក្នុងទស្សនៈនៃលិទ្ធិនៃសេចក្តីសង្គ្រោះ ពីព្រោះវាជាគោលបំណងរបស់ព្រះទៅកាន់រាស្ត្ររបស់ទ្រង់។ អ្វីដែលក្រុមជំនុំផ្តោតលើការនេះនោះជាការលូតលាស់ ការពេញវ័យ និងការរីកចម្រើន។

## ជំពូកទី 7 ក្រុមជំនុំបំរើដើម្បីនឹងសម្រេចបាននូវការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

បន្ទាប់ពីយើងបានរំឭកពីជីវិតនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនោះយើងគួរតែមើលទៅកាន់វិធីសាស្ត្រដែលវាត្រូវបានសម្រេចនៅក្នុងប្រវត្តិសាស្ត្ររបស់ព្រះគម្ពីរនិងរបស់ក្រុមជំនុំជាប្រាកដ។ ដូច្នេះនៅក្នុងជំពូកនេះយើងគិតវិធីសាស្ត្រសំខាន់បួនយ៉ាងដើម្បីនឹងបង្ហាញរូបឆ្លុះនោះនៅក្នុងកិច្ចការរបស់ព្រះជាបន្ត។

### 1. គំនិតដែលពឹងលើការបើកសំដែង

គ្រឹះរបស់ព្រះគម្ពីរដែលការសញ្ជឹងគិតដោយផ្អែកលើការបើកសំដែង ជាវិធីសាស្ត្រនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ ជាការធានាអះអាងដែលលោកគ្រូរបស់ខ្ញុំលោក Jung Am, លោកបណ្ឌិត Dr. Yun Sun Park បានទទួលបទពិសោធន៍នៅក្នុងពេញមួយជីវិតរបស់គាត់ដែលវាត្រូវបានគាំទ្រដោយការបង្រៀនរបស់លោក Herman Bavinck អំពីរទស្សនៈរបស់ព្រះគម្ពីរ។ វាជាការត្រចះត្រចង់នៅក្នុងចិត្តរបស់ខ្ញុំនៅពេលនេះដែលនៅពេលដែលគាត់ស្រែកមកពីគម្រោងដែលយើងគួរតែជឿនៅក្នុងព្រះគម្ពីរដោយគ្មានលក្ខខណ្ឌនៅក្នុងថ្នាក់

ដំបូងនៃការសិក្សាពីព្រះតាមបទគម្ពីរ នៅក្នុងការសិក្សានៅសាលាគម្ពីរ។ ហេតុអ្វី? ការបើកសំដែងជាគម្ពីរតែមួយគត់ ការពឹងលើជាសេចក្តីជំនឿពិត ដើម្បីនឹងថ្វាយខ្លួនរបស់យើងនៅលើព្រះគម្ពីរ ទ្រឹស្តីដូចជាគ្រឹះនៃជីវិតទាំងមូល យើងគួរតែគិតគំនិតបែបព្រះគម្ពីរ។ បន្ទាប់មកសេចក្តីសង្រ្គោះពិតត្រូវតែបានកើតឡើង តាមរយៈការដែលពឹងលើការបើកសម្តែង។ ពិតណាស់ការអះអាងរបស់គាត់ត្រូវបានបកប្រែជាគោលបំណងនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ វិធីសាស្រ្តរបស់វានិងផលផ្លែរបស់វា។ វាជាគ្រឹះរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើងនិងការអធិប្បាយរបស់ពួកសាវ័ក។ ហើយគំរូនិងគោលការណ៍ដែលព្រះអម្ចាស់និងពួកសាវ័កបានដេញតាម។ មនុស្សមួយចំនួនបានយល់ពីពាក្យ ពាក្យចចាមរាមដូចជាការគិតដែលសាមញ្ញនិងការសញ្ជឹងគិតបែបលោកិយ ប៉ុន្តែពាក្យចចាមរាម (គំនិត) មានន័យថាជាការថ្វាយគ្រប់សកម្មភាពទាំងអស់ពេញមួយជីវិត។

ដូចជាដើមឈើដែលខ្សោយមិនអាចយកឈ្នះលើសត្វដ៏ល្អិតជំងឺនិងគ្រោះចង្រៃបាន នោះគំនិតដ៏តូចរបស់យើងជាបែបរបស់គម្ពីរ ដែលគំនិតរបស់យើងត្រូវបានពឹងលើការបើកសម្តែងយ៉ាងស្មោះត្រង់ នោះយើងនឹងក្លាយជាដើមឈើដែលរឹងមាំ ដែលមានសត្វចាបជាច្រើនអាចសំរាកនៅបាន។ វាមានន័យថានៅពេលដែលយើងត្រូវបានគ្រប់គ្រងដោយព្រះបន្ទូលរបស់ព្រះនោះគ្រប់គំនិតរបស់យើងនិងពេញមួយជីវិតរបស់យើងត្រូវបង្ហាញពីរូបឆ្លុះរបស់ព្រះ៖ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ គម្ពីរជាដី ជីវៈប្រវត្តិ និងប្រភព។ ដូច្នេះគម្ពីរផ្ទាល់ផ្តោតលើការពិសោធន៍នៃព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ។ ព្រឹត្តិការណ៍ដែលត្រូវបានពិសោធន៍នៅក្នុងទំនុកដំកើងជំពូក119 និង 19 ចង្អុលថាវាមិនមែនជាចំណេះដឹងសាមញ្ញឬជាប្រាជ្ញាតូចទាប ប៉ុន្តែបង្ហាញនូវរូបភាពនៃម្នាក់ដែលត្រូវបានស្តារឡើងវិញទៅជារូបឆ្លុះរបស់ព្រះទៅក្នុង សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ ដោយការថ្វាយជីវិតទាំងមូលរបស់គេទៅកាន់ការនោះ។ វាមានន័យថាការផ្លាស់ប្រែទៅជារូបឆ្លុះរបស់ព្រះគ្រីស្ទដោយការទទួលនូវសេចក្តីសង្រ្គោះនិងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។

## 2. ជីវិតដែលពឹងលើព្រះវិញ្ញាណ

ក្រៅពីការបើកសំដែងនិងការធ្វើឲ្យយើងបានបើកភ្នែកដោយព្រះវិញ្ញាណបរិសុទ្ធ នោះមនុស្សមានបាបមិនអាចបើកបានឡើយ។ ដូច្នេះនៅពេលដែលមនុស្សមានបាបបានភ្ញាក់ឡើងដោយសារការរកឃើញសេចក្តីពិតពីរ៖ មួយជាការរកឃើញអំពើរបាបរបស់ខ្លួន និងមួយទៀតជាការរកឃើញភាពអស្ចារ្យរបស់ព្រះអម្ចាស់ ដោយការបើកនូវភ្នែកខ្វាក់របស់គេដោយការបើកសំដែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកដែលរកឃើញលំនាំនៃសរសៃខាងក្នុង គួរតែមានសតិនៅក្នុងការដេញតាមសេចក្តីពិតតែមួយមុខគត់ ហើយមានការឆ្លើយតបដោយឯកឯង។ ដូច្នេះនៅពេលដែលប៉ុលប្រាប់ គាត់អាចយល់ពីការបង្គាប់ដែលដេញតាមព្រះវិញ្ញាណបរិសុទ្ធដោយជ្រាលជ្រៅ ហើយធ្វើឲ្យគាត់រស់នៅដូច្នោះដែរ។ ព្រះវិញ្ញាណជាព្រះវិញ្ញាណនៃសិរីល្អនៅក្នុងការបង្កបង្កើតនិងរូបភាពដើមនៃរូបឆ្លុះរបស់ព្រះនៅពេលដែលព្រះបង្កើតមនុស្ស។ ហើយទ្រង់ធ្វើការជាអ្នកដឹកនាំពិត ដែលដឹកនាំពួកគេទៅក្នុងសេចក្តីពិតនៅក្នុងជ្រលងនៃសេចក្តីរងទុក្ខលំបាក។ ទ្រង់ជាសេចក្តីពិតដែលជាសសរនៃពពក និងបង្គោលភ្លើងដែលចង្អុលបង្ហាញនៅក្នុងនិមិត្តរូប។ ដោយជំពាក់ទៅនឹងការនេះ មនុស្សទុច្ចរិត មិនមានសេចក្តីមេត្តា និងមនុស្សមិនស្មោះត្រង់ នោះគេនឹងត្រូវបានផ្លាស់ប្រែទៅជាម្នាក់ដែលមានលក្ខណៈរបស់សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់គ្រប់គ្រងលើដោយកិច្ចការរបស់ព្រះវិញ្ញានបរិសុទ្ធ។ គំនិតដែលពឹងលើព្រះគម្ពីរជាជីវិតដែលពឹងលើព្រះវិញ្ញាណ។

## 3. ជីវិតដែលមានព្រះបន្ទូលជាចំណុចកណ្តាល

នៅពេលដែលយើងបានមកដល់គោលបំណងនេះរួចមកហើយ នោះលំហូរនៃព្រះគម្ពីរជាគែមដែលចែងចាំងបន្តនៅក្នុងលំហូរនៃសេចក្តីប្រោសលោះបែបប្រវត្តិសាស្រ្ត។ ពីព្រោះគ្រឹះនៃព្រះបន្ទូលជាការបើកសំដែងរបស់ព្រះ ការបើកសំដែងរបស់ព្រះជាការបញ្ជាក់ពីលក្ខណៈរបស់ព្រះដូចជាលក្ខណៈរបស់ព្រះដែលមានរួចមក។ គ្រប់អត្ថបទព្រះគម្ពីរសុទ្ធតែមានទំនាក់ទំនងទៅកាន់ការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។ លក្ខណៈជាព្រលឹងនៃការបើកសំដែងនិងជីវជាតិនៃការបើកសំដែង។ ពាក្យផ្សេងទៀត ព្រះគម្ពីរឈរយ៉ាងរឹងមាំលើភ្នំ។ បើ

ទោះជាវាត្រូវបានបញ្ជាក់នៅក្នុងផ្នែកមួយផ្ទាល់ក៏ដោយ ក៏មិនមានអ្នកណាអាចបំផ្លាញវាបានដែរ។ សាវ័កប៉ូលនៅក្នុង ២ធីម៉ូថេ 3:16-17 និយាយថា ព្រះគម្ពីរដូចជារបស់ដែលព្រះបង្កើតមក នោះជាលក្ខណៈរបស់ព្រះ ត្រូវបានផ្លាស់ប្តូរទៅជាព្រះបន្ទូលរបស់ព្រះ។ ដូចដែលព្រះទ្រង់បានដកដង្ហើមទៅកាន់អ័ដាមធ្វើឲ្យគាត់ក្លាយជាព្រលឹងដែលមានជីវិត នោះតួអក្សរនិងគំនិតរបស់មនុស្សត្រូវបានតភ្ជាប់ទៅកាន់គំនិតរបស់ព្រះ ហើយវាបានពេញដោយលក្ខណៈរបស់ព្រះ។ដូច្នេះការធានាអះអាងដែលត្រូវស្រឡាញ់ព្រះមានន័យថាការស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាសេចក្តីជំនឿរបស់មនុស្សរបស់ព្រះ។ ដូច្នេះនៅពេលដែលយើងសញ្ជឹងគិតព្រះគម្ពីរ វាត្រូវបានហៅថាជាព្រះពរ ហើយតាមរយៈព្រះបន្ទូលនោះផ្តល់មកនូវជីវជាតិនៃសេចក្តីសង្គ្រោះមកកាន់យើងដើម្បីសម្រេចនូវសេចក្តីសង្គ្រោះជាព្រះបន្ទូលខាងវិញ្ញាណ។ក្រៅពីការសញ្ជឹងគិតលើបទគម្ពីរ យើងមិនអាចរំពឹងដល់ការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះឡើយ។ ដូច្នេះយ៉ាកុបបានអះអាងថាប្រសិននរណាម្នាក់មើលទៅកាន់បទគម្ពីរដោយប្រុងប្រយត្ន នោះគេនឹងអាចទទួលបានការផ្លាស់ប្រែជាបន្តបន្ទាប់។

### 4. ជីវិតដែលមានការអធិស្ឋានជាចំណុចកណ្តាល

ហើយយើងស្គាល់ពីវិធីសាស្រ្តមួយទៀតដើម្បីនឹងស្តារនូវរូបឆ្លុះរបស់ព្រះនោះជាការអធិស្ឋាន។ ការអធិស្ឋាននេះមិនខុសពីគ្នាទេ ប៉ុន្តែការឆ្លើយតបរបស់អ្នកដែលយល់ព្រះបន្ទូលរបស់ព្រះ។ នៅពេលដែលយើងអធិស្ឋានទៅកាន់ព្រះ នោះយើងអាចផ្លាស់ប្រែដោយព្រះគុណរបស់ព្រះ។ ការអធិស្ឋានជាកន្លែងដែលនៃសេចក្តីពិតទូទៅដែលនឹងត្រូវបានបើកសំដែងមក។ អ័ដាមជាអ្នកដែលបានដើរនៅចន្លោះថ្មនៃភ្លើង ដែលមានពេញដោយវត្តមានរបស់ព្រះនៅក្នុងពិភពលោកនៃការអធិស្ឋាន។ ហើយពិភពលោកនៃការអធិស្ឋានជាអ្នកដែលអធិស្ឋាន។ ដូច្នេះការផ្លាស់ប្រែជាច្រើននៅក្នុងព្រះគម្ពីរកើតឡើងនៅក្នុងពិភពលោកនៃការអធិស្ឋាន។ ការជួបបទពិសោធន៍នូវការប្រកបជាមួយនឹងព្រះតាំងពីស្ថានសួគ៌ត្រូវបានបាត់បង់។ បន្ទប់អធិស្ឋានដែលត្រូវបានហៅថាជាព្រះពរ គឺគ្រប់គ្រីស្ទានទាំងអស់អាចចូលទៅជួបព្រះដោយងាយ។ នៅពេលដែលយើងអធិស្ឋានដោយមិនមានការឈប់បង្អង់ នោះទ្វាររបស់ស្ថានសួគ៌នឹងត្រូវបើកនៅចំពោះយើង ហើយវត្តមានដ៏អស្ចារ្យនឹងមកកាន់យើង។

## 5. ជីវិតដែលមានការថ្វាយបង្គំព្រះជាកណ្តាល

តាមរយៈការថ្វាយបង្គំ នោះម្នាក់ដែលស្តារនូវរូបឆ្លុះរបស់ព្រះត្រូវការការស្តារឡើងវិញថែមទៀតជាបុគ្គលនិងជាផ្នែកនៃក្រុមជំនុំដែលមានទីតាំងនៅកណ្តាលនៃកិច្ចការរបស់ព័ន្ធកិច្ចសហគមន៍របស់ក្រុមជំនុំ។ ក្រុមជំនុំជាកន្លែងបច្ចុប្បន្នដែលការអធិប្បាយព្រះបន្ទូលរបស់ព្រះគួរតែបានអនុវត្តនិងនាំមកនូវលទ្ធផលនិងផលផ្លែមកកាន់យើង។ ពីព្រោះការថ្វាយបង្គំត្រូវមានពេញដោយរូបឆ្លុះនៃសេចក្តីសុចរិត សេចក្តីមេត្តា និងភាពបរិសុទ្ធ ព្រះវិញ្ញាណបរិសុទ្ធនិងសេចក្តីពិតគ្រប់គ្រងលើការនោះ។ ព្រះដែលទ្រង់ស្វែងរកអ្នកដែលថ្វាយបង្គំនៅក្នុងសេចក្តីពិតបញ្ជូនមកនឹងត្រូវបានពេញដោយរូបឆ្លុះរបស់ព្រះ។ ការថ្វាយបង្គំត្រូវមានវត្តមានជាមួយនឹងការគ្រប់គ្រង វត្តមាន និងចេស្តារបស់ព្រះ។

## 6. ជីវិតដែលមានការសិក្សាព្រះគម្ពីរជាចំណុចកណ្តាល

សេចក្តីពិតដែលគោលបំណងនៃការអប់រំ ជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ដោយសារវាជាការសំខាន់នៃការបង្គាប់របស់ព្រះអម្ចាស់។ ក្រសួងអប់រំដើម្បីនឹងបង្រៀននិងធ្វើឲ្យយើងរក្សាការនោះ ជាគោលបំណងនៃការត្រាស់ហៅរបស់អ័ប្រាហាំ លោកុប្បត្តិ 18:19 មានបន្ទូលថា "ដ្បិតអញស្គាល់គាត់ថា គាត់នឹងបង្គាប់ដល់កូនចៅនិងពួកផ្ទះគាត់តរៀងទៅ ឲ្យគេកាន់ខ្ជាប់តាមផ្លូវនៃព្រះយេហូវ៉ា ដើម្បីឲ្យបានប្រព្រឹត្តសេចក្តីសុចរិត និងសេចក្តីទៀងត្រង់ប្រយោជន៍ឲ្យព្រះយេហូវ៉ាបានសម្រេចដល់គាត់ តាមសេចក្តីដែលទ្រង់មានបន្ទូលពីដំណើរគាត់។" ក្រុមជំនុំគួរតែបង្ហាញពីលក្ខណៈរបស់ព្រះ រូបឆ្លុះនៃព្រះ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់តាមរយៈគ្រូសារ។ ផ្ទុយទៅវិញការអប់រំរបស់លោកិយគឺដើម្បីធ្វើឲ្យមានឥរិយាបថល្អ ប៉ុន្តែក្រុមជំនុំបង្ហាញពីរូបឆ្លុះរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ដោយការបង្ខឹងនិងរងទុក្ខលំបាកជាច្រើន។

## 7. ជីវិតដែលមានការផ្សាយដំណឹងល្អជាចំណុចកណ្តាល

ជីវិតសាមញ្ញដើរតាមគោលការណ៍ ឲ្យស្រឡាញ់អ្នកជិតខាងឲ្យដូចខ្លួនឯង ជីវិតដែលបំរើមាន

ន័យថាការបង្ហាញពីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ បើទោះជាពួកគេបានផ្តល់របស់របរខ្លះៗទៅអ្នកដទៃក៏ដោយ ក៏យើងគួរតែបង្ហាញពីលក្ខណៈរបស់ព្រះទៅកាន់អ្នកជិតខាងរបស់យើង ដូចជាការឆ្លើយតបទៅកាន់ជីវិតដែលមានព្រះគ្រីស្ទជាកណ្តាល។ លក្ខណៈរបស់ព្រះគួរតែមានលក្ខណៈពិភពលោក។

## 8. ជីវិតដែលមានព័ន្ធកិច្ចជាចំណុចកណ្តាល

ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះចង់បានការស្មោះត្រង់ទៅកាន់ការបង្គាប់ដ៏ធំរបស់ព្រះអម្ចាស់។ ក្រុមជំនុំគួរតែមកដល់កន្លែងដែលប្រកាសដំណឹងល្អនិងបង្ហាញនូវការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ ដូច្នេះទីនៃការបង្គាប់ដ៏អស្ចារ្យរបស់ព្រះនៅក្នុង ម៉ាកុស 16:15 ដែលបង្ហាញដែលត្រូវប្រកាសដំណឹងល្អទៅកាន់គ្រប់ជីវិតទាំងអស់ មានគោលបំណងដើម្បីនឹងបង្កើតនគររបស់ព្រះនៅក្នុងផែនដី។ យើងត្រូវបង្កើតគ្រប់ទាំងលោកិយដែលមានទំនាក់ទំនងទៅនឹង នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម ឲ្យមានព្រះគ្រីស្ទជាស្តេចហើយធ្វើឲ្យការទាំងនោះត្រូវបានគ្រប់គ្រងដោយព្រះគ្រីស្ទ។នេះជាបេសកកម្មពិតប្រាកដ។ ដោយសារទីបន្ទាល់នៃការប្រកាសដំណឹងល្អជាចេស្តាដែលនឹងត្រូវបង្កើតទៅកាន់គ្រប់មនុស្សទាំងអស់។

# ជំពូកទី 8 ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះជាគោលបំណងនៃព័ន្ធកិច្ចរបស់គ្រូគង្វាល

## 1. ការលូតលាស់នៃក្រុមជំនុំអេភេសូជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

ដូចដែលយើងបានដឹងហើយថាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ ជាជីវិតនៃសេចក្តីសង្គ្រោះដ៏ពេញលេញ បង្ហាញពីលក្ខណៈរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពបរិសុទ្ធនៅក្នុងពន្លឺនៃសេចក្តីប្រោសលោះបែបបទគម្ពីរ។ យើងឈានទៅដែលព័ន្ធកិច្ចរបស់គ្រូគង្វាលត្រូវបានអនុវត្តទៅកាន់ព័ន្ធកិច្ចជាគ្រូគង្វាលរបស់គាត់។ វាមានន័យថារាជរបស់ព្រះនគររបស់ព្រះ ដែលជាគម្រោងការដំបូងរបស់ព្រះ ដែលគួរតែសង់ឡើងដោយសារព្រះផ្ទាល់នៅលើផែនដី។ ក្រុមជំនុំដំបូង ជាពួកជំនុំនៃពួកអ្នកដែលត្រូវបានត្រាស់ហៅតាមរយៈព័ន្ធកិច្ច

របស់គ្រូគង្វាលរបស់គ្រូគង្វាលម្នាក់និងគ្រូបង្រៀន ដែលព្រះបានផ្តល់មកដល់ក្រុមជំនុំ ទុកជាកាដូពិសេសបង្ហាញនូវរូបឆ្លុះរបស់ព្រះ។ ដូច្នេះក្រុមជំនុំត្រូវការគ្រូគង្វាលដែលស្មោះត្រង់។

ដែលប៉ូលបានសម្គាល់ថាគ្រូគង្វាលស្មោះត្រង់គួរតែដេញតាមលក្ខណៈខាងវិញ្ញាណ (១ធីម៉ូថេ 6:11)។ វាមានន័យថា ពួកគេគួរតែមានសេចក្តីសុចរិត សេចក្តីកោតខ្លាចដល់ព្រះ សេចក្តីជំនឿ និងសេចក្តីស្រឡាញ់ទៅកាន់អ្នកជិតខាង និងសេចក្តីអត់ធ្មត់និងសេចក្តីស្លូតបូតទៅកាន់ខ្លួនឯង ដែលចង្អុលទៅកាន់ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

ការបង្ហាញពីរូបឆ្លុះនៅក្នុងគ្រូគង្វាលនៅក្នុងក្រុមជំនុំ ជារបៀបរៀបរយនៃក្រុមជំនុំដែលព្រះបានកំណត់មក។ ដូច្នេះប៉ុលបានសង្កត់ថា គ្រូគង្វាលដែលបានបង្វឹករួចមកតាមរយៈទុក្ខលំបាក ដើម្បីក្លាយជាអ្នកបំរើដែលចេះវែកញែកពីព្រះបន្ទូលរបស់ព្រះយ៉ាងត្រឹមត្រូវ។

ប៉ូលដែលត្រូវបានត្រាស់ហៅមកដោយព្រះ ហើយត្រូវបានដឹកនាំដោយដំណឹងល្អ និងបានថ្វាយខ្លួនទៅកាន់ព្រះ នៅក្នុងដំណើរព័ន្ធកិច្ចលើកទីពីរ នោះគាត់បានរក្សាការស្បថរបស់គាត់នៅត្រង់ Cancer ហើយបានសញ្ជឹងគិតពីនិម្មិតដ៏អស្ចារ្យនៅក្នុងព្រះគ្រីស្ទដើម្បីនឹងផ្សាយដំណឹងល្អទៅកាន់អាស៊ីមីណា និងក្រុងរ៉ូម ហើយបានធ្វើការសម្រាប់គោលបំណងនោះ។ វាជាព័ន្ធទាន់ហាន់ ប៉ុន្តែជាគម្រោងដែលព្រះបានធ្វើមុនពេលដែលទ្រង់បង្កបង្កើត។ ពាក្យមួយទៀតថា គាត់មាននិម្មិតដើម្បីនឹងស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងលោកិយ។

ដូចជានៅក្នុងកិច្ចការជំពូក 20 បង្ហាញថា គាត់បានរក្សាក្រុមជំនុំអេភេសូអស់រយៈពេល៣ឆ្នាំ មានដូចជា គាត់បានបង្រៀនដំណឹងល្អអស់រយៈពេល៦ខែជារៀងរាល់សប្តាហ៍ ហើយបានបែងចែកសិស្សរបស់គាត់ ហើយគាត់បានបង្រៀនព្រះបន្ទូលរបស់ព្រះជារៀងរាល់ថ្ងៃអស់រយៈពេល២ឆ្នាំ រហូតដល់គ្រប់ទាំងតំបន់នៃអាស៊ីមីណាទាំងមូលបានស្តាប់ពីព្រះបន្ទូលរបស់ព្រះ។ នៅក្នុងស្ថានភាពដូច្នេះ ការលូតលាស់របស់ក្រុមជំនុំអេភេសូ។ ភ្លើងនៃការលូតលាស់បានពង្រាយទៅកាន់ក្រុងរ៉ូមតាមរយៈការដឹកនាំរបស់ព្រះដែល ប៉ូលត្រូវជាចំណាត់ខ្មាំងក្នុងនាមជាអ្នកទោសបានមកដល់ក្រុងរ៉ូម ហើយបានស្នាក់នៅផ្ទះជួល ហើយបានប្រកាសពីនគររបស់ព្រះទៅកាន់មនុស្សនៅក្នុងក្រុងរ៉ូម។ បន្ទាប់មកដំណឹងល្អនេះត្រូវបាន

ពង្រាយទៅដល់អឺរ៉ុប អាមេរិកខាងត្បូង អាមេរិកខាងជើង អាហ្វ្រិក និងអាស៊ីអាគ្នេយ៍ចេញមកពីរ៉ូម។ នៅក្នុងពាក្យមួយទៀត វាមានន័យថាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ បើទោះជាបច្ចុប្បន្នមានពេញដោយរូបបែបរបស់មនុស្សជាការងារក្លែងក្លាយ រូបភាពដែលត្រូវបានពង្រាយដោយចេស្តាដូចជាគ្រាប់ពូជល្អិត។ ជាចុងក្រោយនឹងត្រូវបានគ្រប់ដណ្តប់លើពិភពលោកទាំងមូលបាន។

បន្ទាប់មកតាមរយៈសំបុត្ររបស់គ្រូគង្វាលដែលប៉ូលបានផ្ញើទៅកាន់គ្រូគង្វាលធីម៉ូថេ យើងអាចឃើញរូបឆ្លុះរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់គួរតែជារូបឆ្លុះនៃសេចក្តីជំនឿផ្ទាល់និងរូបឆ្លុះរបស់ក្រុមជំនុំជាផ្លូវការ ដូចជាស្តង់ដារដែលសាកសម។ ធាតុបីនៃសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់ជាគោលបំណងដែលគ្រូគង្វាលនិងក្រុមជំនុំផ្ទាល់គួរតែដេញតាម។ នេះជារូបឆ្លុះដើមដែលព្រះគួរតែបង្កើតនៅលើផែនដីតាមរយៈក្រុមជំនុំជាពិត។ ដូច្នេះក្រុមជំនុំយើងនិងគ្រីស្ទាននាពេលបច្ចុប្បន្នគួរតែបង្កើតនូវការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងលោកិយ។ ហើយនៅក្នុងផ្នែកព័ន្ធកិច្ចក្រុមជំនុំគួរតែធ្វើតាមគោលបំណងនេះ ជាបំណងរបស់ព្រះ។

## 2. ការសាកល្បងនៃព្រះគម្ពីរ – ទស្សនៈព្រះគម្ពីរ ការបកស្រាយព្រះគម្ពីរ

គោលបំណងនិងវិធីសាស្ត្រនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ ជាការពិសោធនៃព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ។ វាមានន័យថាទស្សនៈព្រះគម្ពីរនោះនិងទស្សនៈនៃការបកប្រែព្រះគម្ពីរ ជាចំណុចកណ្តាលនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ នៅក្នុងពាក្យមួយទៀតថាគម្ពីរជារូបឆ្លុះរបស់ព្រះដែលជា ការបើកសំដែងដែលមានលក្ខណៈរបស់ព្រះ។ វាមានន័យថាគម្ពីរផ្ទាល់មានគ្រឹះនៃលក្ខណៈបីរបស់ព្រះ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។ ដូចជាអ្នកសរសេរទំនុកដំកើងរកឃើញនៅក្នុងទំនុកដំកើងលេខ 19 លក្ខណៈនៃគម្ពីរ "ភាពឥតខ្ចោះ សេចក្តីជំនឿ សេចក្តីសុចរិត និងភាពបរិសុទ្ធ" ដូចគ្នានឹងលក្ខណៈរបស់ព្រះ។ ដូច្នេះយើងទទួលលក្ខណៈរបស់ព្រះនៅក្នុងគម្ពីរជាលក្ខណៈរបស់ព្រះផ្ទាល់។

សេចក្តីពិតនេះទាមទារនូវការសាកល្បងព្រះគម្ពីរ។ ទំនុកដំកើង 119 ដែលមាន 22 ផ្នែក ដូចជាក្រមអក្សរទំនុកដំកើងបានបញ្ជាក់ថាវាមានទាក់ទងទៅក្នុងទំនាក់ទំនងដែលជ្រៅ។ បទពិសោធន៍នេះបង្ហាញពីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ យើងរកឃើញថារូបភាពដើមនៅក្នុងគម្ពីរផ្ទាល់នៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

ដូច្នេះអ្នកដែលឃើញនូវរូបឆ្លុះនោះជាទូទៅគេនឹងមានចេស្តានៅក្នុងការវែកញែកបទគម្ពីរ។ ដូចជាលោក John Owen ជាអ្នកប្រាជ្ញដ៏ពូកែម្នាក់នៅក្នុងចំណោមអ្នកប្រាជ្ញខាងសាសនៈវិទូជាច្រើន គាត់បានសង្កេតថា អ័ដាមជាអ្នកសាសនៈវិទូ ពីព្រោះគាត់អាចបកស្រាយសេចក្តីពិត ដែលអ័ដាមត្រូវបានបង្កើតនៅក្នុងរូបឆ្លុះរបស់ព្រះ ជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ នៅពេលដែលនរណាម្នាក់បកប្រែគម្ពីរដែលមានពេញដោយរូបឆ្លុះរបស់ព្រះ ពីព្រោះគេត្រូវបានបង្កើតនៅក្នុងរូបឆ្លុះរបស់ព្រះ គាត់អាចផ្លាស់ប្រែទៅជាលក្ខណៈរបស់ព្រះ។ នេះជាគោលបំណងនិងវិធីសាស្ត្រដើម្បីយល់នូវបទគម្ពីរ ដែលជាសភាពដើមនៃរូបឆ្លុះរបស់ព្រះដ៏ត្រឹមត្រូវ។ ដូច្នេះអ្នកដែលបានស្តារឡើងនៅក្នុងរូបឆ្លុះរបស់ព្រះ ជាអ្នកដែលមានបទពិសោធន៍នូវលក្ខណៈរបស់ព្រះគម្ពីរ។

### 3. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះជាគោលបំណងនៃព័ន្ធកិច្ចនៃការអធិប្បាយ

ទស្សនៈនៃការអធិប្បាយរបស់ពួកសាវ័កជាការអធិប្បាយដើម្បីការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ សេចក្តីពិតដែលទទួលព្រះបន្ទូលរបស់ព្រះ ដោយការអធិប្បាយជាសាធារណៈ និងត្រូវបានផ្លាស់ប្រែទៅក្នុងរូបឆ្លុះរបស់ព្រះ ជាកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើនៅក្នុងការទាំងនោះ តាមរយៈការទទួលព្រះបន្ទូលរបស់ព្រះ។ ដូច្នេះការអធិប្បាយមានលក្ខណៈពិសេស ដែលត្រូវបានញែកចេញនូវការណែនាំ ការបង្រៀន។ ដូច្នេះទ្រឹស្តីនៃការអធិប្បាយរបស់ពួកបរិសុទ្ធដែលលោក William Perkins បានឲ្យនិយមន័យនោះជា ការអធិប្បាយដើម្បីនឹងប្រមូលចៀមរបស់ទ្រង់ ប៉ុន្តែបណ្តេញចេញនូវសត្វចចក បង្ហាញពីគោលការណ៍ចម្បងនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។

ដូច្នេះគ្រូគង្វាល ការអធិប្បាយ preaching predation សកម្មភាពនៃការអធិប្បាយ និងការ

ឆ្លើយតបនៃការអធិប្បាយ រួមមានការស្តារឡើងវិញនូវធាតុផ្សំនៃរូបឆ្លុះរបស់ព្រះ។ គ្រូគង្វាលដែលបានស្តារឡើងវិញដោយរូបឆ្លុះនៃព្រះយល់ពីអត្ថបទអធិប្បាយដែលមានលក្ខណៈនៃការស្តារឡើងវិញនូវរូបឆ្លុះនៃព្រះ ហើយប្រកាសសារដល់រាស្ត្រនៃព្រះដើម្បីនឹងផ្លាស់ប្តូរពួកគេចូលក្នុងរូបឆ្លុះនៃសុចរិត សេចក្តីមេត្តាករុណា និងភាពស្មោះត្រង់នៃព្រះ។ ហើយបន្ទាប់មកជាចុងក្រោយពួកគេត្រូវបានប្តូរទៅជារូបឆ្លុះ សេចក្តីសុចរិត សេចក្តីមេត្តាករុណា និងភាពស្មោះត្រង់នឹងត្រូវបានបំពេញនៅទូទាំងផែនដី។ នេះគឺជាភារកិច្ចរបស់គ្រូគង្វាលនិងបេសកកម្មសំខាន់នៅក្នុងគាត់។

### 4. ការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះជានិម្មិតនៃក្រុមជំនុំដើម - កិច្ចការ 2:42-54

នៅក្នុងព័ន្ធកិច្ចគ្រូគង្វាលរបស់ខ្ញុំ ទស្សនៈនិមិត្តរបស់ខ្ញុំត្រូវបានបង្ហាញនៅក្នុងគម្ពីរកិច្ចការ 2: 42-45 ។ និម្មិតនៃក្រុមជំនុំដែលពួកបរិសុទ្ធបានប្រកាន់យកនៅសតវត្សទី 16 - សតវត្សទី 17 គឺជាការរស់ឡើងវិញនៃក្រុមជំនុំដំបូងដែលជាការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។ វាគឺជានិម្មិតដែលយើងគួរតែបន្តជានិច្ច។

វាមានលក្ខណៈប្រាំយ៉ាងគឺ 1) ការបង្រៀនរបស់សាវកគឺជាគ្រឹះសំខាន់ 2) ពួកគេបានលះបង់ខ្លួនឯងដើម្បីអធិស្ឋាន 3) ពួកគេបានលះបង់ខ្លួនឯងដើម្បីប្រមូល។ 4) ជីវិតគ្រួសារដែលបរិសុទ្ធ 5) ក្នុងជីវិតសង្គមពួកគេត្រូវបានគេកោតសរសើរ។ នៅទីនេះអ្វីគ្រប់យ៉ាងគឺជារូបភាពដែលបង្ហាញពីសេចក្តីសុចរិត សេចក្តីមេត្តាករុណា និងភាពស្មោះត្រង់។ ក្រុមជំនុំដើមដំបូងត្រូវបានឈរលើសេចក្តីសុចរិតដែលត្រូវបានបង្ហាញដោយសេចក្តីមេត្តាករុណាហើយត្រូវបានគ្របដណ្តប់ដោយភាពស្មោះត្រង់បង្ហាញពីស្ថានភាពដើមនៃធិបតេយ្យ។ នេះគឺជាតួលេខដ៏ល្អ។

ដូចគ្នានេះផងដែរកម្ពុជាដែលខ្ញុំបម្រើជាមួយព្រះបន្ទូលរបស់ព្រះ ការកត់សម្គាល់នូវចក្ខុវិស័យនេះ គឺជាបំណងប្រាថ្នាដ៏ខ្លាំងក្លារបស់យើង។ នៅក្នុងប្រទេសពុទ្ធសាសនាដែលមានប្រជាជន 95% ក្នុងប្រជាជនចំនួន 14 លាននាក់ដែលគំនិតនិងទំលាប់របស់ពួកគេត្រូវបានរលាយដោយរូបភាពមនុស្សមនុស្សជារូបឆ្លុះរបស់សាតាំង ហើយត្រូវបានពង្រឹង។ មានតែការ

